# ព្រះ

# ត្រៃបិដកបាលី

## នឹង

## សេចក្ដីប្រែជាភាសាខ្មែរ

# វិនយបិដក

## មហាវិភង្គ បឋមភាគ

# ១

### វេរញ្ជកណ្ឌ និង បារាជិកកណ្ឌ

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥៣៧

# អារម្ភកថា

គោរពជូន

[illegible]

[illegible]

このカンボジア語南伝大蔵経を
カンボジアの仏教徒へ
贈ることができることに感謝します。
これが日本の仏教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

ជូនចំពោះប្រជាជាតិខ្មែរ ជាទីគោរព !

ជូនចំពោះប្រជាជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

[illegible]

[illegible]

[illegible]

[illegible]

[illegible] ខែកក្កដា ឆ្នាំ ១៩៩៥

គណៈកម្មការនៃការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកដឹកនាំ [illegible] The Rev. Selkyo Muchaku

ប្រធាន [illegible] The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Eisho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分冊し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、怒りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　碓井　圭一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

Les fonds nécessaires à l'édition du premier volume du TRIPITAKA ont été offerts personnellement par Monsieur PAUL REYNAUD, Ministre des Colonies, en témoignage de l'intérêt que le Gouvernement de la République Française porte au Peuple Cambodgien.

Un exemplaire de ce premier volume a été remis le Vingt-Deux Octobre Mil Neuf Cent Trente et Un, en audience solennelle, à SA MAJESTÉ SISOWATH MONIVONG par Monsieur PAUL REYNAUD, assisté de Monsieur le Gouverneur Général PASQUIER et de Monsieur le Résident Supérieur LAVIT, en présence du Conseil des Ministres, des Chefs de Secte et d'une délégation de tous les bonzes du Royaume.

ប្រាក់ចំណាយ ក្នុងការបោះពុម្ពព្រះត្រៃបិដកខ្មែរនេះ គឺលោកប៉ូលហ្វេណ្ឌ សេដ្ឋបតីក្រសួង ប្រទេសកម្ពុជាខាងចូល ដើម្បីឲ្យឃើញជាក់ស្តែងនៃប្រយោជន៍ដែលកើតការប្រជាធិបតី ជាពិសេស នាំមកឲ្យជល់ខេមរជាតិ ។

សៀវភៅទី ១ នេះ លោកប៉ូលហ្វេណ្ឌ បានថ្វាយមួយច្បាប់ចំពោះព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្ស ក្នុងឱកាសដែលចូលគាល់ជាមង្គល អតីតថ្ងៃវត្តពីរគុណ ឆ្នាំមួយពាន់ប្រាំបួនរយសាមសិបមួយ ជួបជុំជាមួយនឹងលោក ល្បីល្បាណើរ យោធាពលទាហ៊ាន នឹងលោក ល្បីស៊ីដង់ សុបេរីយើរ ឡារ៉ែត នៅទីចំពោះមុខអស់លោកកុងស៊ុយ សេដ្ឋបតីទ្វាព្រះសង្ឃ នាយករាជ្យការណៈ នឹងតំណាងសង្ឃគ្រប់អន្លូ ក្នុងស្រុកខ្មែរមួយក្រុម ។

# ព្រះរាជបតិមាន

*ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្ស ហើយជាបរមរដ្ឋគ្រូសាលា ក្រៅក្រោមសុខុមាល ព្រះរាជក្រឹត្យកម្ពុជាធិបតី ជាកម្មសិទ្ធិសាលាស៊ីសុវត្ថិ*

ទ្រង់សូមអំណរព្រះតេជព្រះគុណ ជាបឋមហេតុនៅទីនេះ ដល់ក្រុងបារាំងសែស ដែលជួយទំនុកបម្រុងក្រុងកម្ពុជា ដោយសុចរិតបានធ្វើឲ្យរុងរឿងតៀងមកនឹងតទៅមុខ ហើយដោយបានបង្កើតមន្ទីរពុទ្ធសាសនបណ្ឌិត្យ បានយកចិត្តទុកដាក់ជួយទំនុកបម្រុងនឹងផ្សាយព្រះបារមីព្រះពុទ្ធសាសនា នឹងជួយឲ្យបោះពុម្ព

ព្រះត្រៃបិដកជាទីមួយរបស់ព្រះពុទ្ធសាសនា ជាសេចក្តីរាប់អានពេញចិត្តរបស់បណ្តាខេមរជនទាំងអស់គ្នាសព្វ ហើយទ្រង់ពុំមានភ្លេចឡើយ ចំពោះអំណរអរគុណដល់ពួកឧបាសកឧបាសិកាដែលមានចិត្តសទ្ធាជ្រះថ្លា បញ្ចេញប្រាក់ចូលជួយឲ្យការដ៏ឧត្តមនេះបានសម្រេច ។

ទ្រង់មានសេចក្តីសោមនស្សជាទីបំផុត ដែលក្នុងរាជ្យផែនដីទ្រង់ព្រះករុណាបានសម្រេចឲ្យមានក្រុមជំនុំព្រះសង្ឃបណ្ឌិតប្រែព្រះបាលីក្នុងគម្ពីរព្រះត្រៃបិដក គឺភាជនៈទាំង ៣ ដែលដឹកដាក់ក្បួនព្រះពុទ្ធសាសនា មានទាំងអស់ប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ មកជាភាសាខេមរៈជាក់ស្តែង ឲ្យបោះពុម្ពទាំងបាលីនិងសម្រាយជាសៀវភៅផ្សាយព្រះមធុរសក្នុងព្រះវិន័យ គឺការក្រិត្យនិងកិច្ចមារយាទ ។ ព្រះសូត្រគឺព្រះធម៌សំរាប់ប្រដៅសត្វឲ្យកាន់វិធីត្រង់ ។ ព្រះអភិធម្ម គឺញ៉ាំងជីវព្រះបរមនិព្វានដែលព្រះពុទ្ធអង្គព្រះសមណគោតមបានត្រាស់ហើយ ទ្រង់សំដែងទុកឲ្យមនុស្ស


សារព្រះរាជព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស

លោកកាន់ប្រព្រឹត្តឲ្យត្រឹមត្រូវ និងបានតម្រង់បេតសិករាល់រូបកាយ ឲ្យប្រកបដោយសេចក្តីបរិសុទ្ធ ជាបំរុងក្នុងការកុសល ទើបបង្កើតជាមគ្គផល ដែលអាចធ្វើឲ្យបានសេចក្តីក្សេមក្សាន្ត និងបំផុតសិរីសួស្តីដ៏ប្រពៃថ្លៃឧត្តម ជាបរមសុខ ដល់បរិសទ្យទាំងពួងគ្រប់គ្នា ។

ដោយហេតុព្រះធម៌ដ៏វិសេសទាំងនោះសុទ្ធតែជាបាលីគឺព្រះពុទ្ធវចនៈពីបុរាណតាំងពីមុនព្រះពុទ្ធសករាជ ២៤៧៤ ទៅទៀត បានជាព្រះសង្ឃនិងឧបាសកប្រើរៀនបេះហាំបាន តែមិនយល់ច្បាស់ថាជាអ្វី បានជាព្រះករុណាទ្រង់ព្រះរាជតំរិះព្រមនិងរាជការប្រតិភូត្តារក្រុងបារាំងសែស មានលោករ៉េស៊ីដង់ត៍សុប៉េរីយ៉េរ ហ្វែរណង់ឡាវីត ជាតំណាង ដែលទ្រង់ស្ងួមអំណរគុណដោយរួសរាន់ ក្នុងឱកាសដែលបានជួយគិតសម្រេចមហាប្រយោជន៍ឧត្តមនេះ ឲ្យបានចំរើនតរិះប្រាជ្ញាជាតិខេមរៈ ឲ្យកាន់តែបេះនឹងមាំមួនឡើង ដើម្បីនឹងរក្សាព្រះពុទ្ធសាសនាឲ្យខ្ជាប់ខ្ជួនជាទី

រុងរឿងនៃក្រុងកម្ពុជា ឥតអាក់ ដោយបានតាំងមន្ទីរពុទ្ធសាសនបណ្ឌិត្យ និងព្រះរាជបណ្ណាល័យ ហើយឲ្យបោះពុម្ពគម្ពីរព្រះត្រៃបិដក ទុកជាគោល ដើម្បីឲ្យអស់មហាជនទាំងឡាយដែលកាន់ព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូចិនទាំងមូល រឹតតែជឿព្រះពុទ្ធសាសនាមហាប្រសើរថែមទៀត ។

ធ្វើក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញចតុមុខនៅថ្ងៃព្រហស្បតិ៍ ១៣ រោចខែស្រាពណ៍ ឆ្នាំមមែត្រីស័ក ព្រះពុទ្ធសករាជ ២៤៧៤ ត្រូវនឹងថ្ងៃ ១០ កញ្ញា ឆ្នាំ ១៩៣១ ។

---

## ការជំនុំរបស់ក្រុមជំនុំ

### អំពីឧប្បត្តិហេតុការកសាងព្រះត្រៃបិដក

ការផ្ទៀងផ្ទាត់ព្រះត្រៃបិដកជាភាសាបាលី និងការប្រែពីបាលីមកជាសម្រាយភាសាខ្មែរនេះ យើងជាក្រុមជំនុំបានចាប់ផ្តើមធ្វើតាំងពីថ្ងៃ ៣ កើតខែបុស្ស ឆ្នាំមមីទោស័ក ពុទ្ធសករាជ ២៤៧២ ត្រូវនឹងថ្ងៃទី ២ ខែមករា ១៩៣០ នៅមន្ទីរព្រះរាជបណ្ណាល័យកម្ពុជា ក្រុងភ្នំពេញ ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ។ ការកសាងព្រះត្រៃបិដកនេះ កើតឡើងដោយព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ដែលទ្រង់ព្រះបំណងឧបត្ថម្ភព្រះពុទ្ធសាសនា ដោយការបោះពុម្ពគម្ពីរព្រះត្រៃបិដក ហើយប្រគល់ការបោះពុម្ពនេះ មកឲ្យព្រះរាជបណ្ណាល័យ ។ ការកសាងព្រះត្រៃបិដកនេះកើតឡើងដោយរាជការប្រព្រឹត្តភាគផង ដោយបានបង្កើតពុទ្ធសាសនបណ្ឌិត្យ

ហើយតម្រូវការឲ្យមួយព្រះរាជបណ្ណាល័យ នឹងឲ្យយកចិត្តទុកដាក់ក្នុងការទាំងឡាយ ដែលមានឧត្តមប្រយោជន៍ដល់ព្រះពុទ្ធសាសនា ។

### អំពីសេចក្ដីចំរើនៃការបោះពុម្ពព្រះត្រៃបិដក

សេចក្ដីចំរើនដែលនាំមុខការបោះពុម្ពព្រះត្រៃបិដកនេះ ឲ្យប្រព្រឹត្តទៅដោយស្រួល ឥតមានទើសទាក់នោះ ព្រោះអាស្រ័យប្រាក់ចំណូលដូចមានសេចក្ដីតទៅនេះ :

១ ដោយព្រះករុណាជាម្ចាស់ជីវិត ព្រះបាទក្រុងកម្ពុជា ទ្រង់បានចំណាយប្រាក់ព្រះរាជទ្រព្យសម្រាប់ព្រះអង្គ ជួយទំនុកបម្រុងក្នុងការបោះពុម្ពនេះ ហើយទ្រង់បានពន្យល់ព្រះរាជវង្សានុវង្សទាំងអស់លោកមន្ត្រីធំតូច នឹងព្រះភិក្ខុសង្ឃ ថេរានុត្ថេរៈ រាជាគណៈឋានានុក្រមឲ្យជួយទំនុកបម្រុងក្នុងការបោះពុម្ពនេះផង ។

២ ដោយព្រះរាជវង្សានុវង្សទាំងអស់លោកកុងស៊ុយសេនាបតី ទាំងអស់លោកមន្ត្រីធំតូច នឹងព្រះភិក្ខុសង្ឃរាជាគណៈឋានានុក្រម នឹងពុទ្ធសាសនិកជនទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូល ព្រមទាំង



ពុទ្ធសាសនិកជនក្នុងដែនកូសាំងស៊ីនផង បានបរិច្ចាគទ្រព្យចូលជួយតាមកំឡាំងសទ្ធាក៏មាន បានបរិច្ចាគទ្រព្យទទួលយកដល់ពេញមួយច្បាប់ ឬច្រើនច្បាប់ក៏មាន ។

៣ ដោយប្រាក់ចំណូលផ្សេង ក្រៅអំពីប្រាក់ដែលបានថ្លែងខាងលើនោះក៏មាន ។ ក្នុងឱកាសនេះលោកប៉ូលពីយណូទ៍ សេនាបតី ក្រសួងត្រួតត្រាប្រទេសរាជ្យជាស្រុកចំណុះ ដែលលោកមានដំណើរអញ្ជើញពីមហានគរបារាំងសែស មកឯប្រទេសឥណ្ឌូចិន បានជ្រាបអំពីការបោះពុម្ពព្រះត្រៃបិដកនេះ លោកក៏មានអនុស្រ័យព្រេកអរជាមួយផង ហើយបានបរិច្ចាគទ្រព្យរបស់លោកចូលជួយឧបត្ថម្ភការបោះពុម្ពនេះ ដើម្បីសំដែងឲ្យឃើញជាក់ស្ដែងថា លោកមានអំណរជាទីបំផុត ក្នុងការបោះពុម្ពព្រះត្រៃបិដកនេះ ។

### អំពីសេចក្ដីយល់ឃើញ
### នៃសេចក្ដីពេញចិត្តរបស់ក្រុមជំនុំ

យើងជាក្រុមជំនុំយល់ឃើញថា ដែលព្រះករុណាជាម្ចាស់ជីវិតជាមួយនឹងរាជការប្រឹក្សាត់ បានចាត់ការបោះពុម្ពព្រះត្រៃ-

បិដកទាំងបាឡីទាំងសម្រាយភ្ជាប់ជាមួយគ្នានេះ ជាការវិសេសប្រសើរបំផុត រាប់ថាជាកុសលដ៏ធំបណ្ដាច់ អាចឲ្យឈ្មោះពេញទីថា បានលើកសង្គាយនា យើងកំណត់តាមការនេះថា «ឧត្តមសង្គីតិ» ប្រែថា «ការលើកសង្គាយនាដ៏ប្រសើរបំផុត» ព្រោះតាំងពីសង្គាយនាជាន់ណា ៗ មក ក៏មិនទាន់មានសេចក្ដីដំណាលថា ដែលបានប្រែជាសម្រាយផង ដរាបដល់ចប់ព្រះត្រៃបិដក ដូចសង្គាយនាក្នុងជាន់នេះទេ ។ ដោយហេតុនេះយើងមានអំណរនឹងសេចក្ដីពេញចិត្តដ៏ក្រៃលែង ដោយមានសង្ឃឹមជាប្រាកដ ដូចសេចក្ដីដែលយើងថ្លែង ដោយសង្ខេបតទៅនេះ

១ អ្នកកាន់ព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋទាំងមូល នឹងមានសេចក្ដីប្រតិបត្តិត្រូវផ្លូវគ្នា ព្រោះមានព្រះត្រៃបិដកនេះជាគ្រូប្រាប់ខុសត្រូវ ជាគោលបារិកសម្រាប់អាងត្រូវគ្នាតែបែបមួយ ហើយនឹងបានកំចាត់បង់នូវអស្មិមានះប្រកាន់ខុសថាជាត្រូវនោះចេញ។

២ ព្រះត្រៃបិដកនេះទុកជាប្រទីបផ្កាលផ្លុះបំភ្លឺអស់មហាជន ឲ្យឃើញសេចក្ដីខុសត្រូវជាក់មិនភាន់ច្រឡំ នាំឲ្យកើត



មានប្រាជ្ញាឈ្លាសវៃល្អ ចេះអៀនខ្មាសវៀរវៀស ស្អប់ខ្ពើមអំពើអាក្រក់ ឲ្យខ្ញីឈ្មោះសង្ឃាត ខំប្រឹងប្រព្រឹត្តសុចរិតល្អគ្រប់ ដែលជាគ្រឿងបង្កើតសេចក្ដីសុខឲ្យមានបរិបូណ៌ឡើង ។ កាលបើអស់បណ្ដាជន មានសេចក្ដីអៀនខ្មាស ជ្រញចិត្តនឹងអំពើអាក្រក់ហើយ ព្រះនគរក៏នឹងថ្កើងរុងរឿង មានកេរ្តិ៍ឈ្មោះក្រអូបសាយទៅក្នុងលោកទាំងមូល ពីព្រោះធម៌សុចរិត មានក្លិនក្រអូបជាបំផុត ជាងក្លិននៃគ្រឿងក្រអូបទាំងអស់ ។

## សំដីរៀបការរបស់ក្រុមជំនុំ

របៀបមុខការគ្រប់យ៉ាង ដែលបានរៀបចំព្រះត្រៃបិដកនេះ យើងជាក្រុមជំនុំ បានធ្វើដោយកំឡាំងព្យាយាមដ៏មាំមួន ព្រមទាំងបានពិនិត្យពិច័យ ដោយល្អិតល្អន់ ដូចមានសេចក្ដីរាយដំណើរការតទៅនេះ:

១ បណ្ដាព្រះត្រៃបិដក គឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម យើងបានចាប់រៀបចំព្រះវិន័យបិដកមុន រួចហើយ

ទើបចៀបចំព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដកតទៅ ធ្វើតាមរបៀបហូរហែ គឺតាមលំដាប់គម្ពីរមុនក្រោយ ។

២ យើងបានយកព្រះត្រៃបិដក អក្សរខមគម្ពីរស្លឹករឹតមក ធ្វើជាច្បាប់ដើម បម្លងស្រង់បាឡីដាក់ក្រដាស ហើយបានយកព្រះត្រៃបិដកគ្រប់យ៉ាង ដែលមាននៅក្នុងព្រះរាជបណ្ណាល័យកម្ពុជា មកធ្វើជាច្បាប់ផ្ទៀងផ្ទៀបគ្នា ។ បើផ្ទៀងផ្ទៀបគ្នាទៅហើយឃើញមានបាឡីត្រង់ណាដែលផ្សេងគ្នាខ្លះ យើងបានស្រង់បាឡីនោះយោងលេខមកដាក់ត្រង់កន្លែងនយលក្ខណៈ "កំណត់ហេតុពន្យល់" ខាងក្រោមមានគំនូសខណ្ឌរាំងដោយខ្សែ ក្រឯលេខដែលយោងមកនោះខាងលើនិងខាងក្រោមត្រូវគ្នា ។ គម្ពីរព្រះត្រៃបិដកប្រទេសអឺរ៉ុប យើងកំណត់នាមដោយបាឡីថា យុរោបិយបោត្ថក ប្រើអក្សរជាអាទិសង្កេតន័យតែ ១ តួថា យុ. ។ គម្ពីរភូមាថា មរម្មបោត្ថក ប្រើអាទិសង្កេតន័យថា ម. ។ គម្ពីរមនថា រាមញ្ញបោត្ថក ប្រើអាទិសង្កេតន័យថា រា. ។ ឯព្រះត្រៃបិដកអក្សរសៀម យើងមិនបានធ្វើយកក្នុងនយលក្ខណៈទេ ព្រោះមាន



ទំនងដូចគ្នានឹងច្បាប់អក្សរខមដែរ ។ បើក្នុងច្បាប់អក្សរខមក្តី អក្សរសៀមក្តី មានបាលីផ្សេងគ្នាខ្លះដោយអន្លើៗ នោះ យើងយោងលេខធ្វើយមកក្នុងនយលក្ខណៈ ប្រាប់ដំណើរដែលផ្សេងគ្នានោះដែរ ។

៣ លុះបានផ្ទៀងបាលីដោយត្រឹមត្រូវហើយ ទើបយកបាឡីនោះមកប្រែរៀងសេចក្តីជាក្រោយ ។ ឯការប្រែនោះយើងបានយកគម្ពីរអដ្ឋកថា ដីកា យោជនា មកមើលជាគំរាប ដើម្បីឱ្យឃើញសេចក្តីជាក់ប្រាកដ ប៉ុន្តែមិនបានប្រែអធិប្បាយតាមន័យក្នុងអដ្ឋកថា ដីកា នោះទេ យើងប្រែតាមសំអាងបាឡីព្រះត្រៃបិដក "តួដើម" នោះប៉ុណ្ណោះ គឺថាបាឡីនោះមានសេចក្តីប៉ុណ្ណោះ យើងប្រែឱ្យគត់ត្រឹមប៉ុណ្ណោះឯង តែបើសព្ទប្រយោគណា ដែលមានសេចក្តីបង្កៀតពិបាកយល់ នោះយើងបន្ថែមពាក្យ ឬសេចក្តីខ្លះ តាមន័យក្នុងអដ្ឋកថា ដីកា ដាក់ក្នុងវង់ក្រចក ( ) នេះ សំគាល់ឱ្យដឹងថា ពាក្យឬសេចក្តីនោះ បញ្ចូលថែមមកទេ ។

ម្យ៉ាងទៀត ប្រយោគខ្លះ មានដំណើរពាក្យពិបាកប្រែ ឲ្យទៅជាសេចក្ដីសម្រួលមកជាសម្រាយនោះពេក បើលុះតែបញ្ចូលពាក្យបន្ថែមមកខ្លះ ទើបមិនដាច់សេចក្ដី កាលបើដូច្នេះ យើងបញ្ចូលពាក្យបន្ថែមមកខ្លះដាក់ក្នុងវង់ក្រចក ( ) នេះ ដែរ ដូចជាពាក្យថា (នេះ)(នោះ) ជាដើម ដើម្បីឲ្យស្រួលតាមលំនាំសេចក្ដីភាសាខ្មែរ ។

៤ ពាក្យឬប្រយោគណា ដែលមានសេចក្ដីជ្រៅកំបាំងពេក បើមិនទាញយកមកអធិប្បាយពន្យល់ផងទេ មុខជានឹងអាចចូលចិត្តសេចក្ដីមិនបាន នោះយើងបានស្រង់យកសេចក្ដីអធិប្បាយពីក្នុងអដ្ឋកថា ឬដីកា យោងលេខមកដាក់ត្រង់ឧបលក្ខណៈខាងក្រោម ដើម្បីឲ្យងាយយល់សេចក្ដីជាក់ប្រាកដឡើងបាន ។

៥ លុះប្រែរួចចប់មួយសម្រេចស្រេចហើយ យើងបានប្រជុំគ្នាផ្ទៀងផ្ទាត់យល់ព្រមថាត្រឹមត្រូវហើយ ក៏ជូនសេចក្ដីច្បាប់ពេញទៅ និងសម្រាយនោះ ថ្វាយទៅអស់លោកកុងស៊ីយ៉េសេនាបតីតាមក្រសួង គ្រាន់តែបានអនុញ្ញាតអំពីលោករ៉េស៊ីដង់ស៊ុប៉េរីយ៉េរ និងអស់លោកកុងស៊ីយ៉េសេនាបតី ព្រមទាំងសម្ដេចព្រះសង្ឃរាជទាំងពីរគណៈស្រេចហើយ ទើបរាជការចាត់ចែងឲ្យបោះពុម្ពទៅ ។



៦ ក្នុងឱកាសដែលបោះពុម្ពព្រះត្រៃបិដកនេះ រាល់សៀវភៅទាំងអស់ យើងបានផ្ទៀងវិញ្ញាសាពុម្ព ដោយប្រុងប្រយ័ត្ន ពិនិត្យពិច័យមាំមួនណាស់ តែបើជាធម្មតាការបោះពុម្ពច្រើនដល់ម្ល៉េះ បើទុកជាពិនិត្យពិច័យយ៉ាងណា ក៏គង់តែនៅមានភ្លាត់ខុសខ្លះបន្តិចបន្តួចមិនលែង ។

# បឋមោ ភាគោ

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### វេរញ្ជកណ្ឌំ

(១) តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ អស្សោសិ ខោ វេរញ្ជោ ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ

# ភាគទី ១

---

## សូមនមស្ការថ្វាយបង្គំ ចំពោះព្រះដ៏មានព្រះភាគជាអរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

### វេរញ្ជកណ្ឌ

[១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរគល់ស្ដៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃដ៏ធំ មានប្រមាណប្រាំរយរូប ។ វេរញ្ជព្រាហ្មណ៍(១) បានឮច្បាស់ (ខ្លួនក៏និយាយហើយ ទើបប្រកាសប្រាប់គ្នាថា) ម្នាលអ្នកទាំងឡាយ បានឮថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវនេះគង់នៅក្បែរគល់ស្ដៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃ មានប្រមាណប្រាំរយរូប ។ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះ ខ្ចរខ្ចាយ សុះសាយ យ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសត្រូវ សៅហ្មងគ្រប់យ៉ាង ជា សម្មាសម្ពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រាជ្ញារបស់ព្រះអង្គ ជា វិជ្ជាចរណសម្បន្ន

---

១ ក្នុងអដ្ឋកថា ថា ព្រាហ្មណ៍នេះ ឈ្មោះ វេរញ្ជៈ ដែលហៅថា វេរញ្ជៈ ព្រោះកើតក្នុងស្រុកវេរញ្ជា ឬនៅក្នុងស្រុកវេរញ្ជានោះ ។

សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណិំ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

(៤) អថខោ វេរញ្ជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ



ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹងនិងគ្រឿងដែលគួរប្រព្រឹត្ត ជា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ជា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ជា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជា បុរិសទម្មសារថិ ព្រោះព្រះអង្គទូន្មាននូវបុរសដែលគួរទូន្មានបាន ជា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ជា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ជា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់កំណើតទៀត ព្រះអង្គបានត្រាស់ដឹង ព្រមទាំងធ្វើឲ្យជាក់ច្បាស់ដោយព្រះអង្គឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចំពោះព្រះអង្គ ទ្រង់ញ៉ាំងនូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ហើយទ្រង់ប្រកាស ទ្រង់សំដែងធម៌ ពីរោះបទដើម បទកណ្ដាលនិងបទចុង ព្រះអង្គប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញ នូវដូចនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនេះ ជាការប្រពៃពេក ។

(៤) គ្រានោះ វេរញ្ជព្រាហ្មណ៍ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយរាក់ទាក់ សំណេះ

សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វេរញ្ជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សុតមេតំ ភោ គោតម ន សមណោ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ[១] មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតីតិ តយិទំ ភោ គោតម តថេវ ន ហិ ភវំ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ តយិទំ ភោ គោតម ន សម្បន្នមេវាតិ ។ នាហំ ព្រាហ្មណ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណ-

១ ម. វុទ្ធេ ។





សំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកតាមប្រព្រឹត្តទៅដោយសេចក្ដីសង្ខេបហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវេរញ្ជព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំបានឮពាក្យថា ព្រះសមណគោតម មិនអភិវាទ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់ទុំ ជាព្រឹទ្ធាចារ្យ មានការចម្រើន រស់នៅកាលយូរឆ្នាំមកហើយ មានអាយុដែលចូលមកក្នុងវ័យចុងក្រោយហើយ ទោះបីត្រាតែអញ្ជើញនូវព្រាហ្មណ៍ទាំងនោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើ) បពិត្រព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំបានឮមកនោះ ជាការពិត ព្រះគោតមដ៏ចំរើន មិនអភិវាទ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់ទុំ ជាព្រឹទ្ធាចារ្យ មានការចម្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុដែលចូលមកក្នុងវ័យចុងក្រោយហើយ ជាសូម្បីតែអញ្ជើញនូវព្រាហ្មណ៍ទាំងនោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើ) បពិត្រព្រះគោតមដ៏ចំរើន កិច្ចមិនអភិវាទជាដើមនោះ មិនសមគួរសោះឡើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ

ព្រាហ្មណិយា បជាយ សទេវមនុស្សាយ យមហំ អភិវាទេយ្យំ វា បច្ចុដ្ឋេយ្យំ វា អាសនេន វា និមន្តេយ្យំ វា ។ យញ្ហិ ព្រាហ្មណ តថាគតោ អភិវាទេយ្យ វា បច្ចុដ្ឋេយ្យ វា អាសនេន វា និមន្តេយ្យ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ អរសរូបោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អរសរូបោ សមណោ គោតមោតិ ។ យេ តេ ព្រាហ្មណ រូបរសា សទ្ទរសា គន្ធរសា រសរសា ផោដ្ឋព្វរសា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា(១) អាយតឹ អនុប្បាទធម្មា ។ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អរសរូបោ សមណោ គោតមោតិ

១ គតាតិបិ បាឋោ ។



នឹងព្រាហ្មណ៍ ទាំងបជុំសត្វ បណ្ដាទេវតា នឹងមនុស្សទាំងឡាយ តថាគត មិនឃើញអ្នកណាមួយ ល្មមឲ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញហៅឲ្យអង្គុយលើអាសនៈនោះឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា បើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា ឬអញ្ជើញហៅអ្នកណាឲ្យអង្គុយលើអាសនៈ ក្បាលរបស់អ្នកនោះ នឹងដាច់ធ្លាក់ចេញជាកង ៧ ។ ហើយព្រាហ្មណ៍ ក៏ពោលពាក្យក្រាបទូលព្រះសាស្ដាថា ព្រះគោតមដ៏ចំរើន ជាមនុស្សសោះកក្រោះ ឥតរសជាតិទេតើ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទីតាំង គួរឲ្យអ្នកផងតិះថា ព្រះសមណគោតមជាមនុស្សសោះកក្រោះ ឥតរសជាតិ ដែលគេថាដោយត្រូវហើយ ម្នាលព្រាហ្មណ៍ ពាក្យរសជាតិ គឺ រូប សំឡេង ក្លិន ឱជារស សម្ផស្ស ទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើទុកស ប្រៀបភក់កៀក ឲ្យអស់លើមិនដូចជាដើមត្នោត ដែលគេក្របលកាស់ផើង ឲ្យលែងដុះតទៅទៀតហើយ ធ្វើមិនឲ្យបានមែកតាកតទៅទៀតហើយ ធ្វើមិនឲ្យមានការកើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងនិយាយថា ព្រះសមណគោតមជាមនុស្សសោះកក្រោះ ឥតរសជាតិនោះ នឹងត្រូវត្រង់ហេតុនេះឯង

នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ ។ និព្ភោគោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ និព្ភោគោ សមណោ គោតមោតិ ។ យេ តេ ព្រាហ្មណ រូបភោគា សទ្ទភោគា គន្ធភោគា រសភោគា ផោដ្ឋព្វភោគា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹ អនុប្បាទធម្មា ។ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ និព្ភោគោ សមណោ គោតមោតិ ។ នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ ។ អកិរិយវាទោ ភវំ គោតមោតិ ។



ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន គ្មានគ្រឿងបរិភោគទេតើ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងនិងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះគ្រឿងបរិភោគ គឺរូប សំឡេង ក្លិន រស សម្ផស្សទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្ដាច់ឫសគល់អស់ហើយ បានធ្វើឲ្យស្រាប់កំពូលទៀតឡើយអស់ហើយ ដូចជាដើមត្នោត ដែលគេត្រឹមបោចសារលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបកកើតទៅទៀតហើយ ជាធម៌មិនមានកំណើតទៅខាងមុខទៀតទេ ម្នាលព្រាហ្មណ៍ ដែលអ្នកផងនិងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគនោះ គឺជាសេចក្ដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកពោលពាក្យហាមកុំធ្វើការ ថាមិនត្រូវធ្វើទេតើ ។

អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោតិ អហញ្ហិ ព្រាហ្មណ អកិរិយំ វទាមិ កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ អកិរិយំ វទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ ។ ឧច្ឆេទវាទោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោតិ អហញ្ហិ ព្រាហ្មណ ឧច្ឆេទំ វទាមិ រាគស្ស ទោសស្ស មោហស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ





ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យបុគ្គលនិយាយ ព្រះសមណគោតម ជាអ្នកពោលពាក្យយកកិរិយាថា មិនគួរធ្វើ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតប្រកាន់និយាយតាមយកថា មិនគួរធ្វើណាមួយ ធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតឡើយ តថាគតតែងនិយាយតាមយកថា មិនគួរធ្វើណាមួយ នូវធម៌ទាំងឡាយជាអកុសលដ៏លាមក ច្រើនប្រការនោះឡើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងនិយាយថា ព្រះសមណគោតម ជាអ្នកពោលពាក្យយកកិរិយាថា មិនគួរធ្វើនោះ គឺដោយសេចក្ដីត្រង់ត្រង់នឹងហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់នឹងហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិលមែនទេ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងនិយាយថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិល ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតប្រកាន់និយាយថា ឲ្យស្រុតកាត់ផ្ដាច់ផ្ដិលនូវរាគៈ ទោសៈ មោហៈ តថាគតតែងនិយាយថា ឲ្យស្រុតកាត់ផ្ដាច់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមក ច្រើនយ៉ាងនោះចេញ

ឧច្ឆេទំ វទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ ។ ជេគុច្ឆី ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោតិ អហញ្ហិ ព្រាហ្មណ ជិគុច្ឆាមិ(១) កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ជិគុច្ឆាមិ(២) អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ ។ វេនយិកោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោតិ ។ អហញ្ហិ ព្រាហ្មណ វិនយាយ ធម្មំ ទេសេមិ រាគស្ស ទោសស្ស មោហស្ស

១ ឥមេសុ ទ្វីសុ ឋានេសុ ជេគុច្ឆាមីតិបិ បាឋោ ទិស្សតិ ។



ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យដាច់សូន្យនោះ ក៏ត្រូវតែហេតុនេះឯង ប៉ុន្តែមិនមែនត្រូវតែហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកខ្ពើមរអើមណាស់ មែនឬ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុដែលគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម ដែលគេថាដោយត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតខ្ពើមសេចក្តីប្រព្រឹត្តអាក្រក់ ដោយកាយ វាចា ចិត្ត តថាគតខ្ពើមសេចក្តីប្រកបចុះនូវអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ (នោះណាស់) ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើមនោះ ក៏ត្រូវហេតុនេះឯង ប៉ុន្តែមិនមែនត្រូវតែហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកបំផ្លាញ មែនឬ ។ ព្រះលោកមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទីគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញ ដែលគេថាដោយត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតសំដែងធម៌ដើម្បីដោះស្រាយប្រតិបត្តិ ដែលបំផ្លាញបង់នូវរាគៈ ទោសៈ

អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ វិនយាយ ធម្មំ ទេសេមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។ តបស្សី ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោតិ តបនីយាហំ ព្រាហ្មណ បាបកេ អកុសលេ ធម្មេ វទាមិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ យស្ស ខោ ព្រាហ្មណ តបនីយា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា តមហំ តបស្សីតិ វទាមិ តថាគតស្ស ខោ ព្រាហ្មណ តបនីយា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា





ព្រោះតថាគតសំដែងធម៌ដើម្បីកំចាត់បង់ ដែលកំចាត់បង់នូវអកុសលធម៌ទាំង ឡាយដ៏លាមកច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកនិយាយ ថា សមណគោតម ជាអ្នកបំផ្លាញ គឺក្រើនក្រើលនោះ មិនមែនដោយ ត្រូវក្រើនហេតុ ដែលអ្នកនិយាយដោយសេចក្តីនោះ ទេ ព្រាហ្មណ៍ ហៅ ថា ព្រះគោតមមិនមែន ជាអ្នកបំផ្លាញនោះទេ ។ ព្រាហ្មណ៍ទូលថា ព្រះគោតម ទ្រង់ជាអ្នកតបៈ ម្នាលព្រាហ្មណ៍ ក៏ហេតុ មានហេតុដែលជន ពួកណា និយាយ ថា ព្រះសមណគោតមជាអ្នកតបៈ ដែលនិយាយនោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាសនិយាយថា ការប្រព្រឹត្តទុច្ចរិត ដោយកាយ វាចា ចិត្ត ជាធម៌ដ៏ដុតកំដៅឲ្យក្តៅក្រហាយ ជាអកុសលធម៌ ដ៏លាមក អកុសលធម៌ទាំងឡាយដ៏លាមក ដែលជាធម៌ដ៏ដុតកំដៅឲ្យ ក្តៅក្រហាយ (នោះ) បើបុគ្គលណាលះបង់បានស្រេចហើយ ដាច់ឫសគល់អស់ហើយ ធ្វើឲ្យដូចជាត្នោតដែលគេកាប់ចោលហើយ ធ្វើមិនឲ្យ មាននៅ ឲ្យលែងកើតតទៅទៀតហើយ តថាគតហៅ បុគ្គលនោះថា អ្នកតបៈ ម្នាលព្រាហ្មណ៍ អកុសលធម៌ទាំងឡាយដ៏លាមក ដែលជាធម៌ដ៏ដុតកំដៅឲ្យក្តៅក្រហាយ (នោះ) តថាគតលះបង់បានស្រេចហើយ ដាច់ឫសគល់អស់ហើយ

តាលាវត្ថុកតា អនភាវំកតា អាយតិំ អនុប្បា-
ទធម្មា អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ
បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី
សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ
វទេសិ ។ អបគព្ភោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស
ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា
វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោតិ
យស្ស ខោ ព្រាហ្មណ អាយតិំ គព្ភសេយ្យា
បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា
អនភាវំកតា អាយតិំ អនុប្បាទធម្មា តមហំ
អបគព្ភោតិ វទាមិ តថាគតស្ស ខោ ព្រាហ្មណ អាយតិំ
គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា



បានធ្វើកុសល ប្រហាក់ប្រហែលទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេ
ក្រឡៀលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមាន
បែបកកើតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀត
ហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកថាតថាគតជា ព្រះសមណគោតម ជាអ្នក
ដុតកំដៅនោះគឺ ព្រោះតែធម៌ហេតុនេះឯង បុគ្គលមិនបានព្រោះតែហេតុ ដែលអ្នក
និយាយសំដៅដល់នោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជា
មនុស្សឥតកំណើតទៅទៀត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍
ពិតមែនហើយ មានហេតុជាទីនាំ ឲ្យអ្នកថាតថាគត ព្រះសមណគោតម
ជាមនុស្សឥតកំណើត ដែលអ្នកថានោះត្រូវហើយ ម្នាលព្រាហ្មណ៍
ព្រោះកិរិយាដេកក្នុងផ្ទៃតទៅទៀត ជំនាត់កើតក្នុងភពតទៅមុខទៀត
បើបុគ្គលណាបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ
បានធ្វើកុសល ប្រហាក់ប្រហែលទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេ
ក្រឡៀលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមាន
បែបកកើតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀត
ហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលព្រាហ្មណ៍
កិរិយាដេកក្នុងផ្ទៃតទៅទៀត ជំនាត់កើតក្នុងភពតទៅមុខទៀត (នោះ)
តថាគតលះបង់បានស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ

តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។

[៣] សេយ្យថាបិ ព្រាហ្មណ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា សម្មា អធិសយិតានិ សម្មា បរិសេទិតានិ សម្មា បរិភាវិតានិ យោ នុ ខោ តេសំ កុក្កុដច្ឆាបកានំ បឋមតរំ បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យ កិន្តិ ស្វាស្ស វចនីយោ ជេដ្ឋោ វា កនិដ្ឋោ វាតិ ។ ជេដ្ឋោតិស្ស ភោ គោតម វចនីយោ សោ ហិ នេសំ ជេដ្ឋោ ហោតីតិ ។ ឯវមេវ ខោ អហំ ព្រាហ្មណ អវិជ្ជាគតាយ បជាយ អណ្ឌភូតាយ បរិយោនទ្ធាយ



បានដកឫសព្រៃបាក់គឺភពទៀត ឲ្យអស់ហើយ ដូចដើមត្នោត ដែលគេ ក្រឡៀលតាស់ហើយ ឲ្យដល់នូវការមិនមានទៀតហើយ បានគ្រឿងឲ្យមិនកើត ដែលមានការមិនកើតទៀតហើយ ឲ្យដល់នូវសេចក្តីមិនកើតតទៅខាងមុខទៀត ហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកនិយាយថា ព្រះសមណគោតម ជា មនុស្សឥតកំណើតនោះ ពិតប្រាកដតាមហេតុនេះ ចុះមិនមែនប្រាកដតាម ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។

(៣) ម្នាលព្រាហ្មណ៍ ប្រៀបដូចជាពងមាន់ចំនួន ៨ ក្តី ១០ ក្តី ១២ ក្តី គឺមេមាន់នោះ ក្រាបលើល្អប្រពៃហើយ ធ្វើឲ្យកក់ក្តៅល្អប្រពៃហើយ ឲ្យបានចំអែកល្អប្រពៃហើយ (លុះដល់វេលាញាស់) កំពស់ក្នុងពួកមាន់ទាំងនោះ កូនមាន់ណា ទំលាយសម្បកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបង្អស់ តើគួរហៅកូនមាន់នោះថា កូនច្បង ឬកូនពៅហ្ន៎ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចំរើន (កូនមាន់នោះ) គេគួរហៅថា កូនច្បង ព្រោះវាជាច្បងជាងគេ ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតក៏ដូចគ្នា ដូចជាពង មាន់ គេគឺហើយ ឋិតក្នុងអវិជ្ជា ដូចជាសត្វកើតក្នុងស្បូន

អវិជ្ជណ្ឌកោសំ បទាលេត្វា ឯកោ វ លោកេ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ ។ ស្វាហំ ព្រាហ្មណ ជេដ្ឋោ សេដ្ឋោ លោកស្ស ។ អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា[១] បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ សោ ខោ អហំ ព្រាហ្មណ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហាសឹ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេសឹ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ

១ ឱ. ម. អសម្មុដ្ឋា ។



ក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទំលាយសម្បកពង គឺសេចក្ដីល្ងង់ ហើយត្រាស់ដឹងនូវឯង ដោយប្រពៃ នូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតដទៃទៀត ប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតឯងជាបុគ្គល ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ម្នាលព្រាហ្មណ៍ ព្យាយាមតថាគតបានប្រារព្ធហើយ មិនបានរួញរាថយ ចំណែកស្មារតី តថាគតក៏ប្រុងមិនឲ្យវង្វេង កាយក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏តាំងនៅល្អជាចិត្តមានអារម្មណ៍តែមួយ ម្នាលព្រាហ្មណ៍ តថាគតឯង លុះដល់ស្រឡះ ដោយស្ងាត់ចាកកាមទាំងឡាយ ស្រឡះជាស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ ក៏ចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ចាកនីវរណ៍នៅហើយ ។ លុះតថាគតឲ្យស្ងប់រម្ងាប់វិតក្កៈ វិចារៈ រួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាធម្មជាតប្រព្រឹត្តទៅខាងក្នុង មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈ វិចារៈ មានតែបីតិនិងសុខ កើតអំពីសមាធិនៅហើយ ។ លុះលះបង់បីតិចេញហើយ តថាគតជាបុគ្គលព្រងើយ មានសតិមានសេចក្ដីដឹងខ្លួននៅហើយ តថាគតសោយសុខដោយនាមកាយផង ពួកអរិយបុគ្គលទាំងឡាយ តែងសរសើរនូវបុគ្គល ដែលបានចូលតតិយជ្ឈាននោះថា ជាបុគ្គលមានចិត្តព្រងើយ

សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ[1] បុព្វេនិវាសានុស្សតិញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ សេយ្យថីទំ ។ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាលីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ

១ ឧ. ម. អាណញ្ជប្បត្តេ ។



ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ ដូច្នេះ តថាគតបានចូលដល់តតិយជ្ឈាន នៅអស់ហើយ ។ ព្រោះលះបង់នូវសេចក្ដីសុខផង ព្រោះលះបង់នូវសេចក្ដីទុក្ខផង ព្រោះរលត់នូវសោមនស្សនិងទោមនស្ស អំពីមុនផង តថាគតបានចូលកាន់ចតុត្ថជ្ឈានឥតទុក្ខ ឥតសុខ មានសតិបរិសុទ្ធ ព្រោះឧបេក្ខា ហើយនៅ ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតឯង ក៏បានបង្អោនចិត្តទៅរលឹក បុព្វេនិវាសានុស្សតិញ្ញាណ (ញាណជាគ្រឿងរលឹកជាតិមុនបាន) ។ តថាគតឯង ក៏រលឹកជាតិដែលធ្លាប់អាស្រ័យនៅមកអំពីមុន ជាអនេកជាតិ ។ រលឹកជាតិមុនដូចម្ដេច ។ រលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ពាន់ជាតិ ១សែនជាតិក៏បាន រលឹកច្រើនសំវដ្ដកប្ប ច្រើនវិវដ្ដកប្ប ច្រើនសំវដ្ដវិវដ្ដកប្បក៏បាន ដូច្នេះថា តថាគតបានកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះ

អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ ព្រាហ្មណ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ អយំ ខោ មេ ព្រាហ្មណ បឋមា អភិនិព្ភិទា អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេសឹ ។



ហើយបានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ តថាគតក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ជាអ្នកទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមណោះ តថាគតនោះច្យុតចាកភពនោះហើយ មកកើតក្នុងភពនេះ ។ តថាគតរលឹកឃើញខន្ធជាតិ ដែលអាស្រ័យនៅពីមុន បានច្រើនជាតិ ព្រមទាំងអាការៈព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះហើយ ដែលតថាគតបានត្រាស់ដឹង ក្នុងយាមជាដំបូងនៃរាត្រី ព្រោះផលសេចក្ដីល្ងង់ខ្លៅផុតទៅ សេចក្ដីចេះដឹងប្រាកដ ក៏កើតឡើង ងងឹតធ្លាក់ផុតទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលគិតមិនធ្វេសប្រហែស ស្មារតី មិនប្រហែសរបស់ប្រើជាផុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅ មានទឹកចិត្តដល់ការយល់នីងតែឡើយ ដូចជាមេមាន់កកទាំងឡាយ ដែលបាន ស្រួលបឋមវិជ្ជានុះដូចគ្នាដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាបឋមវិជ្ជាដែល តថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ញាស់ចេញចាកសម្បកពង ។ កាលបើដែលចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ស្រួលដល់កម្ម ជាចិត្តនឹងនឹងមិនញាប់ញ័រយ៉ាងនេះហើយ ។ តថាគតនាំបង្អោនចិត្តទៅក្នុងញាណ ដែលនាំឲ្យបានត្រាស់ដឹងនូវចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ គឺចុតូបបាតញាណ ។

សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុស-
កេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ
បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថា-
កម្មូបគេ សត្តេ បជានាមិ ឥមេ វត ភោន្តោ សត្តា
កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នា-
គតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា
មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស
ភេទា បរំ មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ
ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយ-
សុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា
មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា
សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស
ភេទា បរំ មរណា សុគតិំ សគ្គំ លោកំ[១] ឧបបន្នាតិ ។
ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុ-
សកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ

១ សគ្គលោកម្បិ បាឋោ ។



ខ្ញុំបានចក្ខុដ៏ប្រសើរ ឃើញនូវសត្វទាំងឡាយ ដែលច្យុតទីតាំងបដិសន្ធិផង
ហើតទាបផង មានសម្បុរល្អផងអាក្រក់ ទៅកាន់សុគតិផងទុគ្គតិ
ដោយចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្ស ហើយខ្ញុំ
ក៏ឃើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា ពួក
សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត
ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្ម ជាមិច្ឆាទិដ្ឋិ
តិះដៀលនូវអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះដល់កាលទំលាយ
ខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ(១) ទុគ្គតិ(២) វិនិបាត(៣)
នរក(៤) មួយសោត ពួកសត្វទាំងឡាយនេះ ប្រកបដោយកាយ-
សុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ
ប្រកាន់នូវកម្ម ជាសម្មាទិដ្ឋិ មិនតិះដៀលអរិយបុគ្គលទាំងឡាយ សត្វ
ទាំងឡាយនោះ លុះដល់កាលទំលាយខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើត
ក្នុងលោកគឺសុគតិ(៥) និងស្ថានសួគ៌(៦) ។ ខ្ញុំបានចក្ខុដ៏ប្រសើរ ឃើញនូវ
សត្វទាំងឡាយ ដែលច្យុតទីតាំងបដិសន្ធិ តាមទៅកើតទីផ្សេង

១ កំណើតសត្វតិរច្ឆាន ។ ២ ប្រេតវិស័យ ។ ៣ អសុរកាយ ដែលធ្លាក់ចុះហើយមិនបានទីពឹង
ពីសុខជាដើម ។ ៤ លោកនរក ឬ កន្លែងទទួលទុក្ខ មានអវិចីជាដើម ។
៥ លោកប្រកបដោយមនុស្សគ្គតិ ។ ៦ ទីឋានទេវតាទាំងឡាយ ។

### វេរញ្ជកណ្ឌោ តេវិជ្ជកថា

សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ។ អយំ ខោ មេ ព្រាហ្មណ រត្តិយា មជ្ឈិមេ យាមេ ទុតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ អយំ ខោ មេ ព្រាហ្មណ ទុតិយា អភិនិព្ភិទា អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេសឹ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ



### វេរញ្ជកណ្ឌ សំដែងអំពីវិជ្ជា

ជាឧបណ្ណាតល្អនឹងអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ដោយចក្ខុជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ គឺឃើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ២ នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាកណ្ដាលនៃរាត្រី លុះដល់សេចក្ដីល្ងង់ខ្លៅបាត់ទៅ សេចក្ដីចេះដឹងប្រាកដ ក៏កើតឡើង ងងឹតក៏បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងប្រឹងព្យាយាម មិនប្រហែសធ្វេស ប្រឹងដុតបំផ្លាញកិលេស មានចិត្តបួនសុទ្ធតែបញ្ជូនទៅមិនអាល័យដល់កាយនិងជីវិតឡើយ ដូចជាកូនមាន់ទាំងឡាយដែលបានចេញវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាវិជ្ជាទី ២ ដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ដែលញាស់ចេញចាកសំបកពង ។ កាលដែលចិត្តជាប់ខ្ជាប់ បរិសុទ្ធផូរផង់ មិនមានកិលេសប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រ យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅកាន់ញាណជាហេតុឲ្យបានអស់ទៅនៃអាសវៈទាំងឡាយ គឺអាសវក្ខយញ្ញាណ តថាគតក៏ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ

ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ អយំ
អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ
អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ
អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភ-
ញ្ញាសឹ ។ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ
កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ(១)
អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ វិមុត្តស្មឹ វិមុត្តមិតិ(២)
ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។
អយំ ខោ មេ ព្រាហ្មណ រត្តិយា បច្ឆិមេ យាមេ
តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា
តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្ប-
មត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ អយំ
ខោ មេ ព្រាហ្មណ តតិយា អភិនិព្ភិទា អហោសិ
កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហាតិ ។

១ [illegible] ចិត្តំ ។ ២ វិមុត្តម្ហីតិ [illegible] ។



ដឹងច្បាស់តាមពិតថា ទាំងនេះជាអាសវៈ ដឹងច្បាស់តាមពិតថា
នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសេចក្តី
រលត់នៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទាឲ្យបានដល់នូវ
សេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ តថាគតឃើញ
យ៉ាងនេះ ចិត្តតថាគតក៏ផុតចាកគ្រឿងត្រាំគឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ
កាលបើចិត្តតថាគតបានរួចផុតស្រឡះហើយ ញាណក៏កើតច្បាស់ដល់
តថាគតថា ចិត្តរួចផុតស្រឡះចាកអាសវៈហើយ តថាគតដឹងច្បាស់
ថា ជាតិរបស់អាត្មាអស់ហើយ ព្រហ្មចរិយធម៌អាត្មាបានប្រព្រឹត្ត
រួចស្រេចហើយ សោឡសកិច្ច អាត្មាក៏បានធ្វើស្រេចហើយ កិច្ចដទៃ
ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលព្រាហ្មណ៍វិជ្ជាទី ៣
នេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាបំផុតនៃរាត្រី លុះដល់
សេចក្តីល្ងង់ខ្លៅខ្ចាត់ខ្ចាយទៅ សេចក្តីចេះដឹងច្បាស់ក៏កើតឡើង ងងឹត
ខ្ចាត់ខ្ចាយទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងតែព្យាយាម ប្រឹងប្រែង
មិនប្រហែសធ្វេស ព្យាយាមដុតបំផ្លាញកិលេស មានចិត្តមូលស្ងប់តែមួយ
មិនអាល័យដល់កាយនិងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយ ដែលបានខ្លួន
វិជ្ជាទី ៣ នុ៎ះដូច្នោះឯង ។ ម្នាលព្រាហ្មណ៍ ការត្រាស់ដឹងរបស់តថាគត
ជាគំរប់ ៣ នេះ ដូចជាទីការញាស់ចេញរបស់កូនមាន់អំពីសម្បកពង ។

(៤) ឯវំ វុត្តេ វេរញ្ជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច ជេដ្ឋោ ភវំ គោតមោ សេដ្ឋោ ភវំ គោតមោ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ(១) ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ អធិវាសេតុ ច មេ ភវំ គោតមោ វេរញ្ជាយំ វស្សាវាសំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។

១ សព្វត្ថ ឯវមេវាតិ បាឋោ ទិស្សតិ ។





(៤) កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគវិញថា ព្រះគោតមដ៏ចំរើន ព្រះអង្គជាចម្បងជាងមនុស្ស ប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចំរើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ក៏ច្បាស់ណាស់) ដូចជាមនុស្សផ្ងាររបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់ទុក ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែកនឹងមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចំរើនប្រោសនូវខ្ញុំព្រះអង្គថាជាឧបាសកដល់សរណគមន៍ស្មើដោយជីវិត មិនកែប្រែណាទេ សូមព្រះគោតមដ៏ចំរើន ទទួលនិមន្តនៅចាំវស្សាជិតក្រុងវេរញ្ជាមួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគក៏ព្រមទទួលនិមន្តដោយតុណ្ហីភាព(១) ។

១ ទទួលនិមន្តដោយស្ងៀម ។

ខោ វេរញ្ជោ ព្រាហ្មណោ ភគវតោ អភិនន្ទិត្វា
ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា
បក្កាមិ ។

(៨) តេន ខោ បន សមយេន វេរញ្ជា ទុព្ភិក្ខា ហោតិ ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ ។ តេន ខោ បន សមយេន ឧត្តរាបថកា អស្សវាណិជា បញ្ចមត្តេហិ អស្សសតេហិ វេរញ្ជំ វស្សាវាសំ ឧបគតា ហោន្តិ ។ តេហិ អស្សមណ្ឌលិកាសុ ភិក្ខូនំ បត្ថបត្ថបុលកំ[១] បញ្ញត្តំ ហោតិ ។ ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេរញ្ជំ[២] បិណ្ឌាយ បវិសិត្វា បិណ្ឌំ អលភមានា អស្សមណ្ឌលិកាសុ បិណ្ឌាយ ចរិត្វា បត្ថបត្ថបុលកំ អារាមំ អាហរិត្វា

១ សព្វត្ថ បត្ថបត្ថមូលកន្តិ ទិស្សតិ ។ ២ ឱ. ម. វេរញ្ជេ ។



លំដាប់នោះ វេរញ្ជព្រាហ្មណ៍ក៏ក្រោកចាកអាសនៈ ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ជៀសចេញទៅ ។

(៨) សម័យនោះឯង ស្រុកវេរញ្ជាកើតអត់បាយ មនុស្សទាំងឡាយងាប់ឆ្អឹងស ... មនុស្សណាដែលក្រីក្រ ... (ដោយសារអត់បាយ) មនុស្សដែលមានប្រាជ្ញា ... សម័យនោះ មានពួកឈ្មួញសេះមកពីឧត្តរាបថប្រទេស នាំសេះចំនួន ៥០០ ចូលមកនៅវស្សាក្នុងស្រុកវេរញ្ជា ។ ពួកឈ្មួញសេះទាំងនោះ ក៏ចាត់ចែងស្រូវដែលជាចំណីសេះ ... ម្នាក់ៗ ... ក្នុងរោងសេះ[១] ... ក្នុងស្រុកវេរញ្ជា ... ក៏ចូលទៅកាន់រោងសេះ ...

១ ស្រូវសម្រាប់ដាក់ជាចំណីសេះ ... ។

ឧទុក្ខលេ កោដ្ដេត្វា កោដ្ដេត្វា បរិភុញ្ជន្តិ ។ អាយស្មា
បនានន្ទោ បត្ថបុលកំ សិលាយំ បិសិត្វា(១)
ភគវតោ ឧបនាមេតិ ។ តំ ភគវា បរិភុញ្ជតិ ។
អស្សោសិ ខោ ភគវា ឧទុក្ខលសទ្ទំ ។ ជានន្តាបិ
តថាគតា បុច្ឆន្តិ ជានន្តាបិ ន បុច្ឆន្តិ កាលំ
វិទិត្វា បុច្ឆន្តិ កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសំហិតំ
តថាគតា បុច្ឆន្តិ នោ អនត្ថសំហិតំ អនត្ថសំហិតេ
សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា
ភគវន្តោ ភិក្ខូ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម
សាវកានំ វា សិក្ខាបទំ បញ្ញបេស្សាមាតិ ។
អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កិំ នុ
ខោ សោ អានន្ទ ឧទុក្ខលសទ្ទោតិ ។ អថខោ
អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។

---

១ ម. បិំសិត្វា ។



យកចុះពីក្រឹមនោះបុកក្នុងត្បាល់រួចហើយឆាន់ ។ ចំណែកខាងព្រះ
អានន្ទដ៏មានអាយុ យកចុះពីក្រឹម ១ ទៀត កិនក្នុងត្បាល់ថ្មហើយយក
ទៅថ្វាយព្រះដ៏មានព្រះភាគ ។ ព្រះអង្គក៏ទ្រង់ទទួលសោយចុះពីក្រឹម
នោះ ។ វេលានោះ ព្រះសម្ពុទ្ធទ្រង់បានឮសូរត្បាល់និងអង្រែនោះហើយ ។
ព្រះតថាគតទាំងឡាយ កាលទ្រង់ជ្រាបនូវហេតុហើយសួរក៏មាន កាលទ្រង់ជ្រាប
ហើយមិនសួរក៏មាន ទ្រង់ជ្រាបច្បាស់នូវកាលគួរហើយសួរក៏មាន ទ្រង់ជ្រាបច្បាស់
នូវកាលគួរហើយមិនសួរក៏មាន ឯព្រះតថាគតទាំងឡាយ ព្រះអង្គទ្រង់
សួរនូវការណាដែលប្រកបដោយប្រយោជន៍ ការដែលមិនប្រកបដោយ
ប្រយោជន៍ ព្រះអង្គមិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់
បានផ្ដាច់បង់នូវការមិនប្រកបដោយប្រយោជន៍ទាំងឡាយ ដោយអរិយមគ្គ
ស្រេចស្រឡះហើយ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ទ្រង់តែងសួរ
នូវភិក្ខុទាំងឡាយ ដោយហេតុពីរប្រការ គឺ ទ្រង់សួរដើម្បីនឹងសំដែងនូវ
ធម៌ ១ ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ១ ។ គ្រានោះ
ព្រះដ៏មានព្រះភាគទ្រង់ហៅព្រះអានន្ទដ៏មានអាយុមក ហើយទ្រង់សួរថា
ម្នាលអានន្ទ សូរសំឡេងនោះជាសូរត្បាល់អ្វីដែរឬអ្វី ។ ទើបព្រះអានន្ទ
ដ៏មានអាយុក្រាបទូលរឿងនុ៎ះឲ្យព្រះដ៏មានព្រះភាគជ្រាបគ្រប់ប្រការ ។

សាធុ សាធុ អានន្ទ តុម្ហេហិ អានន្ទ សប្បុរិសេហិ
វិជិតំ បច្ឆិមា ជនតា សាលិមំសោទនំ អតិមញ្ញិស្សតីតិ ។

[៦] អថខោ អាយស្មា មហាមោគ្គល្លានោ យេន
ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា
ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា
មហាមោគ្គល្លានោ ភគវន្តំ ឯតទវោច ឯតរហិ ភន្តេ
វេរញ្ជា ទុព្ភិក្ខា ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា
ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ ឥមិស្សា ភន្តេ
មហាបឋវិយា ហេដ្ឋិមតលំ សម្បន្នំ[១] សេយ្យថាបិ
ខុទ្ទកមធុំ[២] អនីលកំ ឯវមស្សាទំ សាធាហំ ភន្តេ
បឋវឹ បរិវត្តេយ្យំ ភិក្ខូ បប្បដកោជំ បរិភុញ្ជិស្សន្តីតិ ។

១ ម. ភ. ផលសម្បន្នំ ។ ២ ឱ. ខុទ្ទមធុំ ។



ព្រះបន្ទូលត្រាស់ថា ត្រូវហើយ អានន្ទ ប្រពៃហើយ អានន្ទ អ្នក
ទាំងឡាយជាសប្បុរសឈ្នះវិសេសហើយ ប្រជុំជនខាងក្រោយនឹង
មើលងាយនូវភោជនដែលគេធ្វើនឹង បាយអង្ករក្រហម ព្រមទាំងម្ហូប
លាយដោយសាច់ជាភក្សាហារ (ដល់អ្នកលំបាក) ។

[៦] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ចូលទៅគាល់ព្រះ
ដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព
រួចហើយក៏គង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុគង់ក្នុង
ទីដ៏សមគួរហើយ ក៏ក្រាបទូលសេចក្តីនេះចំពោះព្រះដ៏មានព្រះភាគថា
សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវនេះ ស្រុកវេរញ្ជាកើតអំណត់អត់ស្បៀង
មនុស្សទាំងឡាយចិញ្ចឹមជីវិតរស់នៅដោយកម្រក្រៃពេក មនុស្សណា
ដែលក្រលំបាកស្លាប់ទៅ ឆ្អឹងក៏ប្រាកដមានពណ៌ស (ដូចជាបណ្ណែខ្ចី) មនុស្ស
ដែលមានទ្រព្យសម្បត្តិល្មមទិញស្រូវស្រែអង្ករគេបាន គឺមិនអាចនឹងទិញ
ស្រូវ លើលុះតែមានស្លាកសញ្ញាជាសំគាល់ទោះទើបទិញស្រូវបាន ជនទាំងអស់
ក្នុងស្រុកនោះ មិនងាយយាបនីយការដោយការរើសយកម្រៃកោត សូម
ទ្រង់ព្រះមេត្តាប្រោស ផែនដីក្រោមនៃផែនដីនេះ មានរសជាតិឆ្ងាញ់ដូច
ទឹកឃ្មុំ ដែលស្អាតបរិសុទ្ធឥតលាយដោយពងឃ្មុំ សូមទ្រង់ព្រះមេត្តា
ប្រោស ខ្ញុំព្រះអង្គនឹងប្រែត្រឡប់ផែនដីនេះឲ្យផ្ងារឡើង ដើម្បីឲ្យភិក្ខុ
ទាំងឡាយឆាន់នូវឱជារស ដែលកើតឡើងអំពីស្រទាប់នៃផែនដីនោះ ។

៖ យេ បន តេ មោគ្គល្លាន បឋវិនិស្សិតា បាណា តេ កថំ ករិស្សសីតិ ។ ឯកាហំ ភន្តេ បាណឹ អភិនិម្មិនិស្សាមិ សេយ្យថាបិ មហាបឋវី យេ បឋវិនិស្សិតា បាណា តេ តត្ថ សង្កាមេស្សាមិ ឯកេន ហត្ថេន បឋវឹ បរិវត្តេស្សាមីតិ ។ អលំ មោគ្គល្លាន មា តេ រុច្ចិ បឋវឹ បរិវត្តេតុំ វិបល្លាសំបិ សត្តា បដិលភេយ្យុន្តិ ។ សាធុ ភន្តេ សព្វោ ភិក្ខុសង្ឃោ ឧត្តរកុរុំ បិណ្ឌាយ គច្ឆេយ្យាតិ ។ យេ បន តេ មោគ្គល្លាន ភិក្ខូ អនិទ្ធិមន្តោ តេ កថំ ករិស្សសីតិ ។ តថាហំ ភន្តេ ករិស្សាមិ យថា សព្វោ ភិក្ខុ គច្ឆិស្សន្តីតិ ។ អលំ មោគ្គល្លាន មា តេ រុច្ចិ សព្វស្ស ភិក្ខុសង្ឃស្ស ឧត្តរកុរុំ បិណ្ឌាយ គមនន្តិ ។





ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចុះអ្នកនឹងយកមនុស្ស សត្វទាំងឡាយដែលនៅលើផែនដីនេះ ទុកនៅឯណា ។ ព្រះមហាមោគ្គល្លានទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងនិម្មិតដៃម្ខាង ឲ្យបានធំដូចជាផែនដី ដើម្បីឲ្យសត្វទាំងឡាយដែលនៅលើផែនដី មកនៅលើបាតដៃម្ខាងនោះ ហើយខ្ញុំព្រះអង្គនឹងប្រែឡប់ផែនដីដោយដៃម្ខាង ។ ព្រះអង្គទ្រង់ត្រាស់ថា មោគ្គល្លាន អ្នកកុំពេញចិត្តនឹងត្រឡប់ផែនដីនោះឡើយ សត្វទាំងឡាយនឹងបានទទួលសេចក្ដីជ្រួលច្របល់ ។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះពុទ្ធដីកាដែលទ្រង់ត្រាស់មកនោះប្រពៃហើយ (បើដូច្នោះ) សូមឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯឧត្តរកុរុទ្វីបវិញ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលមោគ្គល្លាន ចុះភិក្ខុទាំងឡាយឯណាដែលមិនមានឫទ្ធិ អ្នកនឹងធ្វើឲ្យភិក្ខុទាំងនោះដូចម្ដេចទៅ ។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុទាំងអស់នឹងទៅបានយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា កុំ មោគ្គល្លាន អ្នកកុំពេញចិត្តឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯឧត្តរកុរុទ្វីបនោះឡើយ ។

[៧] អថខោ អាយស្មតោ សារីបុត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កតមេសានំ ខោ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសិ កតមេសានំ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កតមេសានំ ខោ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសិ កតមេសានំ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។ ភគវតោ ច សារីបុត្ត វិបស្សិស្ស ភគវតោ ច សិខិស្ស



(៧) គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ លោកចូលទៅនៅក្នុងរហោឋានជាទីចេញចាកពួក ហើយសម្ងំនៅក្នុងទីសម្ងាត់ បានសេចក្ដីត្រិះរិះថា ព្រហ្មចរិយធម៌(១) របស់ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌ឋិតនៅយូរ ។ គ្រានោះ ព្រះសារីបុត្តត្ថេរដ៏មានអាយុ ចេញចាកទីសម្ងំក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចូលទៅនៅក្នុងរហោឋានជាទីចេញចាកពួក ហើយសម្ងំនៅក្នុងទីសម្ងាត់ មានសេចក្ដីត្រិះរិះថា ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌ឋិតនៅយូរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១

១ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ចំពោះក្រុមត្រៃសិក្ខា គឺ សីល សមាធិ បញ្ញា ។

ភគវតោ ច វេស្សភុស្ស ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសិ ភគវតោ ច សារីបុត្ត កកុសន្ធស្ស ភគវតោ ច កោនាគមនស្ស ភគវតោ ច កស្សបស្ស ព្រហ្មចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន ភគវតោ ច វិបស្សិស្ស ភគវតោ ច សិខិស្ស ភគវតោ ច វេស្សភុស្ស ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសីតិ ។ ភគវា ច សារីបុត្ត វិបស្សី ភគវា ច សិខី ភគវា ច វេស្សភូ កិលាសុនោ អហេសុំ សាវកានំ វិត្ថារេន ធម្មំ ទេសេតុំ អប្បកញ្ច នេសំ អហោសិ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ អប្បញ្ញត្តំ សាវកានំ សិក្ខាបទំ អនុទ្ទិដ្ឋំ បាតិមោក្ខំ តេសំ ពុទ្ធានំ ភគវន្តានំ អន្តរធានេន





ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ម្នាលសារីបុត្ត ឯព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ ១ ព្រះដ៏មានព្រះភាគព្រះនាមកោនាគមន ១ ព្រះដ៏មានព្រះភាគព្រះនាមកស្សប ១ ជាព្រហ្មចរិយធម៌ឋិតនៅបានយូរ ។ ព្រះសារីបុត្តត្ថេរក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ ព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ បានជាមិនឋិតនៅយូរ តើព្រោះហេតុនិងបច្ច័យដូចម្ដេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ ព្រះអង្គមិនសូវប្រឹងប្រែង[១] សំដែងធម៌ដល់សាវកទាំងឡាយដោយពិស្ដារប៉ុន្មានទេ ព្រហ្មចរិយធម៌មានអង្គ ៩ ប្រការ របស់ព្រះពុទ្ធទាំងឡាយនោះគឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ជាធម៌ពុទ្ធវចនតិច ៗ ណាស់ សិក្ខាបទក៏ព្រះពុទ្ធទាំងនោះមិនបានបញ្ញត្តដល់សាវកទាំងឡាយទេ ឯបាតិមោក្ខ ក៏ព្រះពុទ្ធទាំងនោះមិនបានសំដែងឡើយ ដល់អកាលៈ ដែលព្រះពុទ្ធដ៏មានព្រះភាគ

[១] ប្រែចេញពីពាក្យថា កិលាសុនោ សព្វថ្ងៃនេះប្រែថាខ្ជិល ប៉ុន្តែក្នុងទីនេះបើប្រែថាខ្ជិល នឹងពោលជាក្លែងសេចក្ដី មិនសមតាមន័យក្នុងអដ្ឋកថា ។ ប្រាប់សេចក្ដីថា ព្រះពុទ្ធគ្មានសេចក្ដីខ្ជិលទេ ។

ពុទ្ធានុពុទ្ធានំ សាវកានំ អន្តរធានេន យេ តេ បច្ឆិមា សាវកា នានានាមា នានាគោត្តា នានាជច្ចា នានាកុលា បព្ពជិតា តេ តំ ព្រហ្មចរិយំ ខិប្បញ្ញេវ អន្តរធាបេសុំ សេយ្យថាបិ សារិបុត្ត នានាបុប្ផានិ ផលកេ និក្ខិត្តានិ សុត្តេន អសង្គហិតានិ តានិ វាតោ វិកិរតិ វិធមតិ វិទ្ធំសេតិ តំ កិស្ស ហេតុ យថាតំ សុត្តេន អសង្គហិតត្តា ឯវមេវ ខោ សារិបុត្ត តេសំ ពុទ្ធានំ ភគវន្តានំ អន្តរធានេន ពុទ្ធានុពុទ្ធានំ សាវកានំ អន្តរធានេន យេ តេ បច្ឆិមា សាវកា នានានាមា នានាគោត្តា នានាជច្ចា នានាកុលា បព្ពជិតា តេ តំ ព្រហ្មចរិយំ ខិប្បញ្ញេវ អន្តរធាបេសុំ កិលាសុនោ ច តេ ពុទ្ធា(១) ភគវន្តោ អហេសុំ សាវកេ(២) ចេតសា ចេតោ បរិច្ច ឱវទិតុំ ភូតបុព្វំ សារិបុត្ត

១ ឥទំ បទំ កត្ថចិ ន ទិស្សតិ ។ ២ សាវកានន្តិ អត្ថិ ។



ទាំងឡាយនោះទៅ ដំណើរនេះគឺសាវកទាំងឡាយជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធនោះទៅ សាវកទាំងឡាយជាខាងក្រោយមក ដែលមានឈ្មោះផ្សេង ៗ គ្នា មានគោត្តផ្សេង ៗ គ្នា មានជាតិផ្សេង ៗ គ្នា ចេញពីត្រកូលផ្សេង ៗ គ្នាហើយបួសនោះ ក៏ញុំាងព្រហ្មចរិយធម៌នោះឲ្យសាបសូន្យបាត់អស់ភ្លាមទៅ ម្នាលសារីបុត្ត ដូចជាផ្កាឈើផ្សេង ៗ ដែលគេមិនបានដោតក្រងនឹងខ្សែហើយ គេដាក់លើបន្ទះក្តារ ខ្យល់ក៏រមែងតែបក់រុះកំចាត់កំចាយផ្កាទាំងនោះឲ្យវិនាសអស់ទៅ ខ្យល់ដែលធ្វើនូវផ្កាទាំងនោះឲ្យវិនាសព្រោះហេតុអ្វី ពីព្រោះផ្កាទាំងនោះគេមិនបានដោតក្រងនឹងដោយខ្សែ ដំណើរនេះយ៉ាងណាមិញ ម្នាលសារីបុត្ត លុះកាលណាក៏ផុតខ័នព្រះសម្ពុទ្ធដ៏ទ្រង់ព្រះភាគ (ទាំង ៣ ព្រះអង្គ) នោះ និងពួកសាវកដែលជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះទៅហើយ ពួកសាវកជាន់ក្រោយ ៗ មក មានឈ្មោះ គោត្ត ជាតិផ្សេង ៗ គ្នា ដែលចេញចាកត្រកូលផ្សេង ៗ គ្នាមកបួសនោះ ក៏ញុំាងព្រហ្មចរិយធម៌នោះឲ្យវិនាសទៅឆាប់ភ្លាម ដូចជាផ្កាដែលគេកំចាត់យ៉ាងនោះឯង ម្យ៉ាងទៀត ព្រះពុទ្ធទ្រង់មានសេចក្តីនឿយណាយមិនសូវប្រឹងប្រែងស្ទង់ចិត្ត (របស់សាវក) ដោយព្រះហឫទ័យ (របស់ព្រះអង្គ) ហើយទូន្មានឲ្យសាវកទាំងឡាយប៉ុន្មានឡើយ ម្នាលសារីបុត្ត

វេស្សភូ ភគវា អរហំ សម្មាសម្ពុទ្ធោ អញ្ញតរស្មឹ ភឹសនកេ វនសណ្ឌេ សហស្សំ ភិក្ខុសង្ឃំ ចេតសា ចេតោ បរិច្ច ឱវទតិ អនុសាសតិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសាកត្ថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ អថខោ សារិបុត្ត តស្ស ភិក្ខុសហស្សស្ស[១] វេស្សភុនា ភគវតា អរហតា សម្មាសម្ពុទ្ធេន ឯវំ ឱវទិយមានានំ ឯវំ អនុសាសិយមានានំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ តត្រ សុទំ សារិបុត្ត ភឹសនកស្ស វនសណ្ឌស្ស ភឹសនកតស្មឹ ហោតិ យោ កោចិ អវីតរាគោ តំ វនសណ្ឌំ បវិសតិ យេភុយ្យេន[២] លោមានិ ហំសន្តិ អយំ ខោ សារិបុត្ត ហេតុ អយំ បច្ចយោ យេន ភគវតោ ច វិបស្សិស្ស ភគវតោ ច សិខិស្ស ភគវតោ ច វេស្សភុស្ស ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសីតិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន ភគវតោ ច

១ ពេស៊ី ភិក្ខុសង្ឃស្ស អញ្ញត្ថ ទិស្សតិ ។ ២ ឧ. យេភុយ្យេន ។



ពីដើមបកតមានក្បែរដំណាលឯ ព្រះអរហន្តសម្មាសម្ពុទ្ធដ៏មានព្រះភាគទ្រង់ព្រះនាមវេស្សភូ ព្រះអង្គកំណត់នូវចិត្ត (របស់ភិក្ខុ) ដោយព្រះហឫទ័យ (របស់ព្រះអង្គ) ហើយទ្រង់ទូន្មានប្រៀនប្រដៅភិក្ខុសង្ឃចំនួន ១ ពាន់រូប នៅនាដងព្រៃមួយ ដ៏គួរស្ញែង ដោយពុទ្ធដីកាថា អ្នកទាំងឡាយចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរយកចិត្តទុកដាក់យ៉ាងនេះ កុំយកចិត្តទុកដាក់យ៉ាងនេះឡើយ ចូរលះបង់អំពើយ៉ាងនេះចេញ ហើយចូរសម្រេចនូវគុណដ៏ប្រសើរប្រពៃនៅនេះវិញ ម្នាលសារីបុត្ត នៅវេលាដែលព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះនាមវេស្សភូទ្រង់ទូន្មានប្រៀនប្រដៅយ៉ាងនេះៗហើយ ចិត្តរបស់ភិក្ខុទាំង ១ ពាន់រូបនោះ ក៏បានរួចស្រឡះចាកអាសវៈទាំងឡាយ មិនមានសេសសល់ប្រកាន់មាំឡើយ ម្នាលសារីបុត្ត ដងព្រៃដែលគួរខ្លាចនោះមានក្តីខ្លាចស្រឡាំងកាំងណាស់ បើបុគ្គលណាមួយមិនទាន់ប្រាសចាកតម្រេកនៅឡើយទេ លុះចូលចូលទៅកាន់ដងព្រៃនោះហើយ បុគ្គលនោះមានរោមព្រឺដោយច្រើន ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ ព្រះនាមវិបស្សី ១ ព្រះនាមសិខី ១ ព្រះនាមវេស្សភូ ១ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រោះហេតុនិងបច្ច័យប៉ុណ្ណេះឯង ។ ព្រះសារីបុត្តក្រាបបង្គំទូលសួរទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ

កកុសន្ធស្ស ភគវតោ ច កោណាគមនស្ស
ភគវតោ ច កស្សបស្ស ព្រហ្មចរិយំ ចិរដ្ឋិតិកំ
អហោសីតិ ។ ភគវា ច សារីបុត្ត វិបស្សី
ភគវា ច សិខី ភគវា ច វេស្សភូ
កិលាសុនោ អហេសុំ សាវកានំ វិត្ថារេន ធម្មំ
ទេសេតុំ អប្បកញ្ច នេសំ អហោសិ សុត្តំ គេយ្យំ
វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ
អព្ភុតធម្មំ វេទល្លំ អបញ្ញត្តំ សាវកានំ សិក្ខាបទំ
អនុទ្ទិដ្ឋំ បាតិមោក្ខំ តេសំ ពុទ្ធានំ ភគវន្តានំ អន្តរ-
ធានេន ពុទ្ធានុពុទ្ធានំ សាវកានំ អន្តរធានេន យេ
តេ បច្ឆិមា សាវកា នានានាមា នានាគោត្តា នា-
នាជច្ចា នានាកុលា បព្វជិតា តេ តំ ព្រហ្មចរិយំ
ខិប្បញ្ញេវ អន្តរធាបេសុំ សេយ្យថាបិ សារីបុត្ត នា-
នាបុប្ផានិ ផលកេ និក្ខិត្តានិ សុត្តេន អសង្គហិតានិ
តានិ វាតោ វិកិរតិ វិធមតិ វិទ្ធំសេតិ
តំ កិស្ស ហេតុ យថាតំ សុត្តេន អសង្គហិតត្តា



ព្រះនាមកកុសន្ធ១ ព្រះនាមកោនាគមន១ ព្រះនាមកស្សប១ (តាំងពី
ព្រះអង្គនេះ) បានឋិតនៅយូរ តើព្រោះហេតុដូចម្តេច ? ព្រះ
សម្ពុទ្ធត្រាស់តបថា ម្នាលសារីបុត្ត ព្រោះព្រះមានព្រះភាគព្រះនាមកកុ-
សន្ធ១ ព្រះនាមកោនាគមន៍១ ព្រះនាមកស្សប១ (តាំងពីព្រះអង្គនោះ)
ទ្រង់មានសេចក្តីឧស្សាហ៍ខ្វល់ខ្វាយសំដែងធម៌ដល់ពួកសាវកដោយពិស្តារ
គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ
វេទល្លៈ របស់ព្រះពុទ្ធទាំង ៣ ព្រះអង្គនោះក៏មានច្រើន ព្រះអង្គទ្រង់
បញ្ញត្តសិក្ខាបទ ទ្រង់សំដែងបាតិមោក្ខដល់ពួកសាវក លុះព្រះ
សម្ពុទ្ធទាំងឡាយជាគ្រូនៃលោកបរិនិព្វានទៅ ទ្រង់ប្តូរចិត្តទៅ ពួកសាវកដែល
ក្រោយពីនិព្វានព្រះពុទ្ធទាំងនោះ គឺពួកសាវកទាំងឡាយ សាវកជាច្រើន
ឯទៀតៗ ដែលមាននាមផ្សេងៗគ្នា មានគោត្រផ្សេងៗគ្នា
មានជាតិផ្សេងៗគ្នា ចេញមកពីត្រកូលផ្សេងៗគ្នា ហើយបួសនោះ ក៏
បានញ៉ាំងព្រហ្មចរិយធម៌ ឲ្យឋិតនៅអស់កាលយូរអង្វែងតទៅ ម្នាល
សារីបុត្ត មានឧបមាដូចផ្កាឈើផ្សេងៗ ដែលគេ...
ដាក់លើបន្ទះក្តារ ឲ្យល្អដោយ (ខ្សែ) ...
ផ្កាទាំងឡាយនោះ ... ឡើយ សេចក្តីនេះ ព្រោះហេតុអ្វី ព្រោះ
ផ្កាទាំងនោះគេក្រងទុកយ៉ាងល្អដោយខ្សែ ...

ឯវមេវ ខោ សារីបុត្ត តេសំ ពុទ្ធានំ ភគវន្តានំ អន្តរធានេន ពុទ្ធានុពុទ្ធានំ សាវកានំ អន្តរធានេន យេ តេ បច្ឆិមា សាវកា នានានាមា នានាគោត្តា នានាជច្ចា នានាកុលា បព្វជិតា តេ តំ ព្រហ្មចរិយំ ចិរំ ទីឃមទ្ធានំ ឋបេសុំ អយំ ខោ សារីបុត្ត ហេតុ អយំ បច្ចយោ យេន ភគវតោ ច កកុសន្ធស្ស ភគវតោ ច កោនាគមនស្ស ភគវតោ ច កស្សបស្ស ព្រហ្មចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។

(៤) អថខោ អាយស្មា សារីបុត្តោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា សាវកានំ សិក្ខាបទំ បញ្ញាបេយ្យ ឧទ្ទិសេយ្យ បាតិមោក្ខំ យថយិទំ(១) ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកន្តិ ។ អាគមេហិ ត្វំ សារីបុត្ត

១ ឧ. យថយិទំ ។



ម្នាលសារីបុត្រ សេចក្ដីនេះមានឧបមាយ៉ាងដូច្នោះដែរ លុះព្រះពុទ្ធដ៏មានព្រះភាគទាំងនោះ អន្តរធានទៅហើយ សាវកទាំងឡាយដែលត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះក៏អន្តរធានទៅហើយដែរ សាវកទាំងឡាយជាខាងក្រោយ ដែលមានឈ្មោះផ្សេងៗគ្នា មានគោត្រផ្សេងៗគ្នា មានជាតិផ្សេងៗគ្នា ចេញចាកត្រកូលផ្សេងៗ មកបួស ក៏តាំងព្រហ្មចរិយធម៌ (សាសនា) ឲ្យឋិតនៅអស់កាលអង្វែងវែង ម្នាលសារីបុត្រ នេះឯងជាហេតុ ជាបច្ច័យ នាំឲ្យព្រហ្មចរិយធម៌ របស់ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកោនាគមនៈ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកស្សបៈ ឲ្យឋិតនៅបានយូរ ។

(៤) លំដាប់នោះ ព្រះសារីបុត្រមានអាយុក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគដើម្បីនឹងបញ្ញត្តសិក្ខាបទ ឬសំដែងបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយជាហេតុនឹងឲ្យព្រហ្មចរិយធម៌នេះឋិតនៅអស់កាលអង្វែងវែង ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលសារីបុត្រ អ្នកចូរចាំសិន ម្នាលសារីបុត្រ

អាគមេហិ ត្វំ សារីបុត្ត តថាគតោ វ តត្ថ កាលំ ជានិស្សតិ។ ន តាវ សារីបុត្ត សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ឧទ្ទិសតិ បាតិមោក្ខំ យាវ ន ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ យតោ ច ខោ សារីបុត្ត ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ឧទ្ទិសតិ បាតិមោក្ខំ តេសំយេវ អាសវដ្ឋានិយានំ ធម្មានំ បដិឃាតាយ។ ន តាវ សារីបុត្ត ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ យាវ ន សង្ឃោ វេបុល្លមហត្តំ បត្តោ ហោតិ យតោ ច ខោ សារីបុត្ត សង្ឃោ វេបុល្លមហត្តំ បត្តោ ហោតិ អថ ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ឧទ្ទិសតិ បាតិមោក្ខំ តេសំយេវ អាសវដ្ឋានិយានំ ធម្មានំ បដិឃាតាយ។ ន តាវ



ព្រះតថាគតនឹងជ្រាប អ្នកចាំសិន នឹងដឹងនូវកាលក្នុងកិច្ចដែលទ្រង់បញ្ញត្តសិក្ខាបទនោះឯង ម្នាលសារីបុត្ត ធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ មិនទាន់កើតមានក្នុងសង្ឃក្នុងសាសនានេះដរាបណា ព្រះសាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សំដែងបាតិមោក្ខ ដល់សាវកទាំងឡាយដរាបនោះ ម្នាលសារីបុត្ត លុះតែធម៌ទាំងឡាយជាទីតាំងនៃអាសវៈមានកើតឡើងក្នុងសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សំដែងបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារកំចាត់បង់ធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះឯង ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសយូរច្រើនគ្នាដរាបណា ធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានកើតឡើងក្នុងសង្ឃក្នុងសាសនានេះដរាបនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីធំព្រោះមានភិក្ខុបួសយូរច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈ ក៏នឹងមានកើតឡើងក្នុងសង្ឃក្នុងសាសនានេះ ក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សំដែងបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារកំចាត់ធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈទាំងពួកនោះ ក្នុងកាលនោះឯង

សារីបុត្ត ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ យាវ ន សង្ឃោ វេបុល្លមហត្តំ បត្តោ ហោតិ យតោ ច ខោ សារីបុត្ត សង្ឃោ វេបុល្លមហត្តំ បត្តោ ហោតិ អថ ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ឧទ្ទិសតិ បាតិមោក្ខំ តេសំយេវ អាសវដ្ឋានិយានំ ធម្មានំ បដិឃាតាយ ។ ន តាវ សារីបុត្ត ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ យាវ ន សង្ឃោ លាភគ្គមហត្តំ បត្តោ ហោតិ យតោ ច ខោ សារីបុត្ត សង្ឃោ លាភគ្គមហត្តំ បត្តោ ហោតិ អថ ឥធេកច្ចេ អាសវដ្ឋានិយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ឧទ្ទិសតិ បាតិមោក្ខំ តេសំយេវ អាសវដ្ឋានិយានំ ធម្មានំ បដិឃាតាយ និរព្វុទោ ហិ សារីបុត្ត ភិក្ខុសង្ឃោ



ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្តីធំដោយមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដក្នុងសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីធំដោយមានគ្នាច្រើនក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សំដែងនូវបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការកំចាត់នូវធម៌ដែលជាទីតាំងនៃអាសវៈ ទាំងឡាយនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីធំដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់កើតប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃដល់នូវសេចក្តីធំដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សំដែងនូវបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការកំចាត់នូវធម៌ដែលជាទីតាំងនៃអាសវៈទាំងឡាយនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ ( ឥឡូវ ) ភិក្ខុសង្ឃនៅមិនទាន់មានពុក ( ហៅថាបុគ្គលទ្រុស្តកក្រក់ ) នៅស្អាត

និរាទីនវោ អបគតកាឡកោ សុទ្ធោ បរិយោទាតោ សារេ បតិដ្ឋិតោ ឥមេសំ ហិ សារិបុត្ត បញ្ចន្នំ ភិក្ខុសតានំ យោ បច្ឆិមកោ ភិក្ខុ សោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ ។

(៨) អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាចិណ្ណំ ខោ បនេតំ អានន្ទ តថាគតានំ យេហិ និមន្តិតា វស្សំ វសន្តិ ន តេ អនបលោកេត្វា ជនបទចារិកំ បក្កមន្តិ អាយាមានន្ទ វេរញ្ជំ ព្រាហ្មណំ អបលោកេស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា និវាសេត្វា បត្តចីវរមាទាយ



មិនទាន់មានទោសណាមួយនៅឡើយ ភិក្ខុនៅមានធម៌ជាខ្លឹម ឥតមានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែបរិសុទ្ធ ស្ថិតនៅក្នុងធម៌ជាខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង ៥០០ រូប[១]នេះ ភិក្ខុដែលជាអ្នកដែលយ៉ាងទាបបំផុតនោះ ក៏គង់បានសម្រេចត្រឹមជាព្រះសោតៈ ជាបុគ្គលទៀងមិនមានធម៌ធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលតៗ ទៅទៀតជាប្រាកដ ។

(៨) (លុះចេញវស្សាហើយ) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ហើយមានព្រះបន្ទូលថា អានន្ទ ទំនៀមព្រះតថាគតទាំងឡាយ បើអ្នកណានិមន្តឲ្យនៅចាំវស្សាហើយ តែនៅមិនទាន់បានលាអ្នកនោះៗ ក៏មិនដែលចៀសចេញ (ពីទីនោះ) ទៅកាន់ជនបទចារិកឡើយ ចរិតនេះជាទំនៀមរបស់ព្រះតថាគតទាំងឡាយ មកអានន្ទ យើងនឹងទៅលាវេរញ្ជព្រាហ្មណ៍ ។ ព្រះអានន្ទដ៏មានអាយុក៏ទទួលព្រះពុទ្ធដីកាថា សូមទ្រង់ព្រះមេត្តាប្រោស មែនយ៉ាងនេះហើយ ។ លំដាប់នោះ ព្រះភគវាព្រះអង្គទ្រង់ស្បង់ទ្រង់ចីពរព្រមទាំងបាត្រស្រេចហើយ

---

១ ភិក្ខុទាំង ៥០០ រូប ដែលមកនៅចាំវស្សាជាមួយនឹងព្រះអង្គ ពិតប្រាកដជាព្រះអរិយៈទាំងអស់ឯង ។

ការុញ្ញតា អាមន្តេត្វា បព្វាសមណោ យេន វេស្សន្តរស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ វេស្សន្តរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វេស្សន្តរំ ព្រាហ្មណំ ភគវា ឯតទវោច ឥមន្តិ ត្វំ ព្រាហ្មណ វេស្សន្តរ អបលោ-កេម[1] តំ វណ្ណយ ឋបេ ឥធមនសិករ បញ្ញាមន្តិ ។ សត្ថុ ហោ គោតម ឥមន្តិ ត្វំ មយា វេស្សន្តរ អហំ យោ ឯវរូបេ ភោ ច អញ្ញោ តត្ថ ទោ ហោ អសង្កំ ឯវំ អធាតុកាមស្សា តំ ធាតុគត្វា សន្តោ ពហុកិច្ចា យាចកោ ពហុការណីយោ អនិកសេដ្ឋ បេ តំ គោតមោ សោតុកាមោ គន្តុំ សម្មុំ កិច្ច-សាធូនាតិ ។ អធិកសេសំ ភគវា តុណ្ហីភាវេន ។

———

1. ម. ឋ. អបលោកេមាមិ ។





ទ្រង់យកព្រះអង្គដំណេកនៃកាយព្រះបញ្ចាសមណៈ (ទ្រង់មន្តគាថាក្រោមព្រះ អង្គ៖) ទ្រង់យាងចូលទៅរកលំនៅរបស់វេស្សន្តរព្រាហ្មណ៍ លុះចូល ទៅដល់ហើយ ក៏គង់លើកសំពះដែលគេរៀបចំថ្វាយ ។ គ្រានោះ វេស្ស-ព្រាហ្មណ៍ ក៏ចូលមកតាមព្រះអង្គ លុះមកដល់ទីគាល់ហើយ ក៏ក្រាប ថ្វាយបង្គំព្រះអង្គដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលបើ វេស្សន្តរព្រាហ្មណ៍អង្គុយស្រួលបួលហើយ ក៏ព្រះដ៏មានព្រះភាគ មានព្រះ បន្ទូលថា ព្រាហ្មណ៍ អ្នកឯងចាំទុកនូវមន្តនេះទៅជាវេស្សន្តរ (ស្នេហ៍) របស់អ្នកហើយ ដើម្បីកុំឲ្យអ្នកទាំងពួងទៅកាន់ដំណាក់ ។ វេស្ស-ន្តរព្រាហ្មណ៍ក៏ក្រាបទូលតបថា បពិត្រព្រះគោតមដ៏ចំរើន បើហើយ ខ្ញុំព្រះអង្គចាំទុកនូវមន្តដែលព្រះអង្គប្រទានឲ្យហើយ តែជាទេសនាដែល ខ្ញុំព្រះអង្គបានស្ដាប់នោះ ខ្ញុំព្រះអង្គមិនទាន់ចាំបានទាំងអស់ទេ ឯ ទេសនាទាំងនោះមិនមែនជាអាថ៌ ខ្ញុំព្រះអង្គមិនចាំទាំងអស់មិនបានថ្វាយ នោះទេ (ចេះតែនៅមិនទាន់ចាំបានថ្វាយ) ព្រោះជាកិច្ចត្រូវអ្នកត្រូវ ធ្វើផ្ទះសម្បែង ហើយមានកិច្ចរវល់ច្រើន មានការងារច្រើន ចំណែក ខាងព្រះអង្គវិញ ទ្រង់នឹងបានទេសនាមកពីណា សូមព្រះ គោតមដ៏ចំរើន ព្រមនាំព្រះភិក្ខុសង្ឃទទួលបច្ច័យរបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃ ស្អែកនេះ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។

អថខោ ភគវា តំ ព្រាហ្មណំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ សោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ សោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេត្វា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ តិចីវរេន អច្ឆាទេសិ



លំដាប់នោះ ព្រះដ៏មានព្រះភាគក៏ត្រាស់សំដែងធម្មីកថាឲ្យលោកណាត់ឲ្យវេរញ្ជព្រាហ្មណ៍យល់ច្បាស់ផង ក្នុងបច្ចុប្បន្ននិងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយខ្មាតអស្ចារ្យធ្វើការកុសល រួចទ្រង់ក្រោកចាកអាសនៈ ហើយយាងត្រឡប់មកវិញ ។ លុះវេលាព្រឹកឡើង វេរញ្ជព្រាហ្មណ៍ បង្គាប់ជនទាំងឡាយឲ្យតាក់តែងខាទនីយភោជនីយាហារ (បង្អែមនិងចំអាប) ដ៏ឆ្ងាញ់ពិសាក្នុងលំនៅរបស់ខ្លួនស្រេចហើយ ទើបចាត់បំរើឲ្យទៅក្រាបទូលព្រះដ៏មានព្រះភាគតាមកំណត់ពេលថា បពិត្រព្រះគោតមដ៏ចំរើន កាលនេះជាកាលគួរហើយ ចង្ហាន់ក៏បានរៀបចំស្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ស្បង់ចីពរព្រមទាំងបាត្រហើយ យាងចូលទៅកាន់លំនៅនៃវេរញ្ជព្រាហ្មណ៍ ជាមួយនឹងព្រះភិក្ខុសង្ឃក្នុងវេលាព្រឹកនោះ លុះដល់ហើយទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ ។ វេលានោះ វេរញ្ជព្រាហ្មណ៍ ចាត់អង្គាសថ្វាយនូវខាទនីយភោជនីយាហារ (បង្អែមនិងចំអាប) ដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ក្រៃដល់លោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏ថ្វាយចីវរ ៣ ត្រៃ

ឯកមេកញ្ច ភិក្ខុំ ឯកមេកេន ទុស្សយុគេន អច្ឆាទេសិ ។ អថខោ ភគវា វេរញ្ជំ ព្រាហ្មណំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ភគវា វេរញ្ជាយំ យថាភិរន្តំ វិហរិត្វា អនុបុព្វេន សោរេយ្យំ សង្កស្សំ កណ្ណកុជ្ជំ យេន បយាគបតិដ្ឋានំ តេនុបសង្កមិ ឧបសង្កមិត្វា បយាគបតិដ្ឋានេ គង្គំ នទឹ ឧត្តរិត្វា យេន ពារាណសី តទវសរិ ។ អថខោ ភគវា ពារាណសិយំ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

វេរញ្ជភាណវារំ និដ្ឋិតំ ។





ហើយប្រគេនសម្ពត់ព្រះភិក្ខុសង្ឃ ១ គូ ១ រាល់អង្គ ។ លំដាប់នោះ ព្រះភគវាទ្រង់ត្រាស់សំដែងធម្មីកថា ពន្យល់ឲ្យវេរញ្ជព្រាហ្មណ៍យល់ប្រយោជន៍ ក្នុងបច្ចុប្បន្នជាតិ និងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយក្នុងសម្បត្តិអំពីកុសល រួចព្រះអង្គក្រោកចាកអាសនៈ ហើយទ្រង់យាងត្រឡប់មកវិញ ។ លុះព្រះអង្គគង់នៅជិតស្រុកវេរញ្ជា តាមគួរដល់អធ្យាស្រ័យហើយ ទ្រង់ក៏យាងចេញទៅកាន់ស្រុកសោរេយ្យ រួចទៅនគរសង្កស្ស ហើយហួសទៅនគរកណ្ណកុជ្ជៈ ( កណោជនៅ ) ទ្រង់យាងសំដៅទៅស្រុកបយាគបតិដ្ឋាន លុះទៅដល់ហើយទ្រង់ឆ្លងទន្លេគង្គា ក្នុងស្រុកបយាគបតិដ្ឋាន ហើយយាងទៅដល់នគរពារាណសី ។ គ្រានោះ ព្រះអង្គក៏សំណាក់ក្នុងក្រុងពារាណសី ហើយទ្រង់ចៀសទៅកាន់ចារិកក្នុងក្រុងវេសាលី កាលទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលី ។ បានឮថា ព្រះដ៏មានព្រះភាគព្រះអង្គនៅគង់សម្រេចឥរិយាបថ ក្នុងកូដាគារសាលាក្នុងព្រៃមហាវន ( ព្រៃធំ ) ជិតក្រុងវេសាលីនោះ ។

វេរញ្ជភាណវារៈ អំពីនិមន្តវេរញ្ជព្រាហ្មណ៍ ចប់ ។

សរ់ែជធម៌អំពីមហាវិការក្នុងលោកនេះ

# បារាជិកកណ្ឌំ បឋមសិក្ខាបទំ

(១០) តេន ខោ បន សមយេន វេសាលិយា អវិទូរេ កលន្ទគាមោ(១) ហោតិ ។ តត្ថ សុទិន្នោ នាម កលន្ទបុត្តោ(២) សេដ្ឋិបុត្តោ ហោតិ ។ អថ ខោ សុទិន្នោ កលន្ទបុត្តោ សម្ពហុលេហិ សហាយកេហិ សទ្ធឹ វេសាលឹ អគមាសិ កេនចិទេវ ករណីយេន ។ តេន ខោ បន សមយេន ភគវា មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោ ហោតិ ។ អទ្ទសា ខោ សុទិន្នោ កលន្ទបុត្តោ ភគវន្តំ មហតិយា បរិសាយ បរិវុតំ ធម្មំ ទេសេន្តំ និសិន្នំ ។ ទិស្វានស្ស ឯតទហោសិ យន្នូនាហម្បិ ធម្មំ សុណេយ្យន្តិ ។ អថ ខោ សុទិន្នោ កលន្ទបុត្តោ យេន សា បរិសា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស ខោ សុទិន្នស្ស កលន្ទបុត្តស្ស ឯតទហោសិ យថា យថា ខោ អហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ

១ ម. កលន្ទកគាមោ ឥតិ ។ ២ ម. កលន្ទកោ ។ ៣ ម. កលន្ទកបុត្តោ ។

# បារាជិកកណ្ឌ សិក្ខាបទទី ១

(១០) គ្រានោះឯង មានស្រុកមួយឈ្មោះកលន្ទគ្រាមនៅមិនឆ្ងាយអំពីក្រុងវេសាលី ។ ក្នុងស្រុកនោះ មានកូនសេដ្ឋីម្នាក់ឈ្មោះសុទិន្នកូលបុត្រជាបុត្ររបស់កលន្ទសេដ្ឋី ។ គ្រានោះ សុទិន្នកលន្ទបុត្រព្រមមួយនឹងសំឡាញ់ច្រើននាក់ នាំគ្នាទៅឯក្រុងវេសាលី ដោយមានកិច្ចការអ្វីមួយ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់មានពួកបរិសទ្យច្រើនចោមរោមព្រះអង្គ ទ្រង់កំពុងគង់សំដែងធម៌ ។ សុទិន្នកលន្ទបុត្រ ក៏បានឃើញព្រះអង្គមានពួកបរិសទ្យច្រើនចោមរោមព្រះអង្គ កំពុងគង់សំដែងធម៌ ។ លុះឃើញហើយ សុទិន្នកូលបុត្រនោះក៏មានសេចក្តីត្រិះរិះ អាត្មាអញគួរតែស្តាប់ធម៌ខ្លះ ។ គ្រានោះ សុទិន្នកលន្ទបុត្រក៏ចូលទៅកាន់ទីដែលបរិសទ្យអង្គុយនោះ លុះចូលទៅហើយក៏អង្គុយនៅក្នុងទីមួយដ៏សមគួរ ។ កាលដែលសុទិន្នកុមារកលន្ទបុត្រដែលអង្គុយនៅក្នុងទីមួយដ៏សមគួរហើយ ក៏មានសេចក្តីត្រិះរិះថា ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយដំណើរយ៉ាងណាៗ អាត្មាអញបានស្តាប់យល់តាមដំណើរនោះៗហើយ ប៉ុន្តែបើអាត្មានៅជាគ្រហស្ថគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង

សព្វុប្បលិចំ ព្រហ្មចរិយំ ចរំ យទ្ធកាមំ តេសំ-

ឋសុំ ទិដ្ឋមត្តា តាសាយកាមំ ខ្លាងំ អច្ឆិន្នមូលា អតា-

វត្ថុ អនភាវំ បត្តាដេយ្យន្តិ ។ អយំ ខោ សា បរិសា

ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា

សមុត្តេជិតា សម្បហំសិតា ឆន្ទាយ សា ភគវន្តំ

អភិក្កមេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ

សុទិន្នោ កលន្ទបុត្តោ អចិរវុដ្ឋិតាយ បរិសាយ យេន

ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុទិន្នោ

កលន្ទបុត្តោ ភគវន្តំ ឯតទវោច យថា យថាហំ ភន្តេ

ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ

អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិ-

ខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ ភន្តេ កេសមស្សុំ

ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា





ដូចជាសង្ខដែលគេខាត់ហើយនោះឯង បើកុលបុត្រណា ការសក់នឹងពុកមាត់

ក្នុងកន្លងទៅ ស្លៀកដណ្ដប់សំពត់ដែលជ្រលក់ទឹកអម្ចត់ ហើយចេញចាកផ្ទះទៅបួស

ប្រាសចាកផ្ទះ មិនមែនងាយប្រព្រឹត្តទេ។ ដោយហេតុនោះ ខ្ញុំព្រះអង្គ (គោរព

ប្រព្រឹត្តព្រហ្មចរិយធម៌តក់) ។ ព្រោះខាង ពួកបរិសទ្យនោះ បានស្ដាប់ធម្ម-

កថាដែលព្រះមានព្រះភាគ ទ្រង់សំដែងបញ្ជាក់ឲ្យយល់ឲ្យជឿជាក់ក្នុងការនឹម

ឲ្យអាចកាន់យកហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះអង្គ

រួចធ្វើប្រទក្សិណ ហើយក៏ចេញទៅ ។ ឯសុទិន្នកលន្ទបុត្រ កាលបើ

ពួកបរិសទ្យក្រោកចេញទៅហើយភ្លាម ក៏ចូលទៅគាល់ព្រះដ៏មានព្រះ

ភាគ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

សុទិន្នកលន្ទបុត្រ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូល

ព្រះអង្គថា សូមទ្រង់ព្រះមេត្តាប្រោស ធម៌ដែលព្រះអង្គសំដែងហើយ

ដោយហេតុណាៗ ខ្ញុំព្រះអង្គបានយល់តាមហេតុនោះៗហើយ

ហើយ ប៉ុន្តែម៉្យាងព្រះអង្គនៅគ្រប់គ្រងផ្ទះ (ឃរាវាស) ក៏មិន

ងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង

ដូចជាសង្ខដែលគេខាត់ហើយនោះឯង សូមទានខ្ញុំព្រះអង្គចង់កោរសក់នឹង

ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់ដែលជ្រលក់ហើយចេញចាកផ្ទះ

អនគារិយំ បព្វជិតុំ បព្វាជេតុ មំ ភគវាតិ ។ អនុញ្ញាតោសិ បន ត្វំ សុទិន្ន មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ន ខោ អហំ ភន្តេ អនុញ្ញាតោ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ន ខោ សុទិន្ន តថាគតា អននុញ្ញាតំ មាតាបិតូហិ បុត្តំ បព្វាជេន្តីតិ ។ សោហំ ភន្តេ តថា ករិស្សាមិ យថា មំ មាតាបិតរោ អនុជានិស្សន្តិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ(១) ។

(១១) អថខោ សុទិន្នោ កលន្ទបុត្តោ វេសាលិយំ តំ ករណីយំ តីរេត្វា យេន កលន្ទគាមោ យេន មាតាបិតរោ តេនុបសង្កមិ ឧបសង្កមិត្វា មាតាបិតរោ ឯតទវោច អម្ម តាត យថា យថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ

១ ឥតោ បរំ ក្វចិ អថខោ សុទិន្នោ កលន្ទបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមីតិ ទិស្សតិ ។



មកបួសប្រែសបក្ខុក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ (នោះណាស់) សូមព្រះដ៏មានព្រះភាគទ្រង់បំបួសខ្ញុំព្រះអង្គផង ។ ព្រះសាស្តាទ្រង់ត្រាស់សួរថា ម្នាលសុទិន្ន ចុះអ្នកឯងមានមាតាបិតាបានយល់ព្រមឲ្យចេញចាកផ្ទះមកបួសប្រែសបក្ខុក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការផ្ទះហើយឬ ។ សុទិន្នក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ មាតាបិតាមិនទាន់បានយល់ព្រមឲ្យចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនានៅឡើយទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសុទិន្ន ព្រះតថាគតទាំងឡាយ មិនដែលបំបួសកូនដែលមាតាបិតា មិនទាន់អនុញ្ញាតនោះទេ ។ សុទិន្នក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងខំធ្វើឲ្យមាតាបិតា ព្រមអនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនាឲ្យបាន ។

(១១) លំដាប់នោះ សុទិន្នកលន្ទបុត្រធ្វើនូវសម្រេចកិច្ចការដែលខ្លួនត្រូវធ្វើក្នុងក្រុងវេសាលីនោះស្រេចហើយ ក៏វិលត្រឡប់មកស្រុកកលន្ទវិញ ចូលទៅរកមាតាបិតាហើយនិយាយនឹងមាតាបិតាថា បពិត្រអ្នកម្តាយអ្នកឪពុក ខ្ញុំបានដឹងច្បាស់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងដោយដំណើរយ៉ាងណា ៗ ក៏យល់តាមដំណើរនោះៗហើយ ខ្ញុំបានគិតថា បើខ្ញុំនៅជាគ្រហស្ថគ្រប់គ្រងផ្ទះនោះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌

ឥច្ឆាមហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ អនុជានាថ មំ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ឯវំ វុត្តេ សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ ត្វំ ខោសិ តាត សុទិន្ន អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ មរណេនបិ មយំ តេ អកាមកា វិនា ភវិស្សាម កឹ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ទុតិយម្បិ ខោ សុទិន្នោ កលន្ទបុត្តោ មាតាបិតរោ ឯតទវោច អម្ម តាត យថា យថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា



ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ ខ្ញុំបាទចង់កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់ដែលជ្រលក់តម្លក់ ហើយចេញចាកផ្ទះ ទៅបួសប្រតិបត្តិក្នុងផ្នួសដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ (នោះណាស់) សូមអ្នកម្តាយអ្នកឪពុកអនុញ្ញាតឲ្យខ្ញុំបាទចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនាឲ្យបាន ។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ កាលបើបានឮកូនពោលដូច្នេះហើយ ក៏និយាយតបថា ម្នាលសុទិន្នកូន បាឯងជាបុត្រឯករបស់យើង ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់ចិញ្ចឹមទៅក្នុងសេចក្តីសុខ មានអ្នកទំនុកបំរុងឲ្យបានសេចក្តីសុខ នែសុទិន្នកូន បាឯងមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះឡើយ ទោះបើបាឯងស្លាប់ក្តី យើងក៏មិនចង់ព្រាត់ប្រាសចាកបាឯងទេ យើងនឹងអនុញ្ញាតឲ្យកំពុងរស់នៅឲ្យចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន ។ ទើបសុទិន្នកលន្ទបុត្រនិយាយពាក្យនេះនឹងមាតាបិតាជាគំរប់ពីរដងថា បពិត្រមាតាបិតា ធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយដំណើរយ៉ាងណា ៗ ខ្ញុំបាទយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ (យ៉ាងនេះ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ ខ្ញុំបាទចង់កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់

អគារស្មា អនគារិយំ បព្ពជិតុំ អនុជានាថ មំ អគារស្មា អនគារិយំ បព្ពជ្ជាយាតិ ។ ទុតិយម្បិ ខោ សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ សុទិន្នំ កលន្ទបុត្តំ ឯតទ-វោចុំ ត្វំ ខោសិ តាត សុទិន្ន អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ។ ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ មរណេនបិ មយំ តេ អកាមកា វិនា ភវិស្សាម កិំ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្ពជ្ជាយាតិ ។ តតិយម្បិ ខោ សុទិន្នោ កលន្ទបុត្តោ មាតាបិតរោ ឯតទវោច អម្ម តាត យថា យថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្ពជិតុំ អនុជានាថ មំ អគារស្មា អនគារិយំ បព្ពជ្ជាយាតិ ។ តតិយម្បិ ខោ សុទិន្នស្ស កលន្ទ-បុត្តស្ស មាតាបិតរោ សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ





ព្រលែងអាត្មា ហើយចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនា សូមមាតា-បិតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះ ទៅបួសក្នុងព្រះពុទ្ធសាសនាចុះ ។ ទី ពីរមាតាបិតារបស់សុទិន្នកលន្ទបុត្រ ទើបនិយាយនឹងសុទិន្នកលន្ទបុត្រថា ពីរបីដងហើយ នែសុទិន្នកូន ឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ( ប្រាណី ) តាំងពីរៀងមកក្នុងសេចក្ដីសុខ មានទ្រព្យ ឡើងបានសេចក្ដីសុខ នែតាសុទិន្ន ឯងមិនធ្លាប់ស្គាល់សេចក្ដីទុក្ខព្រួយបន្តិចសោះ ទោះបើស្លាប់ទៅឯងក្ដី យើងមិនចង់ព្រាត់ព្រាសពីឯងទេ បើឯងនឹងអនុញ្ញាតឲ្យឯងរស់នៅឲ្យចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនា ដូចម្ដេចបាន ។ សុទិន្នកលន្ទបុត្រ បាននិយាយពាក្យនេះនឹងមាតាបិតាជាគំរប់បីដងថា បពិត្រមាតាបិតា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអាការណាៗ ដូច្នោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រ-ព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលបុគ្គលខាត់ហើយ មិនងាយទេ ខ្ញុំប្រាថ្នានឹងកោរសក់និងពុកចង្កាហើយស្លៀកដណ្ដប់សំពត់កាសាវៈ ហើយចេញចាកផ្ទះទៅបួសជាបុគ្គលមិនត្រូវការដោយផ្ទះ ហេតុនេះសូមមាតាបិតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួស ជាបុគ្គលមិនត្រូវការដោយផ្ទះវិញចុះ ។ មាតាបិតារបស់សុ-ទិន្នកលន្ទបុត្រ បាននិយាយពាក្យនេះនឹងសុទិន្នកលន្ទបុត្រជាគំរប់បីដងថា

ត្វំ ខោសិ តាត សុទិន្ន អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ មរណេនបិ មយំ តេ អកាមកា វិនា ភវិស្សាម កិំ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ អថខោ សុទិន្នោ កលន្ទបុត្តោ ន មំ មាតាបិតរោ អនុជានន្តិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ តត្ថេវ អនន្តរហិតាយ ភូមិយា និបជ្ជិ ឥធេវ មេ មរណំ ភវិស្សតិ បព្វជ្ជា វាតិ[1] ។ អថខោ សុទិន្នោ កលន្ទបុត្តោ ឯកម្បិ ភត្តំ ន ភុញ្ជិ ទ្វេបិ ភត្តានិ ន ភុញ្ជិ តីណិបិ ភត្តានិ ន ភុញ្ជិ ចត្តារិបិ ភត្តានិ ន ភុញ្ជិ បញ្ចបិ ភត្តានិ ន ភុញ្ជិ ឆបិ ភត្តានិ ន ភុញ្ជិ សត្តបិ ភត្តានិ ន ភុញ្ជិ ។

(១៦) អថខោ សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ ត្វំ ខោសិ តាត សុទិន្ន អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ មរណេនបិ មយំ តេ អកាមកា វិនា ភវិស្សាម

១ បព្វជ្ជាយាតិបិ បាឋោ ។



នែសុទិន្នកូន ឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់បានតែនូវសេចក្តីសុខ មានអ្នកថែទាំឲ្យបានសេចក្តីសុខ នែបា សុទិន្ន បាមិនស្គាល់សេចក្តីទុក្ខបន្តិចសោះ ទោះបើស្លាប់ទៅក្តី យើងក៏មិនប្រាថ្នាឲ្យព្រាត់ប្រាសចាកបា យើងនឹងអនុញ្ញាតបា ដែលកំពុងរស់នៅឲ្យចេញចាកផ្ទះ ហើយបួសក្នុងសាសនាដូចម្តេចបាន ។ គ្រានោះឯង សុទិន្នកលន្ទបុត្រគិតថា មាតាបិតាមិនអនុញ្ញាតអញឲ្យចេញចាកផ្ទះបួសក្នុងសាសនា ដូច្នេះហើយ ក៏ផ្តួលដេកនៅលើផែនដី ប្រាសចាកគ្រឿងក្រាលក្នុងទីនោះឯងដោយគិតថា អញនឹងស្លាប់ក្នុងទីនេះ ឬបួសក្នុងទីនេះជាប្រាកដ ។ គ្រានោះ សុទិន្នកលន្ទបុត្រ មិនបានបរិភោគបាយអស់មួយពេល ២ពេលក៏បាន ៣ពេលក៏បាន ៤ពេលក៏បាន ៥ពេលក៏បាន ៦ពេលក៏បាន ៧ពេលក៏បាន ។

(១៦) លំដាប់នោះ មាតាបិតារបស់សុទិន្នកលន្ទបុត្រនិយាយនឹងសុទិន្នកលន្ទបុត្រថា ម្នាលសុទិន្នកូន ឯងជាកូនប្រុសតែមួយហើយជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់សុខធ្លាប់សប្បាយដោយមានស្រីពីលៀងថែរក្សា សុទិន្នកូន ឯងមិនធ្លាប់ស្គាល់សេចក្តីទុក្ខតិចតួចសោះទេ ទោះបើបាស្លាប់ទៅក្តី យើងក៏មិនចង់ឲ្យព្រាត់ប្រាសចាកបាឡើយ

កឹ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយ ឧដ្ឋេហិ តាត សុទិន្ន ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មយំ អនុជានាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ឯវំ វុត្តេ សុទិន្នោ កលន្ទបុត្តោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ ត្វំ ខោសិ តាត សុទិន្ន អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ មរណេនបិ មយំ តេ អកាមកា វិនា ភវិស្សាម កឹ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយ ឧដ្ឋេហិ តាត សុទិន្ន ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មយំ អនុជានាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ តតិយម្បិ ខោ សុទិន្នោ កលន្ទបុត្តោ តុណ្ហី អហោសិ ។



យើងទើបនឹងអនុញ្ញាតអ្នកកំពុងរស់នៅ ឲ្យចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្ដេចបាន សុទិន្នកូន អ្នកចូរក្រោកឡើងបរិភោគផងផឹកផង ខ្លួនឲ្យគេបម្រើទៅ កាលបើអ្នកបរិភោគផងផឹកផង ខ្លួនឲ្យគេបម្រើហើយ ចូរបរិភោគកាមនិងធ្វើបុណ្យចុះ យើងមិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ ។ កាលបើមាតាបិតាពោលយ៉ាងនេះហើយ សុទិន្នកលន្ទបុត្រ ក៏ស្ងៀមនៅ ។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ និយាយនឹងសុទិន្នកលន្ទបុត្រអស់វារៈ ៣ ដង ថា សុទិន្នកូន អ្នកឯងជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តយើង ធ្លាប់ចំរើនដោយសេចក្ដីសុខ បានទទួលថ្នាក់ថ្នមថែរក្សាសប្បាយ សុទិន្នកូន អ្នកឯងមិនដែលស្គាល់សេចក្ដីទុក្ខតិចតួចសោះ ទោះបីអ្នកឯងស្លាប់ទៅក្ដី យើងមិនចង់ឲ្យព្រាត់ប្រាសចាកអ្នកឯងឡើយ យើងទើបនឹងអនុញ្ញាតដល់អ្នកកំពុងរស់នៅឲ្យចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្ដេចបាន សុទិន្នកូន អ្នកចូរក្រោកឡើងបរិភោគផងផឹកផង ខ្លួនឲ្យគេបម្រើទៅ កាលបរិភោគផងផឹកផង ខ្លួនឲ្យគេបម្រើហើយ ចូរបរិភោគកាមនិងធ្វើបុណ្យតាមប្រាថ្នាចុះ យើងមិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនាទេ ។ សុទិន្នកលន្ទបុត្រក៏ស្ងៀមនៅទៀតជាគំរប់បីដង ។

(១៣) អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា យេន សុទិន្នោ កលន្ទបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ ត្វំ ខោសិ សម្ម សុទិន្ន មាតាបិតូនំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ សម្ម សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ មរណេនបិ តេ មាតាបិតរោ អកាមកា វិនា ភវិស្សន្តិ កឹ បន តំ ជីវន្តំ អនុជានិស្សន្តិ អគារស្មា អនគារិយំ បព្ពជ្ជាយ ឧដ្ឋេហិ សម្ម សុទិន្ន ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មាតាបិតរោ អនុជានន្តិ អគារស្មា អនគារិយំ បព្ពជ្ជាយាតិ ។ ឯវំ វុត្តេ សុទិន្នោ កលន្ទបុត្តោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ





(១៣) លំដាប់នោះ ពួកសំឡាញ់សុទិន្នកលន្ទបុត្រ បាននាំគ្នាចូលទៅនិយាយអង្វរសុទិន្នកលន្ទបុត្រថា នែសុទិន្នសំឡាញ់ អ្នកឯងជាកូនប្រុសតែមួយហើយជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា ធ្លាប់បានសេចក្តីសុខ មានគេទំនុកបំរុងថែរក្សាសប្បាយ នែសុទិន្នសំឡាញ់ អ្នកឯងមិនធ្លាប់ស្គាល់សេចក្តីលំបាកតិចតួចសោះឡើយ ពោះបើអ្នកស្លាប់ទៅក្តី មាតាបិតារបស់អ្នក ក៏មិនចង់ឲ្យព្រាត់ប្រាសចាកអ្នកឡើយ មាតាបិតាទាំងឡាយរបស់អ្នកនឹងអនុញ្ញាតអ្នកដែលកំពុងរស់នៅឲ្យចេញចាកផ្ទះ ទៅបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន នែសុទិន្នសំឡាញ់ ចូរអ្នកក្រោកឡើង បរិភោគបាយ ផឹកទឹក ឲ្យរីករាយ កាលបើអ្នកបរិភោគបាយ ផឹកទឹក ឲ្យរីករាយហើយ នឹងបរិភោគកាមទាំងឡាយ ធ្វើបុណ្យ (ទៀតផង) រីករាយសប្បាយតាមសេចក្តីប្រាថ្នាចុះ មាតាបិតាទាំងឡាយរបស់អ្នក មិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ ។ កាលបើពួកសំឡាញ់របស់សុទិន្នពោលពាក្យយ៉ាងនេះហើយ សុទិន្នកលន្ទបុត្រ ក៏នៅស្ងៀម ។ ពួកសំឡាញ់របស់សុទិន្នកលន្ទបុត្រ បានពោលពាក្យនេះនឹងសុទិន្នកលន្ទបុត្រជាគំរប់ពីរដង ។ បេ ។

ទិ ខោសំ សម្ម សុទិន្ន ។ បេ ។ តតិយម្បិ ខោ សុទិន្នោ កលន្ទបុត្តោ តុណ្ហី អហោសិ ។ អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា យេន សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ ឯតទវោចុំ អម្ម តាត ឯសោ សុទិន្នោ អនន្តរហិតាយ ភូមិយា និបន្នោ ឥធេវ មេ មរណំ ភវិស្សតិ បព្វជ្ជា វាតិ សចេ តុម្ហេ សុទិន្នំ នានុជានិស្សថ អគារស្មា អនគារិយំ បព្វជ្ជំ តត្ថេវ មរណំ អាគមិស្សតិ សចេ បន តុម្ហេ សុទិន្នំ អនុជានិស្សថ អគារស្មា អនគារិយំ បព្វជ្ជំ បព្វជិតម្បិ នំ ទក្ខិស្សថ សចេ សុទិន្នោ នាភិរមិស្សតិ អគារស្មា អនគារិយំ បព្វជ្ជាយ កា តស្ស អញ្ញា គតិ ភវិស្សតិ ឥធេវ បច្ចាគមិស្សតិ អនុជានាថ សុទិន្នស្ស អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អនុជានាម តាតា សុទិន្នស្ស អគារស្មា អនគារិយំ បព្វជ្ជន្តិ ។





បីដងថា ម្នាលសុទិន្នសំឡាញ់ អ្នកឯង ។ បេ ។ សុទិន្នកលន្ទបុត្រក៏នៅតែស្ងៀមស្ងាត់អស់វារៈជាគំរប់បីដង ។ គ្រានោះឯង មាតាបិតាទាំងឡាយរបស់សុទិន្នកលន្ទបុត្រនៅក្នុងទីណា សំឡាញ់ទាំងឡាយរបស់សុទិន្នកលន្ទបុត្រ ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏ពោលនូវពាក្យនេះចំពោះមាតាបិតាទាំងឡាយនៃសុទិន្នកលន្ទបុត្រថា បពិត្រលោកម្តាយលោកឪពុក សុទិន្ននេះ ដេកនៅលើផែនដី ឥតក្រាលនឹងព្រំលម្អិតនានាសោះ ។ ហើយគិតថា សេចក្តីស្លាប់ក្តី បព្វជ្ជាក្តី នឹងមានដល់អាត្មាអញក្នុងទីនេះឯង បើលោកទាំងឡាយមិនព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនាទេ សុទិន្ននឹងដល់នូវសេចក្តីស្លាប់ ក្នុងទីនោះមិនខានឡើយ ប្រសិនណាបើលោកទាំងឡាយព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនា ក៏គង់តែនឹងបានឃើញបុត្រសុទិន្នដែលទៅជាអ្នកបួសក៏បាន បើសុទិន្នមិនត្រេកអរ ក្នុងបព្វជ្ជាហើយ គតិរបស់សុទិន្ននោះប្រែក្លាយទៅក្នុងទីដទៃដូចម្តេចបាន មុខជានឹងត្រឡប់មកក្នុងទីនេះវិញមិនខាន ឡើយ សូមលោកទាំងឡាយ អនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនា ។ មាតាបិតាទាំងឡាយនៃសុទិន្នក៏ពោលថា ម្នាលអ្នកទាំងឡាយ យើងទាំងឡាយព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនាចុះ ។

[១៦] អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា យេន សុទិន្នោ កលន្ទបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សុទិន្នំ កលន្ទបុត្តំ ឯតទវោចុំ ឧដ្ឋេហិ សម្ម សុទិន្ន អនុញ្ញាតោសិ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ អថខោ សុទិន្នោ កលន្ទបុត្តោ អនុញ្ញាតោម្ហិ កិរ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ហដ្ឋោ ឧទគ្គោ បាណិនា គត្តានិ បរិបុញ្ឆន្តោ វុដ្ឋាសិ ។ អថខោ សុទិន្នោ កលន្ទបុត្តោ កតិបាហំ ពលំ គាហេត្វា(១) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុទិន្នោ កលន្ទបុត្តោ ភគវន្តំ ឯតទវោច អនុញ្ញាតោម្ហិ(២) អហំ ភន្តេ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយ បព្វាជេតុ មំ ភគវាតិ ។ អលត្ថ ខោ សុទិន្នោ កលន្ទបុត្តោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ

១ [illegible] គាហេត្វា ពាហេ [illegible] ។ ២ ម. យុ. អនុញ្ញាតោ ។



(១៦) គ្រានោះឯង សុទិន្នកលន្ទបុត្រ នៅក្នុងទីណា សំឡាញ់ទាំងឡាយនៃសុទិន្នកលន្ទបុត្រ ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ បាននិយាយនឹងសុទិន្នកលន្ទបុត្រថា នែសុទិន្នសំឡាញ់ ចូរអ្នកក្រោកឡើង អ្នកឯងមាតាបិតាព្រមព្រៀងអនុញ្ញាតឲ្យចេញចាកផ្ទះ បួសក្នុងព្រះពុទ្ធសាសនាហើយ ។ គ្រានោះ សុទិន្នកលន្ទបុត្រ បានដឹងថា មាតាបិតាព្រមព្រៀងអនុញ្ញាតឲ្យចេញចាកផ្ទះ ដើម្បីបួសក្នុងព្រះពុទ្ធសាសនា (ផ្នួស) ហើយ ក៏មានចិត្តរីករាយ ដូចជាអណ្តែតឡើង ជូតសំអាតខ្លួនដោយដៃទាំងពីរ ហើយក្រោកឡើង ។ គ្រានោះ សុទិន្នកលន្ទបុត្រ សំរេកសំរាន្តបានពីរបីថ្ងៃ ព្រះមានព្រះភាគគង់នៅក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសុទិន្នកលន្ទបុត្រ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាបុគ្គល ដែលមាតាបិតាអនុញ្ញាតឲ្យចេញចាកផ្ទះ ហើយបួសក្នុងភេទជាបុគ្គលមិនមានប្រយោជន៍ដោយការនៅក្នុងផ្ទះហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់បំបួសខ្ញុំព្រះអង្គផង ។ សុទិន្នកលន្ទបុត្រ បាននូវបព្វជ្ជា នឹងឧបសម្បទា

ឧបសម្បទំ ។ អចិរូបសម្បន្នោ ច បនាយស្មា សុទិន្នោ ឯវរូបេ ធុតគុណេ សមាទាយ វត្តតិ អារញ្ញិកោ ហោតិ បិណ្ឌបាតិកោ បំសុកូលិកោ សបទានចារិកោ អញ្ញតរំ វជ្ជិគាមំ ឧបនិស្សាយ វិហរតិ ។

(១៨) តេន ខោ បន សមយេន វជ្ជី ទុព្ភិក្ខា ហោតិ ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ ។ អថខោ អាយស្មតោ សុទិន្នស្ស ឯតទហោសិ ឯតរហិ ខោ វជ្ជី ទុព្ភិក្ខា ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា





ក្នុងសំណាក់ព្រះដ៏មានព្រះភាគហើយ ។ សុទិន្នភិក្ខុដ៏មានអាយុបានឧបសម្បទាហើយមិនយូរប៉ុន្មាន ក៏ប្រព្រឹត្តសមាទានធុតង្គគុណ មានសភាពយ៉ាងនេះ គឺ ជាអ្នកនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ប្រើប្រាស់សំពត់បង្សុកូល និងត្រាច់ទៅ (បិណ្ឌបាត) តាមលំដាប់ផ្ទះ ហើយចូលទៅអាស្រ័យនៅក្នុងស្រុកវជ្ជីឯណានីមួយ ។

(១៨) សម័យនោះឯង ស្រុកវជ្ជីមានអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលត្រូវលំបាកស្លាប់ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិល្មមចិញ្ចឹមជីវិតស្រេចស្រ្តីគេបាន ក៏មិនងាយនឹងចិញ្ចឹមជីវិតដែរ ព្រោះតែមានស្លាកជាទីសំគាល់ទើបចិញ្ចឹមជីវិតបាន ជនទាំងអស់ក្នុងស្រុកនោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក ។ លំដាប់នោះឯង សុទិន្នភិក្ខុដ៏មានអាយុមានសេចក្តីត្រិះរិះដូច្នេះថា ក្នុងកាលឥឡូវនេះ ស្រុកវជ្ជីមានអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលត្រូវលំបាកស្លាប់ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិល្មមចិញ្ចឹមជីវិតស្រេចស្រ្តីគេបានក៏មិនងាយនឹងចិញ្ចឹមជីវិតដែរ ព្រោះតែមានស្លាកជាទីសំគាល់

ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ ពហូ ខោ
បន មេ វេសាលិយំ ញាតកា[១] អឌ្ឍា មហទ្ធនា
មហាភោគា បហូតជាតរូបរជតា បហូតវិត្តូបករណា
បហូតធនធញ្ញា យំនូនាហំ ញាតកេ[២] ឧប-
និស្សាយ វិហរេយ្យំ ញាតកាបិ[៣] មំ និស្សាយ ទានានិ
ទស្សន្តិ បុញ្ញានិ ករិស្សន្តិ ភិក្ខូ ច លាភំ លច្ឆន្តិ
អហញ្ច បិណ្ឌកេន ន កិលមិស្សាមីតិ ។ អថ ខោ
អាយស្មា សុទិន្នោ សេនាសនំ សំសាមេត្វា បត្ត-
ចីវរមាទាយ យេន វេសាលី តេន បក្កាមិ អនុបុព្វេន
ចារិកំ[៤] ចរមានោ[៥] យេន វេសាលី តទវសរិ ។
តត្រ សុទំ អាយស្មា សុទិន្នោ វេសាលិយំ វិហរតិ
មហាវនេ កូដាគារសាលាយំ ។ អស្សោសុំ ខោ
អាយស្មតោ សុទិន្នស្ស ញាតកា សុទិន្នោ កិរ
កលន្ទបុត្តោ វេសាលឹ អនុប្បត្តោតិ ។ តេ អាយស្មតោ
សុទិន្នស្ស សដ្ឋិមត្តេ ថាលិបាកេ ភត្តាភិហារំ អភិ-
ហរិំសុ ។ អថ ខោ អាយស្មា សុទិន្នោ តេ សដ្ឋិមត្តេ ថាលិ-
បាកេ ភិក្ខូនំ វិស្សជ្ជេត្វា បុព្វណ្ហសមយំ និវាសេត្វា

១-២-៣ ម. ឆ. ញាតិ ។ ៤-៥ ពីរបទនេះ បោះពុម្ពសៀម ឥតមាន ។



ចិញ្ចឹមជីវិតបាន ដោយការស្វែងរកនោះ ទំនងនឹងបរិភោគអ-
ាហារបានដោយគ្រប់គ្រាន់ ញាតិទាំងឡាយរបស់អាត្មាអញមានច្រើនក្នុង
ក្រុងវេសាលី ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មាន
មាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ច្រើន មានទ្រព្យនិងស្រូវច្រើន
បើដូច្នោះ គួរតែអាត្មាអញ គប្បីចូលទៅអាស្រ័យនូវញាតិទាំងឡាយ
ហើយនៅ ញាតិទាំងឡាយសោត អាស្រ័យនូវអាត្មាអញហើយ នឹង
ឲ្យទានធ្វើបុណ្យ ភិក្ខុទាំងឡាយនឹងបានលាភផង អាត្មាអញ
នឹងមិនលំបាកដោយបិណ្ឌបាតផង ។ ទើបសុទិន្នភិក្ខុមានអាយុរៀបចំ
សេនាសនៈ ហើយកាន់យកបាត្រនិងចីវរ ក្រុងវេសាលីនៅទិសណា
ក៏ចៀសចេញទៅកាន់ទិសនោះ កាលដែលស្ដេចទៅកាន់ចារិកដោយ
លំដាប់ ៗ ក្រុងវេសាលីនៅទិសណា ក៏ចូលទៅដល់ទីនោះ ។ មាន
ដំណឹងថា សុទិន្នភិក្ខុមានអាយុនៅក្នុងកូដាគារសាលាក្នុងព្រៃមហាវនទៀប
ក្រុងវេសាលីនោះ ។ ពួកញាតិសុទិន្នភិក្ខុមានអាយុបានឮថា សុទិន្ន-
ភិក្ខុជាកលន្ទបុត្រមកដល់ក្រុងវេសាលីហើយ ។ ពួកញាតិទាំង
នោះ ក៏នាំនូវភាជនប្រមាណហុកសិបសម្រាប់ទៅប្រគេនសុទិន្នភិក្ខុមាន
អាយុ ។ លំដាប់នោះឯង សុទិន្នភិក្ខុមានអាយុ ចែកចាយស្រាប់
ប្រមាណហុកសិបនោះ ដល់ភិក្ខុទាំងឡាយ ហើយស្លៀកស្បង់

បត្តចីវរមាទាយ កលន្ទគាមំ បិណ្ឌាយ បាវិសិ កលន្ទ-
គាមេ សបទានំ បិណ្ឌាយ ចរមានោ យេន សកបិតុ
និវេសនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន
អាយស្មតោ សុទិន្នស្ស ញាតិទាសី អាភិទោសិកំ
កុម្មាសំ ឆឌ្ឌេតុកាមា ហោតិ ។ អថខោ អាយស្មា
សុទិន្នោ តំ ញាតិទាសឹ ឯតទវោច សចេ តំ ភគិនិ
ឆឌ្ឌនីយធម្មំ ឥធ មេ បត្តេ អាកិរាតិ ។ អថខោ
អាយស្មតោ សុទិន្នស្ស ញាតិទាសី តំ អាភិទោសិកំ
កុម្មាសំ អាយស្មតោ សុទិន្នស្ស បត្តេ អាកិរន្តី ហត្ថា-
នញ្ច បាទានញ្ច សរស្ស ច និមិត្តំ អគ្គហេសិ ។ អថខោ
អាយស្មតោ សុទិន្នស្ស ញាតិទាសី យេនាយស្មតោ
សុទិន្នស្ស មាតា តេនុបសង្កមិ ឧបសង្កមិត្វា អាយ-
ស្មតោ សុទិន្នស្ស មាតរំ ឯតទវោច យគ្ឃយ្យេ
ជានេយ្យាសិ អយ្យបុត្តោ សុទិន្នោ អនុប្បត្តោតិ ។ សចេ
ជេ សច្ចំ ភណសិ អទាសឹ តំ ករោមីតិ ។ តេន ខោ
បន សមយេន អាយស្មា សុទិន្នោ តំ អាភិទោសិកំ
កុម្មាសំ អញ្ញតរំ កុដ្ដមូលំ និស្សាយ បរិភុញ្ជតិ ។
បិតាបិ ខោ អាយស្មតោ សុទិន្នស្ស កម្មន្តា អាគច្ឆន្តោ



ប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាព្រឹក ហើយចូលទៅកាន់កលន្ទគ្រាម
ដើម្បីបិណ្ឌបាត កាលដើរទៅដើម្បីបិណ្ឌបាតតាមលំដាប់ផ្ទះក្នុងកលន្ទគ្រាម
លំនៅនៃបិតារបស់ខ្លួនទៅត្រង់ណា ចូលទៅត្រង់ទីនោះ ។ ក្នុងសម័យ
នោះឯង ទាសីរបស់ញាតិនៃសុទិន្នភិក្ខុដ៏មានអាយុ មានប្រាថ្នាដើម្បី
បោះចោលនំកុម្មាសផ្អូម ។ គ្រានោះ សុទិន្នភិក្ខុដ៏មានអាយុ និយាយនឹងខ្ញុំ
ស្រីរបស់ញាតិនោះថា ម្នាលនាងទាសី បើនំនោះជារបស់បោះចោលហើយ
ចូរនាងចាក់ដាក់មកក្នុងបាត្រអាត្មានេះវិញ ។ លំដាប់នោះ ខ្ញុំស្រីនៃញាតិ
របស់សុទិន្នដ៏មានអាយុ កំពុងចាក់នំកុម្មាសផ្អូមនោះទៅក្នុងបាត្ររបស់សុទិន្ន
ហើយបានស្គាល់ចំណាំដៃជើងនិងសំឡេងរបស់សុទិន្ននោះច្បាស់ ។
គ្រានោះ មាតារបស់សុទិន្នដ៏មានអាយុនៅត្រង់ណា ខ្ញុំស្រីរបស់
ញាតិនៃសុទិន្នដ៏មានអាយុក៏ចូលទៅរកទីនោះ លុះចូលទៅដល់ហើយ
ក៏និយាយនឹងមាតារបស់សុទិន្នដ៏មានអាយុថា បពិត្រអ្នកម្ចាស់ សូមអ្នក
ជ្រាប សុទិន្នជាអយ្យបុត្រ និមន្តមកដល់ហើយ ។ មាតារបស់សុទិន្នឆ្លើយ
ថា នែនាង បើនាងនិយាយពាក្យពិតមែន អញនឹងឲ្យនាងរួចជាអ្នក
ជា ។ សម័យនោះឯង សុទិន្នភិក្ខុដ៏មានអាយុក៏ឆាន់នំកុម្មាសផ្អូមនោះផ្អែក
ជញ្ជាំងសាលា ១ ។ ចំណែកខាងបិតារបស់សុទិន្នមកពីការងារវិញ

អទ្ទស អាយស្មន្តំ សុទិន្នំ តំ អាភិទោសិកំ កុម្មាសំ អញ្ញតរំ កុឌ្ឌមូលំ និស្សាយ បរិភុញ្ជន្តំ ទិស្វាន យេនា- យស្មា សុទិន្នោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សុទិន្នំ ឯតទវោច អត្ថិ នាម តាត សុទិន្ន អាភិទោសិកំ កុម្មាសំ បរិភុញ្ជិស្សសិ ននុ(១) តាត សុទិន្ន សកំ គេហំ(២) គន្តព្វន្តិ ។ អគមិម្ហា ខោ តេ គហបតិ គេហំ តតោយំ(៣) អាភិទោសិកោ កុម្មាសោ មយា លទ្ធោតិ(៤) ។ អថខោ អាយស្មតោ សុទិន្នស្ស បិតា អាយស្មតោ សុទិន្នស្ស ពាហាយំ គហេត្វា អាយស្មន្តំ សុទិន្នំ ឯតទវោច ឯហិ តាត សុទិន្ន ឃរំ គមិស្សាមាតិ ។ អថខោ អាយស្មា សុទិន្នោ យេន សកបិតុ និវេសនំ តេនុបសង្កមិ ឧប- សង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ អាយស្ម- តោ សុទិន្នស្ស បិតា អាយស្មន្តំ សុទិន្នំ ឯតទវោច ភុញ្ជ តាត សុទិន្នាតិ ។ អលំ គហបតិ កតំ មេ អជ្ជ ភត្ត- កិច្ចន្តិ ។ អធិវាសេហិ តាត សុទិន្ន ស្វាតនាយ ភត្តន្តិ ។ អធិវាសេសិ ខោ អាយស្មា សុទិន្នោ តុណ្ហីភាវេន ។ អថខោ អាយស្មា សុទិន្នោ ឧដ្ឋាយាសនា បក្កាមិ ។

១ ឱ. ម. ននុ ត្វំ ។ ២ ឱ. ម. សកំ គេហំ ។ ៣ ឱ. តតោយំ ។ ៤ មហា លទ្ធោតិ
[illegible]



ក៏បានឃើញសុទិន្នកំពុងឆាន់នំកុម្មាសស្អុយនោះ ផ្អែកជញ្ជាំងណាមួយ លុះឃើញហើយ សុទិន្នគង់នៅក្នុងទីណា (បិតានោះ) ក៏ចូលទៅកាន់ទីនោះ លុះចូលទៅហើយក៏និយាយនឹងសុទិន្នដ៏មានអាយុថា នែសុទិន្នកូន មើល ជាអ្នកមានទ្រព្យសម្បត្តិច្រើន ហេតុអ្វីក៏លោកមកឆាន់នំកុម្មាសស្អុយវិញ សុទិន្នកូនគួរតែលោកទៅឯផ្ទះរបស់ខ្លួនវិញ ។ សុទិន្នភិក្ខុឆ្លើយថា បពិត្រគហបតី អាត្មាបានទៅឯផ្ទះរបស់អ្នកហើយ នំកុម្មាសស្អុយនេះ អាត្មាបានពីផ្ទះនោះមក ។ លំដាប់នោះ បិតាសុទិន្នភិក្ខុ ក៏ចាប់កាន់ដៃសុទិន្នភិក្ខុហើយ និយាយនឹងសុទិន្នថា សុទិន្នកូន លោកចូរមក យើងនឹងទៅផ្ទះ ។ លំដាប់នោះ លំនៅបិតារបស់ខ្លួននៅក្នុងទីណា សុទិន្នដ៏មានអាយុ ក៏ចូលទៅកាន់ទីនោះ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលប្រគេន ។ បិតាក៏និយាយនឹងសុទិន្នដ៏មានអាយុនោះថា សុទិន្នកូន សូមលោកឆាន់ចង្ហាន់ចុះ ។ សុទិន្នឆ្លើយថា កុំឡើយគហបតី ថ្ងៃនេះអាត្មាភាពឆាន់រួចហើយ ។ បិតាឆ្លើយថា សុទិន្នកូន សូមលោកនិមន្តទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។ សុទិន្នភិក្ខុ ក៏ទទួលនិមន្តដោយតុណ្ហីភាព ។ សុទិន្នភិក្ខុក៏ក្រោកចាកអាសនៈហើយនិមន្តទៅកាន់ទីលំនៅរបស់លោក ។

(៣៦) អថខោ អាយស្មតោ សុទិន្នស្ស មាតា តស្សា
រត្តិយា អច្ចយេន ហរិតេន គោមយេន បឋវិំ ឱបុញ្ញាបេត្វា
ទ្វេ បុញ្ជេ ការាបេសិ ឯកំ ហិរញ្ញស្ស ឯកំ សុវណ្ណស្ស
តាវ មហន្តា បុញ្ជា អហេសុំ ឱរតោ ឋិតោ បុរិសោ បារតោ
ឋិតំ បុរិសំ ន បស្សតិ បារតោ ឋិតោ បុរិសោ ឱរតោ ឋិតំ
បុរិសំ ន បស្សតិ តេ បុញ្ជេ កិលញ្ជេហិ បដិច្ឆាទេត្វា
មជ្ឈេ អាសនំ បញ្ញាបេត្វា តិរោករណីយំ បរិក្ខិ-
បាបេត្វា[១] អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកំ
អាមន្តេសិ តេនហិ វធុ យេន អលង្ការេន អលង្កតា
បុត្តស្ស សុទិន្នស្ស បិយា អហោសិ មនាបា
តេន អលង្ការេន អលង្ករោហីតិ ។ ឯវំ អយ្យេតិ
ខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា
អាយស្មតោ សុទិន្នស្ស មាតុយា បច្ចស្សោសិ ។
អថខោ អាយស្មា សុទិន្នោ បុព្វណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ យេន សកបិតុ និវេសនំ តេនុ-
បសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។
អថខោ អាយស្មតោ សុទិន្នស្ស បិតា យេនាយស្មា
សុទិន្នោ តេនុបសង្កមិ ឧបសង្កមិត្វា តេ បុញ្ជេ វិវរាបេត្វា

---

១ យោជយោន បរិក្ខិបិត្វា ឥតិ វិសុទ្ធិ ។



(៣៦) លុះដល់វេលាព្រឹកឡើង មាតាសុទិន្នកុមារ ប្រើមនុស្សឲ្យ
បង្គាប់ផែនដីដោយអាចម៍គោស្រស់ រួចឲ្យគរគំនរទ្រព្យពីរគំនរ គឺ
ប្រាក់ ១ គំនរ មាស ១ គំនរ ជាគំនរធំៗ បុរសឈរខាងអាយមើលទៅ
បុរសឈរខាងនាយមិនឃើញ បុរសឈរខាងនាយមើលមកបុរសឈរ
ខាងអាយក៏មិនឃើញ ហើយឲ្យបិទបាំងគំនរទាំងពីរនោះដោយកន្ទេល
ឲ្យក្រាលអាសនៈក្នុងកណ្ដាល រួចឲ្យបាំងរនាំងព័ទ្ធជុំវិញពីខាងក្រៅ
(គំនរនោះ) ហើយហៅស្រីជាគូពីដើមរបស់សុទិន្នដ៏មានអាយុមកបង្គាប់
ថា កូនស្រី បើដូច្នោះ គ្រឿងប្រដាប់ណាដែលឯងស្អិតស្អាងហើយ
ជាទីស្រឡាញ់គាប់ចិត្តរបស់កូនអញ ឯងស្អិតស្អាងនូវគ្រឿង
ប្រដាប់នោះចុះ ។ ស្រីជាគូពីដើមរបស់សុទិន្នដ៏មានអាយុ ក៏ទទួល
ពាក្យម្ដាយរបស់សុទិន្នដ៏មានអាយុថា បពិត្រម្ចាស់ ។ គ្រានោះ
សុទិន្នដ៏មានអាយុស្លៀកស្បង់យកបាត្រនិងចីវរក្នុងវេលាព្រឹក លំ-
នៅបិតារបស់ខ្លួននៅត្រង់ទីណា ចូលទៅត្រង់ទីនោះ លុះចូលទៅ
ដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកប្រុង ។ លំដាប់
នោះ បិតារបស់សុទិន្នដ៏មានអាយុ សុទិន្នដ៏មានអាយុនៅត្រង់ទីណា
ក៏ចូលទៅត្រង់ទីនោះ លុះចូលទៅដល់ហើយ បង្គាប់អ្នកបម្រើឲ្យបើក

អាយស្មន្តំ សុទិន្នំ ឯតទវោច ឥទន្តេ តាត សុទិន្ន មាតុមត្តិកំ ឥត្ថិកាយ ឥត្ថីធនំ អញ្ញំ បេត្តិកំ អញ្ញំ បិតាមហំ លព្ភា តាត សុទិន្ន ហីនាយាវត្តិត្វា ភោគា ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ ឯហិ ត្វំ តាត សុទិន្ន ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។ តាត ន ឧស្សហាមិ ន វិសហាមិ អភិរតោ អហំ ព្រហ្មចរិយំ ចរាមីតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អាយស្មតោ សុទិន្នស្ស បិតា អាយស្មន្តំ សុទិន្នំ ឯតទវោច ឥទន្តេ តាត សុទិន្ន មាតុមត្តិកំ ឥត្ថិកាយ ឥត្ថីធនំ អញ្ញំ បេត្តិកំ អញ្ញំ បិតាមហំ លព្ភា តាត សុទិន្ន ហីនាយាវត្តិត្វា ភោគា ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ ឯហិ ត្វំ តាត សុទិន្ន ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។ វទេយ្យាម ខោ តំ គហបតិ សចេ ត្វំ នាតិកឌ្ឍេយ្យាសីតិ ។ វទេហិ តាត សុទិន្នាតិ ។ តេនហិ ត្វំ គហបតិ



គំនរទ្រព្យទាំងនោះ ហើយប្រាប់សុទិន្នដ៏មានអាយុថា សុទិន្នកូន នេះជាទ្រព្យសម្បត្តិដើមខាងស្រីរបស់មាតាលោក នៅមានទ្រព្យសម្បត្តិដើមខាងប្រុសរបស់បិតានិងមរតករបស់ជីតាផ្សេងទៀត សុទិន្នកូន បើលោកបានសឹកចេញជាគ្រហស្ថមក នឹងបានប្រើប្រាស់សម្បត្តិផង ធ្វើបុណ្យទាំងឡាយផង សុទិន្នកូន ចូរលោកសឹកចេញជាគ្រហស្ថមក ហើយនឹងប្រើប្រាស់សម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង ។ សុទិន្នតបថា ញោម អាត្មាមិនអាចនឹងសឹកបានទេ ព្រោះអាត្មាពេញចិត្តត្រេកអរនឹងការប្រព្រឹត្តព្រហ្មចរិយធម៌ ។ បិតាសុទិន្នដ៏មានអាយុ និយាយនឹងសុទិន្នដ៏មានអាយុ ជាគំរប់ពីរដងផង ។ បេ ។ ជាគំរប់បីដងថា សុទិន្នកូន នេះជាទ្រព្យសម្បត្តិដើមខាងស្រីរបស់មាតាលោក នៅមានទ្រព្យសម្បត្តិដើមខាងប្រុសរបស់បិតានិងមរតករបស់ជីតាផ្សេងទៀត សុទិន្នកូន បើលោកបានសឹកចេញជាគ្រហស្ថមក នឹងបានគ្រប់គ្រងសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង ។ សុទិន្នកូន ចូរលោកសឹកចេញជាគ្រហស្ថមក ហើយគ្រប់គ្រងសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង ។ សុទិន្នក៏តបថា គហបតី បើញោមអត់ទោសឲ្យអាត្មាភាព ។ នឹងសូមជំរាបញោមបន្តិច ។ បិតាទទួលព្រមថា សុទិន្នកូន ចូរលោកនិយាយមកចុះ មិនជាអ្វីទេ ។ សុទិន្នក៏ប្រាប់ថា គហបតី

មហន្តេ មហន្តេ សាណិបសិព្វកេ ការាបេត្វា ហិរញ្ញសុវណ្ណស្ស បូរាបេត្វា សកដេហិ និព្វាហាបេត្វា មជ្ឈេ គង្គាយ សោតេ ឱសាទេហិ[១] តំ កិស្ស ហេតុ យំ ហិ តេ គហបតិ ភវិស្សតិ តតោនិទានំ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា អារក្ខោ វា សោ តេ ន ភវិស្សតីតិ ។ ឯវំ វុត្តេ អាយស្មតោ សុទិន្នស្ស បិតា អនត្តមនោ អហោសិ កថំ ហិ នាម បុត្តោ សុទិន្នោ ឯវំ វក្ខតីតិ ។ អថ ខោ អាយស្មតោ សុទិន្នស្ស បិតា អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកំ អាមន្តេសិ តេនហិ វធុ ត្វំ បិយា ច មនាបា ច អប្បេវនាម បុត្តោ សុទិន្នោ តុយ្ហំបិ វចនំ ករេយ្យាតិ ។ អថ ខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា អាយស្មតោ សុទិន្នស្ស បាទេសុ គហេត្វា អាយស្មន្តំ សុទិន្នំ ឯតទវោច កីទិសា នាម តា អយ្យបុត្ត អច្ឆរាយោ យាសំ ត្វំ ហេតុ ព្រហ្មចរិយំ ចរសីតិ ។

១ ម. ឱបាតេហិ ។ ឱ. ក. ឱសាទេហិ ។



បើដូច្នោះ ញោមត្រូវបង្គាប់មនុស្សឲ្យធ្វើការុងធំៗ ហើយឲ្យច្រកប្រាក់នឹងមាសឲ្យពេញ រួចដឹកដោយរទេះ យកទៅចាក់ចោលក្នុងកណ្ដាលខ្សែទឹកទន្លេគង្គា ហេតុអ្វីបានជាអាត្មាថាដូច្នោះ គហបតី ព្រោះថាទ្រព្យទាំងពុំនៃតែមានដល់អ្នកណាហើយ សេចក្ដីភ័យក្ដី សេចក្ដីតក់ស្លុតក្ដី សេចក្ដីព្រឺរោមក្ដី ការរក្សាក្ដី តែងមានដល់អ្នកនោះមិនខាន ព្រោះតែទ្រព្យទាំងនោះជាហេតុ (បើញោមយកមាសប្រាក់ទៅចាក់ចោលក្នុងខ្សែទឹកហើយ) សេចក្ដីអន្តរាយមានភ័យជាដើមនោះនឹងមិនមានដល់ញោមឡើយ ។ កាលសុទិន្នដ៏មានអាយុពោលយ៉ាងនេះហើយ បិតារបស់សុទិន្នដ៏មានអាយុបានសេចក្ដីទោមនស្សតូចចិត្ត ហេតុដូចម្ដេច បានជាលោកសុទិន្នជាកូនពោលយ៉ាងនេះ ។ គ្រានោះឯង បិតារបស់សុទិន្នដ៏មានអាយុ ហៅស្រីបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុមកប្រាប់ថា នែនាងស្រី បើដូច្នោះ នាងឯងជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្នកូនអញ នាងចូរធ្វើយ៉ាងណាដើម្បីឲ្យសុទិន្នកូនអញធ្វើតាមពាក្យនាងឯងបាន ។ គ្រានោះឯង ស្រីបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុបានប្រកាន់ជើងទាំងពីររបស់សុទិន្នដ៏មានអាយុ ហើយបាននិយាយពាក្យនេះនឹងសុទិន្នកូនថា បពិត្រអយ្យបុត្រ លោកប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុនៃស្រីអប្សរទាំងឡាយណា ស្រីអប្សរទាំងឡាយនោះមានទ្រង់ទ្រាយប្រាកដដូចម្ដេចទៅ

ន ខោ អហំ ភគិនិ អច្ឆរានំ ហេតុ ព្រហ្មចរិយំ ចរាមីតិ ។ អថខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា អជ្ជ-តគ្គេ មំ អយ្យបុត្តោ សុទិន្នោ ភគិនិវាទេន សមុទាចរតីតិ តត្ថេវ មុច្ឆិតា បបតា ។ អថខោ អាយស្មា សុទិន្នោ បិតរំ ឯតទវោច សចេ គហបតិ ភោជនំ ទាតព្វំ ទេថ មា នោ វិហេឋយិត្ថាតិ ។ ភុញ្ជ តាត សុទិន្នាតិ ។ អថខោ អាយស្មតោ សុទិន្នស្ស មាតា ច បិតា ច អាយស្មន្តំ សុទិន្នំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសុំ សម្បវារេសុំ ។ អថខោ អាយស្មតោ សុទិន្នស្ស មាតា អាយស្មន្តំ សុទិន្នំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯតទវោច ឥទំ តាត សុទិន្ន កុលំ អឌ្ឍំ មហទ្ធនំ មហាភោគំ បហូតជាត-រូបរជតំ បហូតវិត្តូបករណំ បហូតធនធញ្ញំ ។ សក្កា តាត សុទិន្ន ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ ។ ឯហិ ត្វំ តាត សុទិន្ន ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។



សុទិន្នភិក្ខុឆ្លើយថា នែប្អូនស្រី អាត្មាមិនបានប្រព្រឹត្តព្រហ្មចរិយ ព្រោះហេតុតែស្រីអប្សរទាំងនោះទេ ។ វេលានោះ ស្រីបុរាណទុតិយិការបស់សុទិន្នភិក្ខុគិតតាមសេចក្ដីក្នុងចិត្តថា តាំងពីថ្ងៃនេះទៅ លោកសុទិន្នអយ្យបុត្រ ទ្រាំតែហៅអញជាប្អូនស្រី ។ ដូច្នេះហើយ ក៏ដួលសន្លប់ដេកក្នុងទីនោះឯង ។ គ្រានោះ សុទិន្នដ៏មានអាយុបាននិយាយពាក្យនេះនឹងបិតាថា គហបតី បើញោមមានភោជនគួរនឹងឲ្យទានអាត្មា ចូរញោមឲ្យតាមមកចុះ កុំធ្វើការឲ្យលំបាកដល់អាត្មាឡើយ ។ បិតាសុទិន្នឆ្លើយថា សុទិន្នកូន ភោជនាហារមាន សូមលោកនិមន្តឆាន់ចុះ ។ វេលានោះ មាតាបិតារបស់សុទិន្នដ៏មានអាយុបានញ៉ាំងខាទនីយភោជនីយដ៏ឆ្ងាញ់ពិសា ឲ្យសុទិន្នភិក្ខុដ៏មានអាយុឆាន់ ដោយដៃខ្លួនឯង ។ សម័យនោះឯង មាតារបស់សុទិន្នដ៏មានអាយុបាននិយាយនឹងសុទិន្នភិក្ខុ ដែលឆាន់រួចហើយ លែងលូកដៃទៅក្នុងបាត្រហើយថា នែសុទិន្នកូន ត្រកូលនេះស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់បរិបូណ៌ មានគ្រឿងឧបករណៈបរិបូណ៌ មានស្រូវអង្ករបរិបូណ៌ នែសុទិន្នកូន សូមលោកវិលត្រឡប់សឹកចេញជាគ្រហស្ថ ទើបបានប្រើប្រាស់នូវទ្រព្យសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យបានផង ។ សុទិន្នកូន សូមលោកវិលត្រឡប់សឹកចេញជាគ្រហស្ថមក ហើយនឹងបរិភោគនូវសម្បត្តិទាំងឡាយ ធ្វើបុណ្យឲ្យបានចុះ ។

អម្ម ន ឧស្សហាមិ ន វិសហាមិ អភិរតោ អហំ ព្រហ្មចរិយំ ចរាមីតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អាយស្មតោ សុទិន្នស្ស មាតា អាយស្មន្តំ សុទិន្នំ ឯតទវោច ឥទំ តាត សុទិន្ន អម្ហាកំ កុលំ អឌ្ឍំ មហទ្ធនំ មហាភោគំ បហូតជាតរូបរជតំ បហូតវិត្តូបករណំ បហូតធនធញ្ញំ តេនហិ តាត សុទិន្ន ពីជកម្បិ ទេហិ មា នោ អបុត្តកំ សាបតេយ្យំ លិច្ឆវី[៥] អតិហរាបេសុន្តិ ។ ឯតំ ខោ មេ អម្ម សក្កា កាតុន្តិ ។ កហំ បន តាត សុទិន្ន ឯតរហិ វិហរសីតិ ។ មហាវនេ អម្មាតិ ។ អថខោ អាយស្មា សុទិន្នោ ឧដ្ឋាយាសនា បក្កាមិ ។

[១៧] អថខោ អាយស្មតោ សុទិន្នស្ស មាតា អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកំ អាមន្តេសិ យទា វធុ ឧតុនី អហោសិ បុប្ផំ តេ ឧប្បន្នំ ហោតិ អថ មេ អារោចេយ្យាសីតិ ។ ឯវំ អយ្យេតិ ខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា អាយស្មតោ សុទិន្នស្ស មាតុយា បច្ចស្សោសិ ។

៥ សព្វត្ថ បោត្ថកេសុ លិច្ឆវយោតិ បាឋោ ទិស្សតិ ។



សុទិន្នភិក្ខុឆ្លើយថា ម្ដាយ អាត្មាមិនអាចហ៊ាន (ធ្វើយ៉ាងនោះទេ) អាត្មាត្រេកអរចំពោះតែត្រង់ប្រព្រឹត្តព្រហ្មចរិយធម៌ម្យ៉ាង ។ មាតារបស់សុទិន្នភិក្ខុដ៏មានអាយុ បាននិយាយពាក្យនេះ ទើបសុទិន្នភិក្ខុដ៏មានអាយុ ជាគំរប់ពីរដងទៀត ។ បេ ។ ជាគំរប់បីដងទៀតថា សុទិន្នកូន ត្រកូលនេះ ស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគច្រើន មានមាសប្រាក់ច្រើនណាស់ មានគ្រឿងឧបករណ៍ច្រើនណាស់ មានស្រូវអង្ករច្រើនណាស់ សុទិន្នកូន បើដូច្នេះ សូមលោកអាណិតត្រឹមតែឲ្យពូជផងចុះ កុំឲ្យពួកស្ដេចលិច្ឆវីមករឹបជាន់យកទ្រព្យសម្បត្តិរបស់យើង ដែលឥតត្រកូលឥតកូននោះឡើយ ។ សុទិន្នភិក្ខុឆ្លើយថា ម្ដាយ បើត្រឹមតែធ្វើយ៉ាងប៉ុណ្ណោះ អាត្មាអាចធ្វើឲ្យបាន ។ មាតាសុទិន្នសួរថា សុទិន្នកូន សព្វថ្ងៃនេះ លោកគង់នៅឯណា ។ សុទិន្នភិក្ខុតបថា ម្ដាយ អាត្មានៅក្នុងព្រៃមហាវ័ន ។ គ្រានោះឯង សុទិន្នដ៏មានអាយុ ក៏ក្រោកចាកអាសនៈហើយចេញទៅ ។

(១៧) គ្រានោះ មាតារបស់សុទិន្នដ៏មានអាយុ ហៅនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុមក ហើយនិយាយថា ម្នាលនាងកូនប្រសា បើកាលណា នាងមានផ្កាហើយ ផ្កាគឺឈាមរបស់នាងកើតឡើងហើយ នាងត្រូវប្រាប់ដល់ម៉ែ ក្នុងកាលនោះ ។ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បានទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាសម៉ែ ។

អថខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា ន ចិរស្សេវ ឧតុនី អហោសិ បុប្ផំសា ឧប្បជ្ជិ ។ អថខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា អាយស្មតោ សុទិន្នស្ស មាតរំ ឯតទវោច ឧតុនីម្ហិ អយ្យេ បុប្ផំ មេ ឧប្បន្នន្តិ ។ តេនហិ វធុ យេន អលង្ការេន អលង្កតា បុត្តស្ស សុទិន្នស្ស បិយា អហោសិ មនាបា តេន អលង្ការេន អលង្ករោហីតិ ។ ឯវំ អយ្យេតិ ខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា អាយស្មតោ សុទិន្នស្ស មាតុយា បច្ចស្សោសិ ។ អថខោ អាយស្មតោ សុទិន្នស្ស មាតា អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកំ អាទាយ យេន មហាវនំ យេនាយស្មា សុទិន្នោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សុទិន្នំ ឯតទវោច ឥទំ តាត សុទិន្ន កុលំ អឌ្ឍំ មហទ្ធនំ មហាភោគំ បហូតជាតរូបរជតំ បហូតវិត្តូបករណំ បហូតធនធញ្ញំ លព្ភា តាត សុទិន្ន ហីនាយាវត្តិត្វា ភោគា ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ ឯហិ ត្វំ តាត សុទិន្ន ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជស្សុ



លំដាប់នោះ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ មិនយូរប៉ុន្មានក៏មានរដូវ ផ្កាតាមរបៀបនៃនាងនោះក៏កើតឡើង ។ នោះនាងបុរាណ-ទុតិយិការបស់សុទិន្នដ៏មានអាយុ បានប្រាប់មាតារបស់សុទិន្នដ៏មានអាយុយ៉ាងនេះថា ម៉ែ ខ្ញុំមានរដូវហើយ ផ្កាតាមរបៀបរបស់ខ្ញុំកើតហើយ ។ មាតាតបថា ម្នាលនាងកូនប្រសា បើដូច្នោះនាងចូរប្រដាប់កាយដោយគ្រឿងអលង្ការឯណា ដែលជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្នកូន (របស់ម៉ែ) នាងចូរប្រដាប់កាយដោយគ្រឿងសម្រាប់ស្អិតស្អាងនោះចុះ ។ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បានទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាស៎ម៉ែ ។ លំដាប់នោះ មាតារបស់សុទិន្នដ៏មានអាយុ ក៏នាំនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុចូលទៅកាន់ព្រៃមហាវ័នដែលសុទិន្នដ៏មានអាយុនោះនៅ លុះចូលទៅហើយ ក៏បាននិយាយនូវពាក្យនេះនឹងសុទិន្នដ៏មានអាយុថា ម្នាលសុទិន្នកូន ត្រកូលនេះស្តុកស្តម្ភមានទ្រព្យច្រើន មានរបស់ប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន បានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធានស្រូវអង្ករច្រើន ម្នាលសុទិន្នកូន អ្នកត្រឡប់មកកាន់ភេទដ៏ថោកទាប ក៏អាចនឹងបរិភោគនូវភោគសម្បត្តិផង ធ្វើបុណ្យទាំងឡាយផងបាន ម្នាលសុទិន្នកូន អ្នកត្រូវត្រឡប់មកកាន់ភេទជាគ្រហស្ថវិញ ហើយបរិភោគនូវភោគសម្បត្តិផង

បុត្តាធិ ០ តាតេ ហោតិ ។ អម្ម ន ធនស្សកោចិ ន វីស ហាមិ អភិរតោ អហំ ព្រហ្មចរិយំ ចរាមីតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អាយស្មតោ សុទិន្នស្ស មាតា អាយស្មន្តំ សុទិន្នំ ឯតទវោច ឥទំ តាត សុទិន្ន កុលំ អឌ្ឍំ មហទ្ធនំ មហាភោគំ បហូតជាតរូបរជតំ បហូតវិត្តូបករណំ បហូតធនធញ្ញំ តេនហិ តាត សុទិន្ន ពីជកម្បិ ទេហិ មា នោ អបុត្តកំ សាបតេយ្យំ លិច្ឆវិយោ អតិហរាបេសុន្តិ ។ ឯតំ ខោ មេ អម្ម សក្កា កាតុន្តិ បុរាណទុតិយិកាយ ពាហាយំ គហេត្វា មហាវនំ អជ្ឈោគាហេត្វា អប្បញ្ញត្តេ សិក្ខាបទេ អនាទីនវទស្សោ បុរាណទុតិយិកាយ តិក្ខត្តុំ មេថុនំ ធម្មំ អភិវិញ្ញាបេសិ ។ សា តេន គព្ភំ គណ្ហិ ។

(១៨) ភុម្មា ទេវា សទ្ទមនុស្សាវេសុំ និរព្វុទោ វត ភោ ភិក្ខុសង្ឃោ និរាទីនវោ សុទិន្នេន កលន្ទបុត្តេន អព្វុទំ ឧប្បាទិតំ អាទីនវោ ឧប្បាទិតោតិ ។



ធ្វើបុណ្យតាំងពីក្រោយមក ។ សុទិន្នតបថា ញោម អាត្មាសឹកមិនកើតទេ អាត្មាមិនព្រមសឹកទេ អាត្មាត្រេកអរនៃប្រតិបត្តិព្រហ្មចរិយធម៌ ។ មាតារបស់សុទិន្នដ៏មានអាយុ បាននិយាយនឹងសុទិន្នដ៏មានអាយុ អស់វារៈ ២-៣ ដងហើយនិយាយថា ម្នាលសុទិន្នកូន ត្រកូលនេះស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធាន្យស្រូវអង្ករច្រើន ម្នាលសុទិន្នកូន បើដូច្នោះ អ្នកចូរឲ្យពូជតែមួយ កុំឲ្យពួកលិច្ឆវីមកចាប់យកសម្បត្តិទ្រព្យរបស់យើង ដែលជាត្រកូលឥតកូនចៅបាន ។ សុទិន្នឆ្លើយថា ញោម អាត្មាអាចធ្វើកិច្ចនេះជូនបាន ហើយក៏ចាប់ដៃនាងបុរាណទុតិយិកា ទៀតចូលទៅកាន់ព្រៃមហាវន យល់ឃើញថាមិនមានទោស ព្រោះសិក្ខាបទព្រះអង្គមិនទាន់បានបញ្ញត្ត ហើយក៏ញ៉ាំងមេថុនធម្មឲ្យប្រព្រឹត្តជាមួយនាងបុរាណទុតិយិកា អស់វារៈ ៣ ដង នាងក៏មានគភ៌ដោយមេថុនសេពនោះ ។

(១៨) ភុម្មទេវតាទាំងឡាយ ក៏ញ៉ាំងសំឡេងឲ្យឮដូច្នេះថា ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុមិនដែលកើតការ មិនដែលមានទោស (ឥតខ្ចោះ) សុទិន្នកលន្ទបុត្តធ្វើសេចក្តីកើតនៃទោសឲ្យកើតឡើងហើយ ។

ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ តាវតឹសា ទេវា យាមា ទេវា តុសិតា ទេវា និម្មានរតី ទេវា បរនិម្មិតវសវត្តី ទេវា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ និរព្វុទោ វត ភោ ភិក្ខុសង្ឃោ និរាទីនវោ សុទិន្នេន កលន្ទបុត្តេន អព្វុទំ ឧប្បាទិតំ អាទីនវោ ឧប្បាទិតោតិ ។ ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គញ្ឆិ ។ អថខោ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកា តស្ស គព្ភស្ស បរិបាកមន្វាយ បុត្តំ វិជាយិ ។ អថខោ អាយស្មតោ សុទិន្នស្ស សហាយកា តស្ស ទារកស្ស ពីជកោតិ នាមំ អកំសុ អាយស្មតោ សុទិន្នស្ស បុរាណទុតិយិកាយ ពីជកមាតាតិ នាមំ អកំសុ អាយស្មតោ សុទិន្នស្ស ពីជកបិតាតិ នាមំ អកំសុ ។ តេ អបរេន សមយេន ឧភោ អគារស្មា អនគារិយំ បព្វជិត្វា អរហត្តំ សច្ឆាកំសុ ។



ចាតុម្មហារាជិកទេវតាបានឮ សំឡេងភុម្មទេវតាទាំងនោះហើយ ក៏ញុំាងសំឡេងឲ្យឮឡើងទៅ ពួកទេវតាជាន់តាវត្តឹង្ស យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី (រហូតដល់) ពួកព្រហ្ម (បានឮសំឡេងតទៅតាមគ្នាហើយ) ក៏ញុំាងសំឡេងឲ្យឮឡើងថា ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុសង្ឃមិនដែលកើត មិនដែលមានទោស (ឥឡូវនេះ) សុទិន្នកលន្ទបុត្រ មកធ្វើសេចក្ដីកើតនៃទោសឲ្យកើតឡើងហើយ ។ សូរសព្ទ (នោះនេះ) ក៏ឮខ្ទរខ្ទើរឡើងទៅដរាបដល់ព្រហ្មលោកដោយ ១ ខណៈ ១រំពេចនោះឯង ។ គ្រានោះ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ ក៏ស្រាយគភ៌នោះព្រោះនៃការចាស់ឡើងជាលំដាប់ ទើបសំរាលកូនប្រុសម្នាក់ ។ លំដាប់នោះ ពួកសំឡាញ់សុទិន្នដ៏មានអាយុ បានតាំងឈ្មោះទារកនោះថា ពីជក បានតាំងឈ្មោះនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុថា ពីជកមាតា បានតាំងឈ្មោះសុទិន្នដ៏មានអាយុថា ពីជកបិតា ។ លុះដល់សម័យខាងក្រោយមក អ្នកទាំងពីរនោះ បានចេញចាកផ្ទះហើយបួសក្នុងភេទជាបុគ្គលអ្នកមិនមានប្រយោជន៍ដល់ការនៅផ្ទះហើយបានធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផល ។

(១៤) អថខោ អាយស្មតោ សុទិន្នស្ស អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យោហំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា នាសក្ខឹ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុន្តិ ។ សោ តេនេវ កុក្កុច្ចេន តេន វិប្បដិសារេន កិសោ អហោសិ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ អន្តោមនោ លីនមនោ ទុក្ខី ទុម្មនោ វិប្បដិសារី បជ្ឈាយិ ។ អថខោ អាយស្មតោ សុទិន្នស្ស សហាយកា ភិក្ខូ អាយស្មន្តំ សុទិន្នំ ឯតទវោចុំ បុព្វេ ខោ ត្វំ អាវុសោ សុទិន្ន វណ្ណវា អហោសិ បីណិន្ទ្រិយោ បសន្នមុខវណ្ណោ វិប្បសន្នឆវិវណ្ណោ សោ ទានិ ត្វំ ឯតរហិ កិសោ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ



(១៤) គ្រានោះ សេចក្តីសង្ស័យនឹងសេចក្តីក្តៅក្រហាយស្តាយក្រោយ កើតមានដល់សុទិន្នដ៏មានអាយុថា អាត្មាអញត្រូវហៅជាអលាភ លាភមិនមានដល់អាត្មាអញទេ ភាពជាមនុស្ស ពេញហៅអាត្មាអញបានដោយអាក្រក់ មិនមែនជាអាត្មាអញបានដោយល្អទេ ដោយហេតុអាត្មាអញ បានបួសក្នុងធម្មវិន័យ ដែលព្រះសាស្តាទ្រង់សំដែងហើយប្រពៃយ៉ាងនេះ ហើយមិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ។ ព្រោះសេចក្តីសង្ស័យនឹងសេចក្តីក្តៅក្រហាយស្តាយក្រោយនោះឯង សុទិន្នក៏ទៅជាស្គម ប្រែជាមានសម្បុរអាក្រក់ កើតទៅជាពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ មានចិត្តក្រៀមក្រំ ទ្រមឹងទ្រមើយ កើតទុក្ខតូចចិត្ត ទឹកក្តាយក្រោយ សញ្ជប់សញ្ជឹង ។ លំដាប់នោះ ភិក្ខុទាំងឡាយជាសំឡាញ់របស់សុទិន្នដ៏មានអាយុបាននិយាយពាក្យនេះនឹងសុទិន្នដ៏មានអាយុថា ម្នាលអាវុសោសុទិន្ន កាលពីដើមលោកមានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខថ្លា មានសម្បុរផ្ទៃស្បែកផូរផង់ល្អ ឥឡូវនេះលោកទៅជាស្គមសៅហ្មង មានសម្បុរអាក្រក់ កើតពណ៌លឿងស្លេកស្លាំង មានខ្លួនពេញដោយសរសៃ

អន្តោមនោ លីនមនោ ទុក្ខី ទុម្មនោ វិប្បដិសារី បជ្ឈាយសិ ។ កច្ចិ នោ ត្វំ អាវុសោ សុទិន្ន អនភិរតោ ព្រហ្មចរិយំ ចរសីតិ ។ ន ខោ អហំ អាវុសោ អនភិរតោ ព្រហ្មចរិយំ ចរាមិ អត្ថិ មេ បាបកម្មំ[1] កតំ បុរាណទុតិយិកាយ មេថុនោ ធម្មោ បដិសេវិតោ តស្ស មយ្ហំ អាវុសោ អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យោហំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា នាសក្ខឹ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុន្តិ ។ អលំ ហិ តេ អាវុសោ សុទិន្ន កុក្កុច្ចាយ អលំ វិប្បដិសារាយ យំ ត្វំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា ន សក្ខិស្សសិ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុំ

១ ម. បាបំ កម្មំ ។ ម. បាបកំ ។





ហមចិត្តក្រៀមក្រំក្រែមមិនទំរើយ កើតទុក្ខទួញចិត្តក្តៅក្រហាយសញ្ជប់ សញ្ជឹង ម្នាលអាវុសោសុទិន្ន លោកមិនសូវត្រេកអរហើយនៅតែប្រព្រឹត្តព្រហ្មចរិយធម៌ទៅទេឬអ្វី ។ សុទិន្នឆ្លើយតបថា នែលោកដ៏មានអាយុទាំងឡាយ ខ្ញុំមិនមែនមិនត្រេកអរហើយនៅតែប្រព្រឹត្តព្រហ្មចរិយធម៌ទេ ខ្ញុំបានធ្វើបាបកម្មគឺសេពមេថុនធម្មនឹងស្រីបុរាណទុតិយិកា ម្នាលអាវុសោទាំងឡាយ សេចក្តីសង្ស័យនឹងសេចក្តីស្តាយក្រោយក៏កើតមានដល់ខ្ញុំនោះឯងថា អាត្មាអញពេញហៅដល់ឥតលាភ លាភមិនមានដល់អាត្មាអញទេ ភាពជាមនុស្សពេញហៅអាត្មាអញបានដោយអាក្រក់ មិនមែនអាត្មាអញបានដោយល្អទេ ដោយហេតុអាត្មាអញបានបួសក្នុងធម្មវិន័យ ដែលព្រះសាស្តាទ្រង់សំដែងដោយប្រពៃយ៉ាងនេះ ហើយមិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ។ ភិក្ខុទាំងឡាយជាសំឡាញ់ក៏និយាយថា អាវុសោសុទិន្ន លោកបួសក្នុងធម្មវិន័យ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងល្អហើយយ៉ាងនេះ មិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធពេញលេញ ដរាបដល់អស់ជីវិតបាន ព្រោះបើដូច្នោះ សមក៏គួរ

ននុ អាវុសោ ភគវតា អនេកបរិយាយេន វិរាគាយ
ធម្មោ ទេសិតោ នោ សរាគាយ វិសំយោគាយ
ធម្មោ ទេសិតោ នោ សំយោគាយ អនុបាទានាយ
ធម្មោ ទេសិតោ នោ សឧបាទានាយ តត្ថ នាម
ត្វំ អាវុសោ ភគវតា វិរាគាយ ធម្មេ ទេសិតេ
សរាគាយ ចេតេស្សសិ វិសំយោគាយ ធម្មេ
ទេសិតេ សំយោគាយ ចេតេស្សសិ អនុបាទានាយ
ធម្មេ ទេសិតេ សឧបាទានាយ ចេតេស្សសិ
ននុ អាវុសោ ភគវតា អនេកបរិយាយេន
រាគវិរាគាយ ធម្មោ ទេសិតោ មទនិម្មទនាយ





ម្នាលអាវុសោ ហេតុធម្មរបស់ទ្រង់កិច្ចនោះ គួរឲ្យលោកសង្ស័យ គួរឲ្យស្តាយក្រោយមែន ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ (សូត្រ) ដើម្បីឲ្យប្រាសចាកតម្រេក មិនមែនសំដែងដើម្បីឲ្យប្រកបដោយតម្រេកទេ ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប មិនមែនសំដែងដើម្បីតម្រូវទៅរកកិលេសជាគ្រឿងប្រកបទេ ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ មិនមែនសំដែងដើម្បីឲ្យប្រកាន់មាំទេ ( ក្រែងដូច្នេះ ) មិនមែនទេ ឱអាវុសោ ក្រែងធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីឲ្យប្រាសចាកតម្រេក លោកត្រឡប់ជាយល់ថាធម៌នោះជាប្រកបដោយតម្រេកទៅវិញ ក្រែងធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប លោកត្រឡប់ជាចូលចិត្តតម្រូវទៅរកកិលេសជាគ្រឿងប្រកបទៅវិញ ក្រែងធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ លោកទៅជាចូលចិត្តថាឲ្យប្រកាន់មាំវិញ ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ ដើម្បីប្រាសចាកតម្រេក ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីញាំញីនូវសេចក្តីស្រវឹង

បិបាសវិនយាយ អាលយសមុគ្ឃាតាយ វដ្ដុបច្ឆេទាយ តណ្ហក្ខយាយ វិរាគាយ និរោធាយ និព្វានាយ ធម្មោ ទេសិតោ ននុ អាវុសោ មយា អនេកបរិយាយេន កាមានំ បហានំ អក្ខាតំ កាមសញ្ញានំ បរិញ្ញា អក្ខាតា កាមបិបាសានំ បដិវិនយោ អក្ខាតោ កាម-វិតក្កានំ សមុគ្ឃាតោ អក្ខាតោ កាមបរិឡាហានំ វូប-សមោ អក្ខាតោ នេតំ អាវុសោ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ អាវុសោ អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។ អថខោ តេ ភិក្ខូ អាយស្មន្តំ សុទិន្នំ អនេកបរិយាយេន វិគរហិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។



ដើម្បីកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ដើម្បីដកចេញនូវសេចក្តីអាល័យក្នុងកាម ដើម្បីផ្តាច់បង់នូវវដ្ដៈ ដើម្បីអស់ទៅនៃតណ្ហា ដើម្បីគ្មានរាគៈ ដើម្បីនិរោធ ដើម្បីព្រះនិព្វាន (រំលត់ទុក្ខ) មិនមែនឬ ម្នាលអាវុសោ ក៏ការលះបង់នូវកាមទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ការកំណត់ដឹងនូវសេចក្តីសំគាល់ក្នុងកាម ព្រះអង្គក៏ទ្រង់សំដែងហើយ ការកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ព្រះអង្គក៏ទ្រង់សំដែងហើយ ការដកចេញនូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ ក៏ព្រះអង្គទ្រង់សំដែងហើយ ការរម្ងាប់នូវសេចក្តីក្តៅក្រហាយអន្ទះអន្ទែងក្នុងកាមទាំងឡាយ ក៏ព្រះអង្គទ្រង់សំដែងហើយ ដោយអនេក-បរិយាយ (យ៉ាងនេះ) មិនមែនឬ ម្នាលអាវុសោ កម្មនិយាយរបស់លោកនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានោះទេ មិនមែននាំជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ម្នាលអាវុសោ កម្មនិយាយរបស់លោកនេះ រមែងនាំសេចក្តីមិនជ្រះថ្លា ឲ្យកើតមានដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានៅឡើយ ចំណែកជនទាំងឡាយខ្លះដែលជ្រះថ្លាហើយ ឲ្យលាស់ចិត្តចេញទៅវិញទៅទៀត ។ លំដាប់នោះ ភិក្ខុទាំងនោះក៏តិះដៀលលោកសុទិន្នដ៏មានអាយុដោយអនេកបរិ-យាយ ហើយនាំគ្នាក្រាបទូលនូវសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

[៦០] អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ សុទិន្នំ បដិបុច្ឆិ សច្ចំ កិរ ត្វំ សុទិន្ន បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវសីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ(២) មោឃបុរិស អននុលោមិកំ អប្បតិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ មោឃបុរិស ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា ន សក្ខិស្សសិ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុំ ននុ មយា មោឃបុរិស អនេកបរិយាយេន វិរាគាយ ធម្មោ ទេសិតោ នោ សរាគាយ វិសំយោគាយ ធម្មោ ទេសិតោ នោ សំយោគាយ អនុបាទានាយ ធម្មោ ទេសិតោ នោ សឧបាទានាយ តត្ថ នាម ត្វំ មោឃបុរិស មយា វិរាគាយ ធម្មេ ទេសិតេ សរាគាយ ចេតេស្សសិ វិសំយោគាយ ធម្មេ ទេសិតេ

១ ម. បដិសេវសីតិ ។ ២ យោជនាយំ អននុច្ឆវិយន្តិ បាឋោ ទិស្សតិ ។



(៦០) ព្រោះរឿងនោះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរសុទិន្នដ៏មានអាយុក្នុងកាលនោះថា នែសុទិន្ន ឮថាអ្នកឯងសេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ពិតមែនឬ ។ សុទិន្នក្រាបទូលថា សូមទ្រង់ជ្រាប ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស ការដែលអ្នកឯងធ្វើនេះមិនសមគួរ មិនត្រូវទំនង មិនត្រឹមត្រូវ មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែមោឃបុរស ធ្វើម្តេចក៏អ្នកឯងបួសក្នុងធម្មវិន័យដែលតថាគតសំដែងហើយ ដោយប្រពៃយ៉ាងនេះហើយ នៅតែប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបដល់អស់ជីវិតមិនកើត នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ (សូត្រ) ដើម្បីប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប មិនមែនសំដែងដើម្បីត្រូវប្រកបដោយកិលេសជាគ្រឿងប្រកបទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ មិនមែនសំដែងដើម្បីឲ្យប្រកាន់មាំទេ មិនមែនឬ ម្នាលមោឃបុរស ក្នុងធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាករាគៈ អ្នកឯងនឹងគិតប៉ុនប៉ងក្នុងធម៌នោះដើម្បីឲ្យប្រកបដោយរាគៈវិញ ក្នុងធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប

សំយោគាយ ចេតេស្សសិ អនុបាទានាយ ធម្មេ
ទេសិតេ សឧបាទានាយ ចេតេស្សសិ ននុ មយា
មោឃបុរិស អនេកបរិយាយេន រាគវិរាគាយ ធម្មោ
ទេសិតោ មទនិម្មទនាយ បិបាសវិនយាយ អាលយ-
សមុគ្ឃាតាយ វដ្ដុបច្ឆេទាយ តណ្ហក្ខយាយ វិរាគាយ
និរោធាយ និព្វានាយ ធម្មោ ទេសិតោ ននុ មយា
មោឃបុរិស អនេកបរិយាយេន កាមានំ បហានំ
អក្ខាតំ កាមសញ្ញានំ បរិញ្ញា អក្ខាតា កាមបិបា-
សានំ បដិវិនយោ អក្ខាតោ កាមវិតក្កានំ សមុគ្ឃាតោ
អក្ខាតោ កាមបរិឡាហានំ វូបសមោ អក្ខាតោ វរំ តេ
មោឃបុរិស អាសីវិសស្ស ឃោរវិសស្ស មុខេ អង្គជាតំ
បក្ខិត្តំ ន ត្វេវ មាតុគាមស្ស អង្គជាតេ អង្គជាតំ បក្ខិត្តំ





ក៏ឯងនឹង ប្រព្រឹត្តដើម្បីសេចក្តីត្រេក ឬប្រែជាធម៌ដែលតថាគតសំដែងដើម្បីប្រាសចាក
វិញ ក្រែងនឹងប្រព្រឹត្តដើម្បីប្រកាន់ហើយ ដើម្បីមិនឲ្យប្រកាន់ អ្នក
នឹងប្រព្រឹត្តទៅជាប្រយោជន៍ប្រកាន់មាំវិញ ម្នាលមោឃបុរស ធម៌
ដែលតថាគតសំដែងហើយដោយអនេកបរិយាយ ដើម្បីប្រាសចាក
តម្រេក, ធម៌ដែលតថាគតសំដែងហើយ ដើម្បីញាំញីនូវសេចក្តីស្រវឹង
ដើម្បីកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ដើម្បីដកចេញនូវសេចក្តី
អាល័យក្នុងកាម ដើម្បីផ្តាច់បង់នូវវដ្តៈ ដើម្បីអស់ទៅនៃតណ្ហា ដើម្បី
ប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីព្រះនិព្វាន មិនមែនឬ ម្នាល
មោឃបុរស ការលះបង់នូវកាមទាំងឡាយ តថាគតបានសំដែងហើយ
ការកំណត់ដឹងនូវសេចក្តីសំគាល់ក្នុងកាមទាំងឡាយ តថាគតបានសំដែង
ហើយ ការកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ តថា-
គតបានសំដែងហើយ ការដកចេញនូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ
តថាគតបានសំដែងហើយ ការរម្ងាប់នូវសេចក្តីក្តៅក្រហាយ
ក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ ដោយអនេកបរិយាយ
មិនមែនឬ ម្នាលមោឃបុរស អង្គជាតដែលដាក់ទៅក្នុងមាត់អាសិរពិស
ជាសត្វមានពិសខ្លាំងក្លា ប្រសើរជាងអង្គជាតដែលដាក់ទៅក្នុងអង្គជាត

វរន្តេ មោឃបុរិស កណ្ហសប្បស្ស មុខេ អង្គជាតំ បក្ខិត្តំ ន ត្វេវ មាតុគាមស្ស អង្គជាតេ អង្គជាតំ បក្ខិត្តំ វរន្តេ មោឃបុរិស អង្គារកាសុយា អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ[១] អង្គជាតំ បក្ខិត្តំ ន ត្វេវ មាតុគាមស្ស អង្គជាតេ អង្គជាតំ បក្ខិត្តំ តំ កិស្ស ហេតុ តតោនិទានញ្ហិ មោឃបុរិស មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឥតោនិទានញ្ច ខោ មោឃបុរិស កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ តស្ស នាម ត្វំ មោឃបុរិស យំ ត្វំ អសទ្ធម្មំ គាមធម្មំ វសលធម្មំ ទុដ្ឋុល្លំ ឱទកន្តិកំ រហស្សំ ទ្វយំ ទ្វយសមាបត្តឹ សមាបជ្ជិស្សសិ ពហុនំ

---

១ យេភុយ្យេន សជោតិភូតាយាតិ បាឋោ ទិស្សតិ ។



របស់មាតុគ្រាមមិនប្រសើរឡើយ មោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុង មាត់ពស់កែវប្រសើរជាង អង្គជាតដែលអ្នកឯងដាក់ទៅក្នុងអង្គជាតរបស់ មាតុគ្រាមមិនប្រសើរឡើយ មោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងរណ្តៅ រងើកភ្លើងដែលឆេះព្រោលព្រាលប្រសើរជាង អង្គជាតដែលអ្នកឯងដាក់ទៅ ក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរឡើយ ហេតុអ្វី ព្រោះហេតុជាគ គោលដូច្នោះ មោឃបុរស ព្រោះថាមនុស្សដែលដាក់អង្គជាតទៅក្នុង រណ្តៅរងើកភ្លើង គប្បីតែដល់នូវសេចក្តីស្លាប់ឬដល់នូវសេចក្តីទុក្ខប្រហែល នឹងស្លាប់ប៉ុណ្ណោះ ឯមិនបានទៅ លុះបែកកាយស្លាប់ហើយ ទៅកើតក្នុង អបាយ ទុគ្គតិ វិនិបាត នរក ព្រោះបច្ច័យដែលដាក់អង្គជាត ទៅក្នុងរណ្តៅរងើកភ្លើងនោះឡើយ តែមោឃបុរស ចំណែកអង្គជាតដែលដាក់ អង្គជាតទៅក្នុងអង្គជាតរបស់មាតុគ្រាមនោះ តែងលុះបែកកាយហើយ ត្រូវទៅកើតក្នុងអបាយទុគ្គតិ វិនិបាត នរក ម្នាលមោឃ-បុរស ការប្រព្រឹត្តនោះ (ត្រូវតែជាកម្មប្រកបដោយកាមរស់យ៉ាងនេះ) អ្នកឯងនៅតែប្រព្រឹត្តនូវអសទ្ធម្មជាធម៌របស់អ្នកស្រុក ជាធម៌ របស់មនុស្សថោកទាប អាក្រក់ មានកិច្ចដោយទឹកជាទីបំផុត ជាធម៌ លាក់លៀម ជាធម៌របស់ជនពីរៗ អ្នក តែងប្រព្រឹត្តតាមតែប្រមាណនោះ មោឃបុរស (គួរលាសម្លនេះ) ហេតុតែអ្នកឯងហើយជាអ្នកធ្វើអកុសល

ខោ ត្វំ មោឃបុរិស អកុសលានំ ធម្មានំ អាទិកត្តា បុព្វង្គមោ ។ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ មោឃបុរិស អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។ អថខោ ភគវា អាយស្មន្តំ សុទិន្នំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ទុប្បោសតាយ មហិច្ឆតាយ អសន្តុដ្ឋិតាយ សង្គណិកាយ កោសជ្ជស្ស អវណ្ណំ ភាសិត្វា អនេកបរិយាយេន សុភរតាយ សុបោសតាយ អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណំ ភាសិត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញបេស្សាមិ ទស អត្ថវសេ បដិច្ច



ការដើមនៃអកុសលធម៌ទាំងឡាយមានប្រមាណច្រើន ហៅថាជាអ្នកផ្ដើមធ្វើមុនគេ ម្នាលមោឃបុរស កម្មដ៏លាមករបស់អ្នកឯងនេះ មិនបណ្ដាលឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឡើយ មិនមែនដើម្បីជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាថែមឡើងទៀតទេ ម្នាលមោឃបុរស កម្មដ៏លាមករបស់អ្នកឯងនេះ រមែងបណ្ដាលឲ្យកើតសេចក្ដីមិនជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានៅឡើយ និងនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយ ឲ្យប្រែប្រួលចិត្តជាដទៃវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលសុទិន្នដ៏មានអាយុ ដោយអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃការចិញ្ចឹមក្រ ថែទាំក្រ ប្រាថ្នាច្រើន មិនសន្ដោស ច្រឡូកច្រឡំដោយពួកគណៈ និងសេចក្ដីខ្ជិលច្រអូស រួចទ្រង់សំដែងដោយអនេកបរិយាយនូវគុណនៃការដែលគេចិញ្ចឹមងាយ ការដែលគេថែទាំងាយ ប្រាថ្នាតិច សន្ដោស ចិត្តផូរផង់ ការកំចាត់បង់នូវកិលេស ការនាំឲ្យកើតសេចក្ដីជ្រះថ្លា ការមិនសន្សំ និងការប្រារព្ធព្យាយាម ហើយទ្រង់សំដែងធម្មីកថាដ៏សមគួរ ដល់សិក្ខាបទនោះ ដល់សិក្ខាបទនោះចំពោះភិក្ខុទាំងឡាយ ហើយហៅភិក្ខុទាំងឡាយមក (មានព្រះពុទ្ធដីកា) ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង

សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មេថុនំ ធម្មំ បដិសេវេយ្យ បារាជិកោ ហោតិ អសំវាសោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

សុទិន្នភាណវារំ និដ្ឋិតំ ។

[៦១] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វេសាលិយំ មហាវនេ មក្កដឹ អាមិសេន ឧបលាបេត្វា តស្សា មេថុនំ ធម្មំ បដិសេវតិ ។ អថ ខោ សោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ សេនាសនចារិកំ អាហិណ្ឌន្តា យេន តស្ស ភិក្ខុនោ វិហារោ តេនុបសង្កមឹសុ ។



គឺដើម្បីសេចក្ដីល្អដល់សង្ឃ ១ ដើម្បីនៅសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលពាលទាំងឡាយដែលមិនខ្មាសបាប ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីការពារនូវអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាច្រើនឡើង ១ ដើម្បីឲ្យតាំងនៅយូរនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសេពមេថុនធម្ម (ភិក្ខុនោះ) ត្រូវបារាជិក រកសំវាសគ្មាន ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្ត ហើយដល់ភិក្ខុទាំងឡាយ ដោយប្រការយ៉ាងនេះ ។

ភាណវារៈអំពីរឿងសុទិន្នភិក្ខុ ចប់ ។

[៦១] សម័យនោះ មានភិក្ខុ ១ រូប ប្រលោមល្បួងមេស្វា ដោយអាមិសៈ ក្នុងព្រៃមហាវន ទៀបក្រុងវេសាលី ហើយសេពមេថុនធម្មនឹងមេស្វានោះ ។ លំដាប់នោះ ភិក្ខុនោះស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាតក្នុងវេលាព្រឹកព្រហាម ។ ក្នុងសម័យនោះ ភិក្ខុទាំងឡាយច្រើនរូបដើរទៅកាន់សេនាសនចារិក ក៏នាំគ្នាចូលទៅដល់កន្លែងដែលភិក្ខុនោះនៅ ។

អទ្ទសា ខោ សា មក្កដី តេ ភិក្ខូ ទូរតោ វ អាគច្ឆន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេសំ ភិក្ខូនំ បុរតោ កដិម្បិ ចាលេសិ ឆេប្បម្បិ ចាលេសិ កដិម្បិ ឱឌ្ឌិ និមិត្តម្បិ អកាសិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ និស្សំសយំ ខោ សោ ភិក្ខុ ឥមិស្សា មក្កដិយា មេថុនំ ធម្មំ បដិសេវតីតិ ឯកមន្តំ និលីយឹសុ ។ អថខោ សោ ភិក្ខុ វេសាលិយំ បិណ្ឌាយ ចរិត្វា បិណ្ឌបាតំ អាទាយ បដិក្កមិ ។ អថខោ សា មក្កដី យេន សោ ភិក្ខុ តេនុបសង្កមិ ។ អថខោ សោ ភិក្ខុ តំ បិណ្ឌបាតំ ឯកទេសំ ភុញ្ជិត្វា ឯកទេសំ តស្សា មក្កដិយា អទាសិ ។ អថខោ សា មក្កដី តំ បិណ្ឌបាតំ(១) ភុញ្ជិត្វា តស្ស ភិក្ខុនោ កដឹ ឱឌ្ឌិ ។ អថខោ សោ ភិក្ខុ តស្សា មក្កដិយា មេថុនំ ធម្មំ បដិសេវតិ ។ អថខោ តេ ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ ននុ អាវុសោ ភគវតា សិក្ខាបទំ បញ្ញត្តំ កិស្ស ត្វំ អាវុសោ ឥមិស្សា(២) មក្កដិយា មេថុនំ ធម្មំ បដិសេវសីតិ ។ សច្ចំ អាវុសោ ភគវតា សិក្ខាបទំ

១. តំ បិណ្ឌំ ។ ២. [illegible] ។



មេស្វានោះ បានឃើញភិក្ខុអម្បាលនោះមកអំពីចម្ងាយ ក៏ចូលទៅត្រង់កន្លែងដែលភិក្ខុទាំងនោះនៅ លុះចូលទៅដល់ហើយ (គឺសំដែងអាការ) ធ្វើចង្កេះឲ្យញាក់ញ័រផង ញ៉ើកន្ទុយឲ្យញាក់ញ័រផង បើកចង្កេះផង ធ្វើនូវនិមិត្តផង ក្នុងទីចំពោះភិក្ខុទាំងអម្បាលនោះ ។ គ្រានោះ ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនោះសេពមេថុនធម្មនឹងមេស្វានេះដោយពិតប្រាកដមិនសង្ស័យ រួចពួកភិក្ខុនោះនាំគ្នាទៅលាក់ខ្លួនក្នុងទីកំបាំង ១ ។ លំដាប់នោះ ភិក្ខុនោះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលី កាន់បិណ្ឌបាតហើយត្រឡប់មកវិញ ។ គ្រានោះ មេស្វានោះក៏ចូលទៅត្រង់កន្លែងដែលភិក្ខុនោះនៅ ។ លំដាប់នោះ ភិក្ខុនោះ ឆាន់បិណ្ឌបាតនោះមួយចំណែក បានឲ្យដល់មេស្វាមួយចំណែក ។ គ្រានោះ មេស្វាស៊ីបិណ្ឌបាតរួចនោះហើយ ក៏បើកចង្កេះបែរទៅភិក្ខុនោះ ។ លំដាប់នោះ ភិក្ខុនោះក៏សេពមេថុនធម្មនឹងមេស្វានោះ ។ ទើបភិក្ខុទាំងឡាយនោះ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា អាវុសោ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយមិនមែនឬ នែអាវុសោ ហេតុអ្វី ក៏បានជាអ្នកមកសេពមេថុនធម្មនឹងមេស្វានេះ ។ ភិក្ខុនោះ ឆ្លើយថា នែអាវុសោទាំងឡាយ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តពិតមែនហើយ តែសិក្ខាបទនោះ ទ្រង់

បញ្ញត្តំ តញ្ច ខោ មនុស្សិត្ថិយា នោ តិរច្ឆានគតាយាតិ ។ ននុ អាវុសោ តថេវ តំ ហោតិ អននុច្ឆវិកំ អាវុសោ អននុលោមិកំ អប្បតិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ អាវុសោ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា ន សក្ខិស្សសិ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុំ ននុ អាវុសោ ភគវតា អនេក-បរិយាយេន វិរាគាយ ធម្មោ ទេសិតោ នោ សរាគាយ ។បេ។ កាមបរិឡាហានំ វូបសមោ អក្ខាតោ នេតំ អាវុសោ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ អាវុសោ អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។ អថខោ តេ ភិក្ខូ តំ ភិក្ខុំ អនេកបរិយាយេន វិគរហិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។



បញ្ញត្តចំពោះតែស្រីមនុស្ស មិនមែនបញ្ញត្តចំពោះសត្វតិរច្ឆានញីទេ ។ ភិក្ខុទាំងឡាយនោះពោលថា នែអាវុសោ សិក្ខាបទដែលព្រះអង្គបញ្ញត្ត ចំពោះស្រីមនុស្ស គឺដូចសត្វតិរច្ឆានញីដែរ មិនមែនឬ នែអាវុសោ (អំពើការត្រង់ដែលអ្នកធ្វើនោះ) ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ។ នែអាវុសោ គួរបើដែរ អ្នកឯងបួសក្នុងធម្មវិន័យដែលព្រះដ៏មានព្រះភាគត្រាស់សំដែងល្អហើយយ៉ាងនេះក្ដី ទៅអាចប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបអស់ជីវិតមិនកើត នែអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដើម្បីប្រាសចាកតម្រេក មិនមែនដើម្បីប្រកបដោយរាគៈ ។ល។ គឺការរម្ងាប់នូវសេចក្ដីក្ដៅក្រហាយអន្ទះអន្ទែងក្នុងកាមទាំងឡាយ ព្រះអង្គទ្រង់សំដែងហើយដោយអនេកបរិយាយ មិនមែនឬ ម្នាលអាវុសោ អំពើការត្រង់ដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែននាំជនទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាថែមទៀតទេ នែអាវុសោ អំពើការត្រង់ដែលអ្នកនេះរមែងនាំឲ្យកើតសេចក្ដីមិនជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយឲ្យឃ្លាតជ្រះថ្លាទៅវិញ គ្រានោះ ភិក្ខុទាំងឡាយនោះ តិះដៀលភិក្ខុនោះ ដោយបរិយាយច្រើនហើយ នាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ

[៦៦] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា តំ ភិក្ខុំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ភិក្ខុ មក្កដិយា មេថុនំ ធម្មំ បដិសេវសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថញ្ហិ នាម ត្វំ មោឃបុរិស ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា ន សក្ខិស្សសិ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុំ ននុ មយា មោឃបុរិស អនេកបរិយាយេន វិរាគាយ ធម្មោ ទេសិតោ នោ សរាគាយ ។ បេ ។ កាមបរិឡាហានំ វូបសមោ អក្ខាតោ ។ វរំ តេ មោឃបុរិស អាសីវិសស្ស ឃោរវិសស្ស មុខេ អង្គជាតំ បក្ខិត្តំ ន ត្វេវ មក្កដិយា អង្គជាតេ អង្គជាតំ បក្ខិត្តំ វរំ តេ មោឃបុរិស កណ្ហសប្បស្ស មុខេ អង្គជាតំ បក្ខិត្តំ ន ត្វេវ មក្កដិយា អង្គជាតេ អង្គជាតំ បក្ខិត្តំ វរំ តេ មោឃបុរិស អង្គារកាសុយា អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ អង្គជាតំ បក្ខិត្តំ



[៦៦] ព្រោះនិទាននេះ ចំណែកនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុនោះ ក្នុងវេលានោះថា ម្នាលភិក្ខុ ឮថា អ្នកឯងសេពមេថុនធម្មនឹងមេស្វាពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទានពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស (អំពើអាក្រក់ដែលអ្នកឯងធ្វើនេះ) ជាអំពើមិនសមគួរ មិនត្រូវទំនង មិនគួរបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ នែមោឃបុរស គួរបើនៃ អ្នកឯងបួសក្នុងធម្មវិន័យដែលតថាគតសំដែងហើយដោយល្អយ៉ាងនេះត្រឡប់ ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបដល់អស់ជីវិតមិនកើត នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដើម្បីប្រាសចាកតម្រេក មិនមែនដើម្បីប្រកបដោយតម្រេកទេ ។ បេ ។ ក៏រំម្ងាប់នូវសេចក្ដីក្ដៅក្រហាយព្រោះសេចក្ដីតម្រេកក្នុងកាមទាំងឡាយ តថាគតសំដែងហើយដោយអនេកបរិយាយ នែមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់ពស់សិរពិស មានពិសដ៏ក្លៀវក្លា ប្រសើរជាង អ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មេស្វាមិនប្រសើរសោះឡើយ ម្នាលមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់ពស់វែកប្រសើរជាង ដែលអ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មេស្វានោះ មិនប្រសើរសោះឡើយ ម្នាលមោឃបុរស សូវអ្នកឯងដាក់អង្គជាតទៅក្នុងរណ្ដៅរងើកភ្លើងក្ដៅ ដែលកំពុងឆេះសន្ធោសន្ធៅ

៦ ន ត្វេវ មក្កដិយា អង្គជាតេ អង្គជាតំ បក្ខិត្តំ តំ
កិស្ស ហេតុ ឥតោនិទានំ ហិ មោឃបុរិស
មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន
ត្វេវ តប្បច្ចយា កាយស្ស ភេទា បរំ មរណា
អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឥតោ.
និទានញ្ច ខោ មោឃបុរិស កាយស្ស ភេទា បរំ
មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជេយ្យ
តត្ថ នាម ត្វំ មោឃបុរិស យំ ត្វំ អសទ្ធម្មំ
គាមធម្មំ វសលធម្មំ ទុដ្ឋុល្លំ ឱទកន្តិកំ រហស្សំ
ទ្វយំ ទ្វយសមាបត្តិំ សមាបជ្ជិស្សសិ នេតំ មោ-
ឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។
ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ.
៥ យោ បន ភិក្ខុ មេថុនំ ធម្មំ បដិសេវេយ្យ



មានអណ្តាតគ្រឹមចុះប៉ើររវើរញ្ញប្រសើរជាង ឯអង្គជាតដែលអ្នកឯងញុំាង
ទៅក្នុងអង្គជាតរបស់មេស្វានោះ កុំប្រសើរឡើយ ពាក្យដែលគេពោល
ពោលនោះ ព្រោះហេតុអ្វី ម្នាលមោឃបុរស ព្រោះថាគេតែងប៉ះពាល់ដល់
នូវសេចក្ដីស្លាប់ ឬសេចក្ដីទុក្ខស្មើនឹងស្លាប់ ដោយហេតុដែលដាក់ខ្លួនអង្គ-
ជាតទៅក្នុងមាត់ពស់វែកជាដើមនោះក៏ដោយ បុគ្គលនោះលុះរំលាយ
ខន្ធ ចំណុចខាងមុខអំពីមរណៈ មិនទៅកាន់ទុគ្គតិ ប្រេត អសុរកាយ នរក
ព្រោះតែដាក់អង្គជាតទៅក្នុងមាត់ពស់វែកជាដើមនោះទេ ម្នាលមោឃ-
បុរស (តែបុគ្គលនោះ) លុះរំលាយខន្ធ ក៏កើតទៅកាន់តិរច្ឆានកំណើត
ប្រេត អសុរកាយ នរក ព្រោះហេតុដែលដាក់អង្គជាតទៅក្នុងអង្គ-
ជាតមេស្វានេះឯង ម្នាលមោឃបុរស ការបើកនោះមានទោស
ខ្លួនដល់ហើយ អ្នកឯងមិនគួរបំពាននូវសេចក្ដីអសទ្ធម្ម ជាធម៌របស់អ្នក
ស្រុក ជាធម៌របស់មនុស្សថោកទាប គ្រាស់ដោយទោសអាក្រក់ មានទឹក
ដោយទឹកជាទីបំផុត របស់ដែលគេគួរលាក់ ជាធម៌លាក់លៀម ដែល
គេត្រូវប្រព្រឹត្តតែពីរនាក់នោះទេ ម្នាលមោឃបុរស អំពើដែល
អ្នកឯងធ្វើនោះមិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយ
ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-
ឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសេពមេថុនធម្ម

អន្តមសោ តិរច្ឆានគតាយបិ បារាជិកោ ហោតិ អសំវាសោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

មក្កដីវត្ថុ[១] និដ្ឋិតំ ។

(២៣) តេន ខោ បន សមយេន សម្ពហុលា វេសាលិកា វជ្ជីបុត្តកា ភិក្ខូ យាវទត្ថំ ភុញ្ជឹសុ យាវទត្ថំ សុបឹសុ យាវទត្ថំ នហាយឹសុ យាវទត្ថំ ភុញ្ជិត្វា យាវទត្ថំ សុបិត្វា យាវទត្ថំ នហាយិត្វា អយោនិសោ មនសិករិត្វា សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវឹសុ ។ តេ អបរេន សមយេន ញាតិព្យសនេនបិ ផុដ្ឋា ភោគព្យសនេនបិ ផុដ្ឋា រោគព្យសនេនបិ ផុដ្ឋា អាយស្មន្តំ អានន្ទំ ឧបសង្កមិត្វា ឯវំ វទេន្តិ ន មយំ ភន្តេ អានន្ទ ពុទ្ធគរហិនោ ន ធម្មគរហិនោ ន សង្ឃគរហិនោ អត្តគរហិនោ មយំ ភន្តេ អានន្ទ អនញ្ញគរហិនោ

១ ម. យុ. មក្កដីសិក្ខាបទន្តិ ទិស្សតិ ។



ដោយហោចទៅ សូម្បីនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះ ចំពោះភិក្ខុទាំងឡាយដោយហេតុយ៉ាងនេះឯង ។

និទានមេស្វា ចប់ ។

(២៣) ក្នុងសម័យនោះ ពួកភិក្ខុវជ្ជីបុត្រនៅក្នុងក្រុងវេសាលីជាច្រើនរូប នាំគ្នាឆាន់ឆ្អែតហើយសឹង ៗ ស្កប់ហើយស្រង់ទឹក ៗ ហើយឆាន់ ៗ ហើយសឹង ៗ ស្កប់ស្កល់ហើយស្រង់ទឹក ធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវហើយ មិនបានលាសិក្ខា មិនធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំឡាំងថយ (គឺមិនសឹកសិន) ហើយសេពមេថុនធម្ម ។ លុះសម័យតមកខាងក្រោយ ភិក្ខុទាំងនោះ ត្រូវសេចក្ដីព្រាត់ប្រាសចាកញាតិខ្លះ ត្រូវសេចក្ដីវិនាសភោគសម្បត្តិខ្លះ ត្រូវរោគមកបៀតបៀនខ្លះ (ក៏នាំគ្នា) ចូលទៅរកព្រះអានន្ទដ៏មានអាយុ ហើយពោលពាក្យយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចំរើន យើងខ្ញុំទាំងឡាយមិនមែនជាអ្នកតិះដៀលព្រះពុទ្ធ តិះដៀលព្រះធម៌ តិះដៀលព្រះសង្ឃទេ បពិត្រព្រះអានន្ទដ៏ចំរើន យើងខ្ញុំទាំងឡាយជាអ្នកតិះដៀលតែខ្លួនឯង មិនមែនតិះដៀលអ្នកដទៃទេ

ឧបយេម្ហ អសទ្ធិកា ឥមំ អប្បមត្តា ហោ ឥមំ ឯវំ សុក្ខាគេ ឧម្មាទេយ បត្ថេត្វា ភាសុក្ខម្ហា យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិត្វំ ឥធាគមិ ទេ(១) ឥមំ កត្វា អានន្ទ លោកយាម ភគវតា សង្ឃោ មន្ទំ លោកយាម ឧបសម្បទំ ឥធាគមិ ឥមំ វិបស្សតា កុសលានំ ធម្មានំ បុព្វង្គមាន្ត គោចរត្ថិកានំ ធម្មានំ ភាវនានុយោគមនុយុត្តា វិហរេយ្យាម សាធុ កត្វា អានន្ទ ភគវតោ បវេទេហិ អានោទេតិ ។ ឯវមាវុសោតិ ខោ អាយស្មា អានន្ទោ វេសាលិកានំ វជ្ជិបុត្តកានំ បដិស្សុណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច អានោទេសិ ។ អព្ភាគមេតំ អានន្ទ អនវកាសោ យំ តថាគតោ

(១) ម. ម. សិក្ខំ យេវ ។



យើងខ្ញុំទាំងឡាយ បានមកប្រសូតក្នុងបរិវេណដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយប្រពៃណ៍នេះ ក៏ទៅជាប្រក្រតីព្រហ្មចរិយបរិសុទ្ធ ទ្បើបញ្ញាណអស់មួយជីវិតមិនកើត យើងខ្ញុំទាំងឡាយ ទៅកើតជាមនុស្សក្នុងសំណាក់ទីសេដ្ឋ យើងខ្ញុំកើតជាមនុស្សនៃបុណ្យ មកក្រែកព្រះអានន្ទដ៏ចំរើន បើប្រសិនជាយើងខ្ញុំបានចូលបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគអង្គនេះទៀត នោះយើងខ្ញុំគង់នឹងបានឃើញនូវកុសលធម៌ទាំងឡាយ ដ៏នឹងប្រើនប្រកបព្យាយាមដើម្បីធ្វើឲ្យច្បាស់នូវធម៌ទាំងឡាយ ដែលគួរជាទីណាគនៃភាវនាញាណឲ្យចំរើនអស់កម្រមុខនឹងកើតក្រោយ (ពីបរិយាយទីបញ្ចមយាម) ក្នុងកាលឥឡូវនេះ មកក្រែកព្រះអានន្ទដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមលោកម្ចាស់នាំសេចក្តីនេះទៅក្រាបទូលព្រះដ៏មានព្រះភាគឲ្យបានជ្រាប ។ ព្រះអានន្ទដ៏មានអាយុក៏ទទួលពាក្យរបស់ពួកភិក្ខុវជ្ជីបុត្តអ្នកក្រុងវេសាលីថា អើ ករុណា ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏បានក្រាបទូលសេចក្តីនេះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតប្រើតសិក្ខាបទឈ្មោះគរុធម៌ ដែលតថាគត

វជ្ជីនំ វា វជ្ជិបុត្តកានំ វា ការណា សាវកានំ បារាជិកំ សិក្ខាបទំ បញ្ញត្តំ សមូហនេយ្យាតិ ។

(៦៦) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ យោ ខោ(១) ភិក្ខវេ ភិក្ខុ សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវតិ សោ អាគតោ ន ឧបសម្បាទេតព្វោ យោ ច ខោ ភិក្ខវេ ភិក្ខុ(២) សិក្ខំ បច្ចក្ខាយ ទុព្វល្យំ អាវិកត្វា មេថុនំ ធម្មំ បដិសេវតិ សោ អាគតោ ឧបសម្បាទេតព្វោ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ សិក្ខំ អប្បច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា មេថុនំ ធម្មំ បដិសេវេយ្យ អន្តមសោ តិរច្ឆានគតាយបិ បារាជិកោ ហោតិ អសំវាសោតិ ។

១ ម. ចខ ។ ២ សព្វត្ថ ចយោ ខោ ។



ដូចបញ្ញត្តហើយដល់សាវកទាំងឡាយ ព្រោះហេតុនៃពួកអ្នកនៅក្នុងដែនវជ្ជីទាំងឡាយក្តី ព្រោះហេតុនៃវជ្ជីបុត្តកភិក្ខុទាំងឡាយក្តី ដោយអំពើណាអំពើមួយ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ ។

(៦៦) ព្រោះនិទាននេះ ព្រោះដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ពោលព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មិនពោលលាសិក្ខា មិនប្រកាសខ្លួនជាអ្នកមានកំឡាំងថយ ហើយសេពមេថុនធម្ម បើភិក្ខុនោះមក (សូមឧបសម្បទានឹងសង្ឃទៀត) សង្ឃមិនត្រូវឲ្យឧបសម្បទាឡើយ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុណាមួយពោលលាសិក្ខាហើយ ប្រកាសខ្លួនជាអ្នកមានកំឡាំងថយ ហើយសេពមេថុនធម្ម បើភិក្ខុនោះ (សូមបួសទៀត) សង្ឃគប្បីឲ្យឧបសម្បទាចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដល់ព្រមដោយសិក្ខានឹងសាជីវៈ (ដែលតថាគតបញ្ញត្តហើយ) សម្រាប់ភិក្ខុទាំងឡាយ ហើយមិនពោលលាសិក្ខា មិនធ្វើឲ្យជាក់ច្បាស់នូវការជាអ្នកមានកំឡាំងថយ ហើយសេពមេថុនធម្ម ដោយហោចទៅសូម្បីតែនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។

(៤៥) យោ បនាតិ យោ យាទិសោ យថាយុត្តោ យថាជច្ចោ យថានាមោ យថាគោត្តោ យថាសីលោ យថាវិហារី យថាគោចរោ ថេរោ វា នវោ វា មជ្ឈិមោ វា ឯសោ វុច្ចតិ យោ បនាតិ ។

(៤៦) ភិក្ខូតិ ភិក្ខកោតិ ភិក្ខុ ។ ភិក្ខាចរិយំ អជ្ឈុបគតោតិ ភិក្ខុ ។ ភិន្នបដធរោតិ ភិក្ខុ ។ សមញ្ញាយ ភិក្ខុ ។ បដិញ្ញាយ ភិក្ខុ ។ ឯហិភិក្ខូតិ ភិក្ខុ ។ តីហិ សរណគមនេហិ ឧបសម្បន្នោតិ ភិក្ខុ ។ ភទ្រោតិ(១) ភិក្ខុ ។ សារោតិ ភិក្ខុ ។ សេក្ខោតិ ភិក្ខុ ។ អសេក្ខោតិ ភិក្ខុ ។ សមគ្គេន សង្ឃេន ញត្តិចតុត្ថេន កម្មេន អកុប្បេន ឋានារហេន ឧបសម្បន្នោតិ ភិក្ខុ ។

១ [illegible]





(៤៥) ត្រង់ពាក្យថា ណាមួយ អធិប្បាយថា ភិក្ខុជាថេរក្តី ភិក្ខុបួសថ្មីក្តី ភិក្ខុកណ្តាលក្តីឯណា នឹងតាមតែភិក្ខុរូបណា ដែលប្រកបក្នុងកម្មយ៉ាងណា មានជាតិយ៉ាងណា មានឈ្មោះយ៉ាងណា មានគោត្រយ៉ាងណា មានប្រក្រតីយ៉ាងណា មានគ្រឿងនៅយ៉ាងណា មានគោចរយ៉ាងណាក៏ដោយ ភិក្ខុនេះលោកហៅថា (ភិក្ខុ) ណាមួយ ។

(៤៦) ត្រង់ពាក្យថា ភិក្ខុ មានវិគ្រោះថា សមណៈណាជាអ្នកសូម សមណៈនោះហៅថា ភិក្ខុ ។ សមណៈណាចូលទៅកាន់ប្រយត្ន ភិក្ខាចរិយវត្ត សមណៈនោះហៅថា ភិក្ខុ ។ ជនណាទ្រទ្រង់សំពត់ដែលគេកាត់ហើយ ជននោះហៅថា ភិក្ខុ ។ ជនដែលហៅថា ភិក្ខុ ព្រោះហេតុជាបញ្ញត្តិថា សមណៈ ។ ហៅថា ភិក្ខុ ព្រោះប្តេជ្ញាខ្លួន ។ ហៅថា ភិក្ខុ ព្រោះសម្រេចថា ឯហិភិក្ខុ ។ ហៅថា ភិក្ខុ ព្រោះបានឧបសម្បទាដោយសរណគមន៍ ៣ ។ ហៅថា ភិក្ខុ ព្រោះហេតុជាអ្នកចំរើន ។ ហៅថា ភិក្ខុ ព្រោះមានសារធម៌ ។ ហៅថា ភិក្ខុ ព្រោះជាអ្នកសិក្សា ។ ហៅថា ភិក្ខុ ព្រោះមិនចាំបាច់សិក្សា ។ ហៅថា ភិក្ខុ ព្រោះបានឧបសម្បទាដោយញត្តិចតុត្ថកម្មជាដ៏សមគួរដល់ហេតុដែលមិនមានសេចក្តីអន្តរាយ ដោយសង្ឃដែលព្រមព្រៀងហើយ ។ បណ្តាភិក្ខុ

តត្រ យ្វាយំ ភិក្ខុ សមគ្គេន សង្ឃេន ញត្តិចតុត្ថេន កម្មេន អកុប្បេន ឋានារហេន ឧបសម្បន្នោ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។

(៦៣) សិក្ខាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា តត្រ យាយំ អធិសីលសិក្ខា អយំ ឥមស្មឹ អត្ថេ អធិប្បេតា សិក្ខាតិ ។

(៦៤) សាជីវំ នាម យំ ភគវតា បញ្ញត្តំ សិក្ខាបទំ ឯតំ សាជីវំ នាម តស្មឹ សិក្ខតិ តេន វុច្ចតិ សាជីវសមាបន្នោតិ ។

(៦៥) សិក្ខំ អប្បច្ចក្ខាយ ទុព្ពល្យំ អនាវិក្កត្វាតិ អត្ថិ ភិក្ខវេ ទុព្ពល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច អប្បច្ចក្ខាតា ។ អត្ថិ ភិក្ខវេ



ទាំងនោះ ភិក្ខុណាដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មជា ដ៏សមគួរដល់ហេតុដែលមិនមានវិបត្តិកំរើក ដោយសង្ឃដែលព្រមព្រៀងគ្នាហើយ ភិក្ខុនេះ ទ្រង់សំដៅយកក្នុងអត្ថនេះ ។

(៦៣) ត្រង់ពាក្យថា សិក្ខា សំដៅត្រង់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ បណ្តាសិក្ខាទាំង ៣ នោះ សិក្ខាណាដែលហៅថា អធិសីលសិក្ខា សិក្ខានេះទ្រង់សំដៅយកក្នុងសេចក្តីនេះ ។

(៦៤) ត្រង់ពាក្យថា សាជីវៈ គឺសិក្ខាបទណា ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ សិក្ខាបទដែលព្រះមានព្រះភាគបានបញ្ញត្តហើយនុ៎ះ ហៅថា សាជីវៈ ភិក្ខុដែលសិក្សាក្នុងសិក្ខាបទ ហៅថា សាជីវៈ នោះ ទើបលោកហៅថា អ្នកដល់ព្រមដោយ សាជីវៈ ដោយហេតុនោះឯង ។

(៦៥) ត្រង់ពាក្យថា មិនពោលលាសិក្ខា មិនធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំឡាំងថយ (មានព្រះពុទ្ធភាសិតថា) ម្នាលភិក្ខុទាំងឡាយ ភាពណាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា ហៅថា ភិក្ខុមិនបានពោលលាសិក្ខាឡើយក៏មាន ។ ម្នាលភិក្ខុទាំងឡាយ

ទុព្វល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច បច្ចក្ខាតា ។

(៣០) កថញ្ច ភិក្ខវេ ទុព្វល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច អបច្ចក្ខាតា ។ ឥធ ភិក្ខវេ ភិក្ខុ ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដីយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ឧបាសកភាវំ បត្ថយមានោ អារាមិកភាវំ បត្ថយមានោ សាមណេរភាវំ បត្ថយមានោ តិត្ថិយភាវំ បត្ថយមានោ តិត្ថិយសាវកភាវំ បត្ថយមានោ អស្សមណភាវំ បត្ថយមានោ អសក្យបុត្តិយភាវំ បត្ថយមានោ យន្នូនាហំ ពុទ្ធំ បច្ចក្ខេយ្យន្តិ វទតិ វិញ្ញាបេតិ ។ ឯវំបិ ភិក្ខវេ ទុព្វល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច អបច្ចក្ខាតា ។ អថវា បន ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដីយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ



គឺយ៉ាងដែលភិក្ខុបានធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំឡាំងថយហើយ សិក្ខាហៅថា ភិក្ខុបានពោលលាហើយក៏មាន ។

(៣០) ម្នាលភិក្ខុទាំងឡាយ គឺយ៉ាងដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា ហៅថា ភិក្ខុមិនទាន់បានពោលលានៅឡើយ នោះតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អផ្សុកមិនត្រេកអរ ចង់ឃ្លៀងឃ្លាតចាកភេទជាសមណៈ នឿយណាយ ធុញទ្រាន់ ខ្ពើមរអើមនឹងភាពខ្លួនជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ប្រាថ្នាភាពជាឧបាសក ប្រាថ្នាភាពជាអ្នកក្សាអារាម ប្រាថ្នាភាពជាសាមណេរ ប្រាថ្នាភាពជាតិរ្ថិយ ប្រាថ្នាភាពជាតិរ្ថិយសាវក ប្រាថ្នាភាពនៃខ្លួនមិនមែនជាសមណៈ ប្រាថ្នាភាពនៃខ្លួនមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា គឺយ៉ាងដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខាហៅថា ភិក្ខុមិនទាន់បានពោលលានៅឡើយ ។ មួយវិញទៀត ភិក្ខុអផ្សុកមិនត្រេកអរ ចង់ចេញចាកសមណភាព នឿយណាយ ធុញទ្រាន់ ខ្ពើមរអើមនឹងភាពខ្លួនជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ។ បេ ។ ប្រាថ្នានូវភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យ

យន្នូនាហំ ធម្មំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ បេ ។ យន្នូនាហំ សង្ឃំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ សិក្ខំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ វិនយំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ បាតិមោក្ខំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ ឧទ្ទេសំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ ឧបជ្ឈាយំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ អាចរិយំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ សទ្ធិវិហារិកំ(១) បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ អន្តេវាសិកំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ សមានុបជ្ឈាយកំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ សមានាចរិយកំ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ សព្រហ្មចារឹ បច្ចក្ខេយ្យន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ គិហី អស្សន្តិ វទតិ វិព្ភមេតិ ។ យន្នូនាហំ

---

១ បុរេ សទ្ធិវិហារិកន្តិ បឋិត្ត ៤ តំ សព្វត្ថ លមេតិ ។



អ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះធម៌ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះសង្ឃ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់សិក្ខា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់វិន័យ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់បាតិមោក្ខ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ឧទ្ទេស ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ឧបជ្ឈាយ៍ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់អាចារ្យ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់សទ្ធិវិហារិក ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់អន្តេវាសិក ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់គ្រូដែលមានឧបជ្ឈាយ៍ស្មើគ្នា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់គ្រូដែលមានអាចារ្យស្មើគ្នា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់គ្រូអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាគ្រហស្ថ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែ

ឧបាសកោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ យន្នូនាហំ អារាមិកោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ យន្នូនាហំ សាមណេរោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ យន្នូនាហំ តិត្ថិយោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ យន្នូនាហំ តិត្ថិយសាវកោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ យន្នូនាហំ អស្សមណោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ យន្នូនាហំ អសក្យបុត្តិយោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ ឯវម្បិ ភិក្ខវេ ទុព្ពល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច អបច្ចក្ខាតា ។ អថ វា បន ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដិយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ យទិ បនាហំ ពុទ្ធំ បច្ចក្ខេយ្យន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ យទិ បនាហំ អសក្យបុត្តិយោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ អបាហំ(១) ពុទ្ធំ បច្ចក្ខេយ្យន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ អបាហំ

១ ឱ. ម. អបាហំ ។



ខ្ញុំត្រូវទៅជាឧបាសក ១ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាអ្នករក្សាវត្ត ១ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាសាមណេរ ១ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាតិរ្ថិយ ១ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាតិរ្ថិយសាវក ១ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលែងធ្វើជាសមណៈ ១ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលែងធ្វើជាសក្យបុត្រ ១ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯងហៅថា កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកំលាំងថយ ផង សិក្ខាមិនទាន់ហៅថាភិក្ខុបានលាលះនៅឡើយ ១ ម្យ៉ាងវិញទៀត ភិក្ខុអផ្សុកមិនត្រេកអរ ចង់ឃ្លាតចាកសាមញ្ញភាព កាលធុញទ្រាន់ ខ្មាសខ្ពើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ១ ។ បេ ។ ប្រាថ្នាភាពមិនមែនជាសក្យបុត្រ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើមែន មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ ១ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើមែន មានតែខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ ១ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កាលបើហេតុយ៉ាងនេះមានពិតមែន ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ១ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កាលបើយ៉ាងនេះ មានតែខ្ញុំត្រូវលែងធ្វើ

អសក្យបុត្តិយោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ ហន្ទាហំ ពុទ្ធំ បច្ចក្ខេយ្យន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ ហន្ទាហំ អសក្យបុត្តិយោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ ហោតុ មេ ពុទ្ធំ បច្ចក្ខេយ្យន្តិ វទតិ វិញ្ញាបេតិ ។ បេ ។ ហោតុ មេ អសក្យបុត្តិយោ អស្សន្តិ វទតិ វិញ្ញាបេតិ ។ ឯវំបិ ភិក្ខវេ ទុព្វល្យាវិកម្មញ្ច ហោតិ សិក្ខា ច អប្បច្ចក្ខាតា ។ អថ វា បន ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដិយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ មាតរំ សរាមីតិ វទតិ វិញ្ញាបេតិ ។ បិតរំ សរាមីតិ វទតិ វិញ្ញាបេតិ ។ ភាតរំ សរាមីតិ វទតិ វិញ្ញាបេតិ ។ ភគិនឹ សរាមីតិ វទតិ វិញ្ញាបេតិ ។ បុត្តំ សរាមីតិ វទតិ វិញ្ញាបេតិ ។ ធីតរំ សរាមីតិ វទតិ វិញ្ញាបេតិ ។ បជាបតឹ សរាមីតិ វទតិ វិញ្ញាបេតិ ។ ញាតកេ សរាមីតិ វទតិ វិញ្ញាបេតិ ។



ជាសក្យបុត្រ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ណ្ហើយចុះ ខ្ញុំត្រូវតែលះបង់ព្រះពុទ្ធ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ណ្ហើយចុះ ខ្ញុំត្រូវតែលែងធ្វើជាសក្យបុត្រ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ហេតុរបស់ខ្ញុំលើកទុកសិនចុះ ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។ បេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ហេតុរបស់ខ្ញុំលើកទុកសិនចុះ ត្រូវតែខ្ញុំលែងធ្វើជាសក្យបុត្រ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាត្រឡប់ខ្សែ ធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខាមិនទាន់ហៅថាភិក្ខុបានលាលះនៅឡើយ ។ មួយវិញទៀត ភិក្ខុអផ្សុក មិនរីករាយ ប្រាថ្នាដើម្បីឲ្យឃ្លាតចាកសមណភាព ជាទុក្ខ ធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ។ បេ ។ ចង់ឲ្យខ្លួនទៅជាអសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកមាតា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបិតា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបងប្អូនប្រុស ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបងប្អូនស្រី ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកកូនប្រុស ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកកូនស្រី ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកប្រពន្ធ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកញាតិ ។

ចក្ខុ សកមីតំ វេតិ វិញ្ញាបេតិ ៗ កាយំ សកមីតំ វេតិ វិញ្ញាបេតិ ៗ បិតមំ សកមីតំ វេតិ វិញ្ញាបេតិ ៗ ខេត្តំ សកមីតំ វេតិ វិញ្ញាបេតិ ៗ វត្ថុំ សកមីតំ វេតិ វិញ្ញាបេតិ ៗ ហាវញ្ញំ សកមីតំ វេតិ វិញ្ញាបេតិ ៗ សុវណ្ណំ សកមីតំ វេតិ វិញ្ញាបេតិ ៗ សិប្បំ សកមីតំ វេតិ វិញ្ញាបេតិ ៗ បុព្វេ ហសិតំ លបិតំ កីឡិតំ សមនុស្សរាមិតិ វេតិ វិញ្ញាបេតិ ៗ បរិបំ គិត្វាវេ ឥទ្ធិលព្ភារកម្មវេ ពោធិ សិក្ខា ៥ អបរិវត្តានា ៗ សជក បន ទុក្ខិណា ពោ អធិកោ សាមញ្ញា ជវិតុកាមោ គិត្ថាកាវំ អជ្ឈយមានោ មាកយមានោ ជិគុច្ឆមានោ គិហិកាវំ បត្ថយមានោ ៗ បេ ៗ អសក្យបុត្តិយកាវំ បត្ថយមានោ រោគា មេ អត្ថំ សា មយា ចោសេតព្វាតិ វេតិ វិញ្ញាបេតិ ៗ បិតា មេ អត្ថំ សោ មយា ចោសេតព្វាតិ វេតិ វិញ្ញាបេតិ ៗ ភាតា មេ អត្ថំ សោ មយា ចោសេតព្វាតិ វេតិ វិញ្ញាបេតិ ៗ ភគិនី មេ អត្ថំ



និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកឃ្លាតមិត្ត ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកស្រែក ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកចំការ ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកប្រាក់ ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកមាស ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកសិល្បសាស្ត្រ ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកដល់ការសើចការស្រដី និងការលេង អំពីមុន ៗ ចាលភិក្ខុគិតខ្លួនឯង យ៉ាងនេះថា គិហិភេទត្រូវបានដោះស្រាយ ប្រាសចេញចាកពួកអ្នកមានតម្រេកស៊ីផល ប៉ុន្តែសិក្ខាមិនទាន់បានរក្សាទុកការលាឡើយ ៗ មួយវិញទៀត ភិក្ខុអផ្សុក មិនត្រេកអរ ប្រាថ្នាឲ្យឃ្លាតចេញចាកសមណភាព ជាទុក្ខ ធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាចិត្តចង់ភាពគ្រហស្ថ ៗ បេ ៗ ប្រាថ្នាចិត្តចង់ភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមានមាតា ៗ នោះខ្ញុំត្រូវតែចិញ្ចឹម ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បិតារបស់ខ្ញុំមាន បិតានោះខ្ញុំត្រូវតែចិញ្ចឹម ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនប្រុសរបស់ខ្ញុំមាន បងប្អូនប្រុសនោះខ្ញុំត្រូវតែចិញ្ចឹម ៗ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូន

សា មយា បោសេតព្វាតិ វទតិ វិញ្ញាបេតិ ។ បុត្តោ មេ អត្ថិ សោ មយា បោសេតព្វោតិ វទតិ វិញ្ញាបេតិ ។ ធីតា មេ អត្ថិ សា មយា បោសេតព្វាតិ វទតិ វិញ្ញាបេតិ ។ បជាបតី មេ អត្ថិ សា មយា បោសេតព្វាតិ វទតិ វិញ្ញាបេតិ ។ ញាតកា មេ អត្ថិ តេ មយា បោសេតព្វាតិ វទតិ វិញ្ញាបេតិ ។ មិត្តា មេ អត្ថិ តេ មយា បោសេតព្វាតិ វទតិ វិញ្ញាបេតិ ។ ឯវំបិ ភិក្ខវេ ទុព្វល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច អប្បច្ចក្ខាតា ។ អថ វា បន ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដីយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ មាតា មេ អត្ថិ សា មំ បោសេស្សតីតិ វទតិ វិញ្ញាបេតិ ។ បិតា មេ អត្ថិ សោ មំ បោសេស្សតីតិ វទតិ វិញ្ញាបេតិ ។ ភាតា មេ អត្ថិ សោ មំ បោសេស្សតីតិ វទតិ វិញ្ញាបេតិ ។ ភគិនី មេ អត្ថិ សា មំ បោសេស្សតីតិ វទតិ វិញ្ញាបេតិ ។



ស្រីរបស់ខ្ញុំមាន បងប្អូនស្រីនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនប្រុសរបស់ខ្ញុំមាន កូនប្រុសនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនស្រីរបស់ខ្ញុំមាន កូនស្រីនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រពន្ធរបស់ខ្ញុំមាន ប្រពន្ធនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកញាតិរបស់ខ្ញុំមាន ពួកញាតិនោះត្រូវតែខ្ញុំចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកមិត្តរបស់ខ្ញុំមាន ពួកមិត្តនោះខ្ញុំត្រូវតែចិញ្ចឹម ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា គីឡាព្រោះតែធ្វើឲ្យច្បាស់នូវភាពជាអ្នកមានកម្លាំងថយផង សិក្ខាមិនទាន់ហៅថាភិក្ខុបានលាលែងហើយ ។ មួយទៀត ភិក្ខុអផ្សុក មិនត្រេកអរ ចង់ឃ្លាតចេញចាកសមណភាព ផុំទុក ធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពគ្រហស្ថ ។ បេ ។ ប្រាថ្នាភាពជាអសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា មាតារបស់ខ្ញុំមាន មាតានោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បិតារបស់ខ្ញុំមាន បិតានោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនប្រុសរបស់ខ្ញុំមាន បងប្អូនប្រុសនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនស្រីរបស់ខ្ញុំមាន បងប្អូនស្រីនោះនឹងចិញ្ចឹមខ្ញុំ ។

បុត្តា មេ អត្ថិ សោ មំ បោសេស្សតីតិ ឥតិ វិញ្ញាបេតិ ។ ធីតា មេ អត្ថិ សា មំ បោសេស្សតីតិ ឥតិ វិញ្ញាបេតិ ។ ភរិយា មេ អត្ថិ សា មំ បោសេស្សតីតិ ឥតិ វិញ្ញាបេតិ ។ ញាតកា មេ អត្ថិ តេ មំ បោសេស្សន្តីតិ ឥតិ វិញ្ញាបេតិ ។ មិត្តា មេ អត្ថិ តេ មំ បោសេស្សន្តីតិ ឥតិ វិញ្ញាបេតិ ។ គាវោ មេ អត្ថិ តេនាហំ(១) ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ ឯឡកា មេ អត្ថិ តេនាហំ ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ ខេត្តំ មេ អត្ថិ តេនាហំ ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ វត្ថុ មេ អត្ថិ តេនាហំ ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ ហិរញ្ញំ មេ អត្ថិ តេនាហំ ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ សុវណ្ណំ មេ អត្ថិ តេនាហំ ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ សិប្បំ មេ អត្ថិ តេនាហំ ជីវិស្សាមីតិ ឥតិ វិញ្ញាបេតិ ។ ឃរំបិ កិត្តយេ ធុតុល្យាភិគាមន្តេ្យ ហោតិ

---

១ ឆេន ឧបន្ថំ បាឋោ ។



និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនប្រុសរបស់ខ្ញុំមាន កូនប្រុសនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនស្រីរបស់ខ្ញុំមាន កូនស្រីនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រពន្ធរបស់ខ្ញុំមាន ប្រពន្ធនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកញាតិរបស់ខ្ញុំមាន ញាតិទាំងនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកមិត្តរបស់ខ្ញុំមាន មិត្តទាំងនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា គោរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយគោនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ចៀមរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយចៀមនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ស្រែរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយស្រែនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ចំការរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយចំការនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រាក់របស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយប្រាក់នោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា មាសរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយមាសនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា សិល្បសាស្ត្ររបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយសិល្បសាស្ត្រនោះក៏បាន ។ ម្នាលកុមារតូចអើយ យ៉ាងនេះហៅថា គឺយោគ្រាន់តែធ្វើឲ្យច្បាស់នូវការៈជាអ្នកមានទ្រព្យទ័យ

សិក្ខា ច អបច្ចក្ខាតា ។ អថវា បន ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដិយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អស្សក្យបុត្តិយភាវំ បត្ថយមានោ ទុក្ករន្តិ វទតិ វិញ្ញាបេតិ ។ ន សុករន្តិ វទតិ វិញ្ញាបេតិ ។ ទុច្ចរន្តិ វទតិ វិញ្ញាបេតិ ។ ន សុចរន្តិ វទតិ វិញ្ញាបេតិ ។ ន ឧស្សហាមីតិ វទតិ វិញ្ញាបេតិ ។ ន វិសហាមីតិ វទតិ វិញ្ញាបេតិ ។ ន រមាមីតិ វទតិ វិញ្ញាបេតិ ។ នាភិរមាមីតិ វទតិ វិញ្ញាបេតិ ។ ឯវម្បិ ខោ ភិក្ខវេ ទុព្ពល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច អបច្ចក្ខាតា ។

(៣១) កថញ្ច ភិក្ខវេ ទុព្ពល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច បច្ចក្ខាតា ។



ប៉ុន្តែសិក្ខាមិនទាន់ហៅថា ភិក្ខុបានលាលាហើយ ។ ម្យ៉ាងទៀត ភិក្ខុអផ្សុក មិនត្រេកអរ ចង់ចេញចាកភាពជាសមណៈ ធុញទ្រាន់នឹងភាពជាភិក្ខុ ខ្មាស់ ខ្ពើមរអើមភិក្ខុភាព ប្រាថ្នានូវភាពជាគ្រហស្ថ ។ បេ ។ ប្រាថ្នាភាពមិនមែនជាសក្យបុត្រ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) កម្របុគ្គលនឹងធ្វើបាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) បុគ្គលមិនមែនងាយនឹងធ្វើបានទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) បុគ្គលប្រព្រឹត្តបានដោយកម្រ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) បុគ្គលមិនមែនប្រព្រឹត្តបានដោយងាយទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនអាច (នៅក្នុងភេទបព្វជិតបាន) ទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនហ៊ាន (នៅក្នុងភេទបព្វជិត) ទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនត្រេកអរ (នឹងភេទបព្វជិត) ទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនពេញចិត្ត (នឹងភេទបព្វជិត) ទេ ។ ភាពភិក្ខុទន់ខ្សោយ យ៉ាងនេះហៅថា ការធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខាមិនទាន់ហៅថាភិក្ខុបានលាលាហើយ ។

(៣១) ភាពភិក្ខុទន់ខ្សោយ ការដែលភិក្ខុធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកំឡាំងថយ ទាំងសិក្ខាក៏ហៅថាភិក្ខុបានលាលា

ឥធ ភិក្ខវេ ភិក្ខុ ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដីយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ ពុទ្ធំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ ឯវំបិ ភិក្ខវេ ទុព្វល្យាវិកម្មញ្ចេវ ហោតិ សិក្ខា ច បច្ចក្ខាតា ។ អថវា បន ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ អដ្ដីយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ ធម្មំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ សង្ឃំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ សិក្ខំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ វិនយំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ បាតិមោក្ខំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ ឧទ្ទេសំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ ឧបជ្ឈាយំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ អាចរិយំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ សទ្ធិវិហារិកំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។



ដោះអស់ប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អផ្សុក មិនត្រេកអរ ចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ដិនឆ្អន់ ខ្ពើមរអើមនឹងភាពជាភិក្ខុ ប្រាថ្នានូវភាពជាគ្រហស្ថ ។ បេ ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ គឺនិយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ទើបហៅថា ការធ្វើឲ្យជាក់ច្បាស់នូវភាពនៃខ្លួនជាបុគ្គលមានចិត្តទន់ខ្សោយផង ទាំងសិក្ខាក៏ឈ្មោះថាភិក្ខុបានពោលលា ។ មួយទៀត ភិក្ខុអផ្សុក មិនត្រេកអរ ប្រាថ្នាចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ដិនឆ្អន់ ខ្ពើមរអើមនឹងភាពជាភិក្ខុ ពេញចិត្តនឹងភាពជាគ្រហស្ថ ។ បេ ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ គឺនិយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះធម៌ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះសង្ឃ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់សិក្ខា ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់វិន័យ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បាតិមោក្ខ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់នូវឧទ្ទេស ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ឧបជ្ឈាយ៍ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់អាចារ្យ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់សទ្ធិវិហារិក ។

អន្តេវាសិកំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ សមានុ-
បជ្ឈាយកំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ សមា-
នាចរិយកំ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។
សព្រហ្មចារឹ បច្ចក្ខាមីតិ វទតិ វិញ្ញាបេតិ ។ បេ ។
គិហីតិ មំ ធារេហីតិ វទតិ វិញ្ញាបេតិ ។ ឧបាសកោតិ
មំ ធារេហីតិ វទតិ វិញ្ញាបេតិ ។ អារាមិកោតិ មំ
ធារេហីតិ វទតិ វិញ្ញាបេតិ ។ សាមណេរោតិ មំ
ធារេហីតិ វទតិ វិញ្ញាបេតិ ។ តិត្ថិយោតិ មំ ធារេ-
ហីតិ វទតិ វិញ្ញាបេតិ ។ តិត្ថិយសាវកោតិ មំ
ធារេហីតិ វទតិ វិញ្ញាបេតិ ។ អស្សមណោតិ មំ
ធារេហីតិ វទតិ វិញ្ញាបេតិ ។ អសក្យបុត្តិយោតិ មំ
ធារេហីតិ វទតិ វិញ្ញាបេតិ ។ ឯវំ ភិក្ខវេ ទុព្វល្យាវិ-
កម្មញ្ចេវ ហោតិ សិក្ខា ច បច្ចក្ខាតា ។ អថវា បន
ឧក្កណ្ឋិតោ អនភិរតោ សាមញ្ញា ចវិតុកាមោ ភិក្ខុភាវំ
អដ្ដិយមានោ ហរាយមានោ ជិគុច្ឆមានោ គិហិភាវំ
បត្ថយមានោ ។ បេ ។ អសក្យបុត្តិយភាវំ បត្ថយមានោ





(៨៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឯវំ មេ អនាបត្តិ ភវិស្សតីតិ កុសចីរំ និវាសេត្វា ។ បេ ។ វាកចីរំ និវាសេត្វា ផលកចីរំ និវាសេត្វា កេសកម្ពលំ និវាសេត្វា វាលកម្ពលំ និវាសេត្វា ឧលូកបក្ខំ និវាសេត្វា អជិនក្ខិបំ និវាសេត្វា មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(៨៤) តេន ខោ បន សមយេន អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ បីឋកេ និបន្នំ ទារិកំ បស្សិត្វា សារត្តោ អង្គុដ្ឋំ អង្គជាតំ បវេសេសិ ។ សា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សង្ឃាទិសេសស្សាតិ ។





ត្រូវអាបត្តិឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(៨៣) សម័យនោះឯង ភិក្ខុ១រូប ស្ទៀកស្បូវក្រង ។បេ។ ស្ទៀកសំពត់សំបកឈើ ស្ទៀកសំពត់ដែលគេត្បាញដោយបន្ទះឈើ ស្ទៀកសំពត់ដែលគេត្បាញដោយសក់ ស្ទៀកសំពត់ដែលគេត្បាញដោយរោមកន្ទុយសេះ ស្ទៀកសំពត់ដែលគេត្បាញដោយស្លាបមៀម ស្ទៀកស្បែកខ្លាដែលនៅមានទាំងក្រចកទាំងក្រចក ហើយសេពមេថុនធម្ម ដោយគិតថា ការធ្វើយ៉ាងនេះ អាត្មាអញមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(៨៤) សម័យនោះឯង ភិក្ខុ១រូបជាអ្នកប្រព្រឹត្តបិណ្ឌបាត ។ បានឃើញនាងកុមារិកាម្នាក់ដេកនៅលើតាំង ក៏មានចិត្តត្រេកអរ ហើយយកមេដៃ (ខ្លួន) ទៅស៊កបញ្ចូលចំអង្គជាតនាងកុមារិកានោះ ។ នាងក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ តែត្រូវអាបត្តិសង្ឃាទិសេស ។

[៨៤] តេន ខោ បន សមយេន អញ្ញតរោ មាណវកោ ឧប្បលវណ្ណាយ ភិក្ខុនិយា បដិពទ្ធចិត្តោ ហោតិ ។ អថខោ សោ មាណវកោ ឧប្បលវណ្ណាយ ភិក្ខុនិយា គាមំ បិណ្ឌាយ បវិដ្ឋាយ កុដឹ បវិសិត្វា និលីនោ អច្ឆិ ។ ឧប្បលវណ្ណា ភិក្ខុនី បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា បាទេ បក្ខាលេត្វា កុដឹ បវិសិត្វា មញ្ចកេ និសីទិ ។ អថខោ សោ មាណវកោ ឧប្បលវណ្ណំ ភិក្ខុនឹ ឧគ្គហេត្វា ទូសេសិ ។ ឧប្បលវណ្ណា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ អសាទិយន្តិយាតិ ។

[៨៥] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ឥត្ថិលិង្គំ បាតុភូតំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តំយេវ ឧបជ្ឈំ តមេវ ឧបសម្បទំ តានិ វស្សានិ ភិក្ខុនីហិ សង្កមិតុំ



[៨៤] សម័យនោះឯង មាណពម្នាក់មានសេចក្តីប្រតិពទ្ធចិត្ត ចំពោះឧប្បលវណ្ណាភិក្ខុនី ។ កាលដែលឧប្បលវណ្ណាភិក្ខុនីចូលទៅបិណ្ឌបាត ក្នុងស្រុក មាណពនោះក៏ចូលទៅពួននៅក្នុងកុដិអង្គុយ ។ លុះឧប្បលវណ្ណាភិក្ខុនីត្រឡប់មកពីបិណ្ឌបាតវិញ ឆាន់ហើយ ក៏លាងជើង ហើយចូលទៅកាន់កុដិ អង្គុយលើគ្រែ ។ ខណៈនោះ មាណពនោះ ក៏ស្ទាបចាប់ឧប្បលវណ្ណាភិក្ខុនី ហើយប្រទូស្ត ។ ឧប្បលវណ្ណាភិក្ខុនីក៏ប្រាប់សេចក្តីនុះដល់ពួកភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយក៏ប្រាប់សេចក្តីនុះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏នាំសេចក្តីនុះទៅក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧប្បលវណ្ណាមិនត្រូវអាបត្តិទេ ព្រោះមិនបានពេញចិត្តត្រេកត្រអាលឡើយ ។

[៨៥] សម័យនោះឯង ភិក្ខុ ១ រូប ក្លាយភេទខ្លួនប្រែទៅជាស្រី ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យឧបជ្ឈាយ៍នោះដដែល និងឧបសម្បទានោះដដែល និងវស្សាទាំងនោះ...(១)

---

១ ក៏ទ្រង់អនុញ្ញាតមិនបាច់ឲ្យឧបសម្បទាថ្មី ឲ្យបព្វជ្ជាជាថ្មីទៀត វស្សាក៏រាប់ជាបន្ត រាប់ជាស្ត្រីហើយត្រូវនៅជាមួយនឹងភិក្ខុនីទាំងឡាយ ។

យា អាបត្តិយោ ភិក្ខូនំ ភិក្ខុនីហិ សាធារណា តា អាបត្តិយោ ភិក្ខុនីនំ សន្តិកេ វុដ្ឋាតុំ យា អាបត្តិយោ ភិក្ខូនំ ភិក្ខុនីហិ អសាធារណា តាហិ អាបត្តីហិ អនាបត្តីតិ ។ តេន ខោ បន សមយេន អញ្ញតរិស្សា ភិក្ខុនិយា បុរិសលិង្គំ បាតុភូតំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តំយេវ ឧបជ្ឈំ តំយេវ ឧបសម្បទំ តានិ វស្សានិ ភិក្ខូហិ សង្កមិតុំ យា អាបត្តិយោ ភិក្ខុនីនំ ភិក្ខូហិ សាធារណា តា អាបត្តិយោ ភិក្ខូនំ សន្តិកេ វុដ្ឋាតុំ យា អាបត្តិយោ ភិក្ខុនីនំ ភិក្ខូហិ អសាធារណា តាហិ អាបត្តីហិ អនាបត្តីតិ ។

(៨៧) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឃាំ មេ អនាបត្តិ ករិស្សតីតិ មាតុយា មេថុនំ ធម្មំ បដិសេវិ ។បេ។ ធីតុយា មេថុនំ ធម្មំ បដិសេវិ ។បេ។



នឹងអនុញ្ញាតឲ្យនៅរួមជាមួយនឹងភិក្ខុនីទាំងឡាយ (ដូចនឹងទៀត) អាបត្តិណាជារបស់ភិក្ខុដែលទូទៅដល់ភិក្ខុនីទាំងឡាយ តថាគតអនុញ្ញាតឲ្យចេញអាបត្តិនោះ ដើម្បីឲ្យភិក្ខុដែលក្លាយភេទជាស្រីនោះនៅក្នុងសំណាក់ភិក្ខុនីទាំងឡាយបាន អាបត្តិណាជារបស់ភិក្ខុដែលមិនទូទៅដល់ភិក្ខុនីទាំងឡាយ ភិក្ខុនោះមិនត្រូវអាបត្តិព្រោះអាបត្តិនោះឡើយ ។ សម័យនោះឯង ភិក្ខុនី ១ រូប ក្លាយភេទខ្លួនទៅជាប្រុស ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍នោះឯងដែល ឧបសម្បទានោះឯងដែល ចំនួនវស្សាទាំងនោះ នឹងអនុញ្ញាតឲ្យនៅរួមជាមួយនឹងភិក្ខុទាំងឡាយ អាបត្តិណាជារបស់ភិក្ខុនីដែលទូទៅដល់ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចេញអាបត្តិទាំងនោះ ដើម្បីឲ្យភិក្ខុនីដែលក្លាយភេទខ្លួនជាប្រុសនោះនៅក្នុងសំណាក់ភិក្ខុទាំងឡាយបាន អាបត្តិណាជារបស់ភិក្ខុនីដែលមិនទូទៅដល់ភិក្ខុទាំងឡាយទេ (ភិក្ខុនេះ) មិនមានអាបត្តិព្រោះអាបត្តិទាំងនោះឡើយ ។

(៨៧) សម័យនោះឯង ភិក្ខុ ១ រូប សេពមេថុនធម្មនឹងមាតា (របស់ខ្លួន) ដោយយល់ថា ការលើកធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។បេ។ សេពមេថុនធម្មនឹងធីតា (របស់ខ្លួន) ។បេ។

ភគិនិយា មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[៥៨] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មុទុបិដ្ឋិកោ ហោតិ ។ សោ អនភិរតិយា បីឡិតោ អត្តនោ អង្គជាតំ មុខេន អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ លម្ពី ហោតិ ។ សោ អនភិរតិយា បីឡិតោ អត្តនោ អង្គជាតំ អត្តនោ វច្ចមគ្គំ បវេសេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។



សេពមេថុនធម្មនឹងប្អូនស្រី (របស់ខ្លួន) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប សេពមេថុនធម្មនឹងស្រីដែលមាតាបិតាផ្សំផ្គុំឲ្យអំពីមុន ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(៥៨) សម័យនោះឯង ភិក្ខុ ១ រូប មានខ្នងទន់ ។ ភិក្ខុនោះមានសេចក្តីអផ្សុកតប្បៀតប្បៀន ហើយបានយកអង្គជាតខ្លួនមកបៀមនឹងមាត់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប មានអង្គជាតយារវែង ។ ភិក្ខុនោះមានសេចក្តីអផ្សុកតប្បៀតប្បៀន ក៏បានបញ្ចូលអង្គជាតខ្លួនបញ្ចូលទៅក្នុងវច្ចមគ្គ (គឺគូថ) របស់ខ្លួន ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(៤៩) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មតសរីរំ បស្សិ ។ តស្មឹ ច សរីរេ អង្គជាតសាមន្តា វណោ ហោតិ ។ សោ ឯវំ មេ អនាបត្តិ ភវិស្សតីតិ អង្គជាតេ អង្គជាតំ បវេសេត្វា វណេន នីហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មតសរីរំ បស្សិ ។ តស្មឹ ច សរីរេ អង្គជាតសាមន្តា វណោ ហោតិ ។ សោ ឯវំ មេ អនាបត្តិ ភវិស្សតីតិ វណេ អង្គជាតំ បវេសេត្វា អង្គជាតេន នីហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(៥០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សារត្តោ លេបចិត្តស្ស និមិត្តំ អង្គជាតេន ឆុបិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សារត្តោ ទារុធីតលិកាយ និមិត្តំ អង្គជាតេន ឆុបិ ។



(៤៩) សម័យនោះឯង ភិក្ខុ ១ រូប ឃើញសរីរមនុស្សស្លាប់ ។ ឯសរីរនោះ មានដំបៅជិតអង្គជាត ។ ភិក្ខុនោះចុះបញ្ចូលអង្គជាត (ខ្លួន) ទៅក្នុងអង្គជាត (សរីរនោះ) ហើយបន្ទយអង្គជាតចេញមកវិញតាមដំបៅ ដោយគិតថា កាលបើអាត្មាអញធ្វើយ៉ាងនេះ អាត្មាអញនឹងមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប ឃើញសរីរមនុស្សស្លាប់ ។ ឯសរីរនោះមានដំបៅជិតអង្គជាត ។ ភិក្ខុនោះចុះបញ្ចូលអង្គជាត (ខ្លួន) ទៅក្នុងដំបៅ ហើយបន្ទយចេញមកវិញតាមអង្គជាត ដោយគិតថា កាលបើអាត្មាអញធ្វើយ៉ាងនេះ អាត្មាអញនឹងមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(៥០) សម័យនោះឯង ភិក្ខុ ១ រូប មានតម្រេក ហើយយកអង្គជាត (ខ្លួន) ទៅពាល់និមិត្តរបស់រូបគំនូរ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ តែត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុ ១ រូប មានតម្រេក ហើយយកអង្គជាត (ខ្លួន) ទៅពាល់និមិត្តរបស់រូបតុក្កតាដែលធ្វើដោយឈើ ។

តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។

(៦១) តេន ខោ បន សមយេន សុន្ទរោ នាម ភិក្ខុ រាជគហា បព្វជិតោ រថិកាយ គច្ឆតិ ។ អញ្ញតរា ឥត្ថី តំ បស្សិត្វា ឯតទវោច[១] មុហុត្តំ ភន្តេ អាគមេហិ វន្ទិស្សាមីតិ ។ សា វន្ទន្តី អន្តរវាសកំ ឧក្ខិបិត្វា មុខេន អង្គជាតំ អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ សាទិយិ ត្វំ ភិក្ខូតិ ។ នាហំ ភគវា សាទិយិន្តិ ។ អនាបត្តិ ភិក្ខុ អសាទិយន្តស្សាតិ ។

(៦២) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ អហំ វាយមិស្សាមិ ត្វំ មា វាយមិ ឯវន្តេ អនាបត្តិ ភវិស្សតីតិ ។ សោ ភិក្ខុ តថា អកាសិ ។

១ តំ បស្សិត្វា ឯតទវោចាតិ ឥមេ បាឋា មរម្មបោត្ថកេសុ ន ទិស្សន្តិ ។



ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិទុក្កដ ។

(៦១) សម័យនោះឯង ភិក្ខុ១ រូបឈ្មោះសុន្ទរៈ ចេញពីក្រុងរាជគ្រឹះទៅបួស ហើយដើរទៅតាមថ្នល់ ។ មានស្រីម្នាក់បានឃើញភិក្ខុនោះ ហើយក៏និយាយថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់១រំពេចសិន ខ្ញុំព្រះករុណានឹងថ្វាយបង្គំ ។ ស្រីនោះកាលដែលថ្វាយបង្គំ ក៏សើយស្បង់ឡើង ហើយយកមាត់ទៅបៀមអង្គជាត (របស់ភិក្ខុនោះ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬទេ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិទេ ព្រោះមិនត្រេកអរ ។

(៦២) សម័យនោះឯង មានស្រីម្នាក់ បានឃើញភិក្ខុ១រូបហើយ និយាយថា បពិត្រលោកម្ចាស់ សូមនិមន្តលោកម្ចាស់មកសេពមេថុនឯនេះ ។ ភិក្ខុនោះនិយាយថា កុំនាង ការសេពមេថុនធម្មនេះមិនគួរទេ ។ ស្រីនោះតទៅថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តមក (កុំប្រកែក) ខ្ញុំព្រះករុណានឹងព្យាយាម លោកម្ចាស់មិនបាច់ព្យាយាមទេ (នៅតែស្ងៀមបានហើយ) សេពយ៉ាងនេះ លោកម្ចាស់មិនត្រូវអាបត្តិទេ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យស្រីនោះ ។

តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ ត្វំ វាយមាហិ អហំ ន វាយមិស្សាមិ ឯវន្តេ អនាបត្តិ ភវិស្សតីតិ ។ សោ ភិក្ខុ តថា អកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ អព្ភន្តរំ ឃដ្ដេហិ ពហិ មោចេហិ ។ បេ ។ ពហិ ឃដ្ដេហិ អព្ភន្តរំ មោចេហិ ឯវន្តេ អនាបត្តិ ភវិស្សតីតិ ។



ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីម្នាក់មាននាមមិនប្រាកដ បានឃើញភិក្ខុ ១ រូប ហើយនិយាយថា បពិត្រលោកម្ចាស់ សូមនិមន្តលោកមកសេពមេថុនធម្ម (នឹងខ្ញុំសិន) ។ ភិក្ខុនោះឆ្លើយថា កុំនាង អំពើនេះមិនគួរទេ ។ ស្រីនោះក៏និយាយតទៀតថា បពិត្រលោកម្ចាស់ សូមនិមន្តមក សូមលោកម្ចាស់ព្យាយាមចុះ ខ្ញុំព្រះករុណាមិនព្យាយាមទេ ធ្វើយ៉ាងនេះ លោកម្ចាស់មិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យស្រីនោះទៅ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីម្នាក់ លុះឃើញភិក្ខុ ១ រូប ក៏និយាយបបួលថា បពិត្រលោកម្ចាស់ សូមនិមន្តមកសេពមេថុនធម្ម (នឹងខ្ញុំព្រះករុណានេះ) ។ ភិក្ខុនោះឆ្លើយថា កុំប្អូនស្រី អំពើនេះមិនគួរទេ ។ ស្រីនោះក៏តបវិញថា បពិត្រលោកម្ចាស់ សូមលោកនិមន្តមកព្យាយាមក្នុងអង្គជាតខ្ញុំ រួចបញ្ចេញអសុចិទៅខាងក្រៅអង្គជាតវិញ ។ បេ ។ ព្យាយាមខាងក្រៅអង្គជាត ហើយបញ្ចេញអសុចិទៅខាងក្នុងអង្គជាតវិញ ធ្វើយ៉ាងនេះ

សោ ភិក្ខុ តថា អកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[៦៣] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សីវថិកំ គន្ត្វា អក្ខាយិតំ(១) សរីរំ បស្សិត្វា តស្មឹ មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សីវថិកំ គន្ត្វា យេភុយ្យេន អក្ខាយិតំ សរីរំ បស្សិត្វា តស្មឹ មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សីវថិកំ គន្ត្វា យេភុយ្យេន ខាយិតំ(២) សរីរំ បស្សិត្វា តស្មឹ មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សីវថិកំ គន្ត្វា ឆិន្នសីសំ បស្សិត្វា

១ ម. ឧ. អក្ខយិតំ ។ ២ ម. ឧ. ខយិតំ ។



លោកម្ចាស់មិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះក៏ធ្វើតាមពាក្យស្រីនោះទៅ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[៦៣] សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ព្រៃខ្មោច ឃើញសរីរខ្មោចដែលសត្វមិនទាន់ស៊ី ហើយសេពមេថុនធម្មនឹងសរីរខ្មោចនោះ ៗ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ១រូបចូលទៅកាន់ព្រៃខ្មោច ឃើញសរីរខ្មោចដែលសត្វមិនទាន់ស៊ីច្រើនអន្លើប៉ុន្មាន ហើយសេពមេថុនធម្មនឹងសរីរខ្មោចនោះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ១រូបចូលទៅកាន់ព្រៃខ្មោច ឃើញសរីរខ្មោចដែលសត្វស៊ីច្រើនអន្លើ ហើយសេពមេថុនធម្មនឹងសរីរខ្មោចនោះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ព្រៃខ្មោច ឃើញក្បាលខ្មោចដាច់

វដ្ដកតេ(១) មុខេ ឆុបន្តំ អង្គជាតំ បវេសេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សីវថិកំ គន្ត្វា ឆិន្នសីសំ បស្សិត្វា វដ្ដកតេ មុខេ អច្ឆុបន្តំ អង្គជាតំ បវេសេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញតរិស្សា ឥត្ថិយា បដិពទ្ធចិត្តោ ហោតិ ។ សា កាលកតា(២) សុសានេ ឆឌ្ឌិតា(៣) ។ អដ្ឋិកានិ វិប្បកិណ្ណានិ ហោន្តិ ។ អថខោ សោ ភិក្ខុ សីវថិកំ គន្ត្វា អដ្ឋិកានិ សង្កឌ្ឍិត្វា និមិត្តេ អង្គជាតំ បដិបាទេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។

១ ឱ. ម, វដ្ឋកតេ ។ ២ ឱ. ម. ក, កាលង្កតា ។ ៣ ឱ. ម. ឆឌ្ឌិតំ ។



កំប្រើកអង្គជាត (ទ្វារ) ឲ្យចូលទៅក្នុងមាត់ដែលបើកហា ឲ្យប៉ះទន្តឹង (ក្នុងមាត់នោះ) ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូបចូលទៅកាន់ព្រៃខ្មោច ឃើញក្បាលខ្មោចដាច់ហើយបញ្ចូលអង្គជាត (ទ្វារ) ទៅក្នុងមាត់ខ្មោចដែលបើកហា មិនឲ្យប៉ះទន្តឹង (ក្នុងមាត់នោះ) ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូបមានចិត្តប្រតិព័ទ្ធស្រឡាញ់ស្រីម្នាក់ ។ ស្រីនោះធ្វើកាលកិរិយាទៅហើយ គេខ្មោចយកទៅចោលក្នុងព្រៃស្មសាន(១) ។ ឆ្អឹងទាំងឡាយ (នៃខ្មោចស្រីនោះ) ក៏ខ្ចាត់ខ្ចាយពាសពាយ ។ គ្រានោះ ភិក្ខុនោះទៅកាន់ព្រៃខ្មោច ហើយប្រមូលឆ្អឹងទាំងឡាយយកមកដំរៀប ហើយបញ្ចូលអង្គជាត (ទ្វារ) ទៅក្នុងនិមិត្ត (នៃឆ្អឹងនោះ) ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

១ ស្មសាន គឺព្រៃសម្រាប់ចោលខ្មោច ជាពាក្យសំស្ក្រឹតម្យ៉ាងថា ស្មៈសានៈ ដែលមាន ក្លាយមកជា សំសាន ។ ពាក្យបាលីថា សុសាន ។

[៦៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ នាគិយា មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ យក្ខិនិយា មេថុនំ ធម្មំ បដិសេវិ ។ បេ ។ បេតិយា មេថុនំ ធម្មំ បដិសេវិ ។ បេ ។ បណ្ឌកស្ស មេថុនំ ធម្មំ បដិសេវិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[៦៧] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឧបហតិន្ទ្រិយោ ហោតិ ។ សោ នាហំ វេទិយាមិ សុខំ វា ទុក្ខំ វា អនាបត្តិ[១] មេ ភវិស្សតីតិ មេថុនំ ធម្មំ បដិសេវិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ វេទិយិ វា សោ ភិក្ខវេ មោឃបុរិសោ ន វា វេទិយិ អាបត្តិ បារាជិកស្សាតិ ។

១ ម. ឆ. សី. អនាបត្តិ ។



[៦៦] សម័យនោះឯង មានភិក្ខុ ១ រូប សេពមេថុនធម្មនឹងនាគី (នាគញី) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះ មានភិក្ខុ ១ រូបសេពមេថុនធម្មនឹងយក្ខិនី ។ បេ ។ សេពមេថុនធម្មនឹងស្រីប្រេត ។ បេ ។ សេពមេថុនធម្មនឹងមនុស្សខ្ទើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[៦៧] សម័យនោះ មានភិក្ខុ ១ រូប មានឥន្ទ្រិយសាបសូន្យ (គឺមានកាយស្ពឹក) ។ ភិក្ខុនោះក៏សេពមេថុនធម្មដោយគិតថា អាត្មាមិនដឹងសេចក្តីសុខទុក្ខ អាបត្តិនឹងមិនមានដល់អាត្មាឡើយ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរសសោះសូន្យនោះ ទោះបីដឹង (សេចក្តីសុខទុក្ខ) ក្តី មិនដឹងក្តី ក៏ត្រូវអាបត្តិបារាជិកហើយ ។

[៦៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ឥត្ថិយា មេថុនំ ធម្មំ បដិសេវិស្សាមីតិ ឆុបិតមត្តេ វិប្បដិសារី អហោសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។

[៦៧] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភទ្ទិយេ(១) ជាតិយាវនេ ទិវាវិហារគតោ និបន្នោ ហោតិ ។ តស្ស អង្គមង្គានិ វាតុបត្ថទ្ធានិ ហោន្តិ ។ អញ្ញតរា ឥត្ថី បស្សិត្វា អង្គជាតេ អភិនិសីទិត្វា យាវទត្ថំ កត្វា បក្កាមិ ។ ភិក្ខូ កិលិន្នំ បស្សិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ(២) ។ បញ្ចហិ ភិក្ខវេ អាការេហិ អង្គជាតំ កម្មនិយំ(៣) ហោតិ រាគេន វច្ចេន បស្សាវេន វាតេន ឧច្ចាលិង្គបាណកទដ្ឋេន ឥមេហិ ខោ ភិក្ខវេ បញ្ចហាការេហិ អង្គជាតំ កម្មនិយំ ហោតិ

១ ម. ភទ្ទិយនគរេ ។ ២ អយំ [illegible] ។ ៣ ម. កម្មណិយំ ។



[៦៦] សម័យនោះឯង មានភិក្ខុ ១ រូប គិតថាអញនឹងសេពមេថុនធម្មនឹងស្រី ត្រាន់តែយកដៃទៅពាល់ក៏មានសេចក្តីក្តៅក្រហាយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិទុក្កដ ។

[៦៧] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃជាតិយាវ័នក្បែរភទ្ទិយ ហើយសឹងលក់ទៅ ។ អវយវៈតូចធំរបស់ភិក្ខុនោះ មានខ្យល់ចាក់មកកប្តួម (ធ្វើឲ្យលោតនោះរឹងលក់ស៊ប់) ។ មានស្រីម្នាក់ឃើញ ហើយក៏អង្គុយសង្កត់លើអង្គជាត (សេពមេថុន) ស្រេចហើយក៏ចៀសចេញទៅ ។ ភិក្ខុនោះ (ភ្ញាក់ឡើង) ឃើញសេចក្តីសៅហ្មង ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អង្គជាតរមែងរឹងឡើងដោយអាការ ៥ យ៉ាង គឺ ដោយតម្រេក ១ ដោយលាមក ១ ដោយទឹកមូត្រ ១ ដោយខ្យល់ ១ ដោយសត្វរោមសំរោល ១ ម្នាលភិក្ខុទាំងឡាយ អង្គជាតរមែងរឹងឡើងដោយអាការ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ

អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ តស្ស ភិក្ខុនោ រាគេន អង្គជាតំ កម្មនិយំ អស្ស អរហំ សោ ភិក្ខវេ ភិក្ខុ អនាបត្តិ ភិក្ខវេ តស្ស ភិក្ខុនោតិ ។

(៦៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ អន្ធវនេ ទិវាវិហារគតោ និបន្នោ ហោតិ ។ អញ្ញតរា គោបាលិកា បស្សិត្វា អង្គជាតេ អភិនិសីទិ ។ សោ ភិក្ខុ បវេសនំ សាទិយិ បវិដ្ឋំ សាទិយិ ឋិតំ សាទិយិ ឧទ្ធរណំ សាទិយិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ អន្ធវនេ ទិវាវិហារគតោ និបន្នោ ហោតិ ។ អញ្ញតរា អជបាលិកា បស្សិត្វា ។ បេ ។ អញ្ញតរា កដ្ឋហារិកា បស្សិត្វា ។ បេ ។ អញ្ញតរា គោមយហារិកា បស្សិត្វា អង្គជាតេ អភិនិសីទិ ។ សោ ភិក្ខុ បវេសនំ សាទិយិ បវិដ្ឋំ សាទិយិ



អង្គជាតគួរដល់កម្ម ព្រោះតម្រេករបស់ភិក្ខុនោះ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ជាអរហន្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ឥតមានត្រូវអាបត្តិឡើយ ។

(៦៨) សម័យនោះឯង មានភិក្ខុ ១ រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃអន្ធវន ទៀបនគរសាវត្ថី ហើយសឹងលក់ទៅ ។ មានស្រីគង្វាលគោម្នាក់ឃើញ ហើយទៅអង្គុយសង្កត់លើអង្គជាតភិក្ខុនោះ ។ ភិក្ខុនោះកាលអង្គជាតកំពុងចូលទៅក៏ត្រេកអរ ចូលស៊ប់ទៅហើយក៏ត្រេកអរ ស្ថិតនៅក្នុងទីក៏ត្រេកអរ បន្ថយចេញមកវិញក៏ត្រេកអរ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃអន្ធវន ទៀបនគរសាវត្ថី ហើយសឹងលក់ទៅ ។ មានស្រីគង្វាលពពែម្នាក់បានឃើញភិក្ខុនោះ ។ បេ ។ មានស្រីអ្នករកឧសម្នាក់បានឃើញភិក្ខុនោះ ។ បេ ។ មានស្រីអ្នករកអាចម៍គោម្នាក់បានឃើញភិក្ខុនោះ ក៏ទៅអង្គុយសង្កត់លើអង្គជាត ។ ភិក្ខុនោះ កាលដែលអង្គជាតកំពុងចូលទៅ ត្រេកអរ ចូលស៊ប់ទៅហើយ ត្រេកអរ

ឋិតំ សាទិយិ ឧទ្ធរណំ សាទិយិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[២៥] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វេសាលិយំ មហាវនេ ទិវាវិហារគតោ និបន្នោ ហោតិ ។ អញ្ញតរា ឥត្ថី បស្សិត្វា អង្គជាតេ អភិនិសីទិត្វា យាវទត្ថំ កត្វា សាមន្តា ហសមានា ឋិតា ហោតិ ។ សោ ភិក្ខុ បដិពុជ្ឈិត្វា តំ ឥត្ថឹ ឯតទវោច តុយ្ហិទំ កម្មន្តិ ។ អាម មយ្ហិទំ(១) កម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ ជានាសិ(២) ត្វំ ភិក្ខូតិ ។ នាហំ ភគវា ជានាមីតិ ។ អនាបត្តិ ភិក្ខុ អជានន្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វេសាលិយំ មហាវនេ ទិវាវិហារគតោ រុក្ខំ អបស្សាយ និបន្នោ ហោតិ ។ អញ្ញតរា ឥត្ថី បស្សិត្វា អង្គជាតេ អភិនិសីទិ ។ សោ ភិក្ខុ សហសា វុដ្ឋាសិ ។

១ ម. យ. [illegible] ។ ២ ឱ. ម. សាទិយិ ។



ស្ថិតនៅក៏ត្រេកអរ បន្ថយចេញមកវិញក៏ត្រេកអរ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(២៥) សម័យនោះឯង មានភិក្ខុ១រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃមហាវ័ន ទៀបនគរវេសាលី ហើយសឹងលក់ទៅ ។ មានស្រីម្នាក់ចូលមើលឃើញ ក៏ទៅអង្គុយសង្កត់លើអង្គជាត លុះធ្វើកិច្ចសម្រេចហើយ ក៏មកឈរសើចជិតភិក្ខុនោះ ។ ភិក្ខុនោះ ភ្ញាក់ឡើង ហើយនិយាយទៅនឹងស្រីនោះថា អំពើនេះជាអំពើរបស់នាងឬ ។ ស្រីនោះឆ្លើយថា ករុណាលោកម្ចាស់ អំពើនេះជាអំពើរបស់ខ្ញុំករុណា ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងដឹងដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងទេ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកាលបើមិនដឹង មិនមានអាបត្តិទេ ។ សម័យនោះ មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃមហាវ័ន ជិតនគរវេសាលី ហើយសឹងលក់ផ្អែកនឹងដើមឈើ១ ។ មានស្រីម្នាក់ចូលមើលឃើញក៏ទៅអង្គុយសង្កត់លើអង្គជាត ។ ភិក្ខុនោះក៏ក្រោកឡើងដោយរហ័ស ។

តស្ស កុក្កុច្ចំ អហោសិ ។បេ។ សាទិយិ ត្វំ ភិក្ខូតិ ។ នាហំ ភគវា សាទិយិន្តិ ។ អនាបត្តិ ភិក្ខុ អសាទិយន្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វេសាលិយំ មហាវនេ ទិវាវិហារគតោ រុក្ខមូលេ និបន្នោ ហោតិ ។ អញ្ញតរា ឥត្ថី បស្សិត្វា អង្គជាតេ អភិនិសីទិ ។ សោ ភិក្ខុ អក្កមិត្វា បវដ្ដេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ សាទិយិ ត្វំ ភិក្ខូតិ ។ នាហំ ភគវា សាទិយិន្តិ ។ អនាបត្តិ ភិក្ខុ អសាទិយន្តស្សាតិ ។

(៧០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វេសាលិយំ មហាវនេ កូដាគារសាលាយំ ទិវាវិហារគតោ ទ្វារំ វិវរិត្វា និបន្នោ ហោតិ ។ តស្ស អង្គមង្គានិ វាតុបត្ថទ្ធានិ ហោន្តិ ។ តេន ខោ បន សមយេន សម្ពហុលា ឥត្ថិយោ គន្ធញ្ច មាលញ្ច អាទាយ អារាមំ អគមំសុ វិហារបេក្ខិកាយោ ។ អថខោ តា ឥត្ថិយោ តំ ភិក្ខុំ បស្សិត្វា អង្គជាតេ អភិនិសីទិត្វា



ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកាលបើមិនត្រេកអរ មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃមហាវ័ន ជិតនគរវេសាលី ហើយសឹងលក់ផ្តេកនឹងដើមឈើ១ ។ មានស្រីម្នាក់ឃើញហើយ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត ។ ភិក្ខុនោះ ក៏ធាក់ច្រាន (ឲ្យស្រីនោះ) ធ្លាក់ចេញទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកត្រេកអរឬទេ ។ ភិក្ខុនោះក្រាបទូលវិញថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកកាលបើមិនត្រេកអរ មិនមានអាបត្តិទេ ។

[៧០] សម័យនោះ មានភិក្ខុ១រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ជិតនគរវេសាលី បើកទ្វារហើយ ចូលទៅសឹង ។ អវយវៈតូចធំរបស់ភិក្ខុនោះ មានខ្យល់បក់មកបញ្ឈរ (តាំងឡើងលក់ស៊ប់) ។ សម័យនោះ មានស្រីទាំងឡាយច្រើនគ្នាមានប្រាថ្នានឹងទៅមើលវិហារ ទើបកាន់យកគ្រឿងក្រអូបផង ផ្កាកម្រងផង ដើរទៅកាន់អារាម ។ គ្រានោះ ស្រីទាំងអស់នោះបានឃើញភិក្ខុនោះហើយក៏អង្គុយ

យាវទត្ថំ កត្វា បុរិសុសភោ វតាយន្តិ វត្វា គន្ធញ្ច មាលញ្ច អារោបេត្វា បក្កមឹសុ ។ ភិក្ខូ កិលិន្នំ បស្សិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ(១) ។ បញ្ចហិ ភិក្ខវេ អាការេហិ អង្គជាតំ កម្មនិយំ ហោតិ រាគេន វច្ចេន បស្សាវេន វាតេន ឧច្ចាលិង្គបាណកទដ្ឋេន ឥមេហិ ខោ ភិក្ខវេ បញ្ចហាការេហិ អង្គជាតំ កម្មនិយំ ហោតិ ។ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ តស្ស ភិក្ខុនោ រាគេន អង្គជាតំ កម្មនិយំ អស្ស អរហំ សោ ភិក្ខវេ ភិក្ខុ អនាបត្តិ ភិក្ខវេ តស្ស ភិក្ខុនោ ។ អនុជានាមិ ភិក្ខវេ ទិវា បដិសល្លីយន្តេន ទ្វារំ សំវរិត្វា បដិសល្លីយិតុន្តិ ។

(៧១) តេន ខោ បន សមយេន អញ្ញតរោ ភារុកច្ឆកោ ភិក្ខុ សុបិនន្តេន បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវិត្វា អស្សមណោហំ វិព្ភមិស្សាមីតិ ភារុកច្ឆំ គច្ឆន្តោ

១ [illegible]



សន្ទុះពីលើអង្គជាតភិក្ខុ (សេវនកិច្ច) ធ្វើបំណងហើយស្រេច ទើបនិយាយថា ប្រុសនេះ ជាបុរសឧសភៈ ដូច្នេះហើយ លើកឡើងនូវគ្រឿងក្រអូបនិងផ្កាកម្រងហើយក៏ចៀសចេញទៅ ។ ភិក្ខុនោះឃើញសេចក្តីសៅហ្មងក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្ម ដោយអាការ ៥ យ៉ាងគឺ ដោយតម្រេក ១ ដោយអាចម៍ ១ ដោយទឹកមូត្រ ១ ដោយខ្យល់ ១ ដោយសត្វល្អិតខាំ ១ ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្ម ដោយអាការ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្ម ព្រោះតម្រេករបស់ភិក្ខុនោះ មិនមែនជាហេតុជាទីតាំង មិនមែនជាឱកាសឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអរហន្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានអាបត្តិឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ កាលដែលសឹងសម្ងំនៅវេលាថ្ងៃ ត្រូវបិទទ្វារ ហើយសឹងសម្ងំចុះ ។

(៧១) សម័យនោះ មានភិក្ខុ ១ រូបជាកូនអ្នកស្រុកភារុកច្ឆៈ យល់សប្តិឃើញថា សេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ហើយនឹកថាខ្លួនអញមិនមែនជាសមណៈទេ អញនឹងសឹកទៅវិញ ដូច្នេះហើយដើរទៅកាន់

អន្តរាមគ្គេ អាយស្មន្តំ ឧបាលឹ បស្សិត្វា ឯតមត្ថំ អារោចេសិ ។ អាយស្មា ឧបាលិ ឯវមាហ អនាបត្តិ អាវុសោ សុបិនន្តេនាតិ ។

(៩៦) តេន ខោ បន សមយេន រាជគហេ សុបព្វា នាម ឧបាសិកា មុទ្ធប្បសន្នា[១] ហោតិ ។ សា ឯវំទិដ្ឋិកា ហោតិ យា មេថុនំ ធម្មំ ទេតិ សា អគ្គទានំ ទេតីតិ ។ សា ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាហីតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ ឩរន្តរិកាយ[២] ឃដ្ដេហិ ឯវំ តេ អនាបត្តិ ភវិស្សតីតិ ។ សោ ភិក្ខុ តថា អកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សង្ឃាទិសេសស្សាតិ ។ តេន ខោ បន សមយេន រាជគហេ សុបព្វា នាម ឧបាសិកា មុទ្ធប្បសន្នា ហោតិ ។ សា ឯវំទិដ្ឋិកា ហោតិ

១ ឈោក្សុយ្សួ គុរុប្បសន្នាតិ ទិស្សតិ ។ ឆ ។ ម. បាឡិយំ ។



ដំបូរឈ្មោះ ការុគ្គះ ក៏បានឃើញព្រះឧបាលិដ៏មានអាយុក្នុងទីកាត់កណ្ដាលផ្លូវ ហើយនិយាយប្រាប់រឿងនោះ ។ ព្រះឧបាលិដ៏មានអាយុ បានប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ឥតមានអាបត្តិអ្វីដោយព្រោះតែការយល់សប្ដិនោះទេ ។

(៩៦). សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានឧបាសិកាម្នាក់ឈ្មោះ សុបព្វា ជាស្រីមានសេចក្ដីជ្រះថ្លាខ្សោយ ។ នាងមានសេចក្ដីយល់ឃើញយ៉ាងនេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ ។ លុះដល់នាងបានឃើញភិក្ខុ ១ រូប ក៏និយាយនឹងថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នាងសុបព្វាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះភ្លៅចុះ កាលបើលោកព្យាយាមដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះ ។ ទើបភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។

សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានឧបាសិកាម្នាក់ឈ្មោះសុបព្វា ជាស្រីមានសេចក្ដីជ្រះថ្លាខ្សោយ ។ នាងមានសេចក្ដីយល់ឃើញយ៉ាងនេះថា

យា មេថុនំ ធម្មំ នេតិ សា អត្តជាតំ ទេតិ ។ សា ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាហិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ ជាណុយំ(១) ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ ឩរន្តរិយំ(២) ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ ឧបកច្ឆកេ ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ គីវ-យំ(៣) ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ កណ្ណច្ឆិទ្ទេ ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ កេសវដ្តិយំ(៤) ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ អង្គុលន្តរិកាយ ឃដ្តេហិ ។ បេ ។ ឯហិ ភន្តេ ហត្ថេន ឧបក្កមិត្វា មោចេស្សាមិ ឯវន្តេ អនាបត្តិ ភវិស្សតីតិ ។ សោ ភិក្ខុ តថា អកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សង្ឃាទិសេសស្សាតិ ។

---

១ ឱ. ម. ជាណុយា ។ ២ ឱ. ម. ឩរន្តរិកាយ ។ ៣ ឱ. ម. គីវាយ ។ ៤ ឱ. ម. កេសវដ្តិយា ។



ស្រីណាឲ្យធ្លាប់មេថុនធម្ម ស្រីនោះឈ្មោះថាឲ្យធ្លាប់តាមដំបូងប្រសើរ ។ លុះដល់នារីម្នាក់ឃើញភិក្ខុ ១ រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រកែកថា ប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នារីសុំអង្វរទៀតថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ជង្គង់ចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ចិតពោះចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ក្លៀកចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់កចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់រន្ធត្រចៀកចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នួងសក់ចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះម្រាមដៃចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកចុះ ខ្ញុំនឹងព្យាយាមឲ្យចេញទឹកសុក្កៈដោយដៃខ្ញុំ កាលបើធ្វើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ តែត្រូវអាបត្តិសង្ឃាទិសេស ។

(៧៣) តេន ខោ បន សមយេន សាវត្ថិយំ សុបព្វា នាម ឧបាសិកា មុទ្ធប្បសន្នា ហោតិ ។ សា ឯវំទិដ្ឋិកា ហោតិ យា មេថុនំ ធម្មំ ទេតិ សា អគ្គទានំ ទេតីតិ ។ សា ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ ឩរន្តរិកាយ ឃដ្ដេហិ ឯវំ តេ អនាបត្តិ ភវិស្សតីតិ ។ សោ ភិក្ខុ តថា អកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សង្ឃាទិសេសស្សាតិ ។

(៧៤) តេន ខោ បន សមយេន សាវត្ថិយំ សុបព្វា នាម ឧបាសិកា មុទ្ធប្បសន្នា ហោតិ ។ សា ឯវំទិដ្ឋិកា ហោតិ យា មេថុនំ ធម្មំ ទេតិ សា អគ្គទានំ ទេតីតិ ។ សា ភិក្ខុំ បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ អលំ ភគិនិ នេតំ កប្បតីតិ ។ ឯហិ ភន្តេ នាភិយំ





(៧៣) សម័យនោះ ក្នុងក្រុងសាវត្ថី មានឧបាសិកាម្នាក់ឈ្មោះសុព្វា ជាអ្នកមានសេចក្តីជ្រះថ្លាទ្រពោយ ។ នាងមានសេចក្តីយល់ឃើញដូច្នេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ ។ លុះដល់នាងបានឃើញភិក្ខុ ១ រូប ក៏និយាយនឹងភិក្ខុថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រាប់ថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នាងសួរថា លោកម្ចាស់ សូមលោកនិមន្តមកត្រូយយកចន្លោះភ្លៅចុះ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះទៅ ។ ទើបភិក្ខុនោះកើតមានសេចក្តីសង្ស័យ ។ បេ ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិសង្ឃាទិសេស ។

(៧៤) សម័យនោះ ក្នុងក្រុងសាវត្ថី មានឧបាសិកាម្នាក់ឈ្មោះសុព្វា ជាស្រីមានសេចក្តីជ្រះថ្លាទ្រពោយ ។ នាងមានសេចក្តីយល់ឃើញដូច្នេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ ។ លុះនាងបានឃើញភិក្ខុ ១ រូប ក៏និយាយនឹងភិក្ខុថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រាប់ថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នាងសួរថា លោកម្ចាស់ សូមលោកនិមន្តមក

យញ្ចេ ។ បេ ។ ឯហិ ភន្តេ ឧទរវដ្ដិយំ យញ្ចេ ។ បេ ។ ឯហិ ភន្តេ ឧបកច្ឆកេ យញ្ចេ ។ បេ ។ ឯហិ ភន្តេ គីវាយំ យញ្ចេ ។ បេ ។ ឯហិ ភន្តេ កណ្ណច្ឆិទ្ទេ យញ្ចេ ។ បេ ។ ឯហិ ភន្តេ កេសវដ្ដិយំ យញ្ចេ ។ បេ ។ ឯហិ ភន្តេ អង្គុលន្តរិកាយ យញ្ចេ ។ បេ ។ ឯហិ ភន្តេ ហត្ថេន ឧបក្កមិត្វា មោចេស្សាមិ ឯវន្តេ អនាបត្តិ ភវិស្សតីតិ ។ សោ ភិក្ខុ តថា អកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សង្ឃាទិសេសស្សាតិ(១) ។

(៧៩) តេន ខោ បន សមយេន វេសាលិយំ លិច្ឆវិកុមារកា ភិក្ខុំ គហេត្វា ភិក្ខុនិយា វិប្បដិបាទេសុំ ។ ឧភោ សាទិយឹសុ ឧភោ នាសេតព្វា ។ ឧភោ ន សាទិយឹសុ ឧភិន្នំ អនាបត្តិ ។

១ ឧភោ. បុរិមេសុ ឆស្សុ វិសំវាទំ ទិស្សតិ ឧភោ ពេសស្សបិ ឆស្សុ ។



ព្យាយាមត្រង់ផ្ចិតចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នត់ពោះចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ក្លៀកចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់កចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់រន្ធត្រចៀកចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នួងសក់ចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះម្រាមដៃចុះ ។ បេ ។ លោកម្ចាស់ សូមលោកនិមន្តមកចុះ ខ្ញុំព្រះករុណានឹងព្យាយាមឲ្យបញ្ចេញទឹកសុក្កៈដោយដៃខ្ញុំ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះហើយ ។ លុះភិក្ខុនោះកើតមានសេចក្ដីសង្ស័យ ។ បេ ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។

(៧៩) សម័យនោះ ពួកលិច្ឆវីកុមារក្នុងក្រុងវេសាលីចាប់ភិក្ខុ ១ រូបទៅហើយ ឲ្យផ្ដើមរោះមិនគាប់ជាមួយនឹងភិក្ខុនី ។ បើអ្នកទាំងពីរមានសេចក្ដីត្រេកអរដូចគ្នា សង្ឃគប្បីឲ្យអ្នកទាំងពីរសឹកចេញ ។ បើអ្នកទាំងពីរឥតមានសេចក្ដីត្រេកអរទេ អ្នកទាំងពីរមិនមានអាបត្តិឡើយ ។

តេន ខោ បន សមយេន វេសាលិយំ លិច្ឆវិកុមារកា ភិក្ខុំ គហេត្វា សិក្ខមានាយ វិប្បដិបាទេសុំ ។ បេ ។ សាមណេរិយា វិប្បដិបាទេសុំ ។ ឧភោ សាទិយឹសុ ឧភោ នាសេតព្វា ។ ឧភោ ន សាទិយឹសុ ឧភិន្នំ អនាបត្តិ ។

[៧៦] តេន ខោ បន សមយេន វេសាលិយំ លិច្ឆវិកុមារកា ភិក្ខុំ គហេត្វា វេសិយា វិប្បដិបាទេសុំ ។ បេ ។ បណ្ឌកេ វិប្បដិបាទេសុំ ។ បេ ។ គិហិនិយា វិប្បដិបាទេសុំ ។ ភិក្ខុ សាទិយិ ភិក្ខុ នាសេតព្វោ ។ ភិក្ខុ ន សាទិយិ ភិក្ខុស្ស អនាបត្តិ ។ តេន ខោ បន សមយេន វេសាលិយំ លិច្ឆវិកុមារកា ភិក្ខូ គហេត្វា អញ្ញមញ្ញំ វិប្បដិបាទេសុំ ។ ឧភោ សាទិយឹសុ ឧភោ នាសេតព្វា ។ ឧភោ ន សាទិយឹសុ ឧភិន្នំ អនាបត្តិ ។

[៧៧] តេន ខោ បន សមយេន អញ្ញតរោ វុឌ្ឍបព្វជិតោ ភិក្ខុ បុរាណទុតិយិកាយ ទស្សនំ អគមាសិ ។



សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវីកុមារនាំភិក្ខុ ១ រូបទៅ ហើយឲ្យភិក្ខុនោះមិនគាប់ជាមួយនឹងសិក្ខមានា ។ បេ ។ ឲ្យភិក្ខុនោះមិនគាប់ជាមួយនឹងសាមណេរី ។ បើអ្នកទាំងពីរត្រេកអរជាមួយគ្នាហើយ សង្ឃត្រូវឲ្យអ្នកទាំងពីរសឹកចេញ ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរឥតមានអាបត្តិឡើយ ។

(៧៦) សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវីកុមារនាំភិក្ខុ ១ រូបទៅហើយឲ្យភិក្ខុនោះមិនគាប់ជាមួយនឹងស្រីវេស្យា ។ បេ ។ ឲ្យភិក្ខុនោះមិនគាប់ជាមួយនឹងមនុស្សខ្ទើយ ។ បេ ។ ឲ្យភិក្ខុនោះមិនគាប់ជាមួយនឹងស្រីគ្រហស្ថ ។ បើភិក្ខុមានសេចក្តីត្រេកអរ សង្ឃត្រូវឲ្យភិក្ខុ (នោះ) សឹកចេញ ។ បើភិក្ខុឥតមានសេចក្តីត្រេកអរទេ ភិក្ខុ (នោះ) ក៏ឥតមានអាបត្តិឡើយ ។ សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវីកុមារនាំភិក្ខុ ២ រូបទៅ ហើយឲ្យភិក្ខុនោះមិនគាប់ចំពោះគ្នានឹងគ្នា ។ បើអ្នកទាំងពីរមានសេចក្តីត្រេកអរជាមួយគ្នា សង្ឃត្រូវឲ្យអ្នកទាំងពីរសឹកចេញ ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរឥតមានអាបត្តិឡើយ ។

(៧៧) សម័យនោះឯង មានភិក្ខុមួយរូប បួសកាលចាស់ ដើរទៅសួរភរិយាដែលជាគូស្រករ (របស់ខ្លួន) ពីដើម ។

សា ឯហិ ភន្តេ វិព្ភមាតិ អគ្គហេសិ ។ សោ ភិក្ខុ បដិក្កមន្តោ ឧត្តានោ បរិបតិ ។ សា ឧព្ភុជិត្វា អង្គជាតេ អភិនិសីទិ ។ តស្ស កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សាទិយិ ត្វំ ភិក្ខូតិ ។ នាហំ ភគវា សាទិយិន្តិ ។ អនាបត្តិ ភិក្ខុ អសាទិយន្តស្សាតិ ។

[៧៨] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អរញ្ញេ វិហរតិ ។ មិគបោតកោ តស្ស បស្សាវដ្ឋានំ អាគន្ត្វា បស្សាវំ បិវន្តោ មុខេន អង្គជាតំ អគ្គហេសិ ។ សោ ភិក្ខុ សាទិយិ ។ តស្ស កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

បឋមបារាជិកំ និដ្ឋិតំ ។



ឯស្រីនោះក៏និយាយថា បពិត្រលោកដ៏ចំរើន លោកចូររមិលសឹកចេញទៅ ជាហើយក៏ស្ទុះទៅចាប់ ។ ភិក្ខុនោះថយខ្លួន ក៏ដួលផ្ងារទៅក្រោយ ។ ស្រីនោះក៏ឡើងជិះអង្គុយសង្កត់លើអង្គជាត ។ ទើបភិក្ខុនោះមានសេចក្ដីសង្ស័យ ។ ហើយក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្ដាទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងបានត្រេកអរដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរទេ ។ ព្រះសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនបានត្រេកអរ មិនត្រូវអាបត្តិទេ ។

[៧៨] សម័យនោះឯង មានភិក្ខុមួយរូបនៅក្នុងព្រៃ ។ មានកូនម្រឹគ១ ដើរមកកាន់ទីដែលភិក្ខុនោះកំពុងបន្ទោបង់បស្សាវៈ ហើយផឹកទឹកបស្សាវៈ ព្រមទាំងបៀមនូវអង្គជាតភិក្ខុដោយមាត់ ។ ភិក្ខុនោះក៏មានសេចក្ដីត្រេកអរ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

បឋមបារាជិក ចប់ ។

## បារាជិកកណ្ឌ ទុតិយសិក្ខាបទំ

(៧៤) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ ឥសិគិលិបស្សេ តិណកុដិយោ ករិត្វា វស្សំ ឧបគច្ឆិំសុ ។ អាយស្មាបិ ធនិយោ កុម្ភការបុត្តោ តិណកុដិកំ ករិត្វា វស្សំ ឧបគច្ឆិ ។ អថខោ តេ ភិក្ខូ វស្សំវុដ្ឋា តេមាសច្ចយេន តិណកុដិយោ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច បដិសាមេត្វា ជនបទចារិកំ បក្កមិំសុ ។ អាយស្មា បន ធនិយោ កុម្ភការបុត្តោ តត្ថេវ វស្សំ វសិ តត្ថេវ ហេមន្តំ តត្ថេវ គិម្ហំ ។ អថខោ អាយស្មតោ ធនិយស្ស កុម្ភការបុត្តស្ស គាមំ បិណ្ឌាយ បវិដ្ឋស្ស តិណហារិកា កដ្ឋហារិកា តិណកុដិកំ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច អាទាយ អគមំសុ ។ ទុតិយម្បិ ខោ អាយស្មា ធនិយោ កុម្ភការបុត្តោ តិណញ្ច កដ្ឋញ្ច សង្កឌ្ឍិត្វា តិណកុដិកំ អកាសិ ។



## បារាជិកកណ្ឌ សិក្ខាបទ ទី ២

(៧៤) សម័យនោះ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះ មានភិក្ខុច្រើនរូប ជាមិត្តសម្លាញ់ ត្រូវនឹងគ្នាឃើញគ្នាខ្លះ ជាមិត្តសម្លាញ់នៅរួមជាមួយគ្នាខ្លះ ធ្វើកុដិប្រក់ដោយស្មៅក្បែរភ្នំឥសិគិលិ ហើយចាំវស្សា (នៅទីនោះ) ។ មានភិក្ខុ (១ រូប) ឈ្មោះធនិយដ៏មានអាយុជាកូនស្មូនឆ្នាំង ធ្វើកុដិតូចប្រក់ដោយស្មៅ ហើយចាំវស្សានៅទីនោះដែរ ។ គ្រានោះ ភិក្ខុទាំងនោះ លុះចាំវស្សាគ្រប់ ៣ ខែ ហើយក៏រុះរើកុដិស្មៅនោះ ហើយរៀបចំទុកដាក់ស្មៅនឹងឈើ (តាមរបៀបស្រួលបួល) ហើយចេញទៅកាន់ជនបទចារិក ។ ចំណែកខាងលោកធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំង ក៏នៅតែក្នុងទីនោះអស់វស្សានរដូវ ហើយនៅអស់ហេមន្តរដូវ នឹងគិម្ហរដូវ ក្នុងទីនោះ (តទៅទៀត) ។ គ្រានោះ កាលដែលធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅនឹងពួកអ្នករកអុស នាំគ្នារុះកុដិប្រក់ដោយស្មៅ (របស់ធនិយភិក្ខុ) ហើយប្រមូលយកស្មៅនឹងឈើទៅអស់ ។ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏រកស្មៅនឹងឈើមក ហើយសង់កុដិប្រក់ដោយស្មៅជាគំរប់ពីរដង ។

ទុតិយម្បិ ខោ អាយស្មតោ ធនិយស្ស កុម្ភការ-បុត្តស្ស គាមំ បិណ្ឌាយ បវិដ្ឋស្ស តិណហារិយោ កដ្ឋហារិយោ តិណកុដិកំ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច អាទាយ អគមំសុ ។ ទុតិយម្បិ ខោ អាយស្មា ធនិយោ កុម្ភការបុត្តោ តិណញ្ច កដ្ឋញ្ច សំ-កឌ្ឍិត្វា តិណកុដិកំ អកាសិ ។ តតិយម្បិ ខោ អាយស្មតោ ធនិយស្ស កុម្ភការបុត្តស្ស គាមំ បិណ្ឌាយ បវិដ្ឋស្ស តិណហារិយោ កដ្ឋហារិយោ តិណកុដិកំ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច អាទាយ អគមំសុ ។ អថខោ អាយស្មតោ ធនិយស្ស កុម្ភការបុត្តស្ស ឯតទហោសិ យាវតតិយកំ ខោ មេ គាមំ បិណ្ឌាយ បវិដ្ឋស្ស តិណហារិយោ កដ្ឋ-ហារិយោ តិណកុដិកំ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច អាទាយ អគមំសុ អហំ ខោ បន សុសិក្ខិតោ អនវយោ សកេ អាចរិយកេ កុម្ភការកម្មេ បរិ-យោទាតសិប្បោ យន្នូនាហំ សាមំ ចិក្ខល្លំ មទ្ទិត្វា សព្វមត្តិកាមយំ កុដិកំ ករេយ្យន្តិ ។ អថខោ



កាលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក ពួកអ្នករកស្មៅនិងពួកអ្នករកអុស ក៏រុះកុដិស្មៅ ហើយនាំយកស្មៅនិងឈើទៅទៀតជាគំរប់ពីរដង ។ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏គរស្មៅនិងឈើមក ហើយសង់កុដិស្មៅជាគំរប់ពីរដង ។ កាលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក ពួកអ្នករកស្មៅនិងពួកអ្នករកអុស ក៏រុះកុដិស្មៅ ហើយនាំយកស្មៅនិងឈើទៅទៀតជាគំរប់បីដង ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ត្រិះរិះថា កាលអាត្មាអញចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅនិងពួកអ្នករកអុសមករុះរើកុដិ ហើយយកស្មៅនិងឈើទៅអស់ ជាប់អស់វារៈបីដងហើយ ចំណែកអាត្មាអញជាអ្នកសិក្សារៀនសូត្រដោយពេញលេញ ឥតមានខ្វះខាតហើយសិល្បសាស្ត្រណាមួយឡើយ បានចេះច្បាស់ក្នុងសិល្បសាស្ត្រខាងការធ្វើស្មូនឆ្នាំង ក្នុងសំណាក់គ្រូអាចារ្យរបស់ខ្លួនមកហើយដែរ បើដូច្នោះ មានតែអញត្រូវជាន់ដីឥដ្ឋដោយខ្លួនឯង ហើយធ្វើកុដិតូច ១ ឲ្យសុទ្ធតែដោយដីឥដ្ឋទាំងអស់ ។ លំដាប់នោះ ធនិយភិក្ខុដ៏

អាយស្មា ធនិយោ កុម្ភការបុត្តោ សព្វំ ចិក្ខល្លំ មទ្ទិត្វា សព្វមត្តិកាមយំ កុដិកំ ករិត្វា តិណញ្ច កដ្ឋញ្ច គោមយញ្ច សង្កឌ្ឍិត្វា តំ កុដិកំ បចិ ។ សា អហោសិ កុដិកា អភិរូបា ទស្សនីយា បាសាទិកា លោហិតកា[១] សេយ្យថាបិ ឥន្ទគោបកោ ។ សេយ្យថាបិ នាម កិង្កណិកសទ្ទោ ឯវមេវ តស្សា កុដិកាយ សទ្ទោ អហោសិ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទស តំ កុដិកំ អភិរូបំ ទស្សនីយំ បាសាទិកំ លោហិតកំ ទិស្វាន ភិក្ខូ អាមន្តេសិ កឹ ឯតំ ភិក្ខវេ អភិរូបំ ទស្សនីយំ បាសាទិកំ លោហិតកំ សេយ្យថាបិ ឥន្ទគោបកោតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តស្ស មោឃ-បុរិសស្ស អននុលោមិកំ អប្បតិរូបំ អស្សាមណកំ

---

១ ឱ. ម. លោហិតិកា ។



មានអាយុជាកូនស្មូនឆ្នាំង ។ ក៏ជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិសុទ្ធដោយដីសុទ្ធទាំងអស់ រួចហើយយកស្មៅ ឧស និងអាចម៍គោមកដុតកុដិនោះ (ដើម្បីឲ្យឆ្អិន) ។ កុដិនោះមានទ្រង់ទ្រាយល្អ គួរជាទីមើល គួរឲ្យកើតសេចក្តីជ្រះថ្លា មានពណ៌ក្រហម ដូចជាពណ៌នៃសត្វមេក្រៀវ ។ កុដិនោះ (កាលបើមានខ្យល់បក់មកត្រូវក៏មានសំឡេងលាន់ឮ) ដូចជាសំឡេងកណ្តឹង ។ គ្រានោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ កាលយាងចុះពីភ្នំគិជ្ឈកូដ ជាមួយនឹងភិក្ខុច្រើនរូប ទ្រង់ទតឃើញកុដិនោះមានទ្រង់ទ្រាយល្អ គួរជាទីមើល គួរឲ្យកើតសេចក្តីជ្រះថ្លា មានពណ៌ក្រហម លុះទតហើយទើបត្រាស់ហៅភិក្ខុទាំងឡាយមកហើយ មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កុដិនោះមានទ្រង់ទ្រាយល្អ គួរជាទីមើល គួរឲ្យកើតសេចក្តីជ្រះថ្លា មានពណ៌ក្រហម ដូចជាពណ៌នៃសត្វមេក្រៀវដូម្តេច ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគទ្រង់ត្រាប ។ ព្រះសម្មាសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ (ការធ្វើ) របស់មោឃបុរសនោះជាការមិនសមគួរ មិនមានទំនង មិនមានបែបផែន មិនមែនជារបស់សមណៈ

អកប្បិយំ អករណីយំ កថំ ហិ នាម សោ ភិក្ខវេ មោឃបុរិសោ សាមំ ចិក្ខល្លំ មទ្ទិត្វា សព្វ-មត្តិកាមយំ កុដិកំ ករិស្សតិ ន ហិ នាម ភិក្ខវេ តស្ស មោឃបុរិសស្ស បាណេសុ អនុទ្ទយា អនុកម្បា អវិហេសា ភវិស្សតិ គច្ឆថេតំ ភិក្ខវេ កុដិកំ ភិន្ទថ មា បច្ឆិមា ជនតា បាណេសុ បាតព្យំ(១) អាបជ្ជិ ន ច ភិក្ខវេ សព្វមត្តិកាមយា កុដិកា កាតព្វា យោ ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា យេន សា កុដិកា តេនុបសង្កមិំសុ ឧបសង្កមិត្វា តំ កុដិកំ ភិន្ទិំសុ ។ អថខោ អាយស្មា ធនិយោ កុម្ភការបុត្តោ តេ ភិក្ខូ ឯតទវោច កិស្ស មេ តុម្ហេ អាវុសោ កុដិកំ ភិន្ទថាតិ ។ ភគវា អាវុសោ ភេទាបេតីតិ ។ ភិន្ទថាវុសោ សចេ ធម្មស្សាមី ភេទាបេតីតិ ។

១ ម. បាតព្យំ ។ ឆ. សត្តិកាលា ។



មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ចុះហេតុដូចម្តេចក៏បានជាមោឃបុរសនោះជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិសុទ្ធដោយដីឥដ្ឋអស់ (ដូច្នេះ) ម្នាលភិក្ខុទាំងឡាយ សេចក្តីករុណា សេចក្តីអនុគ្រោះ និងសេចក្តីមិនបៀតបៀនដល់ពួកសត្វមានជីវិត ចំនួនជាមិនមានដល់មោឃបុរសនោះទេឬ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទៅទំ-លាយកុដិនោះចេញ កុំឲ្យបណ្តាជនជាខាងក្រោយបៀតបៀនបំផ្លាញដល់ប្រាណជាតិទៀតឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកុដិសុទ្ធដោយដីឥដ្ឋសោះទេ បើភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាថា ករុណាព្រះអង្គដ៏ចំរើន ហើយនាំគ្នាទៅកុដិនោះនៅកន្លែងណា នាំគ្នាចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏វាយបំបាក់កុដិនោះទៅ ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង សួរភិក្ខុទាំងនោះថា នែលោកទាំងឡាយ ចុះហេតុអ្វីបានជាលោកទាំងឡាយវាយបំបាក់កុដិខ្ញុំដូច្នេះ ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ឲ្យវាយបំបាក់ ។ ធនិយភិក្ខុឆ្លើយតបថា អើ លោកដ៏មានអាយុទាំងឡាយ បើព្រះដ៏មានព្រះភាគជាម្ចាស់ធម្ម-សាមីទ្រង់ត្រាស់ឲ្យវាយបំបាក់ ចូរលោកវាយបំបាក់ចុះ ។

(៨០) អថខោ អាយស្មតោ ធនិយស្ស កុម្ភការបុត្តស្ស ឯតទហោសិ យាវតតិយកំ ខោ មេ គាមំ បិណ្ឌាយ បវិដ្ឋស្ស តិណហារិកា កដ្ឋហារិកា តិណកុដិកំ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច អាទាយ អគមំសុ យាបិ មយា សព្វមត្តិកាមយា កុដិកា កតា សាបិ ភគវតា ភេទាបិតា អត្ថិ ច មេ ទារុគហេ គណកោ សន្ទិដ្ឋោ យន្នូនាហំ ទារុគហេ គណកំ ទារូនិ យាចិត្វា ទារុកុដិកំ ករេយ្យន្តិ ។ អថខោ អាយស្មា ធនិយោ កុម្ភការបុត្តោ យេន ទារុគហេ គណកោ តេនុបសង្កមិ ឧបសង្កមិត្វា ទារុគហេ គណកំ ឯតទវោច យាវតតិយកំ ខោ មេ អាវុសោ គាមំ បិណ្ឌាយ បវិដ្ឋស្ស តិណហារិកា កដ្ឋហារិកា តិណកុដិកំ ភិន្ទិត្វា តិណញ្ច កដ្ឋញ្ច អាទាយ អគមំសុ យាបិ មយា សព្វមត្តិកាមយា កុដិកា កតា សាបិ





(៨០) លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រ មានសេចក្ដីត្រិះរិះថា កាលដែលអាត្មាចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅនឹងពួកអ្នករកអុស រុះកុដិដែលធ្វើដោយស្មៅ ហើយនាំគ្នាយកស្មៅនឹងឈើទៅអស់ ដរាបអស់វារៈបីដង កុដិដែលអាត្មាធ្វើហើយឲ្យស្អុះដោយដីទាំងអស់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ប្រើឲ្យភិក្ខុឲ្យបំបាក់ចេញអស់ មានបុរសអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំង[1]ហ្លួង (១ នាក់) អាត្មាធ្លាប់ស្គាល់ដែរ បើដូច្នោះមានតែអាត្មាត្រូវសុំឈើពីអ្នកដែលកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្ដេច ហើយធ្វើកុដិដោយឈើវិញ ។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងក៏ចូលទៅរកអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្ដេច លុះចូលទៅដល់ហើយ ក៏និយាយនឹងអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្ដេចនោះថា ម្នាលអ្នកដ៏មានអាយុ កាលអាត្មាចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅនឹងពួកអ្នករកអុស រុះកុដិដែលធ្វើដោយស្មៅ ហើយនាំគ្នាយកស្មៅនឹងឈើទៅអស់ (តែដូច្នេះឯង) អស់វារៈបីដងហើយ កុដិដែលអាត្មាធ្វើហើយឲ្យស្អុះដោយដីទាំងអស់ នោះ

១ ពាក្យនេះ ច្រើនប្រែថា នាយស្មៀន តែតាមន័យក្នុងអដ្ឋកថា ប្រែថា អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងឈើរបស់ស្ដេច (នាយឃ្លាំងឈើ) ។

កតរោ ភណេ បិតា ទេហិ មេ អាវុសោ ទារូនិ ឥច្ឆាមិ ទារុកុដិកំ កាតុំ ។ នត្ថិ ភន្តេ តាទិសានិ ទារូនិ យានាហំ អយ្យស្ស ទទេយ្យំ អត្ថិ ភន្តេ ទេវគហទារូនិ[1] នគរប្បដិសង្ខារិកានិ អាបទត្ថាយ និក្ខិត្តានិ សចេ តានិ រាជា ទាបេតិ ហរាបេថ ភន្តេតិ ។ ទិន្នានិ អាវុសោ រញ្ញាតិ ។ អថខោ ទារុគហេគណកោ ឥមេ ខោ សមណា សក្យបុត្តិយា ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា រាជាបិមេសំ អភិប្បសន្នោ ន អរហតិ អទិន្នំ ទិន្នន្តិ វត្តុន្តិ អាយស្មន្តំ ធនិយំ កុម្ភការបុត្តំ ឯតទវោច ហរថ ភន្តេតិ[2] ។ អថខោ អាយស្មា ធនិយោ កុម្ភការបុត្តោ តានិ ទារូនិ ខណ្ឌាខណ្ឌិកំ ឆេទាបេត្វា សកដេហិ និព្វាហាបេត្វា ទារុកុដិកំ អកាសិ ។

១ ម. ឱ. ក. ទេវគហទារូនិ ។ ២ កេសុ ត្រៃបិដកេសុ សៃមិសនា ហោតិ ។ អត្ថិ ហិ ឯវំ វុត្តំ អថខោ ទារុគហេគណកស្ស ឯតទហោសិ ឥមេ ខោ សមណា សក្យបុត្តិយា ។ បេ ។ ទិន្នន្តិ វត្តុន្តិ ។ អថខោ ទារុគហេគណកោ អាយស្មន្តំ ធនិយំ កុម្ភការបុត្តំ ឯតទវោច ហរថ ភន្តេតិ ។



ព្រះជីមានព្រះភាគទ្រង់ត្រាស់ប្រើឲ្យភិក្ខុទាំងឡាយបំបាក់បំបែកចោលអស់ ដែល អ្នកមានអាយុ ចូរអ្នកប្រគេនឈើមកខ្ញុំ ៗ ចង់ធ្វើកុដិឈើ ។ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចទូលថា បពិត្រលោកដ៏ចំរើន ឈើដែលខ្ញុំគួរណាល្មមគួរសមនឹងប្រគេនលោកម្ចាស់នោះគ្មានទេ មានតែឈើព្រះរាជទ្រព្យ សម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការការអន្តរាយ លោកម្ចាស់ បើព្រះរាជាទ្រង់ត្រាស់ឲ្យប្រគេន (មានអ្វី) លោកម្ចាស់ឲ្យគេមកនាំយកទៅចុះ ។ ធនិយភិក្ខុនិយាយថា ម្នាលឧបាសក ស្តេចប្រគេនហើយតើ ។ លំដាប់នោះ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចគិតថា ពួកសមណៈទាំងនេះជាសក្យបុត្ត ជាអ្នកប្រព្រឹត្តធម៌ មានសេចក្តីប្រព្រឹត្តស្មើប្រក្រតី មានកិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ លោកនិយាយតែពាក្យពិត លោកជាអ្នកមានសីលនិងមានធម៌ល្អ សូម្បីស្តេចក៏ជ្រះថ្លានឹងសមណៈទាំងនេះពេកក្រៃ (ម្លោះ) របស់ដែលគេមិនបានឲ្យ លោកមិនគួរនឹងនិយាយថាគេឲ្យទេ (លុះគិតដូច្នេះហើយ) ក៏និយាយនឹងធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ឲ្យគេមកនាំយកឈើនោះទៅចុះ ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងឲ្យមនុស្សកាត់ឈើនោះជាកំណាត់តូចកំណាត់ធំ ហើយឲ្យដឹកនាំយកទៅដោយរទេះជាច្រើន ហើយបានធ្វើជាកុដិឈើ ។

(៨០) អថខោ វស្សការោ ព្រាហ្មណោ មគធមហា-
មត្តោ រាជគហេ កម្មន្តេ អនុសញ្ញាយមានោ យេន
ទារុគហេ គណកោ តេនុបសង្កមិ ឧបសង្កមិត្វា
ទារុគហេ គណកំ ឯតទវោច យានិ តានិ ភណេ
ទេវគហទារូនិ នគរបដិសង្ខារិកានិ អាបទត្ថាយ
និក្ខិត្តានិ កហំ តានិ ទារូនីតិ ។ តានិ សាមិ ទារូនិ
ទេវេន អយ្យស្ស ធនិយស្ស កុម្ភការបុត្តស្ស ទិន្នា-
នីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហា-
មត្តោ អនត្តមនោ អហោសិ កថំ ហិ នាម ទេវោ
ទេវគហទារូនិ នគរបដិសង្ខារិកានិ អាបទត្ថាយ
និក្ខិត្តានិ ធនិយស្ស កុម្ភការបុត្តស្ស ទស្សតីតិ ។
អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ យេន
រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមិ
ឧបសង្កមិត្វា រាជានំ មាគធំ សេនិយំ ពិម្ពិសារំ
ឯតទវោច សច្ចំ កិរ(១) ទេវ ទេវគហទារូនិ
នគរបដិសង្ខារិកានិ អាបទត្ថាយ និក្ខិត្តានិ ធនិយស្ស
កុម្ភការបុត្តស្ស ទិន្នានីតិ ។ កោ ឯវមាហាតិ ។



(៨០) គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ
កាលដើរពិនិត្យត្រួតត្រាមើលការងារក្នុងក្រុងរាជគ្រឹះ ក៏ចូលទៅរកអ្នក
កាន់កាប់ដើមឈើក្នុងឃ្លាំងរបស់ស្ដេច លុះចូលទៅដល់ហើយ ក៏និ-
យាយនឹងអ្នកកាន់កាប់ដើមឈើក្នុងឃ្លាំងរបស់ស្ដេចនោះថា នែនាយ
ឈើព្រះរាជទ្រព្យឯណា សម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍
កាលមានអន្តរាយ ឈើនោះនៅឯណា ។ អ្នកកាន់កាប់ដើមឈើក្នុង
ឃ្លាំងរបស់ស្ដេចឆ្លើយថា បពិត្រលោកជាម្ចាស់ ឈើនោះស្ដេចបានប្រ-
គេនទៅធនិយភិក្ខុជាម្ចាស់ជាកូនស្មូនឆ្នាំងហើយ ។ លំដាប់នោះ វស្សការ-
ព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈមានសេចក្ដីតូចចិត្ត (ដោយគិត) ថា
ចុះហេតុអ្វីក៏បានជាស្ដេចប្រគេនឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះ
នគរ ដែលទុកប្រយោជន៍កាលមានអន្តរាយទៅធនិយភិក្ខុជាកូនស្មូនឆ្នាំង
វិញ ។ គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ចូល
ទៅកាន់ទីដែលព្រះបាទពិម្ពិសារមាគធរាជសេនិយពង្សនៅ លុះចូលទៅ
ដល់ហើយក៏ក្រាបទូលថា ខ្ញុំឮថា ឈើព្រះរាជទ្រព្យសម្រាប់ជួសជុល
ព្រះនគរ ដែលទុកប្រយោជន៍កាលមានអន្តរាយ ព្រះអង្គទ្រង់ប្រគេនទៅ
ធនិយភិក្ខុមែនឬ ។ ព្រះបាទពិម្ពិសារស្ដេចថា អ្នកណានិយាយយ៉ាងនេះ ។

ទារុគហគណកោ ទេវាតិ ។ តេនហិ ព្រាហ្មណ ទារុគហគណកំ អាណាបេហីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ទារុគហគណកំ ពន្ធំ អាណាបេសិ ។

(៨៦) អទ្ទសា ខោ អាយស្មា ធនិយោ កុម្ភការបុត្តោ ទារុគហគណកំ ពន្ធំ នីយមានំ(១) ទិស្វាន ទារុគហគណកំ ឯតទវោច កិស្ស ត្វំ អាវុសោ ពន្ធោ នីយសីតិ(២) ។ តេសំ ភន្តេ ទារូនំ កិច្ចាតិ ។ គច្ឆាវុសោ អហំបិ គច្ឆាមីតិ ។ ឯយ្យាសិ ភន្តេ បុរាហំ ហញ្ញាមីតិ ។ អថខោ អាយស្មា ធនិយោ កុម្ភការបុត្តោ យេន រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ យេនាយស្មា ធនិយោ កុម្ភការបុត្តោ តេនុបសង្កមិ

១ ឱ. ម. និយ្យមានំ ។ ២ ឱ. ម. និយ្យសីតិ ។



មហាមាត្យទូលថា បពិត្រព្រះសម្មតិទេព អ្នកកាន់កាប់ថែរក្សាឈើ ។ ព្រះបាទពិម្ពិសារទ្រង់មានព្រះបន្ទូលថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកឯងចូរឲ្យមនុស្សទៅចាប់អ្នកកាន់កាប់ថែរក្សាឈើមកមើល ។ លំដាប់នោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ក៏ឲ្យមនុស្សទៅចាប់ចងអ្នកកាន់កាប់ថែរក្សាឈើហើយនាំមក ។

(៨៦) ធនិយភិក្ខុដ៏មានអាយុជាកូនរបស់ជាងឆ្នាំង បានឃើញអ្នកកាន់កាប់ថែរក្សាឈើ ដែលគេចាប់ចងនាំយកទៅ លុះឃើញហើយ ក៏សួរអ្នកកាន់កាប់ថែរក្សាឈើនោះថា ចុះហេតុអ្វីអាវុសោ ទើបអ្នកត្រូវគេចងនាំយកទៅដូច្នេះ ។ អ្នកកាន់កាប់ថែរក្សាឈើឆ្លើយថា បពិត្រលោកដ៏ចំរើន ព្រោះរឿងឈើនោះ ។ ធនិយភិក្ខុឆ្លើយថា អាវុសោ អ្នកចូរទៅចុះ អាត្មានឹងទៅដែរ ។ អ្នកកាន់កាប់ថែរក្សាឈើឆ្លើយថា លោកម្ចាស់គួរមក ខ្ញុំត្រូវគេសំលាប់មុនហើយ ។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកូនរបស់ជាងឆ្នាំង ក៏ចូលទៅកាន់ព្រះរាជដំណាក់ នៃព្រះបាទពិម្ពិសារមាគធរាជសេនិយគោត្រ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានក្រាលប្រគេន ។ វេលានោះ ព្រះបាទពិម្ពិសារមាគធរាជសេនិយគោត្រ ក៏ចូលទៅរកទីដែលធនិយភិក្ខុដ៏មានអាយុ

ឧបសង្កមិត្វា អាយស្មន្តំ ធនិយំ កុម្ភការបុត្តំ អភិវា-
ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា
មាគធោ សេនិយោ ពិម្ពិសារោ អាយស្មន្តំ ធនិយំ
កុម្ភការបុត្តំ ឯតទវោច សច្ចំ កិរ តយា ភន្តេ
ទេវគហទារូនិ នគរបដិសង្ខារិកានិ អាបទត្ថាយ
និក្ខិត្តានិ អយ្យស្ស ទិន្នានីតិ ។ ឯវំ មហារាជាតិ ។
មយំ ខោ ភន្តេ រាជានោ នាម ពហុកិច្ចា ពហុ-
ករណីយា ទត្វាបិ ន សរេយ្យាម ឥង្ឃ ភន្តេ សរាបេ-
ហីតិ ។ សរសិ ត្វំ មហារាជ បឋមាភិសិត្តោ ឯវរូបឹ
វាចំ ភាសិតា ទិន្នញ្ញេវ សមណព្រាហ្មណានំ តិណកដ្ឋោ-
ទកំ បរិភុញ្ជន្តូតិ ។ សរាមហំ ភន្តេ សន្តិ
ភន្តេ សមណព្រាហ្មណា លជ្ជិនោ កុក្កុច្ចកា
សិក្ខាកាមា តេសំ អប្បមត្តកេបិ កុក្កុច្ចំ ឧប្បជ្ជតិ





ជាកុម្ភការបុត្រគង់នៅ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំចំពោះធនិយភិក្ខុ
ចំណាស់កុម្ភការបុត្រ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទ
ពិម្ពិសារមាគធរាជសេនិយៈ គង់ក្នុងទីដ៏សមគួរហើយ ទើបទ្រង់មានព្រះ
បន្ទូលសួរធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា បពិត្រលោកដ៏ចំរើន
បានឮថា ឈើព្រះករាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកបម្រុង
ការពារអន្តរាយ ខ្ញុំបានប្រគេនលោកពិតមែនឬ ។ ធនិយភិក្ខុទូលថា
ថ្វាយព្រះពរ មហារាជ ពិតមែន ។ ព្រះបាទពិម្ពិសារទ្រង់មានព្រះបន្ទូល
ថា បពិត្រលោកដ៏ចំរើន ធម្មតាយើងជាស្តេចមានកិច្ចច្រើន ការងារ
ដែលត្រូវធ្វើក៏មានច្រើន បើទុកជាយើងឲ្យមែន គឺនឹកមិនឃើញដែរ បើដូច
នេះសូមលោកលើកឲ្យដឹង ។ ធនិយភិក្ខុទូលថា ថ្វាយព្រះពរមហារាជ
សូមព្រះអង្គទ្រង់ព្រះរំពឹងមើល កាលដែលទ្រង់រាជាភិសេកថ្មីៗនោះ
ទ្រង់មានព្រះបន្ទូល មានសេចក្ដីយ៉ាងនេះថា ស្មៅ ឈើ និងទឹក ខ្ញុំបាន
ឲ្យហើយ ដល់សមណៈនិងព្រាហ្មណ៍ទាំងឡាយ ។ ចូរប្រើប្រាស់ (នូវស្មៅ
ឈើនិងទឹកនោះចុះ) ។ ព្រះបាទពិម្ពិសារមានព្រះបន្ទូលថា បពិត្រលោក
ដ៏ចំរើន ខ្ញុំនឹកឃើញហើយ (ប៉ុន្តែថា) សមណៈនិងព្រាហ្មណ៍ទាំងឡាយ
ដែលមានសេចក្ដីអៀនខ្មាស សេចក្ដីសង្ស័យ និងមានសេចក្ដីប្រាថ្នាក្នុង
សិក្ខា សមណៈនិងព្រាហ្មណ៍ទាំងនោះ រមែងកើតមានសេចក្ដីសង្ស័យ

ទេសំ មយា សត្ថាយ ការិតំ ឥទំ ទេវ អញ្ញ អម្ពត្តហិតំ សោ ត្វំ ភន្តេ លោសេន ជាតុំ អធិដ្ឋ ហារិតុំ មញ្ញសិ កថំ ហិ នាម អាមិសា សមណំ វា ព្រាហ្មណំ វា ហនេយ្យុំ វា ពន្ធេយ្យុំ វា បព្វាជេយ្យុំ វា[១] គច្ឆ ភន្តេ លោមេន ត្វំ មុត្តោសិ មា បុនបិ ឯវរូបំ អកាសីតិ ។

(៨៣) មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ[២] វិបាចេន្តិ អលជ្ជិនោ ឥមេ សមណា សក្យបុត្តិយា ទុស្សីលា មុសាវាទិនោ ឥមេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ នដ្ឋំ ឥមេសំ សាមញ្ញំ នដ្ឋំ ឥមេសំ ព្រហ្មញ្ញំ កុតោ ឥមេសំ សាមញ្ញំ កុតោ ឥមេសំ ព្រហ្មញ្ញំ

១ ពាក្យនេះមានក្នុងបាលីភូមា កថំ ហិ នាម អាមិសា សមណំ វា ព្រាហ្មណំ វា វិហេឋេន្តិ ហនេយ្យុំ វា ពន្ធេយ្យុំ វា បព្វាជេយ្យុំ វាតិ ឯកតោ សេសោ បរសោតោ អត្ថិ ។
២ ឆេដ្ឋសង្គាយនបាឋោ ខិយន្តិ បន្តិ ។



គឺថាហេតុនីមួយៗសម្បូរតែបន្តិចបន្តួច ស្មៅ ឈើ និងទឹក ដែលនាំទៅដោយយានជា ៗ ខ្សែរនោះគឺឲ្យចំពោះសមណៈនិងព្រាហ្មណ៍ទាំងនោះ ព្រោះថាស្មៅឈើនិងទឹកនោះឯង ដែលមានគតិព្រោះគមានអ្នកណាហ្នឹងហើយ បពិត្រលោកដ៏ចំរើន លោកសំគាល់ការងាយហេតុបន្តិចបន្តួចនោះ ដើម្បីនាំយកឈើដែលគេមិនបានឲ្យយ៉ាងនេះ មនុស្សទាំងឡាយប្រើដោយនឹងសម្លាប់ ដូចជា ប្រមាថនូវសមណព្រាហ្មណ៍ ដូចម្ដេចក៏ បពិត្រលោកដ៏ចំរើន សូមលោកនិមន្តទៅចុះ លោកឈ្មោះ (ទោស) ហើយ ដោយសាររោម (គឺគេនៃបញ្ញជិត) លោកកុំធ្វើយ៉ាងនេះទៀតឡើយ ។

(៨៣) មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈជាសក្យបុត្តទាំងនេះគ្មានសេចក្ដីអៀនខ្មាស ជាអ្នកទ្រុស្តសីល និយាយកុហក តួណាស់តែសមណៈទាំងនេះប្រព្រឹត្តនូវធម៌ ដោះដូចក្ដី ប្រព្រឹត្តស្មើជាប្រក្រតី នឹងប្រព្រឹត្តនូវធម៌ដ៏ប្រសើរ និយាយទៀងត្រង់ មានសីលនឹងមានធម៌ល្អ ទើបនឹងប្ដេជ្ញា (ខ្លួនជាសមណៈបាន) គាត់នៃសមណៈរបស់លោកទាំងនេះគ្មានទេ ។ ការនៃធម៌ដ៏ប្រសើររបស់លោកទាំងនេះគ្មានទេ សាមញ្ញគុណរបស់លោកទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់លោកទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់លោកទាំងនេះនឹងមានមកអំពីឯណា ព្រហ្មញ្ញគុណរបស់លោកទាំងនេះ

អបគតា ឥមេ សាមញ្ញា អបគតា ឥមេ ព្រហ្មញ្ញា រាជានម្បិ ឥមេ វញ្ចេន្តិ កឹ បន អញ្ញេ មនុស្សេតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ(១) វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា លជ្ជិនោ កុក្កុច្ចកា សិក្ខាកាមា តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ធនិយោ កុម្ភការបុត្តោ រញ្ញោ ទារូនិ អទិន្នំ អាទិយិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ធនិយំ កុម្ភការបុត្តំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ធនិយ រញ្ញោ ទារូនិ អទិន្នំ អាទិយសីតិ(២) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ

១ យោកុយោន ខីយន្តានន្តិ បទន្តិ ។ ២ ម. អាទិយីតិ ។





ទីទាមមកអំពីឯណា លោកទាំងនេះព្រោសហើយចាកសាមញ្ញគុណ លោកទាំងនេះព្រោសហើយចាកព្រហ្មញ្ញគុណ សមណៈទាំងនេះហ៊ានបញ្ឆោតរបស់ស្តេចផែនដី ចំណាន់បើមនុស្សឯទៀតយ៉ាងណាទៅទៀត ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នេះហើយ ។ ពួកភិក្ខុឯណា មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ខ្មាសអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នាក្នុងសិក្ខា ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចម្តេចក៏លោកធនិយកុម្ភការបុត្តជាកូនស្មូនឆ្នាំងកាន់យករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ស្តេច (ដូច្នេះ) ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់នឹងធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា នែធនិយភិក្ខុ ឮថា អ្នកឯងបានយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ព្រះរាជា មែនឬ ។ ធនិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះសម្មាសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលធនិយភិក្ខុថា នែមោឃបុរស អំពើនេះជាកម្មមិនសមគួរ មិនត្រូវទំនង មិនគួរប្រតិបត្តិ មិនមែនជារបស់សមណៈ មិនគប្បី មិនគួរ

កថំ ហិ នាម ត្វំ មោឃបុរិស រញ្ញោ ទារូនិ អទិន្នំ អាទិយិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថ ខ្វេតំ មោឃបុរិស អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។ តេន ខោ បន សមយេន អញ្ញតរោ បុរាណគណកោ មហាមត្តោ ភិក្ខូសុ បព្វជិតោ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថ ខោ ភគវា តំ ភិក្ខុំ ឯតទវោច កិត្តកេន ខោ ភិក្ខុ រាជា មាគធោ សេនិយោ ពិម្ពិសារោ ចោរំ គហេត្វា ហនតិ វា ពន្ធតិ វា បព្វាជេតិ វាតិ ។ បាទេន វា ភគវា បាទារហេន វា អតិរេកបាទេន វាតិ ។ តេន ខោ បន សមយេន រាជគហេ បញ្ចមាសកោ បាទោ ហោតិ ។ អថ ខោ ភគវា អាយស្មន្តំ ធនិយំ កុម្ភការបុត្តំ អនេកបរិយាយេន វិគរហិត្វា





ក្តីឡើយ ម្នាលមោឃបុរស ហេតុអ្វីក៏បានជាអ្នកឯងទៅយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ព្រះរាជា (ដូច្នេះ) ម្នាលមោឃបុរស អំពើនុះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនពួកដែលមិនទាន់ជ្រះថ្លា ទាំងមិនមែននាំឲ្យរឹតតែជ្រះថ្លាលើសលុបដល់ជនពួកដែលជ្រះថ្លាស្រាប់នោះទេ ម្នាលមោឃបុរស អំពើនុះប្រាកដជានាំបណ្តាលមនុស្សពួកខ្លះ ដែលមិនទាន់ជ្រះថ្លា ឲ្យកើតនូវសេចក្តីមិនជ្រះថ្លា ទាំងនាំបណ្តាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យថយជ្រះថ្លាទៅវិញ ។ សម័យនោះ មានមហាមាត្យម្នាក់ កាលដើមធ្លាប់ធ្វើជាហោរក្រមលេខ បានបួសក្នុងសំណាក់ពួកភិក្ខុ (ភិក្ខុនោះឯង) បានទៅអង្គុយជិតព្រះដ៏មានព្រះភាគ ។ វេលានោះ ព្រះអង្គទ្រង់មានព្រះបន្ទូលសួរភិក្ខុនោះថា ម្នាលភិក្ខុ ព្រះបាទពិម្ពិសារមាគធរាជសេនិយចាប់ចោរបានហើយ សម្លាប់ក្តី ឃុំខាំងក្តី និរទេសក្តី ដោយរបស់មានថ្លៃប៉ុន្មាន ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដោយរបស់មានថ្លៃ ១ បាទ ឬក្តី ថ្លៃ ១ បាទ ឬច្រើនជាង ១ បាទ ។ សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ គេយកប្រាក់ ៥ មាសកជា ១ បាទ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ដោយអនេកបរិយាយ

ទុព្ភរតាយ ។ បេ ។ វិរិយារម្ភស្ស វណ្ណំ ភាសិត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យ យថារូបេ អទិន្នាទានេ រាជានោ ចោរំ គហេត្វា ហនេយ្យុំ វា ពន្ធេយ្យុំ វា បព្វាជេយ្យុំ វា ចោរោសិ ពាលោសិ មូឡ្ហោសិ ថេនោសីតិ តថារូបំ ភិក្ខុ អទិន្នំ អាទិយ-មានោ អយម្បិ បារាជិកោ ហោតិ អសំវាសោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៨៤] តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ រជកត្ថរណំ គន្ត្វា រជកភណ្ឌិកំ អវហរិត្វា អារាមំ ហរិត្វា ភាជេសុំ ។ ភិក្ខូ ឯវមាហំសុ



ហើយទ្រង់សំដែងទោសនៃការដែលគេចិញ្ចឹមក្រ ។ បេ ។ ហើយទ្រង់ត្រាស់សរសើរគុណនៃការប្រារព្ធព្យាយាម រួចទ្រង់សំដែងនូវធម្មីកថា ដ៏សមគួរដល់សិក្ខាបទនោះ ឲ្យមានទំនងតាមសិក្ខាបទនោះ ដល់ពួកភិក្ខុទាំងឡាយ ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ ។បេ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចំណែកនៃចិត្តលួច ស្ដេចទាំងឡាយចាប់បាននូវចោរ ហើយត្រូវសម្លាប់ក្ដី ឃុំខាំងក្ដី និរទេសក្ដី ដោយពាក្យថា ឯងជាចោរ ជាមនុស្សពាលវង្វេង ជាមនុស្សលួចទ្រព្យ ព្រោះអទិន្នាទានមានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យដែលគេមិនបានឲ្យមានសភាពដូច្នោះ ភិក្ខុនេះក្ដី ក៏ត្រូវជាបារាជិក រកសំវាសមិនបាន (គឺរកមានកិរិយានៅរួមគ្នាបាន) ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៨៤] សម័យនោះ ពួកឆព្វគ្គិយភិក្ខុទាំងឡាយ ទៅកាន់កន្លែងរបស់ជាងជ្រលក់ ហើយលួចយកបង្វិចសំពត់របស់ជាងជ្រលក់ មកកាន់អារាមហើយចែកគ្នា ។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា

មហាបុញ្ញត្ថ អាវុសោ ពហុំ តុម្ហាកំ ចីវរំ ឧប្បន្នន្តិ ។ កុតោ អាវុសោ អម្ហាកំ បុញ្ញំ ឥធានិ មយំ ចោរគាមណំ គន្ត្វា ចោរភណ្ឌិកំ អវហរិម្ហាតិ ។ ននុ អាវុសោ ភគវតា សិក្ខាបទំ បញ្ញត្តំ កិស្ស តុម្ហេ អាវុសោ ចោរភណ្ឌិកំ អវហរិត្ថាតិ ។ សច្ចំ អាវុសោ ភគវតា សិក្ខាបទំ បញ្ញត្តំ តញ្ច ខោ គាមេ នោ អរញ្ញេតិ ។ ននុ អាវុសោ តថេវ តំ ហោតិ អននុច្ឆវិកំ អាវុសោ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម តុម្ហេ អាវុសោ ចោរភណ្ឌិកំ អវហរិស្សថ នេតំ អាវុសោ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ



ម្នាលអាវុសោ លោកទាំងឡាយជាអ្នកមានបុណ្យច្រើន ចីវរកើតឡើងដល់លោកច្រើន ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ បុណ្យរបស់យើង មានមកពីណា អម្បាញ់មិញ យើងទៅឯកំពង់របស់ចោរដែលគេ ហើយយើងបានលួចយកបង្វិចសំពត់របស់ចោរដែលគេមកទេតើ ។ ភិក្ខុទាំងឡាយនិយាយថា អាវុសោ សិក្ខាបទព្រះបរមគ្រូទ្រង់បញ្ញត្តរួចហើយតើ ចុះហេតុអ្វីបានជាលោកនាំគ្នាទៅលួចបង្វិចសំពត់របស់ចោរដែលគេមក ។ ភិក្ខុទាំងនោះតបថា ម្នាលអាវុសោ សិក្ខាបទព្រះបរមគ្រូជាម្ចាស់ទ្រង់បញ្ញត្តរួចហើយក៏ពិតមែន តែថាសិក្ខាបទនោះ ទ្រង់បញ្ញត្តចំពោះតែក្នុងស្រុក ត្រង់ក្នុងទីក្រៅទ្រង់មិនបញ្ញត្តទេ ។ ភិក្ខុទាំងនោះនិយាយថា អាវុសោ សិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តហើយក្នុងស្រុកនោះក៏ត្រូវជាប់ដូចជាក្នុងទីក្រៅផងដែរ មិនមែនឬអ្វី នែអាវុសោ អំពើដែលលោកធ្វើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែបបទ មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែអាវុសោទាំងឡាយ ចុះហេតុដូចម្តេច ក៏បានជាលោកនាំគ្នាទៅលួចបង្វិចសំពត់របស់ចោរដែលគេមក ម្នាលអាវុសោ កម្មនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ទាំងមិនមែននាំឲ្យរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមានសេចក្តីជ្រះថ្លាហើយនោះទេ ម្នាលអាវុសោ

អប្បសន្នានញ្ចេវ អប្បសាទាយ ប-
សន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។ អថខោ តេ ភិក្ខូ
ឆព្វគ្គិយេ ភិក្ខូ អនេកបរិយាយេន វិគរហិត្វា ភគវតោ
ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មិំ និទានេ
ឯតស្មិំ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ឆព្វគ្គិ-
យេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ រជ-
កត្ថរណំ គន្ត្វា រជកភណ្ឌិកំ អវហរិត្ថាតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃ-
បុរិសា អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អ-
កប្បិយំ អករណីយំ កថំ ហិ នាម តុម្ហេ មោឃបុរិសា
រជកភណ្ឌិកំ អវហរិស្សថ នេតំ មោឃបុរិសា អប្ប-
សន្នានំ វា បសាទាយ ។ បេ ។ បសន្នានញ្ច ឯកច្ចានំ



កម្មនេះ ប្រាកដជានាំបណ្ដាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លា ឲ្យបាន
បានកើតសេចក្ដីជ្រះថ្លា និងនាំបណ្ដាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ
ឲ្យប្រែប្រួលកាយមាយាទដោយបាត់សេចក្ដីជ្រះថ្លាទៅវិញ ។ គ្រានោះ ភិក្ខុ
ទាំងឡាយនោះក៏តិះដៀលឆព្វគ្គិយភិក្ខុ ដោយអនេកបរិយាយហើយក្រាប
ទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរ
នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះ
ឆព្វគ្គិយភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នក
ឯងនាំគ្នាទៅកាន់ទីដែលជាងជ្រលក់គេហាលក្រណាត់សំពត់ ហើយបាន
លួចបន្លំសំពត់របស់ជាងជ្រលក់មែនឬ ។ ឆព្វគ្គិយភិក្ខុទូលថា បពិត្រ
ព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់តិះដៀល
ឆព្វគ្គិយភិក្ខុថា នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ
ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់
សមណ មិនគប្បី មិនគួរធ្វើឡើយ នែមោឃបុរសទាំងឡាយ ចុះ
ហេតុអ្វីបានជាអ្នកទាំងឡាយទៅលួចបន្លំសំពត់របស់ជាងជ្រលក់ នែមោឃ-
បុរស អំពើនេះមិនមែននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់
ជ្រះថ្លាទេ ។ បេ ។ និងនាំបណ្ដាលឲ្យជនពួកខ្លះដែលជ្រះថ្លាហើយ

អញ្ញថត្តាយាតិ ។ អថខោ ភគវា ធនិយំ ភិក្ខុំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ វីរិយារម្ភស្ស វណ្ណំ ភាសិត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ គាមា វា អរញ្ញា វា អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យ យថារូបេ អទិន្នាទានេ រាជានោ ចោរំ គហេត្វា ហនេយ្យុំ វា ពន្ធេយ្យុំ វា បព្វាជេយ្យុំ វា ចោរោសិ ពាលោសិ មូឡ្ហោសិ ថេនោសីតិ តថារូបំ ភិក្ខុ អទិន្នំ អាទិយមានោ អយម្បិ បារាជិកោ ហោតិ អសំវាសោតិ ។



ត្រឡប់ជាការមកលោសាយផ្ដាច់សេចក្ដីជ្រះថ្លាទៅវិញ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់តិះដៀលធនិយភិក្ខុ ដោយព្រះពុទ្ធដីកាជាអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃការដែលគេចិញ្ចឹមក្រ ។ បេ ។ ហើយទ្រង់ត្រាស់សរសើរគុណនៃការប្រារព្ធនូវព្យាយាម រួចហើយទ្រង់សំដែងនូវធម្មីកថា ដ៏សមគួរដល់សិក្ខាបទនោះ ៗ ឲ្យសមទំនងតាមសិក្ខាបទនោះ ៗ ចំពោះភិក្ខុទាំងឡាយ ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ។ បេ ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះថា ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចំណែកនៃចិត្តលួច អំពីស្រុកក្ដី ពីព្រៃក្ដី ស្ដេចទាំងឡាយចាប់បានចោរហើយក៏សម្លាប់ក្ដី ឃុំឃាំងក្ដី និរទេសក្ដី ដោយពាក្យថា ឯងជាចោរ ជាមនុស្សពាលល្ងង់ ជាមនុស្សលួច ព្រោះអទិន្នាទានមានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យដែលគេមិនបានឲ្យ មានសភាពយ៉ាងនោះ ភិក្ខុនេះក្ដី ក៏ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន (គឺឥតមានកិរិយានៅរួមគ្នាបាន) ។

(៨៩) យោ បនាតិ យោ យាទិសោ ។ បេ ។ ឯសោ វុច្ចតិ យោ បនាតិ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ គាមោ នាម ឯកកុដិកោបិ គាមោ ទ្វិកុដិកោបិ គាមោ តិកុដិកោបិ គាមោ ចតុក្កុដិកោបិ គាមោ សមនុស្សោបិ គាមោ អមនុស្សោបិ គាមោ បរិក្ខិត្តោបិ គាមោ អបរិក្ខិត្តោបិ គាមោ គោនិសាទិនិវិដ្ឋោបិ គាមោ យោបិ សត្ថោ អតិរេកចតុមាសនិវិដ្ឋោ សោបិ វុច្ចតិ គាមោ ។ គាមូបចារោ នាម បរិក្ខិត្តស្ស គាមស្ស ឥន្ទខីលេ ឋិតស្ស មជ្ឈិមស្ស បុរិសស្ស លេឌ្ឌុបាតោ[1] អបរិក្ខិត្តស្ស គាមស្ស ឃរូបចារេ ឋិតស្ស មជ្ឈិមស្ស បុរិសស្ស លេឌ្ឌុបាតោ ។ អរញ្ញំ នាម ឋបេត្វា គាមញ្ច គាមូបចារញ្ច អវសេសំ អរញ្ញំ នាម ។ អទិន្នំ នាម យំ អទិន្នំ អនិស្សដ្ឋំ អបរិច្ចត្តំ រក្ខិតំ គោបិតំ

---

១ លេឌ្ឌុបាតោតិបិ បាឋោ ។



(៨៩) ត្រង់ពាក្យថា ណាមួយ សេចក្ដីថា ឯណា ប្រាកដដូចជាឯណា ។ បេ ។ ភិក្ខុនេះ គេហៅថា ណាមួយ ។ ត្រង់ពាក្យថា ភិក្ខុ ។ បេ ។ សេចក្ដីថា ភិក្ខុនេះគេចង់បានក្នុងសេចក្ដីនេះ ។ ដែលឈ្មោះថា ស្រុក (នោះ) គឺស្រុកដែលមានខ្ទមមួយក្ដី ស្រុកដែលមានខ្ទមពីរក្ដី ស្រុកដែលមានខ្ទមបីក្ដី ស្រុកដែលមានខ្ទមបួនក្ដី ស្រុកដែលមានមនុស្សក្ដី ស្រុកដែលឥតមនុស្សក្ដី ស្រុកដែលមានរបងព័ទ្ធជុំវិញក្ដី ស្រុកដែលឥតរបងព័ទ្ធជុំវិញក្ដី ស្រុកដែលគេចូលតាំងនៅថ្មី (មានផ្ទះតែបី) ដូចជាគោឈរក្ដី ក្រុំនោះសោត បរិសណាដែលមានពួកឈ្មួញបានអាស្រ័យនៅលើសពី ៤ ខែឡើងទៅ បរិសនោះក៏គេហៅថា ស្រុក ។ ដែលឈ្មោះថា ឧបចារនៃស្រុក (នោះ) គឺទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្រែបមាត់ទ្វារស្រុកដែលមានរបងព័ទ្ធជុំវិញ ហោះទៅ (ឬ) ទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្រែបឧបចារផ្ទះនៃស្រុកដែលឥតរបងព័ទ្ធជុំវិញ ហោះទៅ ។ ដែលឈ្មោះថា ព្រៃ (នោះ) គឺទីដ៏សេសលើកលែងតែស្រុកនិងឧបចារនៃស្រុកចេញ ឈ្មោះថាព្រៃ ។ ដែលឈ្មោះថា ទ្រព្យដែលគេមិនបានឱ្យ (នោះ) គឺរបស់ណាដែលគេមិនទាន់ឱ្យ មិនទាន់លះបង់ឱ្យ មិនទាន់ដាច់ចិត្តឱ្យ គេរក្សាទុក គេគ្រប់គ្រងទុក

មមាយិតំ បរបរិគ្គហិតំ ឯតំ អទិន្នំ នាម ។ ថេយ្យសង្ខាតន្តិ ថេយ្យចិត្តោ អវហរណចិត្តោ ។

(៨៦) អាទិយេយ្យាតិ អាទិយេយ្យ ហរេយ្យ អវ-ហរេយ្យ ឥរិយាបថំ វិកោបេយ្យ ឋានា ចាវេយ្យ សង្កេតំ វីតិនាមេយ្យ ។

(៨៧) យថារូបំ នាម បាទំ វា បាទារហំ វា អតិរេកបាទំ វា ។ រាជានោ នាម បថព្យា រាជា បទេសរាជា មណ្ឌលិកា អន្តរភោគិកា អក្ខទស្សា មហាមត្តា យេ វា បន ឆេជ្ជភេជ្ជំ អនុសាសន្តិ ឯតេ រាជានោ នាម ។ ចោរោ នាម យោ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ ឯសោ ចោរោ នាម ។ ហនេយ្យុំ វាតិ



គេនៅប្រកាន់ គេនៅហួងហែង ទ្រព្យនោះឈ្មោះថា ទ្រព្យដែលគេមិនបានឲ្យ ។ ត្រង់បទថា ដោយចំណែកនៃចិត្តលួច សេចក្តីថា ភិក្ខុមានចិត្តជាអ្នកលួច គឺថា ភិក្ខុមានចិត្តប្រុងនឹងលួច ។

(៨៦) ត្រង់បទថា គប្បីកាន់យក សេចក្តីថា ភិក្ខុគប្បីកាន់យក គប្បីនាំទៅ គប្បីលួចយក គប្បីឲ្យកំរើកឥរិយាបថ គប្បីឲ្យឃ្លាតចាកទី គប្បីណាត់ទុកទីក្នុងទីដែលកំណត់ ។

[៨៧] ដែលឈ្មោះថា យថារូប (នោះ) គឺទ្រព្យចំនួនមួយបាទ ឬទ្រព្យគួរដល់ថ្លៃមួយបាទ ឬថា លើសអំពីមួយបាទឡើងទៅ ។ ដែលឈ្មោះថា ស្តេចទាំងឡាយ (នោះ) គឺស្តេចធំលើផែនដីទាំងអស់ ស្តេចធំត្រួតប្រទេស ពួកអ្នកត្រួតមណ្ឌល (ចៅហ្វាយខេត្ត) ពួកអ្នកបរិភោគស្រុកជាចំណាប់ (ចៅហ្វាយស្រុក) ពួកអ្នកកាត់ក្តី ពួកមហាមាត្យ គឺនាហ្មឺន ពួកអ្នកឯណាជាអ្នកត្រួតត្រាគំនិតការកាប់សម្លាប់ ពួកអ្នកទាំងនោះ ឈ្មោះថាស្តេច ។ ដែលឈ្មោះថា ចោរ (នោះ) គឺអ្នកណាដែលកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ មានថ្លៃប្រមាណ៥មាសក ឬលើសជាង៥មាសកឡើងទៅ ដោយចំណែកនៃចិត្តលួច អ្នកនោះឈ្មោះថា ចោរ ។ ត្រង់ពាក្យថា គប្បីសម្លាប់ក្តី

ហត្ថេន វា ទណ្ឌេន វា កសាយ វា វេត្តេន វា អឌ្ឍទណ្ឌកេន វា ឆេជ្ជាយ វា ហនេយ្យ ។ ពន្ធេយ្យ វាតិ រជ្ជុពន្ធនេន វា អន្ទុពន្ធនេន វា សង្ខលិកពន្ធនេន វា ឃរពន្ធនេន វា នគរពន្ធនេន វា គាមពន្ធនេន វា និគមពន្ធនេន វា ពន្ធេយ្យ បុរិសគុត្តិំ វា ករេយ្យ ។ បព្វាជេយ្យ វាតិ គាមា វា និគមា វា នគរា វា ជនបទា វា ជនបទប្បទេសា វា បព្វាជេយ្យ ។ ចោរោសិ ពាលោសិ មូឡ្ហោសិ ថេនោសីតិ បរិភាសោ ឯសោ ។

(៨៨) ឥណាវុធំ នាម បាទំ វា បាទារហំ វា អតិរេកបាទំ វា ។ អាទិយមានោតិ អាទិយមានោ ហរមានោ អវហរមានោ ឥរិយាបថំ វិកោបយមានោ ឋានា ចាវយមានោ សង្កេតំ វីតិនាមយមានោ ។



សេចក្ដីថា គប្បីសម្លាប់ដោយដៃក្ដី ដោយដំបងក្ដី ដោយរំពាត់ខ្សែតីក្ដី ដោយផ្តៅក្ដី ដោយដំបងខ្លីក្ដី ដោយកាប់កាត់ក្ដី ។ ត្រង់ពាក្យថា គប្បីចងក្ដី សេចក្ដីថា គប្បីចងដោយចំណងគឺខ្សែក្ដី ដោយចំណងគឺខ្នោះក្ដី ដោយចំណងគឺច្រវាក់ក្ដី ដោយឃុំខាំងក្នុងផ្ទះក្ដី ដោយឃុំខាំងក្នុងក្រុងក្ដី ដោយឃុំខាំងក្នុងស្រុកក្ដី ដោយឃុំខាំងក្នុងនិគមក្ដី ឬគប្បីធ្វើនូវការឃុំខាំងដោយបុរស ។ ត្រង់ពាក្យថា គប្បីបបរបង់ក្ដី ឬថាគប្បីនិរទេសក្ដី សេចក្ដីថា គប្បីបណ្ដេញចេញចាកស្រុកក្ដី ចាកនិគមក្ដី ចាកក្រុងក្ដី ចាកជនបទក្ដី ចាកប្រទេសក្នុងជនបទក្ដី ។ ត្រង់ពាក្យ ៤ ម៉ាត់ថា អ្នកឯងជាចោរ អ្នកឯងជាពាល អ្នកឯងជាមនុស្សល្ងង់ អ្នកឯងជាអ្នកលួចនេះ ជាពាក្យជេរប្រទេច ។

(៨៨) ដែលឈ្មោះថា មានសេចក្ដីជំពាក់ (ទេនះ) គឺទ្រព្យចំនួនមួយបាទ ឬទ្រព្យគួរដល់ថ្លៃមួយបាទ ឬថា ក្រៃលែងជាងមួយបាទឡើងទៅ ។ ត្រង់ពាក្យថា កាលកាន់យក សេចក្ដីថា កាលចាប់យក កាលនាំទៅ កាលលួច កាលឲ្យកំរើកឥរិយាបថ កាលឲ្យឃ្លាតចាកទី កាលឲ្យកន្លងនូវទីដែលកំណត់ ។

[៨៩] អយម្បីតិ បុរិមំ ឧបាទាយ វុច្ចតិ ។ បារាជិកោ ហោតីតិ សេយ្យថាបិ នាម បណ្ឌុបលាសោ ពន្ធនា បវុត្តោ[1] អភព្វោ ហរិតត្ថាយ ឯវមេវ ភិក្ខុ បាទំ វា បាទារហំ វា អតិរេកបាទំ វា អទិន្នំ ថេយ្យសង្ខាតំ អាទិយិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ តេន វុច្ចតិ បារាជិកោ ហោតីតិ ។ អសំវាសោតិ សំវាសោ នាម ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខតា ឯសោ សំវាសោ នាម សោ តេន សទ្ធឹ នត្ថិ តេន វុច្ចតិ អសំវាសោតិ ។

[៩០] ភូមដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ឧទកដ្ឋំ នាវដ្ឋំ យានដ្ឋំ ភារដ្ឋំ អារាមដ្ឋំ វិហារដ្ឋំ ខេត្តដ្ឋំ វត្ថុដ្ឋំ គាមដ្ឋំ អរញ្ញដ្ឋំ ឧទកំ ទន្តបោណំ វនប្បតិ

[1] បមុត្តោតិបិ បាឋោ ។



(៨៩) ត្រង់បទថា ភិក្ខុនេះផង គឺពោលប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន ។ ត្រង់ពាក្យថា ជាបារាជិក អធិប្បាយថា សេចក្ដីឧបមាថា ធម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចត្រឡប់ទៅជាមានពណ៌ខៀវវិញបាន ដូចម្ដេចមិញ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យចំនួន ១ បាទ ឬគួរដល់ថ្លៃ ១ បាទ ឬជាក្រៃលែងជាង ១ បាទឡើងទៅ ដោយចំណែកនៃចិត្តលួច គឺមិនមែនជាសមណមិនមែនជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្រ ដូច្នោះដែរ ព្រោះហេតុនោះ បានជាតថាគតហៅ ភិក្ខុនោះជាបារាជិក ។ ត្រង់បទថា គេសំវាសគ្នាន (នោះ) សេចក្ដីថា សង្ឃកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា ការសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុដែលត្រូវបារាជិកនោះឡើយ ព្រោះហេតុនោះ បានជាតថាគតហៅថា គេសំវាសគ្នាន ។

[៩០] (មាតិកាពាក្យឈ្មោះទ្រព្យ) ទ្រព្យដែលស្ថិតនៅក្នុងដី ស្ថិតនៅលើគោក ស្ថិតនៅក្នុងអាកាស ស្ថិតនៅលើធ្នើ ស្ថិតនៅក្នុងទឹក ស្ថិតនៅក្នុងទូក ស្ថិតនៅលើយាន ស្ថិតនៅលើភារៈ ស្ថិតនៅក្នុងឧទ្យាន ស្ថិតនៅក្នុងវិហារ ស្ថិតនៅក្នុងស្រែ ស្ថិតនៅក្នុងទីដី ស្ថិតនៅក្នុងស្រុក ស្ថិតនៅក្នុងព្រៃ ទឹក ឈើស្ទន់ ដើមឈើ

ហារណកំ ឧបនិធិ សុង្កឃាតំ បាណោ អបទំ ទ្វិបទំ ចតុប្បទំ ពហុប្បទំ ឱចរកោ ឱណិរក្ខោ សំវិទាវហារោ សង្កេតកម្មំ និមិត្តកម្មន្តិ ។

[៩១] ភុម្មដ្ឋំ នាម ភណ្ឌំ ភូមិយំ និក្ខិត្តំ ហោតិ និខាតំ បដិច្ឆន្នំ ។ ភុម្មដ្ឋំ ភណ្ឌំ អវហារបេក្ខោ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ កុទ្ទាលំ វា បិដកំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ តត្ថ ជាតកំ កដ្ឋំ វា លតំ វា ឆិន្ទតិ អាបត្តិ ទុក្កដស្ស ។ បំសុំ ខណតិ វា ព្យូហតិ(១) វា ឧទ្ធរតិ វា អាបត្តិ ទុក្កដស្ស ។ កុម្ភឹ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ អត្តនោ ភាជនំ បវេសេត្វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ អត្តនោ ភាជនគតំ វា ករោតិ មុដ្ឋឹ វា ឆិន្ទតិ អាបត្តិ បារាជិកស្ស ។ សុត្តារុឡ្ហំ ភណ្ឌំ(២) បាមង្គំ វា កណ្ឋសុត្តកំ វា(៣) កដិសុត្តកំ វា សាដកំ វា

១ [illegible] អត្ថិ ។ ២ [illegible] ព្យូហតិ ម. ក. ព្យូហតិ ។ ៣ [illegible] ។





របស់ដែលគេកំពុងនាំទៅ របស់ដែលគេផ្ញើ ទីដែលហាមពន្ធ ( គយ ) សត្វមានជីវិត គឺមនុស្ស សត្វគ្មានជើង សត្វជើងពីរ សត្វជើងបួន សត្វជើងច្រើន អ្នកលបលាក់របស់ដើម្បីឲ្យគេលួច អ្នករក្សារបស់ផ្ញើទុក មួយរំពេច កិរិយាលួចយកដោយបបួលគ្នា សង្កេតកម្ម និមិត្តកម្ម ។

[៩១] ដែលឈ្មោះថាទ្រព្យស្ថិតនៅក្នុងដី ( នោះ ) គឺទ្រព្យដែលគេកប់លាក់ទុកក្នុងដី ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវទ្រព្យដែលស្ថិតនៅក្នុងដី ហើយស្វែងរកគ្នាឲ្យបានជាគំនាក់ក្តី ស្វែងរកចបក្តី កញ្ច្រែងក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាត់នូវឈើ ឬវល្លិដែលកើតក្នុងដីនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុជីក ឬកកាយ ឬគាស់នូវភក់ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុចាប់ពាល់នូវឆ្នាំង ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តបញ្ចូលនូវភាជនៈរបស់ខ្លួនទៅ ហើយចាប់ពាល់នូវវត្ថុមានតម្លៃប្រមាណ ៥ មាសក ឬលើសជាង ៥ មាសកឡើងទៅ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យឲ្យចូលទៅក្នុងភាជនៈរបស់ខ្លួនក្តី កាត់ជាចំណែកដោយក្តាប់ដៃក្តី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវគ្រឿងដែលគេដោតក្នុងខ្សែ គឺខ្សែពួរក្តី ខ្សែកក្តី ខ្សែចង្កេះក្តី សំពត់សាដកក្តី

វេឋនំ វា ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ កោដិយំ គហេត្វា ឧទ្ធរតិ អាបត្តិ ថុល្លច្ចយស្ស ។ ឃំសន្តោ នីហរតិ អាបត្តិ ថុល្លច្ចយស្ស ។ អន្តមសោ កេសគ្គមត្តម្បិ កុម្ភីមុខា មោចេតិ អាបត្តិ បារាជិកស្ស ។ សប្បឹ វា តេលំ វា មធុំ វា ផាណិតំ វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ ឯកេន បយោគេន បិវតិ អាបត្តិ បារាជិកស្ស ។ តត្ថេវ ភិន្ទតិ វា ឆឌ្ឌេតិ វា ឈាបេតិ វា អបរិភោគំ វា ករោតិ អាបត្តិ ទុក្កដស្ស ។

(៨២) ថលដ្ឋំ នាម ភណ្ឌំ ថលេ និក្ខិត្តំ ហោតិ ។ ថលដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(៨៣) អាកាសដ្ឋំ នាម ភណ្ឌំ អាកាសគតំ ហោតិ មោរោ វា កបិញ្ជរោ វា តិត្តិរោ វា វដ្ដកោ វា សាដកំ វា វេឋនំ វា ហិរញ្ញំ វា សុវណ្ណំ វា ឆិជ្ជមានំ បតតិ ។



ឈ្លូតក្តី ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ចាប់ត្រង់ចុង ហើយលើកឡើង ត្រូវអាបត្តិថុល្លច្ច័យ ។ កាលបើរូតទាញនាំយកចេញ ត្រូវអាបត្តិថុល្លច្ច័យ ។ ដោយហោចទៅសូម្បីតែឲ្យផុតអំពីមាត់ឆ្នាំង ប្រមាណប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តផឹកនូវសប្បិក្តី ប្រេងក្តី ទឹកឃ្មុំក្តី ទឹកអំពៅក្តី ជារបស់មានថ្លៃប្រមាណ ៥ មាសក ឬក៏លើសជាង ៥ មាសកឡើងទៅ ដោយប្រយោគតែមួយ ត្រូវអាបត្តិបារាជិក ។ ភិក្ខុទំលាយក្តី ចាក់ចោលក្តី ដុតចោលក្តី ធ្វើ(នូវវត្ថុមានសប្បិជាដើមនោះ) ឲ្យជារបស់ប្រើប្រាស់មិនកើតក្តី ក្នុងទីនោះឯង ត្រូវអាបត្តិទុក្កដ ។

(៨២) ដែលឈ្មោះថា ទ្រព្យស្ថិតនៅលើគោក (នោះ) គឺទ្រព្យដែលគេដម្កល់ទុកលើទីគោក ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចទ្រព្យដែលស្ថិតនៅលើទីគោក ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ចាប់ស្ទាប ត្រូវអាបត្តិទុក្កដ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

(៨៣) ដែលឈ្មោះថា ទ្រព្យស្ថិតនៅក្នុងអាកាស (នោះ) គឺភណ្ឌៈ ដែលទៅក្នុងអាកាស គឺសត្វក្ងោកក្តី ចចាតក្តី ទទាក្តី ចាបក្តី ឬជាសម្ពត់សាដកក្តី ឈ្នួតក្តី ប្រាក់ក្តី មាសក្តី ដែលដាច់ធ្លាក់ចុះ ។ ភិក្ខុមានថេយ្យចិត្ត

អាកាសដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ គមនំ ឧបច្ឆិន្ទតិ អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

[៩៤] វេហាសដ្ឋំ នាម ភណ្ឌំ វេហាសគតំ ហោតិ មញ្ចេ វា បីឋេ វា ចីវរវំសេ វា ចីវររជ្ជុយា វា ភិត្តិខីលេ វា នាគទន្តេ វា រុក្ខេ វា លគ្គិតំ ហោតិ អន្តមសោ បត្តាធារកេបិ ។ វេហាសដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

[៩៥] ឧទកដ្ឋំ នាម ភណ្ឌំ ឧទកេ និក្ខិត្តំ ហោតិ ។ ឧទកដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា



ថា អញនឹងលួចនូវភណ្ឌៈដែលស្ថិតនៅក្នុងអាកាស ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅកាន់ទីក្តី ត្រូវអាបត្តិទុក្កដ ។ ផ្តាច់បង់នូវដំណើរ ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

(៩៤) ដែលឈ្មោះថា ទ្រព្យស្ថិតនៅលើអន្ទោល (នោះ) គឺភណ្ឌៈដែលដម្កល់នៅលើអន្ទោល (អធិប្បាយថា) ទ្រព្យដែលគេដម្កល់ទុកលើគ្រែក្តី លើតាំងក្តី ឬទ្រព្យដែលគេពាក់លើឈើស្នៀតសម្រាប់ពាក់ចីវរក្តី លើខ្សែសម្រាប់ពាក់ចីវរក្តី លើចម្រឹងជញ្ជាំងក្តី លើចង្កៀកក្តី ដែលគេព្យួរទុកលើដើមឈើក្តី ដោយហោចទៅទ្រព្យដែលគេដម្កល់ទុកលើជើងបាត្រក៏ដោយ ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចយកភណ្ឌៈដែលស្ថិតនៅលើអន្ទោល ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅកាន់ទីក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

(៩៥) ដែលឈ្មោះថា ទ្រព្យស្ថិតនៅក្នុងទឹក (នោះ) គឺភណ្ឌៈដែលគេដម្កល់ទុកក្នុងទឹក ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចភណ្ឌៈដែលស្ថិតនៅក្នុងទឹក ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅកាន់ទីក្តី

អាបត្តិ ទុក្កដស្ស ។ និមុជ្ជតិ វា ឧម្មុជ្ជតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ តត្ថ ជាតកំ ឧប្បលំ វា បទុមំ វា បុណ្ឌរីកំ វា ភិសំ វា មច្ឆំ វា កច្ឆបំ វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(៩៦) នាវា នាម យាយ តរតិ ។ នាវដ្ឋំ នាម ភណ្ឌំ នាវាយ និក្ខិត្តំ ហោតិ ។ នាវដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ នាវំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា



ត្រូវអាបត្តិទុក្កដ ។ មុជចុះក្តី ងើបឡើងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ផ្កាឧប្បលក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្រអៅឈូកក្តី ត្រីក្តី អណ្តើកក្តី ដែលកើតក្នុងទឹកនោះ មានថ្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

(៩៦) នាវា (ឆ្លងទឹកមានស្ទឹងនឹងសមុទ្រជាដើម) ដោយរបស់អ្វី របស់នោះឈ្មោះថាទូក[១] ។ ទ្រព្យដែលគេដាក់ក្នុងទូក ឈ្មោះថាទ្រព្យស្ថិតនៅក្នុងទូក ។ ភិក្ខុមានថេយ្យចិត្តគិតថា អាត្មានឹងលួចយកទ្រព្យដែលស្ថិតនៅក្នុងទូក ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ចាប់ពាល់ (ទ្រព្យនោះ) ត្រូវអាបត្តិទុក្កដ ។ (ធ្វើទ្រព្យនោះ) ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ (ធ្វើទ្រព្យនោះ) ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តគិតថា អាត្មានឹងលួចយកទូក ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី

---

១ ក្នុងអដ្ឋកថាថា ស្លាកសម្រាប់ធ្វើឈើក្តី ចាប់ឫស្សីក្តី ក្បូនក្តី ឈ្មោះថា នាវា ដែលប្រើជាទូក ក្នុងទីនេះ ។

អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ពន្ធំ មោចេតិ អាបត្តិ ទុក្កដស្ស ។ ពន្ធំ មោចេត្វា អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ច-យស្ស ។ ឧទ្ធំ វា អធោ វា តិរិយំ វា អន្តមសោ កេសគ្គមត្តម្បិ សង្កាមេតិ អាបត្តិ បារាជិកស្ស ។

[៥៧] យានំ នាម វយ្ហំ រថោ សកដំ សន្ទមានិកា ។ យានដ្ឋំ នាម ភណ្ឌំ យានេ ចតុធា និក្ខិត្តំ ហោតិ ។ យានដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ យានំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។



ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ (ទូកនោះ) ត្រូវអាបត្តិទុក្កដ ។ ធ្វើទូកនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ស្រាយចំណង ត្រូវអាបត្តិទុក្កដ ។ ស្រាយចំណងរួចហើយចាប់ត្រូវ (ទូក) ត្រូវអាបត្តិទុក្កដ ។ (ធ្វើទូក) ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ (ធ្វើទូក) ឲ្យអណ្តែតច្រាសទឹកក្តី បណ្តោយទឹកក្តី ទទឹងទឹកក្តី ដោយហោចទៅ សូម្បីធ្វើឲ្យឃ្លាតចាកទី ប៉ុនចុងម្រៀកសក់ ត្រូវអាបត្តិបារាជិក ។

[៥៧] អង្រឹងស្នែង រថ រទេះ រទេះក្រៀន ឈ្មោះថា យាន ។ ទ្រព្យដែលដាក់ក្នុងយាន ៤ យ៉ាង ឈ្មោះថា ទ្រព្យស្ថិតនៅលើយាន ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលស្ថិតនៅលើយាន ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកយាន ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់យាននោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើយាននោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើយាននោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[៤៨] ភារោ នាម សីសភារោ ខន្ធភារោ កដិភារោ ឱលម្ពកោ ។ សីសេ ភារំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ខន្ធំ ឱរោបេតិ អាបត្តិ បារាជិកស្ស ។ ខន្ធេ ភារំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ កដឹ ឱរោបេតិ អាបត្តិ បារាជិកស្ស ។ កដិយា ភារំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ហត្ថេន គណ្ហាតិ អាបត្តិ បារាជិកស្ស ។ ហត្ថេ ភារំ ថេយ្យចិត្តោ ភូមិយំ និក្ខិបតិ អាបត្តិ បារាជិកស្ស ។ ថេយ្យចិត្តោ ភូមិតោ គណ្ហាតិ អាបត្តិ បារាជិកស្ស ។

[៤៩] អារាមោ នាម បុប្ផារាមោ ផលារាមោ ។ អារាមដ្ឋំ នាម ភណ្ឌំ អារាមេ ចតូហិ ឋានេហិ និក្ខិត្តំ ហោតិ ភូមដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ។ អារាមដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ



[៤៨] ទ្រព្យដែលនៅលើក្បាល (ខ្លួន) នៅលើក (ទ្រព្យដែលក្បៀកលី) នៅលើចង្កេះ (កណ្តៀត) នឹងទ្រព្យដែលយួរនឹងដៃ ឈ្មោះថាភារៈ ។ ភិក្ខុមានថេយ្យចិត្តស្ទាបពាល់ភារៈដែលនៅលើក្បាល ត្រូវអាបត្តិទុក្កដ ។ ធ្វើភារៈនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ភារៈនោះចុះមកដល់ក្រោមក ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តស្ទាបពាល់ភារៈដែលនៅលើក ត្រូវអាបត្តិទុក្កដ ។ ធ្វើភារៈនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ចុះមកដល់ក្រោមចង្កេះ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តស្ទាបពាល់ភារៈដែលនៅលើចង្កេះ ត្រូវអាបត្តិទុក្កដ ។ ធ្វើភារៈនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ចុះមកកាន់បាតដៃ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តដាក់ចុះនូវភារៈដែលនៅក្នុងដៃមកលើផែនដី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តកាន់យកទ្រព្យអំពីផែនដី ត្រូវអាបត្តិបារាជិក ។

[៤៩] សួនផ្កាឈើ សួនផ្លែឈើ ឈ្មោះថាអារាម (សួនច្បារ) ទ្រព្យដែលបុគ្គលដាក់ទុកក្នុងសួនច្បារមាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ចំហអាកាស ១ លើអាកាស ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងសួនច្បារ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យនៅក្នុងសួនច្បារ ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ទៅកាន់ទីក្តី

ឆិន្ទតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ តត្ថ ជាតកំ មូលំ វា តចំ វា បត្តំ វា បុប្ផំ វា ផលំ វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ អារាមំ អភិយុញ្ជតិ អាបត្តិ ទុក្កដស្ស ។ សាមិកស្ស វិមតិំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ សាមិកោ ន មយ្ហំ ភវិស្សតីតិ ធុរំ និក្ខិបតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ សាមិកំ បរាជេតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ បរជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។

[១០០] វិហារដ្ឋំ នាម ភណ្ឌំ វិហារេ ចតូហិ ឋានេហិ និក្ខិត្តំ ហោតិ ភុម្មដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ។



ត្រូវអាបត្តិទុក្កដ ។ ពាល់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានចេតនាលួចពាល់ឫសឈើក្តី សម្បកឈើក្តី ស្លឹកឈើក្តី ផ្កាឈើក្តី ផ្លែឈើក្តី ដែលដុះក្នុងសួនច្បារនោះ ទោះមានតម្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកទៅក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុទាមទារប្រកាន់យកសួនច្បារ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់សួនច្បារសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់សួនច្បារដាក់ធុរៈថា សួនច្បារនេះជាទីចំណែងបាននមកអញវិញទេ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (តាមការដែលជំនុំជំរះក្តីដ៏សមរម្យ ឬក៏ចំពោះត្រកូល ហើយសួរគួរអ្នកវិនិច្ឆ័យឲ្យយកសាក្សីគោរព ធ្វើម្ចាស់សួនច្បារឲ្យចាញ់) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ (គឺបើពួកអ្នកវិនិច្ឆ័យកាត់សេចក្តីនោះតាមធម្មវិន័យតាមសត្ថុសាសនា ហើយត្រូវចាញ់លើខ្លួនឯងវិញ) ត្រូវអាបត្តិថុល្លច្ច័យ ។

[១០០] ទ្រព្យដែលបុគ្គលដាក់ទុកក្នុងវិហារ (វត្ត) មាន ៤ កន្លែង គឺ ក្នុងដី ១ លើគោក ១ ឯអាកាស ១ លើអាកាស ១ ឈ្មោះថា

វិហារដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ វិហារំ អភិយុញ្ជតិ អាបត្តិ ទុក្កដស្ស ។ សាមិកស្ស វិមតិំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ សាមិកោ ន មយ្ហំ ភវិស្សតីតិ ធុរំ និក្ខិបតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ សាមិកំ បរាជេតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ បរជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។

(១០១) ខេត្តំ នាម យត្ថ បុព្វណ្ណំ វា អបរណ្ណំ វា ជាយតិ ។ ខេត្តដ្ឋំ នាម ខេត្តេ ចតូហិ ឋានេហិ និក្ខិត្តំ ហោតិ ភូមដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ។ ខេត្តដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា



ទ្រព្យនៅក្នុងវិហារ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលឋិតនៅក្នុងវិហារ ហើយស្វែងរកគ្នាឲ្យជាគ្នាទៅក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុចោទប្រកាន់យកវិហារ ត្រូវអាបត្តិទុក្កដ ។ ធ្វើម្ចាស់វិហារឲ្យកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់វិហារគិតថា វត្ថុនេះជាមិនបានមកអញវិញទេ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (គឺការដែលដំដើរគុណជំនុំសង្ឃ ឬរាជត្រកូល ភិក្ខុជាអ្នកស្លុត ដល់ភិក្ខុអ្នកវិនិច្ឆ័យឲ្យគាត់សេចក្តីដោយមិនយុត្តិធម៌) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់វិញ (គឺភិក្ខុអ្នកវិនិច្ឆ័យកាត់ក្តីដោយយុត្តិធម៌ ឲ្យភិក្ខុចាញ់វិញ) ត្រូវអាបត្តិថុល្លច្ច័យ ។

[១០១] ស្រែទាំងឡាយ ៧ យ៉ាង មានស្រែសាលីជាដើមក្តី ផ្លែឈើទាំងឡាយ មានសណ្តែកកកដមាសជាដើមក្តី ដុះក្នុងទីណា ទីនោះឈ្មោះថា ខេត្ត (ស្រែ) ។ ទ្រព្យដែលបុគ្គលដំកល់ក្នុងស្រែមាន ៤ កន្លែង គឺកប់ក្នុងដី១ លើគោក១ ឯអាកាស១ លើច្រវ៉ា១ ឈ្មោះថា ទ្រព្យនៅក្នុងស្រែ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យនៅក្នុងស្រែនុ៎ះ ហើយស្វែងរកគ្នាឲ្យជាគ្នាទៅក្តី ដើរទៅម្នាក់ឯងក្តី

អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ តត្ថ ជាតកំ បុព្វណ្ណំ វា អបរណ្ណំ វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារា-ជិកស្ស ។ ខេត្តំ អភិយុញ្ជតិ អាបត្តិ ទុក្កដស្ស ។ សាមិកស្ស វិមតិំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ សាមិកោ ន មយ្ហំ ភវិស្សតីតិ ធុរំ និក្ខិបតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ សាមិកំ បរាជេតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ បរជ្ជតិ អាបត្តិ ថុល្លច្-ចយស្ស ។ ខីលំ វា រជ្ជុំ វា វតិំ វា មរិយាទំ វា សង្កាមេតិ អាបត្តិ ទុក្កដស្ស ។ ឯកំ បយោគំ អនា-គតេ អាបត្តិ ថុល្លច្ចយស្ស ។ តស្មិំ បយោគេ អាគតេ អាបត្តិ បារាជិកស្ស ។





ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ស្រូវកើតនឹងទីនោះ មានស្រូវសាលីជាដើមក្តី វត្ថុឈើកើតនឹងទីនោះ មានសណ្តែកកដមាសជាដើមក្តី ដែលដុះក្នុងស្រែនោះ មានថ្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកទៅក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុទាមទារប្រកាន់យកស្រែ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់ស្រែកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់ស្រែដាក់ធុរៈថា ស្រែមុខជានឹងមិនបានមកអញវិញទេ ដូច្នេះ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (គឺកាលដែលជំនុំជំរះក្តីដ៏មុំសង្ស ឬគង់កាត់ក្តីត្រូវ ហើយសូកគូកម្មការវិនិច្ឆ័យឲ្យយកសាក្សីកោងធ្វើម្ចាស់ស្រែឲ្យចាញ់) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ (គឺ បើពួកអ្នកវិនិច្ឆ័យកាត់ក្តីនោះតាមធម៌ជាសុតសាសនា ហើយក្រឡប់ជាចាញ់លើខ្លួនឯងវិញ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបង្កិតគោលក្តី ខ្សែក្តី របងក្តី ទំនប់ក្តី ត្រូវអាបត្តិទុក្កដ ។ នៅតែប្រយោគមួយមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ ។ លុះប្រយោគមួយនោះមកដល់ ត្រូវអាបត្តិបារាជិក ។

(១០៤) វត្ថុ នាម អារាមវត្ថុ វិហារវត្ថុ ។ វត្ថុដ្ឋំ នាម ភណ្ឌំ វត្ថុស្មឹ ចតូហិ ឋានេហិ និក្ខិត្តំ ហោតិ ភុម្មដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ។ វត្ថុដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ វត្ថុំ អភិយុញ្ជតិ អាបត្តិ ទុក្កដស្ស ។ សាមិកស្ស វិមតិំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ សាមិកោ ន មយ្ហំ ភវិស្សតីតិ ធុរំ និក្ខិបតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ សាមិកំ បរាជេតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ បរជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ ខីលំ វា រជ្ជុំ វា





[១០៤] ទីសួនច្បារនិងទីវត្តឈ្មោះថា វត្ថុ (ទីដី) ។ ទ្រព្យដែលគេដម្កល់ទុកលើទីដី មាន៤កន្លែង គឺ ក្នុងដី ១ លើគោក ១ ឯអាកាស ១ លើឆ្នើរ ១ ឈ្មោះថាទ្រព្យឋិតនៅក្នុងទីដី ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលគេដម្កល់ទុកក្នុងទីដី ស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅរកក្តី ត្រូវអាបត្តិទុក្កដ ។ ពាល់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទីតាំង ត្រូវអាបត្តិបារាជិក ។ ភិក្ខុចោទប្រកាន់យកទីដី ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់ដីកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់ដីដាក់ធុរៈថា ដីនុះនឹងមិនបានមកអញវិញទេ ដូច្នេះ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់ដើមចាញ់ (គឺកាលដែលជំនុំជំរះក្នុងទីជំនុំសង្ឃប្តឹងក្តីករត្រូវ ហើយភិក្ខុអ្នកវិនិច្ឆ័យឲ្យយកសាក្សីគេបាន ធ្វើឲ្យម្ចាស់ដីឲ្យចាញ់) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ (គឺបើភិក្ខុអ្នកវិនិច្ឆ័យនោះកាន់តាមធម៌វិន័យតាំងសក្ខីសាសនា ហើយត្រឡប់ជាចាញ់ខ្លួនឯងវិញ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុដកនូវគោលក្តី ខ្សែក្តី

វតឹ វា មរិយាទំ វា សង្កាមេតិ អាបត្តិ ទុក្កដស្ស ។ ឯកំ បយោគំ អនាគតេ អាបត្តិ ថុល្លច្ចយស្ស ។ តស្មឹ បយោគេ អាគតេ អាបត្តិ បារាជិកស្ស ។

(១០៣) ខេត្តដ្ឋំ នាម ខេត្តេ ចតូហិ ឋានេហិ និក្ខិត្តំ ហោតិ ភុម្មដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ។ ខេត្តដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(១០៤) វត្ថុ នាម យំ មនុស្សានំ បរិក្ខិត្តំ ហោតិ ឃរំ[១] វត្ថុ ។ វត្ថុដ្ឋំ នាម វត្ថុស្មឹ

១ ម. ឆ. តិ ។





របងក្តី កំផែងក្តី ត្រូវអាបត្តិទុក្កដ ។ នៅសល់ប្រយោគមួយ មិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ ។ លុះប្រយោគមួយនោះមកដល់[១] ត្រូវអាបត្តិបារាជិក ។

(១០៣) ទ្រព្យដែលគេដាក់ទុកក្នុងស្រែមាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើស្ពៃ ១ ឈ្មោះថាទ្រព្យនៅក្នុងស្រែ ។ ភិក្ខុមានចិត្តគិតថា អញនឹងលួចទ្រព្យដែលឋិតនៅក្នុងស្រែហ្នុះ ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ពាល់ត្រូវទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។

(១០៤) ដែលហៅថា វត្ថុ គឺទីណាដែលពួកមនុស្សហ៊ុមព័ទ្ធទុក ទីនោះឈ្មោះថា វត្ថុ ។ ទ្រព្យដែលបុគ្គលដាក់ទុកក្នុងវត្ថុមាន

១ អដ្ឋកថា ថា [illegible] ទី ១ ត្រូវទុក្កដ ទី ២ ត្រូវថុល្លច្ច័យ ទី ៣ ត្រូវបារាជិក ។

អរញ្ញេ ចតូហិ ឋានេហិ និក្ខិត្តំ ហោតិ ភូមដ្ឋំ ថលដ្ឋំ អាកាសដ្ឋំ វេហាសដ្ឋំ ។ អរញ្ញដ្ឋំ ភណ្ឌំ អវហរិស្សាមីតិ ថេយ្យចិត្តោ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ តត្ថ ជាតកំ កដ្ឋំ វា លតំ វា តិណំ វា បញ្ចមាសកំ វា អតិរេក-បញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(១០៨) ឧទកំ នាម ភាជនគតំ វា ហោតិ បោក្ខរណិយំ[១] វា តឡាកេ វា ។ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ អត្តនោ ភាជនំ បវេសេត្វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ឧទកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។

១ ម. ឧ. បោក្ខរណិយា ។



៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើចន្លោះ ១ ឈ្មោះថាទ្រព្យឋិតនៅក្នុងព្រៃ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលឋិតនៅក្នុងព្រៃនុ៎ះ ហើយស្វែងរកគ្នាឲ្យបានគ្នាទៅក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្ត ហើយចាប់ពាល់ឈើក្តី វល្លិ៍ក្តី ស្មៅក្តី កើតក្នុងព្រៃនោះ តម្លៃប្រមាណ ៥ មាសកក្តី ដែលលើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។

(១០៨) ទឹកដែលមាននៅក្នុងភាជនៈក្តី ក្នុងស្រះក្តី ក្នុងបឹងក្តី ឈ្មោះថាទឹក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ទឹកនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទឹកនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទឹកនោះឲ្យហូរឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ទឹកដែលមានតម្លៃប្រមាណ ៥ មាសកក្តី ថ្លៃលើសពី ៥ មាសកក្តី ឲ្យចូលទៅក្នុងភាជនៈរបស់ខ្លួន

ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ អត្តនោ ភាជនគតំ ករោតិ អាបត្តិ បារាជិកស្ស ។ មរិយាទំ ឆិន្ទតិ អាបត្តិ ទុក្កដស្ស ។ មរិយាទំ ឆិន្ទិត្វា បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ឧទកំ និក្ខាមេតិ អាបត្តិ បារាជិកស្ស ។ អតិរេកមាសកំ វា ឩនបញ្ចមាសកំ វា អគ្ឃនកំ ឧទកំ និក្ខាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ មាសកំ វា ឩនមាសកំ វា អគ្ឃនកំ ឧទកំ និក្ខាមេតិ អាបត្តិ ទុក្កដស្ស ។

(១០៦) ទន្តបោណំ នាម ឆិន្នំ វា អច្ឆិន្នំ វា ។ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(១០៧) វនប្បតិ នាម យោ មនុស្សានំ បរិគ្គហិតោ ហោតិ រុក្ខោ បរិភោគោ ។ ថេយ្យចិត្តោ ឆិន្ទតិ បហារេ បហារេ អាបត្តិ ទុក្កដស្ស ។ ឯកំ បហារំ អនាគតេ អាបត្តិ ថុល្លច្ចយស្ស ។ តស្មិំ បហារេ អាគតេ អាបត្តិ បារាជិកស្ស ។



ត្រូវអាបត្តិទុក្កដ ។ ធ្វើទឹកនោះឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទឹកនោះឱ្យបានដល់ភាជនៈរបស់ខ្លួន ត្រូវអាបត្តិបារាជិក ។ ភិក្ខុទំលុះភ្លឺស្រែ ត្រូវអាបត្តិទុក្កដ ។ ទំលុះភ្លឺស្រែហើយបង្ហូរយកទឹកមានថ្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិបារាជិក ។ ភិក្ខុបង្ហូរយកទឹកមានថ្លៃលើសពី ១ មាសកក្តី ថយពី ៥ មាសកចុះមកក្តី ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបង្ហូរយកទឹកមានថ្លៃ ១ មាសកក្តី ថយចុះពី ១ មាសកមកក្តី ត្រូវអាបត្តិទុក្កដ ។

(១០៦) (ឈើសម្រាប់ដុសធ្មេញ) ដែលគេកាត់ហើយក្តី គេមិនបានកាត់ក្តី ហៅថាឈើស្ទន់ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ឈើស្ទន់ដែលមានថ្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឱ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

(១០៧) ឈើណាជាគ្រឿងប្រើប្រាស់ ដែលមានពួកមនុស្សថែរក្សាទុក ឈើនោះឈ្មោះថាដើមឈើ ។ ភិក្ខុមានថេយ្យចិត្តកាត់ឈើនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗប្រហារ ។ នៅប្រហារមួយទៀតមិនទាន់មកដល់ (គឺជានៅតែប្រហារមួយទៀតនឹងដាច់) ត្រូវអាបត្តិថុល្លច្ច័យ ។ លុះប្រហារមួយទៀតនោះមកដល់ (គឺជាបានកាត់ដាច់ហើយ) ត្រូវអាបត្តិបារាជិក ។

(១០៧) ហារណកំ នាម អញ្ញស្ស ហារណកំ ភណ្ឌំ ។ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ សហភណ្ឌហារកំ នេស្សាមីតិ បឋមំ បាទំ សង្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ ទុតិយំ បាទំ សង្កាមេតិ អាបត្តិ បារាជិកស្ស ។ បតិតំ ភណ្ឌំ គណ្ហិស្សាមីតិ បាតាបេតិ អាបត្តិ ទុក្កដស្ស ។ បតិតំ ភណ្ឌំ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(១០៨) ឧបនិធិ នាម ឧបនិក្ខិត្តំ ភណ្ឌំ ។ ទេហិ មេ ភណ្ឌន្តិ វុច្ចមានោ នាហំ គណ្ហាមីតិ ភណតិ អាបត្តិ ទុក្កដស្ស ។ សាមិកស្ស វិមតិំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ សាមិកោ ន មយ្ហំ ទស្សតីតិ ធុរំ និក្ខិបតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ



(១០៧) ទ្រព្យដែលបុគ្គលដទៃកំពុងនាំទៅ ឈ្មោះថា ទ្រព្យដែលគេកំពុងនាំទៅ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតឋានកន្លែង ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថា អញនឹងលួចយកទ្រព្យព្រមទាំងអ្នកនាំទ្រព្យ ហើយឲ្យមនុស្សនោះដើរទៅ ១ ជំហានដំបូង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យមនុស្សនោះដើរទៅបាន ២ ជំហាន ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងយករបស់ដែលជ្រុះចុះ ហើយធ្វើរបស់គេឲ្យជ្រុះធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់របស់ដែលជ្រុះនោះ មានថ្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឲ្យឃ្លាតផុតឋានកន្លែង ត្រូវអាបត្តិបារាជិក ។

(១០៨) ទ្រព្យដែលគេផ្ញើទុក ឈ្មោះថាបញ្ញើ ។ ម្ចាស់បញ្ញើនិយាយថា លោកចូរឲ្យទ្រព្យមកខ្ញុំ ភិក្ខុពោលថា អាត្មាមិនបានទទួលទុកទេ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់របស់កើតសេចក្តីសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់របស់ដាក់ធុរៈថា (ភិក្ខុនេះ) នឹងមិនឲ្យអញវិញទេ (ភិក្ខុនោះ) ត្រូវអាបត្តិបារាជិក ។ ភិក្ខុកាន់ក្រមវិនិច្ឆ័យ-

សាមិកំ បរាជេតិ អាបត្តិ បារាជិកស្ស ។ ធម្មំ ចរន្តោ បរជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។

(១១០) សុង្កឃាតំ នាម រញ្ញា ឋបិតំ ហោតិ បព្វតខណ្ឌេ វា នទីតិត្ថេ វា គាមទ្វារេ វា អត្រ បវិដ្ឋស្ស សុង្កំ គណ្ហន្តូតិ ។ តត្រ បវិសិត្វា រាជគ្គំ ភណ្ឌំ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ បឋមំ បាទំ សុង្កឃាតំ អតិក្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បារាជិកស្ស ។ អន្តោសុង្កឃាតេ ឋិតោ ពហិសុង្កឃាតំ បាតេតិ អាបត្តិ បារាជិកស្ស ។ សុង្កំ បរិហរតិ អាបត្តិ ទុក្កដស្ស ។

(១១១) បាណោ នាម មនុស្សបាណោ វុច្ចតិ ។ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។



ឲ្យសម្រេចសេចក្តីឲ្យម្ចាស់បញ្ញើចាញ់ ត្រូវអាបត្តិបារាជិក ។ កាលក្រមវិនិច្ឆ័យសម្រេចសេចក្តីតាមធម៌ ភិក្ខុត្រឡប់ចាញ់វិញ ត្រូវអាបត្តិថុល្លច្ច័យ ។

(១១០) ទីសម្រាប់ហូតពន្ធដែលព្រះបរមក្សត្រទ្រង់បញ្ញត្តទុក ជំពាក់អ្នកចូលទៅក្នុងទីនោះ ៗ គឺត្រង់ជ្រោះភ្នំក្តី ត្រង់កំពង់ទឹកក្តី ត្រង់ទីជិតទ្វារស្រុកក្តី ក្នុងកន្លែងសម្រាប់យកពន្ធពីអ្នកដំណើរ ឈ្មោះថាគយ ។ ភិក្ខុចូលទៅក្នុងគយនោះហើយ មានថេយ្យចិត្ត ចាប់ពាល់នូវទ្រព្យដ៏គួរដល់ព្រះរាជាទ្រង់យកពន្ធ មានថ្លៃ ៥ មាសក្តី លើសពី ៥ មាសក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុញុំាងទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុឈានជំហានទី ១ ឲ្យកន្លងទីគយទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុឈានជំហានទី ២ ឲ្យកន្លងទីគយទៅ ត្រូវអាបត្តិបារាជិក ។ ភិក្ខុឋិតនៅក្នុងទីគយរបស់គយ ហើយបោះទម្លាក់របស់ឲ្យធ្លាក់ចុះទៅខាងក្រៅទីគយរបស់គយ ត្រូវអាបត្តិបារាជិក ។ ភិក្ខុវាងទ្រព្យគេចពន្ធ (ដោយគេចពីទីគយ) ត្រូវអាបត្តិទុក្កដ ។

(១១១) សត្វគឺមនុស្ស ហៅថាសត្វមានជីវិត ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់មនុស្សនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។

ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ បទសា នេស្សាមីតិ បឋមំ បាទំ សង្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ ទុតិយំ បាទំ សង្កាមេតិ អាបត្តិ បារាជិកស្ស ។

(១១២) អបទំ នាម អហិ មច្ឆា ។ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

(១១៣) ទ្វិបទំ នាម មនុស្សា បក្ខជាតា ។ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារា-ជិកស្ស ។ បទសា នេស្សាមីតិ បឋមំ បាទំ សង្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ ទុតិយំ បាទំ សង្កាមេតិ អាបត្តិ បារាជិកស្ស ។

(១១៤) ចតុប្បទំ នាម ហត្ថី អស្សា ឱដ្ឋា គោ-ណា គទ្រភា បសុកា ។ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ច-យស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។



ឲ្យផុតចាកទីទៅ ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថា អញនឹងនាំមនុស្សនោះទៅដោយជើង ហើយឲ្យឈានជំហានទី ១ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ២ ទៅ ត្រូវអាបត្តិបារាជិក ។

(១១២) ពស់ ត្រី ឈ្មោះ សត្វគ្មានជើង ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវសត្វគ្មានជើង មានដំឡៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក ។

(១១៣) មនុស្ស សត្វស្លាប ហៅថា សត្វមានជើងពីរ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវសត្វជើងពីរនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារា-ជិក ។ ភិក្ខុគិតថា អញនឹងនាំយកសត្វជើង ២ ទៅដោយជើង ហើយឲ្យឈានជំហានទី ១ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ២ ត្រូវអាបត្តិបារាជិក ។

(១១៤) ដំរី សេះ អូដ្ឋ គោ លា ពពួកសត្វចិញ្ចឹម ហៅថា សត្វមានជើង ៤ ។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់សត្វជើង ៤ នោះ ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក ។

បទសា នេស្សាមីតិ បឋមំ បាទំ សង្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ ទុតិយំ បាទំ សង្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ តតិយំ បាទំ សង្កាមេតិ អាបត្តិ ថុល្លច្ចយស្ស ។ ចតុត្ថំ បាទំ សង្កាមេតិ អាបត្តិ បារាជិកស្ស ។

[១០៨] ពហុប្បទំ នាម វិច្ឆិកា សតបទី ឧច្ចាលិង្គបាណកា ។ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ បទសា នេស្សាមីតិ សង្កាមេតិ បទេ បទេ អាបត្តិ ថុល្លច្ចយស្ស ។ បច្ឆិមំ បាទំ សង្កាមេតិ អាបត្តិ បារាជិកស្ស ។

[១០៩] ឱចរកោ នាម ភណ្ឌំ ឱចរិត្វា អាចិក្ខតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ ភណ្ឌំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។





ភិក្ខុគិតថា អញនឹងនាំបណ្ដើរនូវសត្វជើង ៤ ទៅដោយជើង ហើយឲ្យឈានជំហានទី ១ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ២ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ៣ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ៤ ទៅ ត្រូវអាបត្តិបារាជិក ។

[១០៨] ខ្ទួយ ក្អែប ដង្កូវរមាស់ ហៅថា ពួកសត្វមានជើងច្រើន ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់សត្វមានជើងច្រើននោះ មានដំឡៃ ៥ មាសកក្ដី ហួស ៥ មាសកក្ដី ត្រូវអាបត្តិទុក្កដ ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថា អញនឹងនាំបណ្ដើរសត្វមានជើងច្រើនទៅដោយជើង ហើយញុំាងសត្វមានជើងច្រើនឲ្យឈានទៅ ត្រូវអាបត្តិថុល្លច្ច័យ គ្រប់ជំហាន ។ ញុំាងជើងទីបំផុតរបស់សត្វនោះឲ្យឈានទៅ ត្រូវអាបត្តិបារាជិក ។

[១០៩] ភិក្ខុស៊ើបគន់ទ្រព្យដែលគេទុកដាក់ធ្វេសប្រហែស ហើយប្រាប់ (ភិក្ខុដទៃ) ថា លោកចូរលួចទ្រព្យឈ្មោះនេះមក (ភិក្ខុនោះ) ហៅថា អ្នកស៊ើបការរបស់ឲ្យគេលួច ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុអ្នកទទួលបង្គាប់នោះលួចយកទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីររូប ។

[១១៧] ឱណិរក្ខោ នាម អាហដំ ភណ្ឌំ គោបេន្តោ ។ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ ថេយ្យចិត្តោ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។

[១១៨] សំវិទាវហារោ នាម សម្ពហុលា សំវិទហិត្វា ឯកោ ភណ្ឌំ អវហរតិ អាបត្តិ សព្វេសំ បារាជិកស្ស ។

[១១៩] សង្កេតកម្មំ នាម សង្កេតំ ករោតិ បុរេភត្តំ វា បច្ឆាភត្តំ វា រត្តឹ វា ទិវា វា តេន សង្កេតេន តំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ តេន សង្កេតេន តំ ភណ្ឌំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ តំ សង្កេតំ បុរេ វា បច្ឆា វា តំ ភណ្ឌំ អវហរតិ មូលដ្ឋស្ស អនាបត្តិ អវហារកស្ស អាបត្តិ បារាជិកស្ស ។





[១១៧] ភិក្ខុអ្នកថែរក្សាទ្រព្យដែលគេនាំមកផ្ញើទុកក្នុងរបស់ណើរ ហៅថា អ្នករក្សាបញ្ញើ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវទ្រព្យមានដំឡៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[១១៨] ដែលហៅថាការលួចយកតាមការបបួលគ្នា (នោះ) គឺភិក្ខុដែលរួមគំនិតព្រមគ្នាច្រើនរូប ភិក្ខុ ១ រូបទៅលួចយកទ្រព្យបានមក ត្រូវអាបត្តិបារាជិកទាំងអស់គ្នា ។

[១១៩] ភិក្ខុធ្វើសញ្ញាកំណត់ពេលវេលា ហៅថា សង្កេតកម្ម ភិក្ខុប្រើភិក្ខុឲ្យទៅលួចថា អ្នកចូរលួចយកទ្រព្យនោះដោយសង្កេតនោះ គឺវេលាព្រឹកក្តី ល្ងាចក្តី យប់ក្តី ថ្ងៃក្តី ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលួចទ្រព្យនោះបានមកតាមសង្កេតនោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុទៅលួចទ្រព្យនោះមុនសង្កេតនោះក្តី ក្រោយក្តី ភិក្ខុអ្នកប្រើដើមមិនត្រូវអាបត្តិទេ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។

(១៦០) និមិត្តកម្មេ នាម អក្ខឹ វា និខណិស្សាមិ ភមុកំ វា ឧក្ខិបិស្សាមិ សីសំ វា ឧក្ខិបិស្សាមិ តេន និមិត្តេន តំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ តេន និមិត្តេន តំ ភណ្ឌំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ តំ និមិត្តំ បុរេ វា បច្ឆា វា តំ ភណ្ឌំ អវហរតិ មូលដ្ឋស្ស អនាបត្តិ អវហារកស្ស អាបត្តិ បារាជិកស្ស ។

(១៦១) ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ មញ្ញមានោ តំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ មញ្ញមានោ អញ្ញំ អវហរតិ មូលដ្ឋស្ស អនាបត្តិ អវហារកស្ស អាបត្តិ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ អញ្ញំ មញ្ញមានោ



(១៦០) ភិក្ខុធ្វើនិមិត្តក្រៀមសំគាល់ឲ្យលួច ហៅថានិមិត្តកម្ម គឺ ភិក្ខុបង្គាប់ភិក្ខុដទៃថា ខ្ញុំនឹងប៉ប្រិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី អ្នកចូរលួចយកទ្រព្យនោះមកតាមនិមិត្តនោះ ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ លួចទ្រព្យនោះបានមកតាមនិមិត្តនោះ ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុអ្នកទទួលបង្គាប់ទៅលួចទ្រព្យនោះបានមកមុននិមិត្តនោះក្តី ក្រោយក្តី ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិទេ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។

(១៦១) ភិក្ខុបង្គាប់ភិក្ខុដទៃថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះសំគាល់ទ្រព្យនោះបានហើយ ទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះសំគាល់ទ្រព្យនោះបានហើយ ទៅលួចទ្រព្យដទៃបានមកវិញ ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិទេ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះត្រឡប់សំគាល់ទ្រព្យដទៃវិញ តែទៅលួចទ្រព្យ

តំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អា-
ណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។
សោ អញ្ញំ មញ្ញមានោ អញ្ញំ អវហរតិ មូលដ្ឋស្ស
អនាបត្តិ អវហារកស្ស អាបត្តិ បារាជិកស្ស ។ ភិក្ខុ
ភិក្ខុំ អាណាបេតិ ឥត្ថន្នាមស្ស បាវទ ឥត្ថន្នាមោ
ឥត្ថន្នាមស្ស បាវទតុ ឥត្ថន្នាមោ ឥត្ថន្នាមំ ភណ្ឌំ អវ-
ហរតូតិ អាបត្តិ ទុក្កដស្ស ។ សោ ឥតរស្ស អារោ-
ចេតិ អាបត្តិ ទុក្កដស្ស ។ អវហារកោ បដិគ្គណ្ហាតិ
មូលដ្ឋស្ស អាបត្តិ ថុល្លច្ចយស្ស ។ សោ តំ ភណ្ឌំ
អវហរតិ អាបត្តិ សព្វេសំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ
អាណាបេតិ ឥត្ថន្នាមស្ស បាវទ ឥត្ថន្នាមោ ឥត្ថន្នាមស្ស
បាវទតុ ឥត្ថន្នាមោ ឥត្ថន្នាមំ ភណ្ឌំ អវហរតូតិ អាបត្តិ
ទុក្កដស្ស ។ សោ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស ។



បានមក ត្រូវតាមសំគាល់ទ្រព្យដែលភិក្ខុប្រើនោះ ត្រូវអាបត្តិបារាជិកទាំងពីរ
នាក់ ។ ភិក្ខុបង្គាប់ភិក្ខុថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នក
ប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះ សំគាល់ថាទ្រព្យ
ដទៃទៅលួចបានទ្រព្យដទៃមកវិញ ភិក្ខុអ្នកបង្គាប់ដើមមិនត្រូវអាបត្តិឡើយ
ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។ ភិក្ខុបង្គាប់ភិក្ខុថា លោកចូរទៅ
ប្រាប់តដល់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះឯងទៅប្រាប់តដល់ភិក្ខុឈ្មោះ
នេះថា ភិក្ខុឈ្មោះនេះចូរទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើដើមត្រូវ
អាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ទី១ នោះទៅប្រាប់ភិក្ខុអ្នកទទួលបង្គាប់
ទី២ ភិក្ខុអ្នកទទួលបង្គាប់ទី១ នោះត្រូវអាបត្តិទុក្កដក្នុងខណៈប្រាប់ ។ (ភិក្ខុ
អ្នកទទួលបង្គាប់ទី២ទៅប្រាប់ដល់អ្នកទទួលបង្គាប់ទី៣) ភិក្ខុអ្នកទទួល
បង្គាប់ទី៣ព្រមទទួលនឹងទៅលួច ភិក្ខុអ្នកបង្គាប់ដំបូងត្រូវអាបត្តិថុល្លច្ច័យ ។
ភិក្ខុអ្នកទទួលបង្គាប់ទី៣នោះទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិក
ទាំងអស់គ្នា ។ ភិក្ខុបង្គាប់ភិក្ខុថា លោកចូរទៅប្រាប់តដល់ភិក្ខុឈ្មោះ
នេះ ឲ្យភិក្ខុឈ្មោះនេះឯងទៅប្រាប់តដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរ
ទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើដើមត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នក
ទទួលបង្គាប់ទី១ នោះទៅប្រើភិក្ខុដទៃ (ក្រៅអ្នកទទួលបង្គាប់ទី៣វិញ) ខ្លួនអ្នក
ទទួលបង្គាប់ទី១ នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រើ ។ អ្នកទទួលបង្គាប់

អវហារកោ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ ភណ្ឌំ អវហរតិ មូលដ្ឋស្ស អនាបត្តិ អាណាបកស្ស ច អវហារកស្ស ច អាបត្តិ បារា-ជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ គន្ត្វា បុន បច្ចាគច្ឆតិ នាហំ សក្កោមិ តំ ភណ្ឌំ អវហរិតុន្តិ ។ សោ បុន អាណាបេតិ យទា សក្កោសិ តទា តំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ ភណ្ឌំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស សោ តំ អាណា-បេត្វា វិប្បដិសារី ន សាវេតិ មា អវហរីតិ សោ តំ ភណ្ឌំ អវហរតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ អាណាបេត្វា វិប្បដិសារី



ទី ៣ ទទួលនឹងទៅលួច អ្នកទទួលបង្គាប់ទី ៣ នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈទទួល ។ អ្នកទទួលបង្គាប់ទី ៣ នោះទៅលួចទ្រព្យនោះបានមក អ្នកប្រើដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកទទួលបង្គាប់ទី ១ និងភិក្ខុអ្នកលួចទី ៣ ។ ភិក្ខុបង្គាប់ភិក្ខុឯទៀតថា លោកចូរទៅលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រើ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅហើយត្រឡប់មកវិញប្រាប់ថា ខ្ញុំមិនអាចនឹងទៅលួចយកទ្រព្យនោះមកទេ ។ ភិក្ខុអ្នកបង្គាប់ប្រើម្តងទៀតថា លោកអាចលួចយកបានក្នុងពេលណា ចូរលួចទ្រព្យនោះក្នុងពេលនោះចុះ ភិក្ខុអ្នកបង្គាប់នោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់លួចយកទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុឯទៀតថា លោកចូរលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកបង្គាប់នោះ លុះបង្គាប់ភិក្ខុនោះហើយ មានសេចក្តីក្តៅក្រហាយស្តាយក្រោយវិញ តែមិនបានប្រាប់ភិក្ខុនោះថា អ្នកកុំលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់នោះទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុឯទៀតថា លោកចូរទៅលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកបង្គាប់នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈបង្គាប់ ។ ភិក្ខុអ្នកបង្គាប់នោះ លុះបង្គាប់ភិក្ខុនោះហើយ មានសេចក្តីក្តៅក្រហាយ

សាវេតិ មា អវហរីតិ ។ សោ អាណត្តោ អហំ តយាតិ តំ ភណ្ឌំ អវហរតិ មូលដ្ឋស្ស អនាបត្តិ អវហារកស្ស អាបត្តិ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ភណ្ឌំ អវហរាតិ អាបត្តិ ទុក្កដស្ស ។ សោ តំ អាណាបេត្វា វិប្បដិសារី សាវេតិ មា អវហរីតិ សាធូតិ ឱរមតិ ឧភិន្នំ អនាបត្តិ ។

(១៦៦) បញ្ចហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ បារាជិកស្ស បរបរិគ្គហិតញ្ច ហោតិ បរបរិគ្គហិតសញ្ញី ច គរុកោ ច ហោតិ បរិក្ខារោ បញ្ចមាសកោ វា អតិរេកបញ្ចមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានាចាវេតិ អាបត្តិ បារាជិកស្ស បញ្ចហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ថុល្លច្ចយស្ស បរបរិគ្គហិតញ្ច



ស្តាយក្រោយវិញ ត្រឡប់ហាមឃាត់ថា លោកកុំលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់នោះ មិនព្រមត្រឡប់ទាំងលួចតាម ពោលតបថា លោកបង្គាប់ខ្ញុំហើយ រួចទៅលួចយកទ្រព្យនោះបានមក ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។ ភិក្ខុបង្គាប់ភិក្ខុឯទៀតថា លោកចូរលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកបង្គាប់នោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្តីក្តៅក្រហាយស្តាយក្រោយវិញ ត្រឡប់ឃាត់ថា លោកកុំទៅលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់ទទួលពាក្យថាប្រពៃហើយ ក៏លែងលួចទៅ ភិក្ខុទាំងពីររូបមិនត្រូវអាបត្តិឡើយ ។

(១៦៦) ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិបារាជិក គឺទ្រព្យដែលអ្នកដទៃហួងហែងគ្រង ១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងគ្រង ១ បរិក្ខារមានដំឡៃច្រើន ចំនួន ៥ មាសក ឬលើសពី ៥ មាសក ១ មានថេយ្យចិត្តកើតឡើងប្រាកដ ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិបារាជិក ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ញុំាងរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ គឺទ្រព្យដែលអ្នកដទៃហួងហែងគ្រង ១

ហោតិ បរបរិគ្គហិតសញ្ញី ច លហុកោ ច ហោតិ បរិក្ខារោ អតិរេកមាសកោ វា ឩនបញ្ចមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ថុល្លច្ចយស្ស ។ បញ្ចហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ទុក្កដស្ស ។ បរប-រិគ្គហិតញ្ច ហោតិ បរបរិគ្គហិតសញ្ញី ច លហុកោ ច ហោតិ បរិក្ខារោ មាសកោ វា ឩនមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ទុក្កដស្ស ។

(១៦៣) ឆហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ បារាជិកស្ស ន ច សកសញ្ញី ន ច វិស្សាសគ្គាហី ន ច តាវកាលិកំ គរុកោ ច ហោតិ បរិក្ខារោ បញ្ច-មាសកោ វា អតិរេកបញ្ចមាសកោ វា ថេយ្យចិត្តញ្ច



សំគាល់ថា ទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានថ្លៃស្រាលគឺ ប្រមាណលើសពី ១ មាសក ឬថយពី ៥ មាសកចុះមក ១ មានថេយ្យ-ចិត្តកើតឡើងប្រាកដ ១, ញ៉ាំងរបស់នោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិថុល្លច្ច័យ ។ (បើមិនទាន់ញ៉ាំងរបស់នោះឲ្យឃ្លាតចាកទីទេ) ភិក្ខុចាប់ពាល់ត្រូវអាបត្តិទុក្កដ ។ ញ៉ាំងរបស់នោះឲ្យកំរើក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា ១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានថ្លៃស្រាលប្រមាណ ១ មាសក ឬថយពី ១ មាសក ១ មានថេយ្យចិត្តកើតឡើងប្រាកដ ១ ញ៉ាំងរបស់នោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិទុក្កដ ។ (សូម្បីមិនទាន់ឲ្យឃ្លាតចាកទី) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ ។

(១៦៣) ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៦ យ៉ាង ត្រូវអាបត្តិបារាជិក គឺមិនបានសំគាល់ថាជារបស់ខ្លួន ១ មិនបានកាន់យកដោយវិស្សាសៈ ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានថ្លៃច្រើនប្រមាណ ៥ មាសក ឬលើសពី ៥ មាសក ១ មានថេយ្យចិត្ត

បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឋានា ចាវេតិ អាបត្តិ បារាជិកស្ស ។ ឆហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ថុល្លច្ចយស្ស ន ច សកសញ្ញី ន ច វិស្សាសគ្គាហី ន ច តាវកាលិកំ លហុកោ ច ហោតិ បរិក្ខារោ អតិរេកមាសកោ វា ឩនបញ្ចមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ថុល្លច្ចយស្ស ។ ឆហាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ទុក្កដស្ស ន ច សកសញ្ញី ន ច វិស្សាសគ្គាហី ន ច តាវកាលិកំ លហុកោ ច ហោតិ បរិក្ខារោ មាសកោ វា ឩនមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ទុក្កដស្ស ។



តាំងឡើងព្រមគ្នា ១ ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិបារាជិក ។ (បើមិនទាន់ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ញុំាងរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៦ យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ គឺមិនបានសំគាល់ថាជារបស់ខ្លួន ១ មិនបានកាន់យកដោយស្និទ្ធស្នាល ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានថ្លៃតិចប្រមាណលើសពី ១ មាសក ឬថយពី ៥ មាសកមក ១ មានថេយ្យចិត្តតាំងឡើងព្រមគ្នា ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិថុល្លច្ច័យ ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យដោយអាការ ៦ យ៉ាង ត្រូវអាបត្តិទុក្កដ គឺមិនបានសំគាល់ថាជារបស់ខ្លួន ១ មិនបានកាន់យកដោយស្និទ្ធស្នាល ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានថ្លៃតិចប្រមាណ ១ មាសក ឬថយពី ១ មាសកមក ១ មានថេយ្យចិត្តតាំងឡើងព្រមគ្នា ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិទុក្កដ ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ ។

(១៦៦) បញ្ចហិ អាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ទុក្កដស្ស ន ច បរបរិគ្គហិតំ ហោតិ បរបរិគ្គហិតសញ្ញី ច គរុកោ ច ហោតិ បរិក្ខារោ បញ្ចមាសកោ វា អតិរេកបញ្ចមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ទុក្កដស្ស ។ បញ្ចហិ អាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ទុក្កដស្ស ន ច បរបរិគ្គហិតំ ហោតិ បរបរិគ្គហិតសញ្ញី ច លហុកោ ច ហោតិ បរិក្ខារោ អតិរេកមាសកោ វា ឩនបញ្ចមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ទុក្កដស្ស ។ បញ្ចហិ អាការេហិ អទិន្នំ អាទិយន្តស្ស អាបត្តិ ទុក្កដស្ស ន ច បរបរិគ្គហិតំ ហោតិ បរបរិគ្គហិតសញ្ញី ច លហុកោ ច ហោតិ បរិក្ខារោ មាសកោ វា ឩនមាសកោ វា ថេយ្យចិត្តញ្ច បច្ចុបដ្ឋិតំ ហោតិ



(១៦៦) ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យ ដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងគ្រង ១ សំគាល់ថាជាទ្រព្យមានអ្នកដទៃហួងហែងគ្រង ១ បរិក្ខារមានដំឡៃច្រើន ប្រមាណ ៥ មាសក ឬលើសពី ៥ មាសក ១ មានថេយ្យចិត្តកើតឡើងប្រាកដ ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិទុក្កដ ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ គឺត្រូវអាបត្តិទុក្កដ ។ ញុំាងទ្រព្យនោះឲ្យកំរើក គឺត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យ ដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងគ្រង ១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងគ្រង ១ បរិក្ខារមានដំឡៃតិចប្រមាណលើសពី ១ មាសក ឬថយពី ៥ មាសកចុះមក ១ មានថេយ្យចិត្តកើតឡើងប្រាកដ ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិទុក្កដ ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ គឺត្រូវអាបត្តិទុក្កដ ។ ញុំាងទ្រព្យនោះឲ្យកំរើក គឺត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យ ដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងគ្រង ១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងគ្រង ១ បរិក្ខារមានដំឡៃតិចប្រមាណ ១ មាសក ឬថយពី ១ មាសកចុះមក ១ មានថេយ្យចិត្តកើតឡើងប្រាកដ ១

អាមសតិ អាបត្តិ ទុក្កដស្ស ។ ផន្ទាបេតិ អាបត្តិ ទុក្កដស្ស ។ ឋានា ចាវេតិ អាបត្តិ ទុក្កដស្ស ។

[១៦៨] អនាបត្តិ សកសញ្ញិស្ស វិស្សាសគ្គាហេ តាវកាលិកេ បេតបរិគ្គហេ តិរច្ឆានគតបរិគ្គហេ បំសុកូលសញ្ញិស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អទិន្នាទានម្ហិ បទភាជនីយំ និដ្ឋិតំ ។

[១៦៩] រជកេហិ បញ្ចក្ខាតា
ចតុរោត្ថរណេហិ ច
អន្ធការេន វេ[១] បញ្ច
បញ្ច ហារណកេន ច
និរុត្តិយា បញ្ចក្ខាតា
វាតេហិ អបរេ ទុវេ

១ ឱសិ ចាបិ ។



ញុំាងទ្រព្យនោះឲ្យឃ្លាតផុតពាក់ទី ១ ត្រូវអាបត្តិទុក្កដ ។ (បើមិនទាន់ឲ្យឃ្លាតផុតពាក់ទី ២) គ្រាន់តែចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ ។

[១៦៨] ភិក្ខុកាន់យកដោយសំគាល់ថាជារបស់ខ្លួន កាន់យកដោយស្និទ្ធស្នាលនឹងគ្នា កាន់យកជារបស់ខ្ចី កាន់យករបស់ដែលពួកប្រេតហួងហែងក្តី កាន់យករបស់ដែលសត្វតិរច្ឆានហួងហែងក្តី កាន់យកដោយសំគាល់ថាជារបស់បង្សុកូល ភិក្ខុឆ្កួត ភិក្ខុអាទិកម្មិក (អម្បាលនេះ) មិនត្រូវអាបត្តិឡើយ ។

អទិន្នាទាន បទភាជនីយៈ ចប់ ។

(មាតិកានៃរឿង បញ្ជីរឿងតាមលំដាប់ដែលនឹងសំដែងតទៅ ដូចខាងក្រោមនេះ)

[១៦៩] រឿងភិក្ខុ ៥ រូបលួចសំពត់របស់ជាងជ្រលក់ រឿងភិក្ខុ ៤ រូបលួចគ្រឿងក្រាល រឿងភិក្ខុ ៥ រូបលួចទ្រព្យក្នុងវេលាយប់ (ដោយចំណាំទុកតាំងថ្ងៃ) រឿងភិក្ខុ ៥ រូបលួចទ្រព្យដែលខ្លួនកាន់ជួយនាំទៅ រឿងភិក្ខុ ៥ រូបពោលតែពាក្យថាលួច (តែគ្មានថេយ្យចិត្ត) រឿងភិក្ខុ ២ រូបទៀត រើសសន្លូតសាដកនឹងឈ្នួតដែលប៉ើងទៅដោយខ្យល់

អសម្ភិន្នេ កុសាចារោ

ជន្តាឃរេ[1] សេហា ចស

វិឃាសេហិ បញ្ចក្ខាតា

បញ្ច ចេវ អម្ពលកា

ទុក្កត្ថ ក្ខាមសញ្ញ

បូវសត្តុលិមោទកា

សបរិក្ខារត្ថវិកា

ភិសិវសា[2] ច ចិក្ខាមិ[3]

ទារុដំយញ្ញ វិស្សាសំ

សសញ្ញាយ ចប ទុវេ

សត្ត ទាវហារមាតិ

សត្ត ចេវ អភិហរុំ

សង្ឃស្ស អវហរុំ សត្ត

បុប្ផំ អបរេ ទុវេ

១ ឧ. ម. ជន្តាឃរេ ។ ២ ក. ភិសិវសេ ។ ៣ ឧ. ម. ចិវរេ ។





រឿងភិក្ខុ ១ រូបទស់យកសម្ពត់បំសុកូលអំពីសាកសពដែលមិនទាន់បែកធ្លាយ រឿងភិក្ខុ ១ រូបលួចបាយស្ងោកចាវ រឿងព្រះការទន្ទ្រោបៀបធៀបស្មើរបស់ភិក្ខុទាំងពីរនោះ រួមទាំងរឿងភិក្ខុ ៥ ពួកដែលឆាន់កាក[1]សត្វផង ត្រូវជា ១០ រឿងភិក្ខុ ៥ រូបមិនមានហេតុ គួរយកទ្រព្យភោជនីយា-ហារដែលគេចែកដល់សត្វ រឿងភិក្ខុ ៥ រូបលួចស្វាយ សាច់ នំ ស្លុត្រោម មិនខ្សុម ក្នុងវេលាស្រេកអត់ឃ្លាន រឿងពួកភិក្ខុលួចបរិក្ខារព្រមទាំងថង់យាម រឿងពួកភិក្ខុលួចពូករបស់សង្ឃទុកដេកលើរោងស្បៀង រឿងភិក្ខុលួចចីវរក្នុងវិហារហើយមិនហ៊ានចេញទៅក្រៅ រឿងភិក្ខុទាញទាក់ទងរបស់ភិក្ខុជាសំឡាញ់ព្រោះសេចក្ដីស្និទ្ធស្នាល រឿងភិក្ខុ ៦ រូបទៀតយកទ្រព្យរបស់ភិក្ខុដទៃឆាន់ហើយសំគាល់ថាជារបស់ខ្លួន រឿងភិក្ខុ ៧ ពួកប្រែកមិនទទួលខ្ទះជាលួចយក រឿងភិក្ខុ ៧ ពួកទាំងចំណុចលួចយកដីក រឿងភិក្ខុ ៧ រូបលួចយកទ្រ-ព្យរបស់សង្ឃ រឿងភិក្ខុ ៦ រូបទៀតលួចផ្កា រឿងភិក្ខុ

១ របស់ដែលសល់អំពីសត្វស៊ី ។

ទិយេភ ច វុត្តកម្មោ

បណ្ណំ ផលំ អត្ថាមេ

ស្វូតកា ច មិសា មជ្ជា

យាចញ្ញាចំ បត្តុយំ

ទុវេ មេសី ទុវេ នារ

បំសុកូលំ ទុវេ នពា

អនុបុព្វធោនេន

ទិនិវុញ្ញ ច មរិម្មយំ

សាកិច្ចយា ចទ្ទុភ ឲ្យខ្ញី

វុត្ត វិយាសា ទុវេ តិណោ

សមុប្បេ កានយេ សត្ត

សត្ត នេរ៍ អសន្តិកា



៣ រូបទៅនិយាយយករបស់អំពីគ្រហស្ថ បង្ហាត់នៃភិក្ខុទៅ៤ សមណៈកន្សែងលលាតខ្លាស់គ្រហស្ថ រឿងភិក្ខុ ៣ រូបយក វត្ថុបណ្ណាកែវតនិស្ស រឿងភិក្ខុកន្លះផ្តើចជាប់អន្ទាក់លែង រឿងភិក្ខុកន្លះម្រឹគជាប់អន្ទាក់លែង រឿងភិក្ខុកន្លះត្រីជាប់លបលែង រឿងភិក្ខុ ១ រូបលួចប្រមៀលគល្លាទៅក្នុងបាន រឿងភិក្ខុ ៦ រូបលួចយកផ្កាសាល រឿងភិក្ខុ ៦ ពួកលួចបកឈើក្បួនរបស់គេ រឿងភិក្ខុ ១ រូបបំសុកូលយកសម្លត់សាដកគេរបស់គេ រឿងភិក្ខុ ៦ រូប រើសយកសម្លត់សាដកអណ្តែតទឹក រឿងភិក្ខុ ១ រូបលួចទឹកសប្បិ(១) រឿងពួកភិក្ខុលួចដៃគ្នាលួចទ្រព្យគេ ហើយចែកគ្នាមិនគេញ ៥ មាសតម្លាក់ រឿងភិក្ខុ ៦ រូបលួចទាក្លាជាតិម្លាក់ ១ ក្លាប់ វេលាក្រឹសកក្លែអត់ជាយ រឿងភិក្ខុ ៦ ពួកបំសុកូលយកសាច់ដែលសល់អំពីបោះបង់ភោគ រឿងភិក្ខុ ៦ រូបលួចស្មៅគេ រឿងភិក្ខុ ៧ ពួកយកតាមទ័ពរបស់សង្ឃទៅចែកគ្នាឆាន់ រឿងភិក្ខុ ៧ ពួកមិនហ៊ានទទួលតាមទ័ពដែលមនុស្សមិនមែនម្ចាស់ប្រគេន រឿង

---

១ ទឹកដោះគោដែលគេចំអិនញ៉ាំឡើងទៅជាខ្លាញ់ដែលហៅថា ប្រេង

នហារុកា មត្តិកា ទ្វេ តិណកំ

សង្ឃស្ស សត្ត អវហាសុំ សេយ្យំ

សស្សាមិកំ ច ជាតិ នីហរេយ្យុំ

ហរេយ្យុំ សស្សាមិកំ នាវាយ សង្គំ

ចម្បា រាជគហេ ទេវ

វេសាលិយា ច អដ្ឋកា

ពារាណសី ច កោសម្ពី

សាគលា ទឡ្ហិកេន ចាតិ ។

[១៦៨] តេន ខោ បន សមយេន ឆព្វគ្គិយា

ភិក្ខូ រជកត្ថរណំ គន្ត្វា រជកភណ្ឌិកំ អវហរិំសុ ។





ភិក្ខុយកឈើរបស់សង្ឃទៅដាក់ក្នុងវិហារដោយគិតជាខ្ចី រឿងភិក្ខុលួចទឹករបស់សង្ឃ រឿងភិក្ខុលួចដីស្អិតរបស់សង្ឃ រឿងភិក្ខុ ២ រូបលួចស្មៅដែលពូនរបស់សង្ឃ រឿងភិក្ខុ ៧ រូបលួចគ្រឿងសេនាសនៈរបស់សង្ឃ រឿងភិក្ខុយកសេនាសនៈសម្រាប់វិហារមានម្ចាស់ទៅប្រើប្រាស់ហើយចោល រឿងភិក្ខុ ១ ពួកក្រៅពីមានព្រះភាគទ្រង់អនុញ្ញាតឲ្យនាំគ្រឿងសេនាសនៈរបស់គេប្រើប្រាស់បាន រឿងពួកភិក្ខុទីជាសិស្សរបស់ចុល្លបន្ថកភិក្ខុទីកន្លែងក្រុងចម្បានិងក្រុងរាជគ្រឹះ ទៅនិយាយយកចបចណោយល្អប្រឡូរដោយសម្តៅកក្ដាយ ទីកន្លែងទឹកឃ្មុំក្នុងក្រុងរាជគ្រឹះ ឧបដ្ឋាករបស់ចុល្លបន្ថកភិក្ខុ រឿងអដ្ឋកក្នុងក្រុងវេសាលី ខែកមគ្គកដល់ខ្ទមគហបតី រឿងបិលិន្ទវច្ឆក្នុងក្រុងពារាណសី នាំយកក្មេងពីគាត់របស់ឧបដ្ឋាក មិនមែនជាចោរបានមកដោយឫទ្ធិ រឿងភិក្ខុជាសំឡាញ់ទាំង ២ នាក់ក្នុងក្រុងកោសម្ពី រើសរើសកញ្ចប់ក្រណាត់ឲ្យដល់ម្ចាស់ រឿងភិក្ខុជាសទ្ធិវិហារិករបស់ទឡ្ហិកត្ថេរក្នុងក្រុងសាគលលួចយកឈ្នួលកោរសក់គេ ។

(១៦៨) សម័យនោះឯង ឆព្វគ្គិយភិក្ខុនាំគ្នាទៅកាន់ទីកន្លែងហាលសំពត់នៃជាងជ្រលក់ ហើយលួចយកទ្រព្យរបស់ជាងជ្រលក់ ។

តេសំ កុក្កុច្ចំ អហោសិ ភគវតា សិក្ខាបទំ បញ្ញត្តំ កច្ចិ នុ ខោ មយំ បារាជិកំ អាបត្តិំ អាបន្នាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អាបត្តិំ តុម្ហេ ភិក្ខវេ អាបន្នា បារាជិកន្តិ ។

[១៦៨] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រជកត្ថរណំ គន្ត្វា មហគ្ឃំ ទុស្សំ បស្សិត្វា ថេយ្យចិត្តំ ឧប្បាទេសិ ។ តស្ស កុក្កុច្ចំ អហោសិ កច្ចិ នុ ខោ អហំ បារាជិកំ អាបត្តិំ អាបន្នោតិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អនាបត្តិ ភិក្ខុ ចិត្តុប្បាទេតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រជកត្ថរណំ គន្ត្វា មហគ្ឃំ ទុស្សំ បស្សិត្វា ថេយ្យចិត្តោ អាមសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រជកត្ថរណំ គន្ត្វា មហគ្ឃំ ទុស្សំ បស្សិត្វា ថេយ្យចិត្តោ ផន្ទាបេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។



ភិក្ខុអម្បាលនោះមានសេចក្ដីសង្ស័យថា សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ យើងទាំងឡាយត្រូវអាបត្តិបារាជិកហើយឬហ្ន៎ ។ ទើបក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[១៦៨] សម័យនោះ មានភិក្ខុ១រូបទៅកាន់កន្លែងហាលកណ្ដាលនៃជាងជ្រលក់ បានឃើញសំពត់មានដំឡៃច្រើន ហើយញុាំងថេយ្យចិត្តឲ្យកើតឡើង ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិបារាជិកហើយឬហ្ន៎ ។ ទើបក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើថេយ្យចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិទេឡើយ ។ សម័យនោះ មានភិក្ខុ១រូបទៅកាន់កន្លែងហាលកណ្ដាលនៃជាងជ្រលក់ ឃើញសំពត់មានដំឡៃច្រើនមានថេយ្យចិត្តគិតលួចហើយពាល់ពាល់សំពត់នោះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់កន្លែងហាលកណ្ដាលនៃជាងជ្រលក់ បានឃើញសំពត់មានដំឡៃច្រើន មានថេយ្យចិត្តគិតលួចហើយធ្វើសំពត់នោះឲ្យកំរើក ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។

អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រជកត្ថរណំ គន្ត្វា មហគ្ឃំ ទុស្សំ បស្សិត្វា ថេយ្យចិត្តោ ឋានា ចាវេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៦៨) តេន ខោ បន សមយេន អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ មហគ្ឃំ ឧត្តរត្ថរណំ បស្សិត្វា ថេយ្យចិត្តំ ឧប្បាទេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ ចិត្តុប្បាទេតិ ។ តេន ខោ បន សមយេន អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ មហគ្ឃំ ឧត្តរត្ថរណំ បស្សិត្វា ថេយ្យចិត្តោ អាមសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។ បេ ។ ថេយ្យចិត្តោ ផន្ទាបេសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ បេ ។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់កន្លែងហាលសំពត់នៃជាងជ្រលក់ បានឃើញសំពត់មានតម្លៃច្រើន មានថេយ្យចិត្តគិតលួច ហើយញ៉ាំងសំពត់នោះឲ្យឃ្លាតចាកទីតាំង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៦៨] សម័យនោះឯង មានភិក្ខុ១រូបអ្នកត្រាច់ទៅបិណ្ឌបាត បានឃើញកម្រាលដ៏ប្រសើរមានតម្លៃច្រើន ហើយញ៉ាំងថេយ្យចិត្តឲ្យកើតឡើង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើថេយ្យចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុ១រូបអ្នកត្រាច់ទៅបិណ្ឌបាត បានឃើញកម្រាលដ៏ប្រសើរមានតម្លៃច្រើន មានថេយ្យចិត្តគិតលួចហើយចាប់ពាល់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។ បេ ។ ភិក្ខុមានថេយ្យចិត្ត ធ្វើរបស់នោះឲ្យកម្រើក ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។ បេ ។

ថេយ្យចិត្តោ ឋានា ចាវេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៣០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទិវា ភណ្ឌំ បស្សិត្វា និមិត្តំ អកាសិ រត្តិំ អវហរិស្សាមីតិ ។ សោ តំ មញ្ញមានោ តំ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកស្ស ។ បេ ។ តំ មញ្ញមានោ អញ្ញំ អវហរិ ។ បេ ។ អញ្ញំ មញ្ញមានោ តំ អវហរិ ។ បេ ។ អញ្ញំ មញ្ញមានោ អញ្ញំ អវហរិ ។ បេ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកស្ស ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទិវា ភណ្ឌំ បស្សិត្វា និមិត្តំ អកាសិ រត្តិំ អវហរិស្សាមីតិ ។ សោ តំ[១] មញ្ញមានោ

១ ឱ. ម. អញ្ញំ ។



ភិក្ខុមានថេយ្យចិត្តញ៉ាំងរបស់នោះឲ្យឃ្លាតចាកទី ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៣០) សម័យនោះឯង មានភិក្ខុ ១ រូប ឃើញទ្រព្យក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តសំគាល់ថា អញនឹងលួចយកទ្រព្យនោះក្នុងវេលាយប់ ។ ភិក្ខុនោះកាលបើសំគាល់ទ្រព្យនោះបានហើយ ក៏លួចយកទ្រព្យនោះមក ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ បេ ។ ភិក្ខុសំគាល់ទ្រព្យនោះបាន (ក្នុងវេលាថ្ងៃហើយ ដល់វេលាយប់) លួចយកទ្រព្យដទៃបានមកវិញ ។ បេ ។ (វេលាថ្ងៃ) សំគាល់ទ្រព្យដទៃ (តែដល់វេលាយប់) ត្រឡប់លួចបានទ្រព្យនោះមក ។ បេ ។ សំគាល់ទ្រព្យដទៃបានហើយ ទៅលួចយកទ្រព្យដទៃបានមក ។ បេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ឃើញទ្រព្យក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តសំគាល់ថា អញនឹងលួចយកទ្រព្យនោះក្នុងវេលាយប់ ។ ភិក្ខុនោះសំគាល់ទ្រព្យនោះបានហើយ

អន្តរេន គណ្ហំ អវហរិ ។ តស្ស កុក្កុច្ចំ អហោ-សិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។

(១៣៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញស្ស ភណ្ឌំ ហរន្តោ សីសេ ភារំ ថេយ្យចិត្តោ អាមសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។បេ។ ថេយ្យចិត្តោ ផន្ទាបេសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។បេ។ ថេយ្យចិត្តោ ខន្ធំ ឱរោបេសិ ។បេ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។បេ។ ខន្ធេ ភារំ ថេយ្យចិត្តោ អាមសិ ។បេ។ ថេយ្យចិត្តោ ផន្ទាបេសិ ។បេ។ ថេយ្យចិត្តោ កដឹ ឱរោបេសិ ។បេ។ កដិយា ភារំ ថេយ្យចិត្តោ អាមសិ ។បេ។



(របស់គេ) ត្រឡប់ចូលបានទៅទៀតរបស់ខ្លួនមកវិញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

(១៣៦) សម័យនោះឯង មានភិក្ខុ១រូប ទូលនាំយករបស់អ្នកដទៃទៅផ្សារ (ពេលកំពុងដើរ) កើតមានថេយ្យចិត្តហើយចាប់ពាល់របស់តាំងនៅលើក្បាល ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។បេ។ ភិក្ខុមានថេយ្យចិត្តហើយញុំារបស់នោះឲ្យកំរើក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់របស់ចុះមកត្រឹមក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ភារៈដែលតាំងនៅលើក ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយធ្វើភារៈ[1]នោះឲ្យកំរើក ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់ភារៈចុះមកត្រឹមចង្កេះ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ភារៈដែលតាំងនៅលើចង្កេះ ។បេ។

---

១ បានដល់របស់ដែលគេនាំទៅ ដោយអាការដាក់លើក្បាលជាដើម គឺទំនួលឬអង្រែក ។

ថេយ្យចិត្តោ ផន្ទាបេសិ ។ បេ ។ ថេយ្យចិត្តោ ហត្ថេន អគ្គហេសិ ។ បេ ។ ហត្ថេ ភារំ ថេយ្យចិត្តោ ភូមិយំ និក្ខិបិ ។ បេ ។ ថេយ្យចិត្តោ ភូមិតោ អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៣៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អជ្ឈោកាសេ ចីវរំ បត្ថរិត្វា វិហារំ បាវិសិ ។ អញ្ញតរោ ភិក្ខុ មាយិទំ ចីវរំ នស្សីតិ បដិសាមេសិ ។ សោ និក្ខមិត្វា តំ ភិក្ខុំ បុច្ឆិ អាវុសោ មយ្ហំ ចីវរំ កេន អវហដន្តិ ។ សោ ឯវមាហ មយា អវហដន្តិ ។ សោ តំ អាទិយិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ និរុត្តិបថោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ និរុត្តិបថេតិ ។



ភិក្ខុមានថេយ្យចិត្តគិតលួច ហើយធ្វើភារៈឲ្យកំរើក ។ បេ ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់យកដោយដៃ ។ បេ ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់ភារៈដែលតាំងនៅទីដៃមកលើផែនដី ។ បេ ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់យកភារៈអំពីផែនដី ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៣៦) សម័យនោះឯង មានភិក្ខុ ១ រូប ហាលចីវរក្នុងទីវាល ហើយចូលទៅកាន់វិហារ ។ មានភិក្ខុឯទៀតទុកដាក់ចីវរនោះដោយគិតថា កុំឲ្យចីវរនេះបាត់ទៅឡើយ ។ ភិក្ខុនោះចេញពីវិហារទៅ ហើយសួរភិក្ខុនោះថា អាវុសោ ចីវររបស់ខ្ញុំ លោកណាលួចយកទៅ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា (ចីវរលោក) យើងលួចយកហើយ ។ ភិក្ខុម្ចាស់ចីវរនោះចាប់ប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្រាន់តែថាដោយពាក្យ (តែគ្មានថេយ្យចិត្តទេ) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើគ្រាន់តែថាដោយពាក្យ អ្នកមិនត្រូវអាបត្តិទេឡើយ ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បីឋេ ចីវរំ និក្ខិបិត្វា ។ បេ ។ បីឋេ និសីទនំ និក្ខិបិត្វា ។ បេ ។ ហេដ្ឋាបីឋេ បត្តំ និក្ខិបិត្វា វិហារំ បាវិសិ ។ អញ្ញតរោ ភិក្ខុ មាយិទំ បត្តោ នស្សីតិ បដិសាមេសិ ។ សោ និក្ខមិត្វា តំ ភិក្ខុំ បុច្ឆិ អាវុសោ មយ្ហំ បត្តោ កេន អវហដោតិ ។ សោ អាហ មយា អវហដោតិ ។ សោ តំ អាទិយិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ ទវាយាតិ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី វតិយា ចីវរំ បត្ថរិត្វា វិហារំ បាវិសិ ។ អញ្ញតរា ភិក្ខុនី មាយិទំ ចីវរំ នស្សីតិ បដិសាមេសិ ។ សា និក្ខមិត្វា តំ ភិក្ខុនឹ បុច្ឆិ អយ្យេ មយ្ហំ ចីវរំ កេន អវហដន្តិ ។ សា អាហ មយា អវហដន្តិ ។ សា តំ អាទិយិ អស្សមណីសិ ត្វន្តិ ។



សម័យនោះ មានភិក្ខុ ១ រូប ទុកដាក់ចីវរលើតាំង ។ បេ ។ ទុកដាក់សំពត់និសីទនៈលើតាំង ។ បេ ។ ទុកដាក់បាត្រក្រោមតាំង ហើយចូលទៅកាន់វិហារ ។ មានភិក្ខុឯទៀតទុកដាក់បាត្រនោះ ដោយគិតថា កុំឲ្យបាត្រនេះបាត់ទៅឡើយ ។ ភិក្ខុម្ចាស់បាត្រនោះចេញពីវិហារហើយ ទៅសួរភិក្ខុនោះថា អាវុសោ បាត្ររបស់ខ្ញុំ លោកណាលួចយកទៅ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា (បាត្ររបស់លោក) យើងលួចយកហើយ ។ ភិក្ខុម្ចាស់បាត្រចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើគិតលេងពោលពាក្យលេង មិនត្រូវអាបត្តិទេឡើយ ។ សម័យនោះឯង មានភិក្ខុនី ១ រូប ហាលចីវរនឹងរបង ហើយចូលទៅកាន់វិហារ ។ មានភិក្ខុនីឯទៀតទុកដាក់ចីវរនោះដោយគិតថា កុំឲ្យចីវរនេះបាត់ទៅឡើយ ។ ភិក្ខុនីជាម្ចាស់ចីវរនោះចេញពីវិហារទៅ ហើយសួរភិក្ខុនីនោះថា នាង ចីវររបស់ខ្ញុំអ្នកណាលួចយកទៅ ។ ភិក្ខុនីនោះពោលតបយ៉ាងនេះថា (ចីវរនាង) យើងលួចយកហើយ ។ ភិក្ខុនីម្ចាស់ចីវរនោះចោទប្រកាន់ភិក្ខុនីនោះថា នាងមិនមែនជាសមណីទេ ។

តស្សា កុក្កុច្ចំ អហោសិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ ចិត្តុប្បាទេ ។

(១៣៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វាតមណ្ឌលិកាយ ឧក្ខិត្តំ សាដកំ បស្សិត្វា សាមិកានំ ទស្សាមីតិ អគ្គហេសិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កិំចិត្តោ ត្វំ ភិក្ខូតិ ។ អថេយ្យចិត្តោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ អថេយ្យចិត្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វាតមណ្ឌលិកាយ ឧក្ខិត្តំ វេឋនំ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តោ អគ្គហេសិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ



ភិក្ខុនីនោះមានសេចក្តីសង្ស័យ ។ ទើបភិក្ខុនីនោះប្រាប់សេចក្តីនុះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយបានប្រាប់សេចក្តីនុះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើត្រឹមតែគោលពាក្យទេ (ភិក្ខុនីនេះ) មិនត្រូវអាបត្តិឡើយ ។

(១៣៣) សម័យនោះឯង មានភិក្ខុ ១ រូប ឃើញសម្ពត់សាដក ហើរទៅដោយខ្យល់កំបុតត្បូង ក៏បានរើសយកដោយគិតថា អញនឹងឲ្យដល់ជនទាំងឡាយជាម្ចាស់សម្ពត់ ។ ពួកម្ចាស់សម្ពត់ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានថេយ្យចិត្តគិតលួចទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនមានថេយ្យចិត្តឥតមានអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប មានថេយ្យចិត្តហើយបានរើសយកឈ្នួតក្បាលរបស់គេ ដែលហើរទៅដោយខ្យល់កំបុតត្បូង ដោយគិតថា ក្រែងម្ចាស់របស់ទាំងឡាយឃើញមុន (ហើយយកទៅ) ។ ពួកម្ចាស់របស់ចោទ

អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ ថេយ្យចិត្តោ អហំ ភគវាតិ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៣៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សុសានំ គន្ត្វា អភិន្នេ សរីរេ បំសុកូលំ អគ្គហេសិ ។ តស្មឹ ច សរីរេ បេតោ អធិវត្ថោ ហោតិ ។ អថ ខោ សោ បេតោ តំ ភិក្ខុំ ឯតទវោច មា ភន្តេ មយ្ហំ សាដកំ អគ្គហេសីតិ ។ សោ ភិក្ខុ អនាទិយន្តោ អគ្គហេសិ(១) ។ អថ ខោ តំ សរីរំ ឧដ្ឋហិត្វា តស្ស ភិក្ខុនោ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អថ ខោ សោ ភិក្ខុ វិហារំ បវិសិត្វា ទ្វារំ ថកេសិ ។ អថ ខោ តំ សរីរំ តត្ថេវ បរិបតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស ។ ន ច ភិក្ខវេ អភិន្នេ សរីរេ បំសុកូលំ គហេតព្វំ យោ គណ្ហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

១ ម.ឆ. អគ្គហេសិ ។





ប្រាប់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានចិត្តគិតលួច ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងលួចមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៣៦] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ទីស្មសាន ហើយបានកាន់យកសម្ពត់បំសុកូលអំពីសរីរៈខ្មោចដែលមិនទាន់បែកធ្លាយ ។ តែក្នុងសរីរៈខ្មោចនោះមានប្រេតមកអាស្រ័យនៅ ។ គ្រានោះ ប្រេតនោះបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា បពិត្រលោកដ៏ចំរើន លោកកុំយកសាដករបស់ខ្ញុំឡើយ ។ ភិក្ខុនោះមិនអើពើនឹងពាក្យប្រេតនោះ ក៏នៅតែកាន់យកទៅ ។ ខណៈនោះសរីរៈនោះក្រោកឡើង ហើយដេញជាប់តាមក្រោយខ្នងភិក្ខុនោះ ។ លំដាប់នោះឯង ភិក្ខុនោះក៏ចូលទៅកាន់វិហារ ហើយបិទទ្វារ ។ សរីរៈនោះ ក៏ដួលក្នុងទីនោះឯង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីកាន់យកសម្ពត់បំសុកូលអំពីសរីរៈខ្មោចដែលមិនទាន់បែកធ្លាយ ភិក្ខុណាកាន់យក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

[១៣៤] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស ចីវរេ ភាជិយមានេ ថេយ្យចិត្តោ កុសំ សង្កាមេត្វា ចីវរំ អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៣៥] តេន ខោ បន សមយេន អាយស្មា អានន្ទោ ជន្តាឃរេ អញ្ញតរស្ស ភិក្ខុនោ អន្តរវាសកំ អត្តនោ មញ្ញមានោ និវាសេសិ ។ អថខោ សោ ភិក្ខុ អាយស្មន្តំ អានន្ទំ ឯតទវោច កិស្ស មេ ត្វំ អាវុសោ អានន្ទ អន្តរវាសកំ និវាសេសីតិ ។ សកសញ្ញី អហំ អាវុសោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ សកសញ្ញិស្សាតិ ។

[១៣៦] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ គិជ្ឈកូដា បព្វតា ឱរោហន្តា សីហវិឃាសំ បស្សិត្វា បចាបេត្វា បរិភុញ្ជិំសុ ។ តេសំ កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ សីហវិឃាសេតិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ គិជ្ឈកូដា បព្វតា ឱរោហន្តា



[១៣៤] សម័យនោះឯង មានភិក្ខុ១រូប កាលគេកំពុងតែចែកចីវរ របស់សង្ឃ មានថេយ្យចិត្តគិតលួច ហើយបានផ្លាស់ស្លាកខ្លួន លួចយកចីវរភិក្ខុដទៃ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៣៥] សម័យនោះឯង ព្រះអានន្ទដ៏មានអាយុសំគាល់ស្បង់ របស់ភិក្ខុដទៃថាជារបស់ខ្លួន ហើយស្លៀកក្នុងរោងភ្លើង ។ គ្រានោះឯង ភិក្ខុម្ចាស់ស្បង់នោះ បានសួរព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោ អានន្ទ ហេតុអ្វីបានជាលោកស្លៀកស្បង់របស់ខ្ញុំ ។ ព្រះអានន្ទនិយាយតបថា អាវុសោ ខ្ញុំសំគាល់ថាជារបស់ខ្ញុំ ។ ពួកភិក្ខុក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុអ្នកកាន់យកដោយសំគាល់ថា ជារបស់ខ្លួនទេ ។

[១៣៦] សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ចុះពីភ្នំគិជ្ឈកូដ បានឃើញកាកសត្វសីហ ហើយយកមកចម្អិនឆាន់ ។ ភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការឆាន់កាកសត្វសីហ មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ចុះ

ព្យគ្ឃវិឃាសំ បស្សិត្វា ។ បេ ។ ទីបិវិឃាសំ បស្សិត្វា ។ បេ ។ តរច្ឆវិឃាសំ បស្សិត្វា ។ បេ ។ កោកវិឃាសំ បស្សិត្វា បចាបេត្វា បរិភុញ្ជិំសុ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ តិរច្ឆានគតបរិគ្គហេតិ ។

(១៣៥) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស ឱទនេ ភាជិយមានេ អបរស្ស ភាគំ ទេហីតិ អមូលកំ អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សម្បជានមុសាវាទេ បាចិត្តិយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស ខាទនីយេ ភាជិយមានេ ។ បេ ។ សង្ឃស្ស បូវេ ភាជិយមានេ ។ បេ ។ សង្ឃស្ស ឧច្ឆុម្ហិ ភាជិយមានេ ។ បេ ។ សង្ឃស្ស តិម្ពរូសកេ ភាជិយមានេ អបរស្ស ភាគំ ទេហីតិ អមូលកំ អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។



អំពីភិក្ខុជាច្រើន ហើយបានឃើញកាសត្វខ្លាធំ ។ បេ ។ ឃើញកាសត្វខ្លាដំបង ។ បេ ។ ឃើញកាសត្វឆ្កែចចក[1] ។ បេ ។ ឃើញកាសត្វឆ្កែព្រៃ ហើយនាំគ្នាយកមកចំអិនបរិភោគ ។ ភិក្ខុទាំងឡាយនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុជារបស់សត្វតិរច្ឆាន មិនត្រូវអាបត្តិឡើយ ។

(១៣៥) សម័យនោះឯង មានភិក្ខុ ១ រូប កាលគេកំពុងចែកបាយដល់សង្ឃ ខ្លួននិយាយថា លោកម្ចាស់ ១ ចំណែកទៀតដើម្បីភិក្ខុផង ជាដូច្នោះហើយក៏កាន់យកបាយនោះដោយឥតមានមូល ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហកប៉ុណ្ណោះ ។ សម័យនោះឯង មានភិក្ខុ ១ រូប កាលគេកំពុងចែកខាទនីយាហារដល់សង្ឃ ។ បេ ។ កាលគេកំពុងចែកនំដល់សង្ឃ ។ បេ ។ កាលគេកំពុងចែកអំពៅដល់សង្ឃ ។ បេ ។ កាលគេកំពុងចែកផ្លែទន្លាប់ដល់សង្ឃ ក៏ពោលថា លោកម្ចាស់ ១ ចំណែកដើម្បីភិក្ខុឯទៀតផង ជាដូច្នោះហើយក៏កាន់យកចំណែកនោះដោយឥតមានមូល ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា

---

១ ប្រែថា ឆ្កែព្រៃ ក៏បាន ។

អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សម្បជានមុសាវាទេ បាចិត្តិយស្សាតិ ។

[១៣៩] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទុព្ភិក្ខេ ឱទនិយឃរំ បវិសិត្វា បត្តបូរំ ឱទនំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទុព្ភិក្ខេ សូនឃរំ បវិសិត្វា បត្តបូរំ មំសំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទុព្ភិក្ខេ បូវឃរំ បវិសិត្វា បត្តបូរំ បូវំ ថេយ្យចិត្តោ អវហរិ ។ បេ ។ បត្តបូរំ សក្ខលិយោ ថេយ្យចិត្តោ អវហរិ ។ បេ ។ បត្តបូរំ មោទកេ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។



ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហកប៉ុណ្ណោះ ។

[១៣៩] សម័យនោះឯង មានភិក្ខុ១រូបចូលទៅកាន់ផ្ទះដែលគេដាំបាយ ក្នុងវេលាស្រែកអត់បាយ មានថេយ្យចិត្តហើយបានលួចយកបាយពេញ១បាត្រ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ផ្ទះរបស់អ្នកចំអិនសាច់លក់ក្នុងវេលាស្រែកអត់បាយ ហើយមានថេយ្យចិត្តលួចយកសាច់ដាក់ពេញ១បាត្រ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ផ្ទះធ្វើនំក្នុងវេលាស្រែកអត់បាយ ហើយមានថេយ្យចិត្តបានលួចយកនំដាក់ពេញ១បាត្រ ។ បេ ។ មានថេយ្យចិត្តហើយលួចយកនំក្រៀបដាក់ពេញ១បាត្រ ។ បេ ។ មានថេយ្យចិត្តហើយបានលួចយកនំអន្សមដាក់ពេញ១បាត្រ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៦០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទិវា បរិក្ខារំ បស្សិត្វា និមិត្តំ អកាសិ រត្តឹ អវហរិស្សាមីតិ ។ សោ តំ មញ្ញមានោ តំ អវហរិ ។បេ។ តំ មញ្ញមានោ អញ្ញំ អវហរិ ។បេ។ អញ្ញំ មញ្ញមានោ តំ អវហរិ ។បេ។ អញ្ញំ មញ្ញមានោ អញ្ញំ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ទិវា បរិក្ខារំ បស្សិត្វា និមិត្តំ អកាសិ រត្តឹ អវហរិស្សាមីតិ ។ សោ តំ(១) មញ្ញមានោ អត្តនោ បរិក្ខារំ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។

(១៦១) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បីឋេ(២) ទុស្សំ បស្សិត្វា ឥតោ គណ្ហន្តោ បារាជិកោ ភវិស្សាមីតិ សហ បីឋកេន សង្កាមេត្វា អវហាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

---

១ ម. ន. អញ្ញំ ។ ២ ម. ម. ចីវេ បីឋកំ ។



[១៦០] សម័យនោះឯង មានភិក្ខុ ១ រូប ឃើញបរិក្ខារក្នុងវេលាថ្ងៃ ហើយធ្វើនិមិត្តទុកថា អញនឹងលួចយកក្នុងវេលាយប់ ។ ភិក្ខុនោះសំគាល់របស់នោះដូច្នេះហើយ លួចយករបស់នោះឯងមក ។បេ។ សំគាល់របស់នោះដូច្នេះហើយ លួចយករបស់ដទៃមកវិញ ។បេ។ សំគាល់របស់ដទៃ ត្រឡប់លួចយករបស់នោះមកវិញ ។បេ។ សំគាល់របស់ដទៃ លួចយករបស់ដទៃមក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ឃើញបរិក្ខារក្នុងវេលាថ្ងៃ ហើយក៏ធ្វើនិមិត្តទុកថា អញនឹងលួចយកក្នុងវេលាយប់ ។ ភិក្ខុនោះសំគាល់របស់នោះហើយ ត្រឡប់លួចយកបរិក្ខាររបស់ខ្លួនឯងមកវិញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

(១៦១) សម័យនោះឯង មានភិក្ខុ ១ រូប ឃើញសំពត់ដាក់នៅលើតាំង ហើយគិតថា កាលអញយកសំពត់អំពីទីនេះ មុខជានឹងត្រូវអាបត្តិបារាជិក ហើយក៏លើកយកសំពត់នោះព្រមទាំងតាំងទៅផង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៦៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស ភិសឹ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៦៧] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ចីវរវំសេ ចីវរំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៦៨] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វិហារេ ចីវរំ អវហរិត្វា ថេនោ និក្ខមន្តោ បារាជិកោ ភវិស្សាមីតិ វិហារា ន និក្ខមិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ និក្ខមេយ្យ វា សោ ភិក្ខវេ មោឃបុរិសោ ន វា និក្ខមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[១៦៩] តេន ខោ បន សមយេន ទ្វេ ភិក្ខូ សហាយកា ហោន្តិ ឯកោ[១] គាមំ បិណ្ឌាយ បាវិសិ ទុតិយោ[២] សង្ឃស្ស ខាទនីយេ ភាជិយមានេ សហាយកស្ស ភាគំ គហេត្វា

---

១ ឱ. ឯកោ ភិក្ខុ ។ ២ សព្វត្ថ ទុតិយោ ភិក្ខូតិ អាគតំ ។



[១៦៦] សម័យនោះឯង ភិក្ខុ១រូបមានថេយ្យចិត្ត ហើយលួចយកភួករបស់សង្ឃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៦៧] សម័យនោះឯង ភិក្ខុ១រូបមានថេយ្យចិត្ត ហើយលួចយកចីវរដែលដាក់លើខ្សែស្ពៀវ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៦៨] សម័យនោះឯង មានភិក្ខុ១រូបលួចយកចីវរក្នុងវិហារ ហើយគិតថា កាលអញចេញអំពីវិហារនេះទៅ អញនឹងត្រូវអាបត្តិបារាជិកមិនខាន ហើយក៏ពុំបានចេញអំពីវិហារឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះគប្បីចេញទៅក្តី មិនគប្បីចេញទៅក្តី គង់តែត្រូវអាបត្តិទុក្កដដែរ ។

[១៦៩] សម័យនោះឯង មានភិក្ខុ២រូបជាសំឡាញ់នឹងគ្នា ភិក្ខុ១រូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឯភិក្ខុទី២ កាលបើគេចែកខាទនីយាហារដល់សង្ឃ ក៏បានកាន់យកចំណែករបស់ភិក្ខុជាសំឡាញ់

តស្ស វិស្សាសគ្គា បរិភុញ្ជិ ។ សោ ជានិត្វា តំ ចោទេសិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កិំចិត្តោ ត្វំ ភិក្ខូតិ ។ វិស្សាសគ្គាហោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ វិស្សាសគ្គាហេតិ ។

[១៤៦] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ចីវរកម្មំ ករោន្តិ ។ សង្ឃស្ស ខាទនីយេ ភាជិយមានេ សព្វេសំ បដិវីសា អាហរិត្វា ឧបនិក្ខិត្តា ហោន្តិ ។ អញ្ញតរោ ភិក្ខុ អញ្ញតរស្ស ភិក្ខុនោ បដិវីសំ អត្តនោ មញ្ញមានោ បរិភុញ្ជិ ។ សោ ជានិត្វា តំ ចោទេសិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សកសញ្ញិស្សាតិ[១] ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ចីវរកម្មំ ករោន្តិ ។ សង្ឃស្ស ខាទនីយេ ភាជិយមានេ អញ្ញតរស្ស ភិក្ខុនោ បត្តេន

១ ឱ. ម. សញ្ញិស្សាតិ ។



ហើយបរិភោគដោយសេចក្ដីស្និទ្ធស្នាលនឹងគ្នា ។ ភិក្ខុសំឡាញ់នោះដឹង ហើយចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណទេ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នក មានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គកាន់យកដោយសេចក្ដីស្និទ្ធស្នាលនឹងគ្នា ។ ព្រះអង្គទ្រង់ត្រាស់ ថា ម្នាលភិក្ខុ បើកាន់យកដោយសេចក្ដីស្និទ្ធស្នាលដូច្នោះ អ្នកមិនត្រូវ អាបត្តិឡើយ ។

[១៤៦] សម័យនោះឯង ភិក្ខុច្រើនរូប ធ្វើនូវចីវរកម្ម ។ កាល គេចែកខាទនីយាហារដល់សង្ឃ ខាទនីយាហារជាចំណែករបស់ភិក្ខុទាំង អស់នោះ គេក៏បាននាំយកទៅទុកដាក់ ១ កន្លែងហើយ ។ មានភិក្ខុ ១ រូប សំគាល់ចំណែករបស់ភិក្ខុឯទៀតថាជារបស់ខ្លួន ហើយឆាន់អស់ទៅ ។ ភិក្ខុម្ចាស់របស់នឹងដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់ ខ្លួន ។ សម័យនោះឯង ភិក្ខុច្រើនរូបធ្វើនូវចីវរកម្ម ។ កាលគេចែក ខាទនីយាហារដល់សង្ឃ ភិក្ខុយកបាត្រ(ភិក្ខុឯទៀត)មកទទួលយកចំណែក

អញ្ញតរស្ស ភិក្ខុនោ បដិវិសោ បត្តេ ឋបិតោ ហោតិ ។ បត្តសាមិកោ ភិក្ខុ អត្តនោ សញ្ញាយ បរិភុញ្ជិ ។ សោ ជានិត្វា តំ ចោទេសិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សកសញ្ញាយាតិ ។

[១៤៧] តេន ខោ បន សមយេន អម្ពចោរកា អម្ពំ បាតេត្វា ភណ្ឌិកំ អាទាយ អគមំសុ ។ សាមិកា តេ ចោរេ អនុពន្ធឹសុ ។ ចោរកា សាមិកេ បស្សិត្វា ភណ្ឌិកំ បាតេត្វា បលាយឹសុ ។ ភិក្ខូ តំ បំសុកូលសញ្ញាយ បដិគ្គហាបេត្វា បរិភុញ្ជឹសុ ។ សាមិកា តេ ភិក្ខូ ចោទេសុំ អស្សមណាត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ កឹចិត្តា តុម្ហេ ភិក្ខវេតិ ។ បំសុកូលសញ្ញិនោ មយំ ភគវាតិ ។



របស់ភិក្ខុដទៃទៀត ហើយយកទៅទុក ។ ភិក្ខុម្ចាស់បាត្រស្គាល់ជាក់របស់ខ្លួន ហើយឆាន់អស់ទៅ ។ ភិក្ខុនោះដឹងហើយចោទប្រកាន់ភិក្ខុម្ចាស់បាត្រនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលស្គាល់ជាក់របស់ខ្លួន ។

[១៤៧] សម័យនោះឯង ពួកចោរលួចស្វាយ បេះផ្លែស្វាយបាន ហើយវេចសំពាយស្វាយដើរទៅ ។ ពួកមនុស្សជាម្ចាស់ស្វាយនាំគ្នាដេញតាមពួកចោរអស់នោះ ។ ពួកចោរឃើញម្ចាស់ស្វាយទាំងឡាយដេញតាម ក៏ទំលាក់សំពាយស្វាយរត់គេចទៅ ។ ភិក្ខុទាំងឡាយស្គាល់សំពាយស្វាយនោះ ថាជារបស់បង្សុកូល ហើយឆាន់ទៅ ។ ពួកម្ចាស់ស្វាយចោទប្រកាន់ភិក្ខុអស់នោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានចិត្តគិតដូចម្តេច ។ ភិក្ខុទាំងឡាយនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយស្គាល់ថាជារបស់បង្សុកូល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

អនាបត្តិ ភិក្ខវេ បំសុកូលសញ្ញិស្សាតិ ។ តេន ខោ បន សមយេន ជម្ពុចោរកា ។បេ។ លពុជចោរកា ។បេ។ បនសចោរកា ។បេ។ តាលបក្កចោរកា ។បេ។ ឧច្ឆុចោរកា ។បេ។ តិម្ពរូសកចោរកា តិម្ពរូសកេ ឱចិនិត្វា ភណ្ឌិកំ អាទាយ អគមំសុ ។ សាមិកា តេ ចោរេ អនុពន្ធឹសុ ។ ចោរា សាមិកេ បស្សិត្វា ភណ្ឌិកំ បាតេត្វា បលាយឹសុ ។ ភិក្ខូ តំ បំសុកូលសញ្ញិនោ បដិគ្គាហាបេត្វា បរិភុញ្ជឹសុ ។ សាមិកា តេ ភិក្ខូ ចោទេសុំ អស្សមណត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ បំសុកូលសញ្ញិស្សាតិ ។

[១៥៨] តេន ខោ បន សមយេន អម្ពចោរកា អម្ពំ បាតេត្វា ភណ្ឌិកំ អាទាយ អគមំសុ ។ សាមិកា តេ ចោរេ អនុពន្ធឹសុ ។ ចោរា សាមិកេ បស្សិត្វា ភណ្ឌិកំ បាតេត្វា បលាយឹសុ ។ ភិក្ខូ បុរេ សាមិកា បស្សន្តិ ថេយ្យចិត្តា បរិភុញ្ជឹសុ ។ សាមិកា តេ ភិក្ខូ





កាលបើមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូលឡើយ ។ សម័យនោះឯង ពួកចោរលួចព្រីង ។បេ។ ពួកចោរលួចខ្នុរសំឡ ។បេ។ ពួកចោរលួចខ្នុរណាំង ។បេ។ ពួកចោរលួចត្នោតទុំ ។បេ។ ពួកចោរលួចអំពៅ ។បេ។ ពួកចោរលួចផ្លែទន្លាប់ នាំគ្នាលួចបេះផ្លែទន្លាប់ពីដើមឈើ ចងហើយរែកជាសំពាយស្ពាយដើរទៅ ។ ពួកម្ចាស់ទន្លាប់ដេញតាមពួកចោរអម្បាលនោះ ។ ពួកចោរទាំងឡាយឃើញពួកម្ចាស់ទន្លាប់ហើយក៏ទំលាក់សំពាយចោលរត់ទៅ ។ ភិក្ខុទាំងឡាយឃើញ សំគាល់នូវសំពាយនោះថាជារបស់បំសុកូល ហើយនាំគ្នាទទួលទានទៅ ។ ពួកជនជាម្ចាស់នាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល ។

[១៥៨] សម័យនោះឯង ពួកចោរលួចស្វាយ បេះផ្លែស្វាយចុះ ហើយរែកជាសំពាយស្ពាយដើរទៅ ។ ពួកម្ចាស់ស្វាយដេញតាមពួកចោរទាំងអម្បាលនោះ ។ ពួកចោរទាំងឡាយឃើញពួកម្ចាស់ស្វាយ ហើយទំលាក់សំពាយចោលរត់ទៅ ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ស្វាយគេឃើញមុន ទើបនាំគ្នាឆាន់អស់ទៅ ។ ពួកម្ចាស់ស្វាយ

ចោទេសុំ អស្សមណត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ តុម្ហេ ភិក្ខវេ អាបន្នា បារាជិកន្តិ ។ តេន ខោ បន សមយេន ជម្ពុចោរកា ។ បេ ។ លពុជចោរកា ។ បេ ។ បនសចោរកា ។ បេ ។ តាលបក្កចោរកា ។ បេ ។ ឧច្ឆុចោរកា ។ បេ ។ តិម្ពរូសកចោរកា តិម្ពរូសកេ ឧច្ចិនិត្វា ភណ្ឌិកំ អាទាយ អគមំសុ ។ សាមិកា តេ ចោរេ អនុពន្ធឹសុ ។ ចោរកា សាមិកេ បស្សិត្វា ភណ្ឌិកំ បាតេត្វា បលាយឹសុ ។ ភិក្ខូ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តា បរិភុញ្ជឹសុ ។ សាមិកា តេ ភិក្ខូ ចោទេសុំ អស្សមណត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ តុម្ហេ ភិក្ខវេ អាបន្នា បារាជិកន្តិ ។

(១៦៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស អម្ពំ ថេយ្យចិត្តោ អវហរិ ។ បេ ។ សង្ឃស្ស ជម្ពុំ ។ បេ ។



នាំគ្នាទៅចោទប្រកាន់ពួកភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ពួកចោរលួចព្រីង ។ បេ ។ ពួកចោរលួចខ្នុរសំឡូ ។ បេ ។ ពួកចោរលួចផ្លែខ្នុរណាំង ។ បេ ។ ពួកចោរលួចផ្លែត្នោតទុំ ។ បេ ។ ពួកចោរលួចអំពៅ ។ បេ ។ ពួកចោរលួចផ្លែទន្លាប់ លួចរបស់ផ្លែទន្លាប់ទាំងឡាយបានហើយ វេចជាសំពាយស្ពាយដើរទៅ ។ ម្ចាស់ទន្លាប់ទាំងឡាយដេញតាមពួកចោរអម្បាលនោះ ។ ចោរទាំងឡាយ ឃើញម្ចាស់ទន្លាប់ហើយ ទំលាក់សំពាយចោលហើយរត់ទៅ ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ទន្លាប់ទាំងឡាយគេមកឃើញមុន ទើបនាំគ្នាឆាន់អស់ទៅ ។ ម្ចាស់ទន្លាប់ទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[១៦៨] សម័យនោះឯង ភិក្ខុ ១ រូប មានថេយ្យចិត្តលួចយកស្វាយរបស់សង្ឃ ។ បេ ។ លួចយកផ្លែព្រីងរបស់សង្ឃ ។ បេ ។

សង្ឃស្ស លពុជំ ។ បេ ។ សង្ឃស្ស បនសំ ។ បេ ។ សង្ឃស្ស តាលបក្កំ ។ បេ ។ សង្ឃស្ស ឧច្ឆុំ ។ បេ ។ សង្ឃស្ស តិម្ពរូសកំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៨០] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បុប្ផារាមំ គន្ត្វា ឱចិតំ បុប្ផំ បញ្ចមាសកគ្ឃនកំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បុប្ផារាមំ គន្ត្វា បុប្ផំ ឱចិនិត្វា បញ្ចមាសកគ្ឃនកំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៨១] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គាមកំ គច្ឆន្តោ អញ្ញតរំ ភិក្ខុំ ឯតទវោច អាវុសោ តុយ្ហំ ឧបដ្ឋាកកុលំ វុត្តោ វជ្ជេមីតិ ។ សោ គន្ត្វា ឯកំ សាដកំ អាហរាបេត្វា អត្តនា បរិភុញ្ជិ ។



លួចយកផ្លែខ្នុរសំឡរបស់សង្ឃ ។ បេ ។ លួចយកផ្លែខ្នុរណាំងរបស់សង្ឃ ។ បេ ។ លួចយកផ្លែត្នោតទុំរបស់សង្ឃ ។ បេ ។ លួចយកអំពៅរបស់សង្ឃ ។ បេ ។ មានថេយ្យចិត្តហើយលួចយកផ្លែខ្លាប់របស់សង្ឃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៨០) សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់សួនផ្កា ហើយមានថេយ្យចិត្តលួចយកផ្កាមានតំលៃ ៥ មាសកដែលម្ចាស់គេបេះទុក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់សួនផ្កា ហើយមានថេយ្យចិត្តលួចបេះផ្កាមានតំលៃ ៥ មាសក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៨១) សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ស្រុកតូចមួយ ហើយបាននិយាយនឹងភិក្ខុ ១ រូបថា អាវុសោ លោកផ្តាំខ្ញុំហើយ ខ្ញុំនឹងទៅប្រាប់ត្រកូលជាឧបដ្ឋាករបស់លោក ។ ភិក្ខុនោះទៅហើយបានឲ្យត្រកូលនោះយកសម្ពត់សាដក ១ មក ហើយប្រើប្រាស់ដោយខ្លួនឯង ។

សោ ជានិត្វា ន ទោនេសុំ អស្សមបណោ.
សុំ ទិដ្ឋិ ។ តស្ស ញាត្តុំ អបោសុំ ។ បេ ។
អនាបត្តិ ភិក្ខុ ឋាភេតកស្ស ៤ ៤ ភិក្ខុវេ វុត្តា
វត្ថុមត្តំ វត្តព្វា យោ វទេយ្យ អាបត្តិ ទុក្កដស្សាតិ ។
តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ តាមតំ
តទ្ធតំ ។ អញ្ញតរោ ភិក្ខុ នំ ភិក្ខុំ ឯតទវោច
អាវុសោ មយ្ហំ ឧបជ្ឈាកាកុសំ វុត្តា វត្ថុមំគំ ។
សោ តុដ្ឋោ ឃុតសាជតំ អាបាកបេត្វា ឯតំ អត្ថា
ឋាភេត្វា ឯតំ តស្ស ភិក្ខុនោ អនាសុំ ។ សោ
ជានិត្វា ន ទោនេសុំ អស្សមបណោសុំ ទិដ្ឋិ ។ តស្ស
ញាត្តុំ អបោសុំ ។ បេ ។ អនាបត្តិ ភិក្ខុ ឋាភេតកស្ស
៤ ៤ ភិក្ខុវេ វុត្តា វត្ថុមត្តំ វត្តព្វា យោ វទេយ្យ អាបត្តិ
ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ
ភិក្ខុ តាមតំ តទ្ធត្ថា អញ្ញតរំ ភិក្ខុំ ឯតទវោច
អាវុសោ មយ្ហំ ឧបជ្ឈាកាកុសំ វុត្តា វត្ថុមំគំ ។ សោមុំ





ភិក្ខុមកជិតដល់ទីវត្តហើយ ទោះបើកាន់ភិក្ខុនោះថា លោកមិន
មែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ
តែភិក្ខុកុំគប្បីពោលថា អ្នកដាំទុំហើយ ទុំនឹងត្រូវប់សួរ តែភិក្ខុណាពោល
ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូប ទៅកាន់
ស្រុកដទៃមួយ ។ ភិក្ខុឯទៀតបាននិយាយពាក្យនេះនឹងភិក្ខុនោះថា អាវុសោ
ទុំបាំហើយ លោកត្រូវប់ត្រូវឧបជ្ឈាយ៍របស់ខ្លួន ។ ភិក្ខុនោះទៅហើយ
ឲ្យត្រូវឧបជ្ឈាយ៍នោះយកសំពត់សាដក ១ មក ហើយប្រើប្រាស់
សំពត់សាដក ១ ដោយខ្លួនឯង រួចឲ្យសំពត់សាដក ១ ដល់ភិក្ខុមកជិតដល់
ទីវត្តនោះ ។ ភិក្ខុនោះដឹងហើយ ទោះបើកាន់ភិក្ខុនោះថា លោកមិន
មែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់
ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ តែភិក្ខុកុំគប្បីពោល
ថា លោកចុំបាំហើយ ទ្រាប់ចុះដូច្នេះ តែភិក្ខុណាពោល ភិក្ខុនោះ
ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូប ទៅកាន់ស្រុកដទៃ
មួយ ហើយបាននិយាយពាក្យនេះនឹងភិក្ខុឯទៀតថា អាវុសោ លោក
ដាំទីទុំហើយ ទុំនឹងត្រូវប់ត្រូវឧបជ្ឈាយ៍របស់លោក ។ ឯភិក្ខុនោះ

ឯវមាហ វុត្តោ វជ្ជេហីតិ ។ សោ តត្ថ អានេត្វា សាដកំ តុលំ កុម្ភំ ទោណំ តណ្ឌុលំ អាហរាបេត្វា អត្តនា បរិភុញ្ជិ ។ សោ ជានិត្វា តំ ចោទេសិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស ឧ ឲ ភិក្ខូ វុត្តោ វជ្ជេមីតិ វុត្តញ្ច ឧ ឲ វុត្តោ វជ្ជេហីតិ វុត្តញ្ច យោ វជ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៨៦) តេន ខោ បន សមយេន អញ្ញតរោ បុរិសោ មហគ្ឃំ មណឹ អាទាយ អញ្ញតរេន ភិក្ខុនា សទ្ធឹ អទ្ធានមគ្គប្បដិបន្នោ ហោតិ ។ អថ ខោ សោ បុរិសោ សុង្កដ្ឋានំ បស្សិត្វា តស្ស ភិក្ខុនោ អជានន្តស្ស ថវិកាយ មណឹ បក្ខិបិត្វា សុង្កដ្ឋានំ អតិក្កមិត្វា អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ នាហំ ភគវា ជានាមីតិ ។



ក៏បាននិយាយយ៉ាងនេះថា ខ្ញុំបានផ្តាំផ្ញើលោកហើយ លោកប្រាប់ចុះ ។ ភិក្ខុនោះទៅហើយឲ្យគ្រួសារបញ្ជូនកញ្ចប់នោះយកសំពត់ ១ សម្ពុកៈ(១) ស្ករអំពៅ ១ តុលៈ(២) អង្ករ ១ ទោណៈ(៣)មកហើយបរិភោគដោយខ្លួនឯង ។ ភិក្ខុអ្នកជិតដិតនឹងគ្រួសារនោះដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថា លោកផ្តាំផ្ញើខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ ម្យ៉ាងទៀត កុំគប្បីពោលថា ខ្ញុំផ្តាំផ្ញើលោកហើយ លោកប្រាប់ចុះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

(១៨៦) សម័យនោះឯង បុរសម្នាក់នាំយកកែវមណីមានដំឡៃច្រើន ហើយដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុឯទៀត ។ លំដាប់នោះ បុរសនោះឃើញទីគយហើយ ដាក់កែវមណីក្នុងថង់យាមរបស់ភិក្ខុនោះ ។ ឥតដឹងឡើយ លុះកន្លងផុតទីគយហើយ ក៏យកកែវមណីពីថង់យាមមកវិញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច ។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិន

១ មាត្រាវាល់ធ្ងន់ស្មើនឹងមានៈ ៤ តម្លឹង ១ អាឡ្ហកៈ ។ ២ ទម្ងន់ ២០ ដំឡឹង ។ ៣ ត្រឡឹងវាល់ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ ។

អនាបត្តិ អជានន្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ បុរិសោ មហគ្ឃំ មណឹ អាទាយ អញ្ញតរេន ភិក្ខុនា សទ្ធឹ អទ្ធានមគ្គប្បដិបន្នោ ហោតិ ។ អថខោ សោ បុរិសោ សុង្កដ្ឋានំ បស្សិត្វា គិលានាលយំ ករិត្វា អត្តនោ ភណ្ឌិកំ តស្ស ភិក្ខុនោ អទាសិ ។ អថខោ សោ បុរិសោ សុង្កដ្ឋានំ អតិក្កមិត្វា តំ ភិក្ខុំ ឯតទវោច អាហរ មេ ភន្តេ ភណ្ឌិកំ នាហំ អគិលានោតិ ។ កិស្ស បន ត្វំ អាវុសោ ឯវរូបំ អកាសីតិ ។ អថខោ សោ បុរិសោ តស្ស ភិក្ខុនោ ឯតមត្ថំ អារោចេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ នាហំ ភគវា ជានាមីតិ ។ អនាបត្តិ ភិក្ខុ អជានន្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សត្ថេន សទ្ធឹ អទ្ធានមគ្គប្បដិបន្នោ ហោតិ ។ អញ្ញតរោ បុរិសោ តំ ភិក្ខុំ អាមិសេន ឧបលាបេត្វា សុង្កដ្ឋានំ បស្សិត្វា មហគ្ឃំ មណឹ តស្ស ភិក្ខុនោ អជានន្តស្ស ថវិកាយ បក្ខិបិត្វា សុង្កដ្ឋានំ អតិក្កាមេតិ ។



ទាន់ដឹងសោះឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមិនដឹង ។ សម័យនោះឯង បុរសម្នាក់នាំយកកែវមណីមានដំឡៃច្រើនទៅកាន់ផ្លូវឆ្ងាយជាមួយនឹងភិក្ខុឯទៀត ។ លំដាប់នោះ បុរសនោះឃើញទីគយហើយ ក៏ធ្វើអាការឈាក់ខ្លួនជាឈឺ ហើយបានប្រគល់បង្វិចកែវមណីរបស់ខ្លួនដល់ភិក្ខុនោះ ។ គ្រានោះឯង បុរសនោះដើររំលងទីហួសទីគយទៅហើយ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ សូមលោកយកបង្វិចរបស់ខ្ញុំមក ខ្ញុំមិនឈឺទេ ។ ភិក្ខុនោះសួរថា អាវុសោ ចុះហេតុអ្វីបានជាអ្នកធ្វើអាការយ៉ាងនេះ ។ ទើបបុរសនោះប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុនោះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្ដេច ។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងសោះឡើយ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមិនដឹង ។ សម័យនោះឯង មានភិក្ខុ ១ រូប ដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងពួកឈ្មួញរទេះ ។ បុរសម្នាក់ក៏លួងលោមភិក្ខុនោះដោយអាមិស លុះឃើញទីគយហើយ បានដាក់កែវមណីមានដំឡៃច្រើនដល់ភិក្ខុនោះដោយពាក្យថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់យកកែវមណីនេះ ឲ្យរំលងទីគយទៅផង ។

អថ ខោ សោ ភិក្ខុ តំ មណឹ សុង្កដ្ឋានំ អតិក្កាមេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៨៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បាសេ ពទ្ធំ សូករំ ការុញ្ញេន មុញ្ចិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ ការុញ្ញាធិប្បាយោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ ការុញ្ញាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បាសេ ពទ្ធំ សូករំ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តោ មុញ្ចិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បាសេ ពទ្ធំ មិគំ ការុញ្ញេន មុញ្ចិ ។ បេ ។ បាសេ ពទ្ធំ មិគំ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តោ មុញ្ចិ



ភិក្ខុនោះយកកែវមណិនោះ រំលងទីគយទៅក្នុងកាលនោះឯង ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៨៣) សម័យនោះឯង មានភិក្ខុ ១ រូប ដោះលែងជ្រូកជាប់អន្ទាក់ ដោយសេចក្ដីករុណា ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានសេចក្ដីប្រាថ្នាដោយសេចក្ដីករុណា (ហើយដោះលែងទៅ) ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមានសេចក្ដីប្រាថ្នាដោយសេចក្ដីករុណាទេ ។ សម័យនោះឯង មានភិក្ខុ ១ រូប ឃើញជ្រូកជាប់អន្ទាក់ ក៏មានថេយ្យចិត្តគិតថា ក្រែងម្ចាស់គេឃើញមុន ហើយដោះលែងជ្រូកនោះទៅ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ដោះលែងសត្វម្រឹគជាប់អន្ទាក់ ដោយសេចក្ដីករុណា ។ បេ ។ ភិក្ខុឃើញម្រឹគជាប់អន្ទាក់មានថេយ្យចិត្តគិតថា ក្រែងម្ចាស់គេឃើញមុន ហើយដោះលែងម្រឹគនោះទៅ

។ បេ ។ កុមិនេ មច្ឆេ ការុញ្ញេន មុញ្ចិ ។ បេ ។ កុមិនេ មច្ឆេ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តោ មុញ្ចិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៩៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ យានេ ភណ្ឌំ បស្សិត្វា ឥតោ គណ្ហន្តោ បារាជិកោ ភវិស្សាមីតិ អក្កមិត្វា បវដ្ដេត្វា អគ្គហេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៩៧) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កុលលេន ឧក្ខិត្តំ មំសបេសឹ សាមិកានំ ទស្សាមីតិ អគ្គហេសិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អថេយ្យចិត្តស្សាតិ ។



។ បេ ។ ភិក្ខុដោះលែងត្រីទាំងឡាយដែលជាប់លបដោយសេចក្តីករុណា ។ បេ ។ ភិក្ខុឃើញត្រីទាំងឡាយជាប់លបមានថេយ្យចិត្តថា នឹងត្រូវម្ចាស់គេឃើញមុន ហើយដោះលែងត្រីនោះទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៩៦) សម័យនោះឯង មានភិក្ខុ១រូប ឃើញទ្រព្យនៅក្នុងយាន ហើយគិតថា បើអញយកពីទីនេះមុខជានឹងត្រូវអាបត្តិបារាជិក រួចលួសប្រមៀលឲ្យធ្លាក់ចុះ ហើយក៏កាន់យកទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(១៩៧) សម័យនោះឯង មានភិក្ខុ១រូប បានរើសយកដុំសាច់ដែលសត្វខ្លែងពាំយកទៅ ដោយគិតថា អញនឹងប្រគល់ឲ្យពួកម្ចាស់សាច់ ។ ពួកម្ចាស់សាច់ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានថេយ្យចិត្ត ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កុលលេន ឧក្ខិត្តំ មំសបេសឹ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តោ អគ្គហេសិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៩៦] តេន ខោ បន សមយេន មនុស្សា ឧឡុម្បំ ពន្ធិត្វា អចិរវតិយា នទិយា ឱសារេន្តិ ។ ពន្ធនេ ឆិន្នេ កដ្ឋានិ វិប្បកិណ្ណានិ អគមំសុ ។ ភិក្ខូ បំសុកូលសញ្ញិនោ ឧទ្ធរិំសុ ។ សាមិកា តេ ភិក្ខូ ចោទេសុំ អស្សមណាត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ បំសុកូលសញ្ញិស្សាតិ ។ តេន ខោ បន សមយេន មនុស្សា ឧឡុម្បំ ពន្ធិត្វា អចិរវតិយា នទិយា ឱសារេន្តិ ។ ពន្ធនេ ឆិន្នេ កដ្ឋានិ វិប្បកិណ្ណានិ អគមំសុ ។ ភិក្ខូ បុរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តា ឧទ្ធរិំសុ ។ សាមិកា តេ ភិក្ខូ ចោទេសុំ អស្សមណាត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។



សម័យនោះឯង មានភិក្ខុ ១ រូប ឃើញដុំសាច់ដែលសត្វត្មាតពាំយកទៅ មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយក៏កាន់យកដុំសាច់នោះទៅ ។ ពួកម្ចាស់សាច់នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៩៦) សម័យនោះឯង មនុស្សទាំងឡាយចងក្បូន ហើយបណ្តែតតាមស្ទឹងអចិរវតី ។ កាលចំណងក្បូនដាច់ ឈើទាំងឡាយក៏អណ្តែតខ្ចាត់ខ្ចាយទៅ ។ ភិក្ខុទាំងឡាយសំគាល់ថា ជារបស់បំសុកូល ហើយនាំគ្នាស្រង់យកឡើង ។ ពួកម្ចាស់ក្បូននាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយ មិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល ។ សម័យនោះឯង មនុស្សទាំងឡាយចងក្បូន ហើយបណ្តែតតាមស្ទឹងអចិរវតី ។ កាលចំណងក្បូនដាច់ ឈើទាំងឡាយក៏អណ្តែតខ្ចាត់ខ្ចាយទៅ ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ឈើគេឃើញមុន ហើយស្រង់យកឡើង ។ ពួកម្ចាស់ឈើនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុទាំងអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។

អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកស្ស ។

(១៨៧) តេន ខោ បន សមយេន អញ្ញតរោ គោបាលកោ រុក្ខេ សាដកំ អាលគ្គេត្វា ឧច្ចារំ អកាសិ ។ អញ្ញតរោ ភិក្ខុ បំសុកូលសញ្ញី អគ្គហេសិ ។ អថ ខោ សោ គោបាលកោ តំ ភិក្ខុំ ចោទេសិ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បំសុកូលសញ្ញិស្សាតិ ។

(១៨៨) តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ នទិំ តរន្តស្ស រជកានំ ហត្ថតោ មុត្តំ សាដកំ បាទេ លគ្គំ ហោតិ ។ សោ ភិក្ខុ សាមិកានំ ទស្សាមីតិ អគ្គហេសិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អថេយ្យចិត្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ នទិំ តរន្តស្ស រជកានំ ហត្ថតោ មុត្តំ សាដកំ



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិ បារាជិកហើយ ។

(១៨៧) សម័យនោះឯង មានបុរសគង្វាលគោម្នាក់ ពាក់សម្ពត់សាដកនឹងដើមឈើ ហើយក៏ទៅបន្ទោបង់ឧច្ចារៈ ។ ភិក្ខុ ១ រូប សំគាល់ថាជារបស់បង្សុកូល ហើយក៏កាន់យកទៅ ។ គ្រានោះ បុរសគង្វាលគោនោះចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បង្សុកូល ។

(១៨៨) សម័យនោះឯង កាលភិក្ខុ ១ រូបកំពុងឆ្លងស្ទឹង សម្ពត់សាដកក៏របូតអំពីដៃជាងជ្រលក់ទាំងឡាយ ហើយទៅជាប់នឹងជើងភិក្ខុ ។ ភិក្ខុនោះក៏កាន់យកសម្ពត់សាដកនោះដោយគិតថា អញនឹងឲ្យដល់ម្ចាស់ទាំងឡាយ ។ ពួកម្ចាស់សម្ពត់សាដកក៏នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានថេយ្យចិត្ត ។ សម័យនោះឯង កាលភិក្ខុ ១ រូប កំពុងឆ្លងស្ទឹង សម្ពត់សាដករបូតអំពីដៃនៃជាងជ្រលក់ទាំងឡាយ ហើយរសាត់ទៅ

ចារេ លគ្គំ ហោតិ ។ សោ ភិក្ខុ ឱរេ សាមិកា បស្សន្តីតិ ថេយ្យចិត្តោ អវហរិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៥៩) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សប្បិកុម្ភឹ បស្សិត្វា ថោកំ ថោកំ បរិភុញ្ជិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។

(១៦០) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ សំវិទហិត្វា អគមំសុ ភណ្ឌំ អវហរិស្សាមាតិ ។ ឯកោ ភណ្ឌំ អវហរិ ។ តេ ឯវមាហំសុ ន មយំ បារាជិកា យោ អវហដោ សោ បារាជិកោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អាបត្តឹ តុម្ហេ ភិក្ខវេ អាបន្នា បារាជិកន្តិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ សំវិទហិត្វា ភណ្ឌំ អវហរិត្វា ភាជេសុំ ។ តេហិ ភាជិយមានេ



ជាប់នឹងជើងភិក្ខុ ។ ភិក្ខុនោះមានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់សម្លត់សាដកឃើញមុខ ហើយក៏កាន់យកទៅ ។ ម្ចាស់សម្លត់សាដកទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៥៩] សម័យនោះឯង ភិក្ខុ ១ រូបបានឃើញឆ្នាំងដាក់សប្បិ ហើយបានឆាន់បន្តិចៗម្តង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

[១៦០] កាលនោះ ភិក្ខុទាំងឡាយច្រើនរូបបាននិយាយបបួលគ្នាថា យើងទាំងឡាយនឹងទៅលួចទ្រព្យ ហើយនាំគ្នាទៅ ។ ភិក្ខុ ១ រូបលួចទ្រព្យបានមក ។ ភិក្ខុទាំងឡាយនោះបាននិយាយគ្នាយ៉ាងនេះថា ពួកយើងមិនត្រូវអាបត្តិបារាជិកទេ លោកណាលួចបានមក លោកនោះត្រូវអាបត្តិបារាជិក ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។ កាលនោះ ភិក្ខុទាំងឡាយច្រើនរូបបបួលគ្នាលួចទ្រព្យបានមកហើយក៏ចែកគ្នា ។ កាលដែលភិក្ខុទាំងឡាយនោះកំពុងចែកគ្នា

ឯកមេកស្ស បដិវិសោ បញ្ចមាសកោ បូរោ ។ តេ ឯវមាហំសុ ន មយំ បារាជិកាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អាបត្តិ តុម្ហេ ភិក្ខវេ អាបន្នា បារាជិកន្តិ ។

(១៦១) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ ទុព្ភិក្ខេ អាបណិកស្ស តណ្ឌុលមុដ្ឋិំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ ទុព្ភិក្ខេ អាបណិកស្ស មុគ្គមុដ្ឋិំ ។បេ។ មាសមុដ្ឋិំ ។បេ។ តិលមុដ្ឋិំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៦២) តេន ខោ បន សមយេន សាវត្ថិយំ អន្ធវនេ ចោរកា គាវឹ ហន្ត្វា មំសំ ខាទិត្វា សេសកំ បដិសាមេត្វា អគមំសុ ។ ភិក្ខូ បំសុកូលសញ្ញិនោ បដិគ្គហាបេត្វា បរិភុញ្ជិំសុ ។ ចោរកា តេ ភិក្ខូ ចោទេសុំ



ភិក្ខុ ១ រូប ៗ បានចំណែកម្នាក់ពេញ ៥ មាសក ។ ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះថា យើងទាំងឡាយមិនត្រូវអាបត្តិបារាជិកទេ ។ ទើបនាំគ្នាក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[១៦១] សម័យនោះ ភិក្ខុ ១ រូប កាលក្រុងសាវត្ថីកើតទុរ្ភិក្ស អត់បាយ (ភិក្ខុនោះ) មានថេយ្យចិត្ត ហើយលួចយកអង្ករបស់អ្នកផ្សារ ប្រមាណ ១ ក្ដាប់ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះ ភិក្ខុ ១ រូប កាលក្រុងសាវត្ថីកើតទុរ្ភិក្សអត់បាយ មានថេយ្យចិត្ត ហើយលួចយកសណ្ដែកបាយរបស់អ្នកផ្សារ ១ ក្ដាប់ ។បេ។ សណ្ដែកកផមាស ១ ក្ដាប់ ។បេ។ ល្ង ១ ក្ដាប់ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៦២] សម័យនោះ ពួកចោរសម្លាប់មេគោ ស៊ីសាច់ហើយក៏ទុកដាក់សាច់ដ៏សេសសល់ក្នុងព្រៃអន្ធវនទៀបក្រុងសាវត្ថី ហើយនាំគ្នាទៅ ។ ភិក្ខុទាំងឡាយសំគាល់ថាជារបស់បង្សុកូល ហើយនាំគ្នាកាន់យកសាច់នោះបរិភោគទៅ ។ ពួកចោរនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះ

អស្សមណកំ ហោតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បំសុកូលសញ្ញិស្សាតិ ។ តេន ខោ បន សមយេន សាវត្ថិយំ អន្ធវនេ ចោរកា សូករំ ហន្ត្វា មំសំ ខាទិត្វា សេសកំ បដិសាមេត្វា អគមំសុ ។ ភិក្ខូ បំសុកូលសញ្ញិនោ បដិគ្គហាបេត្វា បរិភុញ្ជឹសុ ។ ចោរកា តេ ភិក្ខូ ចោទេសុំ អស្សមណកំ ហោតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បំសុកូលសញ្ញិស្សាតិ ។

(១៦៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ តិណក្ខេត្តំ គន្ត្វា លូនំ តិណំ បញ្ចមាសកគ្ឃនកំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(១៦៤) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ តិណក្ខេត្តំ គន្ត្វា តិណំ លាយិត្វា បញ្ចមាសកគ្ឃនកំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។



ថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល ។ សម័យនោះ ពួកចោរសម្លាប់ជ្រូកស៊ីសាច់ ហើយទុកដាក់សាច់ដ៏សេសសល់ ក្នុងព្រៃអន្ធវ័ន ទៀបក្រុងសាវត្ថី ហើយនាំគ្នាទៅ ។ ភិក្ខុទាំងឡាយសំគាល់ថាជារបស់បំសុកូល ហើយនាំគ្នាទទួលយកសាច់នោះមកឆាន់ ។ ពួកចោរទាំងនោះប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល ។

(១៦៣) កាលនោះ ភិក្ខុ១រូប ទៅកាន់ស្រែស្មៅ (ចម្ការស្មៅ) មានថេយ្យចិត្តហើយប្រុងលួចយកស្មៅដែលគេច្រូតទុក មានថ្លៃ ៥ មាសក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

(១៦៤) សម័យនោះ ភិក្ខុ១រូប ទៅកាន់ស្រែស្មៅ មានថេយ្យចិត្តហើយលួចច្រូតយកស្មៅគេមានថ្លៃ ៥ មាសក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៦៩] តេន ខោ បន សមយេន អាគន្តុកា ភិក្ខូ សង្ឃស្ស អម្ពំ បាចាបេត្វា បរិភុញ្ជឹសុ ។ អាវាសិកា ភិក្ខូ តេ ភិក្ខូ ចោទេសុំ អស្សមណាត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ កឹចិត្តា តុម្ហេ ភិក្ខវេតិ ។ បរិភោគត្ថាយ មយំ ភគវាតិ ។ អនាបត្តិ ភិក្ខវេ បរិភោគត្ថាយាតិ ។ តេន ខោ បន សមយេន អាគន្តុកា ភិក្ខូ សង្ឃស្ស ជម្ពុំ ។ បេ ។ សង្ឃស្ស លពុជំ ។ បេ ។ សង្ឃស្ស បនសំ ។ បេ ។ សង្ឃស្ស តាលបក្កំ ។ បេ ។ សង្ឃស្ស ឧច្ឆុំ ។ បេ ។ សង្ឃស្ស តិម្ពរូសកំ បាចាបេត្វា បរិភុញ្ជឹសុ ។ អាវាសិកា ភិក្ខូ តេ ភិក្ខូ ចោទេសុំ អស្សមណាត្ថ តុម្ហេតិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បរិភោគត្ថាយាតិ ។



[១៦៩] សម័យនោះ ភិក្ខុទាំងឡាយជាអាគន្តុក (ភិក្ខុអ្នកមកថ្មី) ញ៉ាំងគេឲ្យចំអិនផ្លែស្វាយរបស់សង្ឃ ហើយបរិភោគទៅ ។ ភិក្ខុម្ចាស់អាវាសទាំងឡាយចោទប្រកាន់ភិក្ខុជាអាគន្តុកទាំងនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអាគន្តុកទាំងនោះ មានសេចក្តីសង្ស័យ ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកគិតដូចម្តេច ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយមានចិត្តប្រាថ្នាដើម្បីនឹងបរិភោគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីនឹងបរិភោគទេ ។ សម័យនោះ ភិក្ខុទាំងឡាយជាអាគន្តុកញ៉ាំងគេឲ្យចំអិនផ្លែព្រីងរបស់សង្ឃ ។ បេ ។ ផ្លែខ្នុរសំឡរបស់សង្ឃ ។ បេ ។ ផ្លែខ្នុរណាំងរបស់សង្ឃ ។ បេ ។ ផ្លែត្នោតទុំរបស់សង្ឃ ។ បេ ។ អំពៅរបស់សង្ឃ ។ បេ ។ ផ្លែទន្លាប់របស់សង្ឃ ហើយនាំគ្នាបរិភោគទៅ ។ ពួកភិក្ខុដែលជាម្ចាស់អាវាសនាំគ្នាចោទប្រកាន់ភិក្ខុអាគន្តុកទាំងនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអាគន្តុកទាំងនោះ មានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីនឹងបរិភោគទេ ។

(១៦៦) តេន ខោ បន សមយេន អម្ពបាលកា ភិក្ខូនំ អម្ពផលំ ទេន្តិ ។ ភិក្ខូ គោបកា ឥមេ ឥស្សរា នយិមេ ទាតុន្តិ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ គោបកស្ស ទានេតិ ។ តេន ខោ បន សមយេន ជម្ពុបាលកា ។ បេ ។ លពុជបាលកា ។ បេ ។ បនសបាលកា ។ បេ ។ តាលបក្កបាលកា ។ បេ ។ ឧច្ឆុបាលកា ។ បេ ។ តិម្ពរូសកបាលកា ភិក្ខូនំ តិម្ពរូសកេ ទេន្តិ ។ ភិក្ខូ គោបកា ឥមេ ឥស្សរា នយិមេ ទាតុន្តិ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ គោបកស្ស ទានេតិ ។

(១៦៧) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស ទារុំ តាវកាលិកំ ហរិត្វា អត្តនោ វិហារស្ស កុដ្ដំ ឧបត្ថម្ភេសិ ។ ភិក្ខូ តំ ភិក្ខុំ ចោទេសុំ



(១៦៦) សម័យនោះ ពួកមនុស្សអ្នករក្សាស្វាយនាំគ្នាប្រគេនផ្លែស្វាយដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានទទួល ដោយគិតថា មនុស្សអម្បាលនេះ ជាឥស្សរៈត្រឹមតែរក្សាថែទាំប៉ុណ្ណោះ មនុស្សអម្បាលនេះមិនជាឥស្សរៈដើម្បីនឹងឲ្យបានទេ ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើតាមវត្ថុដែលបុគ្គលអ្នករក្សាគេឲ្យហើយ (ភិក្ខុអ្នកទទួល) មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មនុស្សអ្នករក្សាព្រីងទាំងឡាយ ។ បេ ។ អ្នករក្សាខ្នុរសំប៉ុងទាំងឡាយ ។ បេ ។ អ្នករក្សាខ្នុរណាំងទាំងឡាយ ។ បេ ។ អ្នករក្សាផ្លែត្នោតទុំទាំងឡាយ ។ បេ ។ អ្នករក្សាអំពៅទាំងឡាយ ។ បេ ។ អ្នករក្សាផ្លែចន្ទាប់ទាំងឡាយ នាំគ្នាប្រគេនផ្លែចន្ទាប់ទាំងឡាយ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានទទួល ដោយគិតថា មនុស្សអម្បាលនេះជាឥស្សរៈត្រឹមតែរក្សាប៉ុណ្ណោះ មនុស្សអម្បាលនេះមិនជាឥស្សរៈដើម្បីនឹងឲ្យទេ ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុ ព្រោះតាមវត្ថុដែលអ្នកថែរក្សាឲ្យនោះទេ ។

(១៦៧) សម័យនោះ ភិក្ខុ ១ រូបនាំឈើរបស់សង្ឃយកទៅទប់ទម្ក (ជួសជុល) ជញ្ជាំងវិហាររបស់ខ្លួន ។ ភិក្ខុទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុ

អស្សមណោសិ ភន្តេ ។ តស្ស កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ កិំចិត្តោ ត្វំ ភិក្ខូតិ ។ តាវកាលិកោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ តាវកាលិកេតិ ។

[១៦៨] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស ឧទកំ ថេយ្យចិត្តោ អវហរិ ។ បេ ។ សង្ឃស្ស មត្តិកំ ថេយ្យចិត្តោ អវហរិ ។ បេ ។ សង្ឃស្ស មុញ្ជកតិណំ(១) ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស មុញ្ជកតិណំ ថេយ្យចិត្តោ ឆេទាបេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

[១៦៩] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស មញ្ចំ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។

១. ម. មុញ្ជតិណំ ។



នោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគិតថាជារបស់ខ្ចី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើការយកជារបស់ខ្ចីដូច្នោះ អ្នកមិនមានអាបត្តិឡើយ ។

[១៦៨] សម័យនោះ ភិក្ខុ១រូបមានថេយ្យចិត្ត ហើយបានលួចយកទឹករបស់សង្ឃ ។ បេ ។ មានថេយ្យចិត្តហើយលួចយកដីរបស់សង្ឃ ។ បេ ។ មានថេយ្យចិត្តហើយបានលួចយកស្មៅបាបូសរបស់សង្ឃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ១រូបមានថេយ្យចិត្ត ហើយលួចផ្តាច់ស្មៅបាបូសរបស់សង្ឃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ចយ ។

[១៦៩] សម័យនោះ ភិក្ខុ១រូប មានថេយ្យចិត្ត ហើយលួចយកគ្រែរបស់សង្ឃ ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ ។ បេ ។

អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សង្ឃស្ស បីឋំ ។ បេ ។ សង្ឃស្ស ភិសឹ ។ បេ ។ សង្ឃស្ស ពិម្ពោហនំ ។ បេ ។ សង្ឃស្ស កវាដំ ។ បេ ។ សង្ឃស្ស អាលោកសន្ធឹ ។ បេ ។ សង្ឃស្ស គោបានសឹ ថេយ្យចិត្តោ អវហរិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[១៧០] តេន ខោ បន សមយេន ភិក្ខូ អញ្ញតរស្ស ឧបាសកស្ស វិហារបរិភោគំ សេនាសនំ អញ្ញត្រ បរិភុញ្ជន្តិ ។ អថ ខោ សោ ឧបាសកោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថញ្ហិ នាម ភទន្តា អញ្ញត្រ បរិភោគំ អញ្ញត្រ បរិភុញ្ជិស្សន្តីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អញ្ញត្រ បរិភោគោ អញ្ញត្រ បរិភុញ្ជិតព្វោ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ភិក្ខូ ឧបោសថគ្គំបិ[១] សន្និសជ្ជម្បិ ហរិតុំ កុក្កុច្ចាយន្តា ឆមាយំ និសីទន្តិ ។ គត្តានិបិ ចីវរានិបិ បំសុកិតានិ ហោន្តិ ។

១ ក. ឧបោសថគ្គេ ។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប មានថេយ្យចិត្តហើយលួចយកតាំងរបស់សង្ឃ ។ បេ ។ ពូករបស់សង្ឃ ។ បេ ។ ខ្នើយរបស់សង្ឃ ។ បេ ។ សន្ទះទ្វាររបស់សង្ឃ ។ បេ ។ សន្ទះបង្អួចរបស់សង្ឃ ។ បេ ។ ឈើបន្ទឹមរបស់សង្ឃ ។ សេចក្តីសង្ខេបមានដល់ត្រឹមនោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[១៧០] សម័យនោះ ភិក្ខុទាំងឡាយយកសេនាសនៈរបស់ឧបាសកម្នាក់ ដែលគេចុះដាក់សម្រាប់ប្រើប្រាស់ក្នុងវត្ត ទៅប្រើប្រាស់ក្នុងទីដទៃ ។ គ្រានោះ ឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយមិនសមបើនឹងយករបស់គេសម្រាប់ប្រើប្រាស់ក្នុងទីដទៃ ទៅប្រើប្រាស់ក្នុងទីដទៃវិញ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រឿងប្រើប្រាស់របស់គេក្នុងទីដទៃ ភិក្ខុមិនគប្បីយកទៅប្រើប្រាស់ក្នុងទីដទៃទេ តែភិក្ខុណាយកទៅប្រើប្រាស់ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះ ភិក្ខុទាំងឡាយប្រុងនឹងនាំយកអាសនៈសំរាប់អង្គុយ គឺរោងឧបោសថ ។ ហើយមានសេចក្តីសង្ស័យមិនហ៊ាននាំយកទៅ ហើយក៏អង្គុយលើផែនដី ។ ខ្លួនក្តី ចីវរក្តី ក៏ប្រឡាក់ដោយធូលី ។

ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តាវកាលិកំ ហរិតុន្តិ ។

[១៩១] តេន ខោ បន សមយេន ចម្បាយំ ថុល្លនន្ទាយ ភិក្ខុនិយា អន្តេវាសី ភិក្ខុនី ថុល្លនន្ទាយ ភិក្ខុនិយា ឧបដ្ឋាកកុលំ គន្ត្វា អយ្យា ឥច្ឆតិ តេកដុលយាគុំ បាតុន្តិ បចាបេត្វា ហរិត្វា អន្តរា បរិភុញ្ជិ ។ សា ជានិត្វា តំ ចោទេសិ អស្សមណីសិ ត្វំ ។ តស្សា កុក្កុច្ចំ អហោសិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ សម្បជានមុសាវាទេ បាចិត្តិយស្សាតិ ។ តេន ខោ បន សមយេន រាជគហេ ថុល្លនន្ទាយ ភិក្ខុនិយា អន្តេវាសី ភិក្ខុនី ថុល្លនន្ទាយ ភិក្ខុនិយា ឧបដ្ឋាកកុលំ គន្ត្វា អយ្យា



ភិក្ខុទាំងឡាយយកសេចក្ដីនុ៎ះក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយខ្ចីរបស់ទាំងនោះទៅប្រើប្រាស់បាន ។

[១៩១] សម័យនោះឯង ភិក្ខុនី ១ រូបជាសិស្សរបស់ថុល្លនន្ទាភិក្ខុនី នៅក្នុងក្រុងចម្បា ទៅកាន់ត្រកូលជាឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី ហើយបង្គាប់ត្រកូលនោះថា ថុល្លនន្ទាភិក្ខុនីជាម្ចាស់ចង់ឆាន់បបរ ដែលលាយគ្រឿងត្រីកដុក ហើយក៏យកទៅឆាន់ពាក់កណ្ដាលផ្លូវខ្លួនឯង ។ ថុល្លនន្ទាភិក្ខុនីនោះដឹងហើយចោទប្រកាន់សិស្សនោះថា នាងឯងមិនមែនជាសមណីទេ ។ ភិក្ខុនីនោះមានសេចក្ដីរង្កៀសក្នុងចិត្ត ។ ទើបភិក្ខុនីនោះនាំរឿងនុ៎ះទៅជំរាបប្រាប់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីនាំយករឿងនុ៎ះទៅប្រាប់ដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុនាំយករឿងនុ៎ះទៅក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហក ។ សម័យនោះឯង ភិក្ខុនី ១ រូប ជាសិស្សថុល្លនន្ទាភិក្ខុនីនៅក្នុងក្រុងរាជគ្រឹះ ទៅកាន់ត្រកូលជាឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី ហើយបង្គាប់ត្រកូលនោះថា ថុល្លនន្ទាភិក្ខុនីជាម្ចាស់

[illegible] បចាបេត្វា ហរិត្វា អត្តនា បរិភុញ្ជិ ។ តេ ជានិត្វា តំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ សម្បជានមុសាវាទេ បាចិត្តិយស្សាតិ ។

(១៣២) តេន ខោ បន សមយេន វេសាលិយំ អាយស្មតោ អជ្ជុកស្ស ឧបដ្ឋាកស្ស គហបតិស្ស ទ្វេ ទារកា ហោន្តិ បុត្តោ ច ភាគិនេយ្យោ ច ។ អថ ខោ សោ គហបតិ អាយស្មន្តំ អជ្ជុកំ ឯតទវោច ឥមំ ភន្តេ ឱកាសំ យោ ឥមេសំ ទ្វិន្នំ ទារកានំ សទ្ធោ ហោតិ បសន្នោ តស្ស អាចិក្ខេយ្យាសីតិ ។ សោ កាលមកាសិ[១] ។ តេន ខោ បន សមយេន តស្ស គហបតិស្ស ភាគិនេយ្យោ សទ្ធោ ហោតិ បសន្នោ ។ អថ ខោ អាយស្មា អជ្ជុកោ តំ ឱកាសំ

១ [illegible] បញ្ញាយតិ ។



ចម្អិនខំឲ្យមានរសឆ្ងាញ់ក្រៃពេក ហើយក៏យកទៅបរិភោគដោយខ្លួនឯង ។ ពួកភិក្ខុទាំងនោះដឹងហើយចោទប្រកាន់ភិក្ខុនោះថា លោកឯងមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុនោះមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហក ។

(១៣២) សម័យនោះឯង ក្មេងពីរនាក់ គឺកូនប្រុស ១ ក្មួយប្រុស ១ របស់គហបតីជាឧបដ្ឋាករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ ក្នុងក្រុងវេសាលី ។ គ្រានោះ គហបតីនោះបាននិយាយពាក្យនេះនឹងព្រះអជ្ជុកត្ថេរដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ដំបន់ក្មេងទាំងពីរនាក់នេះ ក្មេងណាមានសទ្ធាជ្រះថ្លា ព្រះករុណាគប្បីប្រាប់ឱកាសនេះដល់ក្មេងនោះ ។ គហបតីនោះធ្វើកាលកិរិយាទៅ ។ សម័យនោះឯង ក្មួយរបស់គហបតីនោះមានសទ្ធាជ្រះថ្លា ។ លំដាប់នោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បានប្រាប់ឱកាសនោះ

តស្ស ភាគិនេយ្យស្ស អាចិក្ខិ ។ សោ តេន សាប-តេយ្យេន កុដុម្ពញ្ច សណ្ឋបេសិ ទានញ្ច បដ្ឋបេសិ ។ អថខោ តស្ស គហបតិនោ បុត្តោ អាយស្មន្តំ អានន្ទំ ឯតទវោច កោ នុ ខោ ភន្តេ អានន្ទ បិតុនោ ទាយជ្ជោ បុត្តោ វា ភាគិនេយ្យោ វាតិ ។ បុត្តោ ខោ អាវុសោ បិតុនោ(១) ទាយជ្ជោតិ ។ អយំ ភន្តេ អយ្យោ អជ្ជុកោ អម្ហាកំ សាប-តេយ្យំ អម្ហាកំ មេថុនកស្ស អាចិក្ខីតិ ។ អស្សម-ណោ អាវុសោ អាយស្មា អជ្ជុកោតិ ។ អថខោ អាយស្មា អជ្ជុកោ អាយស្មន្តំ អានន្ទំ ឯតទវោច ទេហិ មេ អាវុសោ អានន្ទ វិនិច្ឆយន្តិ ។ តេន ខោ បន សមយេន អាយស្មា ឧបាលិ អាយស្មតោ អជ្ជុ-កស្ស បក្ខោ ហោតិ ។ អថខោ អាយស្មា ឧបាលិ អាយស្មន្តំ អានន្ទំ ឯតទវោច យោ នុ ខោ អាវុសោ អានន្ទ សាមិកេន ឥមំ ឱកាសំ ឥត្ថន្នាមស្ស អាចិក្ខា-ហីតិ(២) វុត្តោ តស្ស អាចិក្ខតិ កឹ សោ អាបជ្ជតីតិ ។

១ [illegible] ។ ២ ម. ឆ. អាចិក្ខាតិ ។





ដល់ទារកដែលជាក្មួយនោះ ។ ទារកដែលជាក្មួយនោះ ក៏បានចិញ្ចឹមទ្រព្យ នូវគ្រួសារ និងតាំងទានដោយសម្បត្តិនោះ ។ លំដាប់នោះ កូនរបស់គហបតីនោះ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចំរើន អ្នកណាជាអ្នកទទួលមត៌ករបស់បិតា គឺកូនឬក្មួយ ។ ព្រះអានន្ទនិយាយតបថា ម្នាលអ្នកដ៏មានអាយុ កូនទើបត្រូវទទួលមត៌ករបស់បិតាបាន ។ កូនរបស់គហបតីនោះបាននិយាយតទៅទៀតថា បពិត្រព្រះអានន្ទដ៏ចំរើន លោកម្ចាស់អជ្ជុកៈនេះ ប្រាប់សម្បត្តិរបស់ខ្ញុំដល់បងប្អូនជីដូនមួយរបស់ខ្ញុំហើយ ។ ព្រះអានន្ទតបថា ម្នាលអ្នកដ៏មានអាយុ អជ្ជុកៈដ៏មានអាយុនេះ មិនមែនជាសមណៈទេ ។ គ្រានោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ លោកចូរឲ្យសេចក្តីវិនិច្ឆ័យដល់ខ្ញុំចុះ ។ សម័យនោះឯង ព្រះឧបាលីដ៏មានអាយុ ជាបក្សពួករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ ។ លំដាប់នោះ ព្រះឧបាលីដ៏មានអាយុ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ភិក្ខុណាដែលម្ចាស់ទ្រព្យគេប្រាប់ថា លោកចូរប្រាប់ឱកាសនេះដល់អ្នកនេះ ហើយភិក្ខុនោះទៅប្រាប់ដល់អ្នកនោះ ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះអានន្ទ

ន សោ(១) ភន្តេ កិញ្ចិ អាបជ្ជតិ អន្តមសោ ទុក្កដមត្តម្បិ ។ អយំ អាវុសោ អាយស្មា អជ្ឈិតោ សាមិកេន ធំ ទំការសំ ឥត្ថម្ភស្ស អាចិក្ខាហីតិ វុត្តោ តស្ស អាចិក្ខិ អនាបត្តិ អាវុសោ អាយស្មតោ អជ្ឈេតស្សាតិ ។

(១៧៣) តេន ខោ បន សមយេន ពារាណ-សិយំ អាយស្មតោ បិលិន្ទវច្ឆស្ស ឧបដ្ឋាកកុលំ ចោរេហិ ឧបទ្ទុតំ ហោតិ ទ្វេ ច ទារកា នីតា ហោន្តិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ តេ ទារកេ ឥទ្ធិយា អានេត្វា បាសាទេ ឋបេសិ ។ មនុស្សា តេ ទារកេ បស្សិត្វា អយ្យស្សាយំ បិលិន្ទវច្ឆស្ស ឥទ្ធានុភាវោតិ អាយស្មន្តេ បិលិន្ទវច្ឆេ អភិប្បសីទឹសុ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា បិលិន្ទវច្ឆោ ចោរេហិ នីតេ ទារកេ អា-នេស្សតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១ [illegible]



ឡើយ ក៏បានទៅវិញថា បពិត្រលោកដ៏ចំរើន ភិក្ខុនោះមិនត្រូវអាបត្តិសូម្បីបន្តិចទេ ដោយហេតុនោះទើបតែអាបត្តិទុក្កដក៏មិនត្រូវដែរ ។ ព្រះឧបាលី ឆ្លើយថា ម្នាលអាវុសោ ព្រះអង្គអ្នកដ៏មានអាយុនេះ ម្ចាស់ទ្រព្យបានផ្ដាំទុកថា លោកគួរប្រាប់ទ្រព្យនេះដល់ឈ្មោះនេះ ក៏បានប្រាប់ដល់អ្នកនោះវិញ ម្នាលអាវុសោ អង្គនេះដ៏មានអាយុមិនត្រូវអាបត្តិទេ ។

( ១៧៣ ) សម័យនោះឯង ក្នុងក្រុងពារាណសី ពួកចោរនាំគ្នាប្លន់ត្រកូលឧបដ្ឋាករបស់ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយនាំយកក្មេងពីរនាក់ទៅ ។ លំដាប់នោះ ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ សំដែងឫទ្ធិទៅនាំយកក្មេងទាំងពីរនាក់នោះបានមក ហើយទុកក្នុងប្រាសាទ ។ មនុស្សទាំងឡាយបានឃើញក្មេងទាំងពីរនាក់នោះហើយ និយាយថា នេះជាឫទ្ធានុភាពរបស់លោកម្ចាស់បិលិន្ទវច្ឆៈ ហើយក៏នាំគ្នាជ្រះថ្លានឹងព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុក្រៃលែង ។ ភិក្ខុទាំងឡាយនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា បិលិន្ទវច្ឆត្ថេរដ៏មានអាយុមិនសមគួរនឹងទៅនាំយកក្មេងពីរនាក់ ដែលពួកចោរបាននាំយកទៅហើយ ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

អនាបត្តិ ភិក្ខវេ ឥទ្ធិមន្តស្ស ឥទ្ធិវិសយេនាតិ ។

(១៧៦) តេន ខោ បន សមយេន ទ្វេ ភិក្ខូ សហាយកា ហោន្តិ បណ្ឌុកោ ច កបិលោ ច ។ ឯកោ គាមកេ វិហរតិ ឯកោ កោសម្ពិយំ ។ អថខោ តស្ស ភិក្ខុនោ គាមកា កោសម្ពឹ គច្ឆន្តស្ស អន្តរាមគ្គេ នទឹ តរន្តស្ស សូករិកានំ ហត្ថតោ មុត្តា មេទវដ្ដិ បាទេ លគ្គា ហោតិ ។ សោ ភិក្ខុ សាមិកានំ ទស្សាមីតិ អគ្គហេសិ ។ សាមិកា តំ ភិក្ខុំ ចោទេសុំ អស្សមណោសិ ត្វន្តិ ។ តំ ឧត្តិណ្ណំ អញ្ញតរា គោបាលិកា បស្សិត្វា ឯតទវោច ឯហិ ភន្តេ មេថុនំ ធម្មំ បដិសេវាតិ ។ សោ បកតិយាហំ អស្សមណោតិ តស្សា មេថុនំ ធម្មំ បដិសេវិត្វា កោសម្ពឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។



ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុ មានឫទ្ធិទេ ព្រោះវិស័យនៃឫទ្ធិ ។

(១៧៦) សម័យនោះឯង ភិក្ខុពីររូបជាសំឡាញ់គ្នា ឈ្មោះ បណ្ឌុកៈ ១ កបិលៈ ១ ។ ភិក្ខុ ១ រូបនៅស្រុកស្រែ ១ រូបនៅក្នុងក្រុង កោសម្ពី ។ គ្រាដែលភិក្ខុនោះចេញពីស្រុកស្រែ ទៅកាន់ក្រុងកោសម្ពី កាលកំពុងឆ្លងទឹកស្ទឹងក្នុងកណ្ដាលផ្លូវ កាវខ្លាញ់ជ្រូកអំពីដៃ នៃមនុស្សអ្នកសម្លាប់ជ្រូកពីដៃទាំងឡាយទៅជាប់ខ្នងជើងរបស់ភិក្ខុនោះ ។ ភិក្ខុ នោះបានកាន់យកដោយគិតថា អាត្មានឹងឲ្យដល់ពួកម្ចាស់វិញ ។ ពួកម្ចាស់ទាំងនោះចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ស្រីគង្វាលគោម្នាក់ឃើញភិក្ខុនោះឆ្លងទឹកស្ទឹងរួចហើយបាននិយាយពាក្យ នេះថា បពិត្រលោកម្ចាស់ លោកចូរមកសេពមេថុនធម្មនឹងខ្ញុំ ។ ភិក្ខុ នោះគិតថា អាត្មាមិនមែនជាសមណៈតាមប្រក្រតីទេ ទើបព្រមសេព មេថុនធម្មនឹងស្រីនោះហើយទៅកាន់ក្រុងកោសម្ពី ប្រាប់សេចក្ដីនុះដល់ ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុះចំពោះព្រះដ៏មាន ព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ភិក្ខុនោះមិនត្រូវ

អនាបត្តិ ភិក្ខុ អជិគ្ឃាបនាយ បារាជិកស្ស អាបត្តិ ចេតុំ ធម្មំ សមាយោគេ បារាជិកស្សាតិ ។

(១៧៥) តេន ខោ បន សមយេន សាវត្ថិយំ អាយស្មតោ ឧបនន្ទស្ស សទ្ធិវិហារិកោ ភិក្ខុ អនភិរតិយា បីឡិតោ អាបណិកស្ស វេឋនំ អវហរិត្វា អាយស្មន្តំ ឧបនន្ទំ ឯតទវោច អស្សមណោ អហំ ភន្តេ វិព្ភមិស្សាមីតិ ។ កឹ តយា អាវុសោ កតន្តិ ។ អាបណិកស្ស វេឋនំ គណ្ហាមិ ភន្តេតិ(១) ។ អាហរាបេត្វា អគ្ឃាបេសិ ។ តំ អគ្ឃាបេន្តំ ន បញ្ចមាសកំ(២) អគ្ឃតិ ។ អនាបត្តិ អាវុសោ បារាជិកស្សាតិ ធម្មឹ កថំ អកាសិ ។ សោ ភិក្ខុ អភិរមីតិ ។

ទុតិយភាណវារំ និដ្ឋិតំ ។

១ ខេពល់បិឯមខ្មែរយាកូរស អគ្ឃស្ស វិនេទិសណា យេការ ។ តត្ថ ហិ សោ ឯតមត្ថំ អាហោបេសិតំ ទេវ្ត ។ ១ ឧបនន្ទ ហោន្តុកេ វាមញ្ញហោន្តុកេ ច ក្លៀវិសោយបរិក្ខា បញ្ញាយតំ ។ ២ ម. បញ្ចមាសកេ ។ ឧ. បញ្ចមាសកោ ។





អាបត្តិបារាជិក ព្រោះគំនិតនេះ ត្រូវអាបត្តិបារាជិក ព្រោះសេចក្តី ចេតនានេះ ។

(១៧៥) សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ព្រះឧបនន្ទ ដ៏មានអាយុ ក្នុងសាវត្ថីនគរ មានសេចក្តីមិនសប្បាយមកបៀតបៀន ក៏ទៅលួចយកឈ្នួតរបស់អ្នកផ្សារ ហើយបាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុ យ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំមិនមែនជាសមណៈទេ ខ្ញុំនឹងសឹក (សិក្ខាបទ) ។ ព្រះឧបនន្ទ បានសួរថា ម្នាលអាវុសោ អ្នកធ្វើខុសនូវអ្វីហើយ ។ ភិក្ខុនោះប្រាប់ថា បពិត្រលោកដ៏ចំរើន ខ្ញុំលួចយកឈ្នួតរបស់អ្នកផ្សារ ។ ព្រះឧបនន្ទក៏ឲ្យយកឈ្នួតនោះមក ហើយកាត់ថ្លៃ ។ ឈ្នួតនោះកាត់ថ្លៃទៅ មិនដល់៥មាសក ។ ព្រះឧបនន្ទប្រាប់ថា ម្នាលអាវុសោ អ្នកមិនត្រូវអាបត្តិបារាជិកទេ ដូច្នេះហើយ ក៏បានសំដែងធម្មីកថា ។ ឯភិក្ខុនោះមានសេចក្តីត្រេកអរក្រៃពេក ។

ទុតិយភាណវារ ចប់ ។

## បារាជិកកណ្ឌេ តតិយសិក្ខាបទំ

[១៧៦] តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន ភគវា ភិក្ខូនំ អនេកបរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អសុភសមាបត្តិយា វណ្ណំ ភាសតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លីយិតុំ នម្ហិ កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា

## បារាជិកកណ្ឌ សិក្ខាបទទី ៣

(១៧៦) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា(១) ក្នុងព្រៃមហាវន(២) ទៀបក្រុងវេសាលី(៣) ។ កាលនោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងអសុភកថា ទ្រង់សំដែងរៀបរាប់អំពីអសុភ ទ្រង់សំដែងនូវគុណនៃការចំរើនអសុភកម្មដ្ឋាន ទ្រង់សំដែងនូវគុណនៃអសុភសមាបត្តិក្នុងអសុភកម្មដ្ឋានជាញឹកញយ ដោយបរិយាយដ៏ច្រើន ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតចង់ចេញពួនសម្ងំនៅអស់កាលកន្លះខែ (ក្នុងកម្មដ្ឋាន) កុំឲ្យអ្នកណាមួយចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូបជាអ្នកនាំបិណ្ឌបាតទៅឲ្យតថាគត ។ ចំណែកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ឯវំ ភន្តេ (យ៉ាងហ្នឹងព្រះអង្គ) តាំងពីកាលនោះមក

១ សាលា គឺផ្ទះមានកំពូល ។ តាមអដ្ឋកថា ថា ក្នុងព្រៃមហាវននោះ គេសាងវិហារ សង់សាលាធ្វើកំពូលដូចសម្រាប់ជាទីប្រថាប់នៃព្រះមានព្រះភាគ ។ ២ គឺព្រៃធំមួយស្មុគស្មាញដែលដុះជាប់គ្នាមិនដាច់ រហូតទៅទល់នឹងមហាសមុទ្រ (ពីព្រៃហេមពាន្ត) ។ ៣ ឈ្មោះក្រុងរបស់ស្ដេចលិច្ឆវី គឺធ្វើមហាទីក្រុងចំនួន ៣ មានកំពែងព័ទ្ធជុំវិញដល់ ៣ ជាន់ ។ (សេចក្ដីនេះមានពិស្ដារក្នុងគម្ពីរបាឡិអដ្ឋកថា គម្ពីរជាតកនិបាត) ។

ជាតស្ស គោចិ ករណ្ឌំ ឧបសង្កមតិ អញ្ញត្រ ឋានេន បណ្ណចាតង្គិយាភេទ ។ ភិក្ខុ ភាតា ទោ អានេសបរិ-យាយេន អសុភកថំ ភាសតិ អសុភាយ វណ្ណំ ភា-សតិ អសុភភាវនាយ វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អសុភសមាបត្តិយា វណ្ណំ ភាសតី តេ[១] អនេកា-ការវោការំ អសុភភាវនានុយោគមនុយុត្តា វិហរន្តិ ។ តេ សកេន កាយេន អដ្ដីយន្តិ ហរាយន្តិ ជិគុច្ឆន្តិ សេយ្យថាបិ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ សីសំ នហាតោ អហិកុណបេន វា កុក្កុរកុណបេន វា មនុស្សកុណបេន វា កណ្ឋេ អាលគ្គេន[២] អដ្ដីយេយ្យ ហរាយេយ្យ ជិគុច្ឆេយ្យ ឯវមេវ តេ ភិក្ខូ សកេន កាយេន អដ្ដីយន្តា ហរាយន្តា ជិគុច្ឆន្តា អត្តនាបិ អត្តានំ ជីវិតា វោរោបេន្តិ អញ្ញមញ្ញម្បិ ជីវិតា វោរោបេន្តិ មិគ-លណ្ឌិកម្បិ សមណកុត្តកំ ឧបសង្កមិត្វា ឯវំ វទន្តិ[៣]

១ សេរី ភេទាបេវ កាវិត្តំ ។ ៤ ឧ. ម. អាលគ្គេន ។ ក. អាលគ្គេន ។ ៣ ម. ឧ. វទន្តិ ។



មិនមានអ្នកណាមួយចូលទៅគាល់ព្រះដ៏មានព្រះភាគឡើយ វៀរលែងតែភិក្ខុមួយរូបជាអ្នកនាំបិណ្ឌបាតទៅថ្វាយព្រះអង្គ ។ ភិក្ខុទាំងឡាយគិតថា ព្រះដ៏មានព្រះភាគទ្រង់សំដែងនូវអសុភកថា ទ្រង់សំដែងរៀបរាប់គុណនៃអសុភ ទ្រង់សំដែងគុណនៃការចំរើនអសុភកម្មដ្ឋាន ទ្រង់សំដែងគុណនៃអសុភសមាបត្តិ ក្នុងអសុភកម្មដ្ឋានដោយច្រើនក្រៃលែង ។ ដោយបរិយាយដ៏ច្រើនតែមួយ ស្វះស្វែងខ្វះខ្វាយហើយក៏នាំគ្នាប្រកបសេចក្ដីព្យាយាមក្នុងការចំរើនអសុភកម្មដ្ឋានជាច្រើនបែបច្រើនយ៉ាង ។ ភិក្ខុទាំងនោះក៏អាសន្លើមខ្ពើម រឿយណាយខ្ពើមខ្ពើមនឹងកាយរបស់ខ្លួនឯង មានឧបមាដូចជាស្រី ឬប្រុសកំលោះ ជាអ្នកមានតិរិយាស្អិតស្អាងជាប្រក្រតី ងូតទឹកកក់ក្បាលហើយ រមែងខ្មាសរឿយណាយខ្ពើមរខ្ពើមសាកអសុភពស់ សាកអសុភឆ្កែ ឬសាកអសុភមនុស្សដែលគេព្យួរនឹងកយ៉ាងណាមិញ ភិក្ខុទាំងនោះក៏ខ្មាសរឿយណាយខ្ពើមខ្ពើមនឹងកាយរបស់ខ្លួនយ៉ាងនោះឯង ទើបសំលាប់ខ្លួនឯងខ្លះ សំលាប់គ្នានឹងគ្នាខ្លះ ចូលទៅរកសមណកុត្តក[១] ឈ្មោះមិគលណ្ឌិក ហើយពោល

១ តាមន័យក្នុងអដ្ឋកថាថា សមណកុត្តក ប្រែថា អ្នកទ្រទ្រង់នូវភេទត្រូវតែសមណៈ ។ ក្នុងដីកាថា អ្នកធ្វើកិច្ចការបម្រើសមណៈ ។ មានសេចក្ដីពន្យល់ក្នុងអដ្ឋកថាថា ជា តាក់កោរសក់ទុកឡើងសល់បន្តិចនុកក្បាល គាត់ស្លៀកសម្ពត់ប្រើលក់អង្គមួយ ទង់ពន្ធយ ចំណុចជីវិតដោយសារអាហារដែលលើសសល់អំពីភិក្ខុសង្ឃ ។ ឯពាក្យថា មិគលណ្ឌិក គឺជាឈ្មោះរបស់គាត់ ។

សាធុ នោ អាវុសោ ជីវិតា វោរោបេហិ ឥទំ តេ បត្តចីវរំ ភវិស្សតីតិ ។ អថខោ មិគលណ្ឌិកោ សមណកុត្តកោ បត្តចីវរេហិ ភាដោ សម្ពហុលេ ភិក្ខូ ជីវិតា វោរោបេត្វា លោហិតកំ(១) អសឹ អាទាយ យេន វគ្គុមុទា នទី តេនុបសង្កមិ ។ អថខោ មិគលណ្ឌិកស្ស សមណកុត្តកស្ស លោហិតកំ តំ(២) អសឹ ធោវន្តស្ស អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ ពហុំ វត មយា អបុញ្ញំ បសុតំ យោហំ ភិក្ខូ សីលវន្តេ កល្យាណធម្មេ ជីវិតា វោរោបេសិន្តិ ។ អថខោ អញ្ញតរា មារកាយិកា ទេវតា អភិជ្ជមានេ ឧទកេ អាគន្ត្វា មិគលណ្ឌិកំ សមណកុត្តកំ ឯតទវោច សាធុ សាធុ សប្បុរិស លាភា តេ សប្បុរិស សុលទ្ធំ តេ សប្បុរិស ពហុំ តយា សប្បុរិស បុញ្ញំ បសុតំ យំ ត្វំ អតិណ្ណេ តារេសីតិ ។ អថខោ

១. ម. លោហិតកតំ ។ ២ [illegible] ។



យ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ យើងសូមអង្វរអ្នក ។ ចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រនិងចីវរទាំងនេះ នឹងបានជារបស់អ្នក ។ គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិក ទទួលស៊ីឈ្នួលយកបាត្រនិងចីវរហើយ ក៏ផ្តាច់បង់ជីវិតភិក្ខុទាំងឡាយជាច្រើនរូប ហើយកាន់ដាវប្រឡាក់ឈាមដើរទៅកាន់ស្ទឹងឈ្មោះវគ្គុមុទា ។ កាលដែលសមណកុត្តកឈ្មោះមិគលណ្ឌិកកំពុងលាងដាវប្រឡាក់ឈាមនោះ ( តាក់ ) ក៏កើតសេចក្តីសង្ស័យ ក្តៅក្រហាយ ស្តាយក្រោយក្នុងកាលនោះ ដោយគិតឃើញថា ការនេះមិនមែនជាលាភរបស់អញទេតើ មិនធ្លាប់ជាលាភរបស់អញមិនបានឡើយ ជាតិជាមនុស្សអញបានហើយក្រណាស់ ជាតិជាមនុស្សឈ្មោះថា អញបានដោយងាយមិនមែនឡើយ អញបានបាបច្រើនណាស់ ព្រោះអញបានផ្តាច់បង់ជីវិតភិក្ខុអ្នកមានសីលនិងធម៌ល្អ ។ លំដាប់នោះ ទេវតាជាពួករបស់មារដើរមកលើទឹកមិនមានបែកធ្លាយ បាននិយាយពាក្យនេះនឹងសមណកុត្តកឈ្មោះមិគលណ្ឌិកថា ល្អហើយ ៗ អ្នកសប្បុរស ការនេះជាលាភរបស់អ្នកហើយ អ្នកសប្បុរស ជាតិជាមនុស្សអ្នកក៏បានដោយល្អហើយ អ្នកសប្បុរស អ្នកបានប្រសព្វបុណ្យច្រើនហើយ អ្នកសប្បុរស ព្រោះអ្នកបានញុំាងជនទាំងឡាយដែលមិនទាន់ឆ្លងសង្សារវដ្តឲ្យឆ្លងផុតទៅបាន ។ គ្រានោះឯង សមណកុត្តក

មិគលណ្ឌិកោ សមណកុត្តកោ លាភា វត មេ សុលទ្ធំ វត មេ ពហុំ វត មយា បុញ្ញំ បសុតំ អតិណ្ណេ តារេហំ តារេមីតិ តិណ្ហំ(១) អសិំ អាទាយ វិហារេន វិហារំ បរិវេណេន បរិវេណំ ឧបសង្កមិត្វា ឯវំ វទេតិ កោ អតិណ្ណោ កំ តារេមីតិ ។ តត្ថ យេ តេ ភិក្ខូ អវីតរាគា តេសំ តស្មឹ សមយេ ហោតិ ភយំ ហោតិ ឆម្ភិតត្តំ ហោតិ លោមហំសោ ។ យេ បន តេ ភិក្ខូ វីតរាគា តេសំ តស្មឹ សមយេ ន ហោតិ ភយំ ន ហោតិ ឆម្ភិតត្តំ ន ហោតិ លោមហំសោ ។ អថខោ មិគលណ្ឌិកោ សមណកុត្តកោ ឯកំបិ ភិក្ខុំ ឯកាហេន ជីវិតា វោរោបេសិ ទ្វេបិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ តយោបិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ ចត្តារោបិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ បញ្ចបិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ ។បេ។ ទសបិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ

១ ឱ. ម. ក. តិក្ខំ ។





ឈ្មោះមិគលណ្ឌិក ក៏នឹកថា ឱហ្ន៎ (ការនេះ) ជាលាភរបស់អញ ឱហ្ន៎ ជាទីមនុស្សអញបានដោយល្អហើយ ឱហ្ន៎ អញបានប្រសព្វបុណ្យជាច្រើន ឱហ្ន៎ អញបានញ៉ាំងជនទាំងឡាយដែលមិនទាន់ឆ្លង (សង្សារវដ្ត) ឲ្យឆ្លងផុតទៅបាន លុះគិតដូច្នេះហើយ ក៏កាន់ដាវមុតដើរចេញពីវិហារចូលទៅកាន់វិហារ ចេញពីបរិវេណចូលទៅកាន់បរិវេណហើយពោលយ៉ាងនេះថា លោកណាមិនទាន់ឆ្លង (សង្សារវដ្ត) ខ្ញុំនឹងឲ្យលោកណាឆ្លងសង្សារវដ្តបាន ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណាដែលមិនទាន់ប្រាសចាករាគៈ សេចក្ដីខ្លាច សេចក្ដីញាប់ញ័រ និងសេចក្ដីព្រឺរោម ក៏មានដល់ភិក្ខុទាំងនោះជាប្រាកដក្នុងសម័យនោះ ។ ចំណែកភិក្ខុទាំងឡាយណា ដែលប្រាសចាករាគៈហើយ សេចក្ដីខ្លាច សេចក្ដីញាប់ញ័រ និងសេចក្ដីព្រឺរោម ក៏មិនមានដល់ភិក្ខុទាំងនោះក្នុងសម័យនោះឡើយ ។ គ្រានោះ សមណកុត្តកឈ្មោះមិគលណ្ឌិក ក៏ផ្ដាច់បង់ជីវិតភិក្ខុក្នុងមួយថ្ងៃ ១ រូបក៏មាន ក្នុង ១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុពីររូបក៏មាន ១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុបីរូបក៏មាន ១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុបួនរូបក៏មាន ១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុប្រាំរូបក៏មាន ។បេ។ ១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុដប់រូបក៏មាន

វីសម្បិ(១) ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ តឹសម្បិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ ចត្តាលីសម្បិ(២) ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ បញ្ញាសម្បិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ សដ្ឋិម្បិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ ។

(១៧៧) អថខោ ភគវា តស្ស អឌ្ឍមាសស្ស អច្ចយេន បដិសល្លានា វុដ្ឋិតោ អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ អានន្ទ តនុភូតោ វិយ ភិក្ខុសង្ឃោតិ ។ តថា ហិ បន ភន្តេ ភគវា ភិក្ខូនំ អនេកបរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អសុភសមាបត្តិយា វណ្ណំ ភាសតិ តេ ច ភន្តេ ភិក្ខូ ភគវា ខោ អនេកបរិយាយេន អសុភកថំ កថេតិ អសុភាយ វណ្ណំ ភាសតិ អសុភភាវនាយ វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អសុភសមាបត្តិយា វណ្ណំ ភាសតីតិ អនេកាការវោការំ

១. វីសតិ ។ ម. ក. វីសតិម្បិ ។ ២ ម. ចត្តារីសំ ។



១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុម្ភៃរូបក៏មាន ១ ថ្ងៃផ្ដាច់បង់ជីវិតភិក្ខុសាមសិបរូបក៏មាន មួយថ្ងៃផ្ដាច់បង់ជីវិតភិក្ខុសែសិបរូបក៏មាន មួយថ្ងៃផ្ដាច់បង់ជីវិតភិក្ខុហាសិបរូបក៏មាន មួយថ្ងៃផ្ដាច់បង់ជីវិតភិក្ខុហុកសិបរូបក៏មាន ។

(១៧៧) គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីសម្ងំក្នុងព្រះកម្មដ្ឋានរយៈកន្លះខែនោះទៅ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុដោយព្រះពុទ្ធដីកាថា ដូចម្ដេចហ្ន៎ អានន្ទ ពួកភិក្ខុសង្ឃហាក់ដូចជាស្ដួចស្ដើងទៅ ។ ទើបព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតដូចព្រះពុទ្ធដីកាណាស់ ព្រោះព្រះដ៏មានព្រះភាគទ្រង់សំដែងអសុភកថា ដោយបរិយាយដ៏ច្រើន ទ្រង់សរសើររៀបរាប់ពីអសុភ ទ្រង់សរសើរគុណអសុភភាវនា ទ្រង់សរសើរគុណនៃអសុភសមាបត្តិ ក្នុងអសុភកម្មដ្ឋានជាញឹកញយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងនោះ ក៏គិតថា ព្រះដ៏មានព្រះភាគ ទ្រង់សំដែងអសុភកថា ដោយបរិយាយដ៏ច្រើន ទ្រង់សរសើររៀបរាប់ពីអសុភកថា ទ្រង់សរសើរគុណអសុភភាវនា ទ្រង់សរសើរគុណនៃការប្រកបដោយអសុភកម្មដ្ឋានជាញឹកញយ ហើយ (តំណ)

អសុភភាវនានុយោគមនុយុត្តា វិហរន្តិ ។ តេ សកេន កាយេន អដ្ដីយន្តិ ហរាយន្តិ ជិគុច្ឆន្តិ សេយ្យថាបិ នាម ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ សីសំ ន្ហាតោ អហិកុណបេន វា កុក្កុរកុណបេន វា មនុស្សកុណបេន វា កណ្ឋេ អាសត្តេន អដ្ដីយេយ្យ ហរាយេយ្យ ជិគុច្ឆេយ្យ ឯវមេវ តេ ភិក្ខូ សកេន កាយេន អដ្ដីយមានា ហរាយមានា ជិគុច្ឆមានា សត្ថហារកំ បរិយេសន្តិ អញ្ញមញ្ញម្បិ ជីវិតា វោរោបេន្តិ មិគលណ្ឌិកម្បិ សមណកុត្តកំ ឧបសង្កមិត្វា ឯវំ វទន្តិ សាធុ នោ អាវុសោ ជីវិតា វោរោបេហិ ឥទំ តេ បត្តចីវរំ ភវិស្សតីតិ អថខោ មិគលណ្ឌិកោ សមណកុត្តកោ បត្តចីវរេហិ ភតោ ឯកម្បិ ភិក្ខុំ ឯកាហេន ជីវិតា វោរោបេសិ ។ បេ ។ សដ្ឋិម្បិ ភិក្ខូ ឯកាហេន ជីវិតា វោរោបេសិ សាធុ ភន្តេ ភគវា អញ្ញំ បរិយាយំ អាចិក្ខតុ យថាយំ ភិក្ខុសង្ឃោ អញ្ញាយ សណ្ឋហេយ្យាតិ ។ តេនហានន្ទ



ប្រកបសេចក្តីព្យាយាមក្នុងអសុភភាវនា ជាច្រើនអនេកណាស់ ។ ចំណែកភិក្ខុទាំងនោះ ជាទុក្ខនឿយណាយ ខ្ពើមរអើមនឹងកាយរបស់ខ្លួន ប្រៀបដូចជាស្រីក្រមុំ ឬបុរសក្មេងកំលោះ មានជាតិជាអ្នកស្អិតស្អាង លុះងូតទឹកកក់ក្បាលហើយ រមែងជាទុក្ខនឿយណាយ ខ្ពើមរអើមសាកអសុភពស់ក្តី សាកអសុភឆ្កែក្តី សាកអសុភមនុស្សក្តី ដែលចងព្យួរនឹងក មានឧបមាយ៉ាងណាមិញ ភិក្ខុទាំងអម្បាលនោះ កាលជាទុក្ខនឿយណាយខ្ពើមរអើមនឹងកាយរបស់ខ្លួន ក៏មានឧបមេយ្យយ៉ាងនោះ ទើបផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងក៏មាន ខ្លះចាក់សម្លាប់គ្នាផ្តាច់បង់ជីវិតទៅវិញទៅមកក៏មាន ខ្លះក៏ចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក អ្នកចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រនិងចីវរនេះនឹងបានជារបស់អ្នក បពិត្រព្រះអង្គដ៏ចំរើន គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិក លុះបានទទួលស៊ីឈ្នួលយកបាត្រនិងចីវរហើយ ទើបផ្តាច់បង់ជីវិតភិក្ខុមួយរូបមួយថ្ងៃក៏មាន ។ បេ ។ មួយថ្ងៃផ្តាច់បង់ជីវិតភិក្ខុហុកសិបរូបក៏មាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ ភិក្ខុសង្ឃនេះគប្បីស្ថិតស្ថេរនៅបានដោយហេតុណា សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងហេតុនោះដទៃទៀត ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ

យាវតិកា ភិក្ខូ វេសាលិំ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា យាវតិកា ភិក្ខូ វេសាលិំ ឧបនិស្សាយ វិហរន្តិ តេ សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច សន្និបតិតោ ភន្តេ ភិក្ខុសង្ឃោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។

[១៥៨] អថខោ ភគវា យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ អយម្បិ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ



ភិក្ខុទាំងអម្បាលមាណដែលអាស្រ័យនៅក្នុងក្រុងវេសាលី អ្នកចូរឲ្យភិក្ខុអម្បាលនោះទាំងអស់ប្រជុំគ្នាក្នុងឧបដ្ឋានសាលាចុះ ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ដូច្នេះហើយ ភិក្ខុទាំងឡាយមានប្រមាណប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលី ព្រះអានន្ទក៏បង្គាប់ភិក្ខុអម្បាលនោះទាំងអស់ឲ្យប្រជុំគ្នាក្នុងឧបដ្ឋានសាលា[១] ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃប្រជុំគ្នាស្រេចហើយ ព្រះករុណាម្ចាស់ សូមព្រះដ៏មានព្រះភាគ ទ្រង់សំគាល់កាលគួរក្នុងកាលឥឡូវនេះ ។

[១៥៨] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលតាក់តែងថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ស្រេចហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម៌ស្ងប់ផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំដោយវត្ថុដទៃ ជាគ្រឿងនៅ នាំមកនូវសេចក្ដីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយៗ ឲ្យ

១ សាលាជាទីបម្រើ គឺសាលាសម្រាប់ប្រជុំប្រឹក្សាដោយកិច្ចផ្សេងៗ មានទេសនាជាដើម ។

ឋានសោ អន្តរធាបេតិ វូបសមេតិ សេយ្យថាបិ ភិក្ខវេ គិម្ហានំ បច្ឆិមេ មាសេ ឩហតំ រជោជល្លំ តមេនំ មហាអកាលមេឃោ ឋានសោ អន្តរធាបេតិ វូបសមេតិ ឯវមេវ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ កថំ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា



សាបសូន្យទៅផង ឲ្យស្ងប់រម្ងាប់ផង ដោយទំនងដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចធូលីដែលឡើងហុយក្នុងបច្ឆិមមាសនៃរដូវដែលជាចុងនៃគិម្ហឧតុ ដីទឹកសាប មហាអកាលមេឃ (ភ្លៀងធំធ្លាក់ខុសកាលវេលា) តែងញ៉ាំងធូលីនោះឲ្យអន្តរធាន ឲ្យស្ងប់ទៅបាន ដោយទំនងដ៏សមគួរបានឆាប់រហ័សវិញ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើន ធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ស្ងប់ផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ នឹងជាធម៌ដោយវៀរចាកផង ជាគ្រឿងនៅនាំមកនូវសេចក្ដីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រម្ងាប់ទៅ ដោយទំនងដ៏សមគួរបាន ដូចម្ដេចខ្លះ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិដែលបុគ្គលចំរើនហើយ តើដូចម្ដេច ដែលបុគ្គលធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ស្ងប់ផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ នឹងជាធម៌ដោយវៀរចាកផង ជាគ្រឿងនៅនាំមកនូវសេចក្ដីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រម្ងាប់ទៅ ដោយទំនងដ៏សមគួរ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅកាន់ទីជិតគល់ឈើក្ដី ទៅកាន់ផ្ទះដ៏ស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ដំកល់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន

សោ សតោវ អស្សសតិ សតោ បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ



ភិក្ខុនោះមានសតិ ដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែងក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែងក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចូលខ្លី (ភិក្ខុ) សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង រួចដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង រួចដកដង្ហើមចូល សិក្សាថា អាត្មារម្ងាប់កាយសង្ខារ (គឺខ្យល់អស្សាសបស្សាស) រួចដកដង្ហើមចេញ សិក្សាថា អាត្មានឹងរម្ងាប់កាយសង្ខារ រួចដកដង្ហើមចូល សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវបីតិ (គឺសេចក្តីឆ្អែតកាយឆ្អែតចិត្ត) រួចដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវបីតិ រួចដកដង្ហើមចូល សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវសុខ (គឺសុខកាយសុខចិត្ត) រួចដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវសុខ រួចដកដង្ហើមចូល សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ (គឺវេទនានឹងសញ្ញា) រួចដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ រួចដកដង្ហើមចូល សិក្សាថា

សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ



អញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចូល សិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចូល សិក្សាថា អញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចូល សិក្សាថា អញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាឃើញ ។ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ សឹមដកដង្ហើមចេញ

បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ឯវំ ភាវិតោ ខោ ភិក្ខវេ អានាបានស្សតិសមាធិ ឯវំ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចន-កោ ច សុខោ ច វិហារោ ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ ។

(១៧៩) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិ-បុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ អត្តនាបិ អត្តានំ ជីវិតា វោរោបេន្តិ អញ្ញមញ្ញម្បិ ជីវិតា វោរោបេន្តិ មិគ-លណ្ឌិកំបិ សមណកុត្តកំ ឧបសង្កមិត្វា ឯវំ វទន្តិ សាធុ នោ អាវុសោ ជីវិតា វោរោបេហិ ឥទំ តេ បត្តចីវរំ ភវិស្សតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា



សិក្សាថា អញនឹងពិចារណារឿយ ៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ ហើយដកដង្ហើមចូល ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិដែលបុគ្គលបានចំរើនហើយយ៉ាងនេះ ដែលបុគ្គលធ្វើឲ្យច្រើនហើយយ៉ាងនេះ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនប្រឡូកប្រឡំនឹងធម៌ដោយឡែកផង ជាគ្រឿងនៅតាមកនូវសេចក្តីសុខផង តែងញាំងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើង ៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់ទៅ ដោយទំនងនៃសមគួរ ។

(១៧៩) ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សាកសួរភិក្ខុទាំងឡាយក្នុងគ្រានោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្លាស់គ្នាផ្តាច់បង់ជីវិតទៅវិញទៅមកខ្លះ ភិក្ខុចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិក ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក ៗ ចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រនិងចីវរទាំងនេះនឹងបានជារបស់អ្នក (យ៉ាងនេះ) ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏ទ្រង់ព្រះភាគ

អននុច្ឆវិកំ ភិក្ខវេ តេសំ ភិក្ខូនំ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម តេ ភិក្ខវេ ភិក្ខូ អត្តនាបិ អត្តានំ ជីវិតា វោរោបេស្សន្តិ អញ្ញមញ្ញម្បិ ជីវិតា វោរោបេស្សន្តិ មិគលណ្ឌិកម្បិ សមណកុត្តកំ ឧប-សង្កមិត្វា ឯវំ វក្ខន្តិ សាធុ នោ អាវុសោ ជីវិតា វោរោបេហិ ឥទំ តេ បត្តចីវរំ ភវិស្សតីតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេយ្យ សត្ថហារកំ វាស្ស បរិយេសេយ្យ អយម្បិ បារាជិ-កោ ហោតិ អសំវាសោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១៨០] តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ គិលានោ ហោតិ ។ តស្ស បជាបតិ អភិរូបា ហោតិ ទស្សនីយា បាសាទិកា





ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយបានធ្វើហើយនេះ មិនសម មិនចំនង មិនគួរ មិនមែនជាកិច្ចរបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេចបានជាពួកភិក្ខុទាំងនោះទៅផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្តាស់គ្នាឲ្យផ្តាច់ជីវិតទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តក ឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក ។ ចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រនិងចីវរនេះនឹងបានជារបស់អ្នក ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្លែងផ្តាច់បង់កាយរបស់មនុស្សឲ្យឃ្លាតចាកជីវិតក្តី ពោលបើស្វែងរកគ្រឿងសស្ត្រាវុធ (គ្រឿងសម្លាប់) ពន់កាយមនុស្សនោះក្តី ភិក្ខុនេះឯងហៅថា ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៨០] សម័យនោះឯង មានឧបាសកម្នាក់មានជម្ងឺ ។ ប្រពន្ធរបស់ឧបាសកនោះ មានរូបល្អស្រស់បស់គួរឲ្យគយគន់ជាទីនាំមកនូវ

ឆព្វគ្គិយា ភិក្ខូ តស្សា ឥត្ថិយា បដិពទ្ធចិត្តា ហោន្តិ ។ អថខោ ឆព្វគ្គិយានំ ភិក្ខូនំ ឯតទហោសិ សចេ ខោ សោ អាវុសោ ឧបាសកោ ជីវិស្សតិ ន មយំ តំ ឥត្ថឹ លភិស្សាម ហន្ទ មយំ អាវុសោ តស្ស ឧបាសកស្ស មរណវណ្ណំ សំវណ្ណេមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ យេន សោ ឧបាសកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ ឧបាសកំ ឯតទវោចុំ ត្វំ ខោសិ ឧបាសក កតកល្យាណោ កតកុសលោ កតភីរុត្តាណោ អកតបាបោ អកតលុទ្ទោ អកតកិព្វិសោ កតំ តយា កល្យាណំ អកតំ តយា បាបំ កឹ តុយ្ហិមិនា បាបកេន ទុជ្ជីវិតេន មតន្តេ ជីវិតា សេយ្យោ ឥតោ ត្វំ កាលង្កតោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧប-បជ្ជិស្សសិ តត្ថ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេស្សសីតិ ។ អថខោ



សេចក្ដីជ្រះថ្លា ។ ពួកឆព្វគ្គិយភិក្ខុមានចិត្តប្រតិព័ទ្ធចំពោះស្រីនោះ ។ គ្រានោះ សេចក្ដីត្រិះរិះនេះបានមានដល់ពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោទាំងឡាយ បើឧបាសកនោះនឹងរស់នៅ ពួកយើងមុខជានឹងមិនបានស្រីនោះទេ ម្នាលអាវុសោទាំងឡាយ បើដូច្នោះយើង (នាំគ្នា) ពណ៌នាគុណនៃសេចក្ដីស្លាប់ដល់ឧបាសកនោះ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាចូលទៅកាន់ទីដែលឧបាសកនោះនៅ លុះចូលទៅដល់ហើយក៏និយាយពាក្យនេះនឹងឧបាសកនោះថា ម្នាលឧបាសក អ្នកឯងបានធ្វើអំពើល្អមកហើយ បានធ្វើកុសលមកហើយ បានធ្វើកម្មជាគ្រឿងការពារភ័យខ្លាចរួចហើយ អ្នកឯងមិនដែលធ្វើបាប មិនដែលធ្វើអំពើលាមក មិនដែលធ្វើអំពើអាក្រក់ អំពើល្អអ្នកបានធ្វើហើយ បាបអ្នកមិនបានធ្វើឡើយ អ្នកឯងមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ អ្នកធ្វើកាលកិរិយា រំលាយខន្ធស្លាប់ចាកមនុស្សលោកនេះទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិ ឬស្ថានសួគ៌ អ្នកនឹងបានឆ្អែតស្កប់ស្កល់ (នឹងបានទេវស្រីអប្សរទាំងឡាយ) បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វក្នុងស្ថានសួគ៌នោះ ។ គ្រានោះឯង

សោ ឧបាសកោ សច្ចំ ខោ អយ្យា អាហំសុ អហញ្ហិ កតកល្យាណោ កតកុសលោ កតភី-រុត្តាណោ អកតបាបោ អកតលុទ្ទោ អកតកិ-ព្វិសោ កតំ មយា កល្យាណំ អកតំ បាបំ កឹ មយ្ហិមិនា បាបកេន ទុជ្ជីវិតេន មយ្ហំ មតំ ជីវិតា សេយ្យោ ឥតោ អហំ កាលកតោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមិ តត្ថ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេស្សាមីតិ ។ សោ អសប្បាយានិ ចេវ ភោជនានិ ភុញ្ជិ អសប្បា-យានិ ច ខាទនីយានិ ខាទិ អសប្បាយានិ ច សាយនីយានិ សាយិ អសប្បាយានិ ច បានានិ បិវិ ។ តស្ស អសប្បាយានិ ចេវ ភោជនានិ ភុញ្ជ-តោ អសប្បាយានិ ច ខាទនីយានិ ខាទតោ





ឧបាសកនោះគិតថា លោកម្ចាស់ទាំងឡាយនិយាយ ( នេះ ) ពិតណាស់ ព្រោះតែអញជាមនុស្សបានធ្វើអំពើល្អមកហើយ បានធ្វើកុសលមកហើយ បានធ្វើទីពឹងនៃភ័យ ( ក្នុងគ្រាក្ស័យ ) ហើយ បាបអញមិនដែលធ្វើឡើយ អំពើអាក្រក់ក៏អញមិនដែលធ្វើ មិនធ្លាប់ធ្វើអំពើអាក្រក់សោះ អំពើប្រពៃអញបានធ្វើហើយ បាបអញមិនធ្លាប់ធ្វើឡើយ អញមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អញស្លាប់ទៅប្រសើរជាងរស់នៅ អញធ្វើកាលកិរិយាហើយលាទីខ្លួន ស្លាប់ចាកមនុស្សលោកនេះទៅកាន់បរលោក នឹងកើតក្នុងភូមិមនុស្សសុគតិ ឬ ស្ថានសួគ៌ អញមុខជានឹងបានឆ្អែតស្កប់ស្កល់ ( ឲ្យស្រីទេពអប្សរទាំងឡាយ ) បម្រើដោយកាមគុណទាំង ៥ ដែលជាទិព្វក្នុងស្ថានសួគ៌នោះ ។ ឧបាសកនោះបរិភោគភោជនទាំងឡាយដែលមិនសប្បាយ ( គឺអាហារដែលស្អុយ ធ្វើឲ្យកើតរោគ ) ទំពាស៊ីខាទនីយៈ ( គ្រឿងទំពា ) ដែលមិនសប្បាយផង ស្លាបស្លាក់នូវវត្ថុសម្រាប់ស្លាបស្លាក់ដែលមិនសប្បាយផង ផឹកទឹកដែលមិនសប្បាយផង ។ កាលឧបាសកនោះបរិភោគភោជនដែលមិនសប្បាយតែម្យ៉ាងផង កាលទំពាស៊ីខាទនីយវត្ថុដែលមិនសប្បាយផង

អសប្បាយានិ ច សាយនីយានិ សាយិតោ អសប្បាយានិ ច បានានិ បិវិតោ ខរោ អាពាធោ ឧប្បជ្ជិ ។ សោ តេន អាពាធេន កាលមកាសិ ។ តស្ស បជាបតិ ឧជ្ឈាយតិ ខីយតិ វិបាចេតិ អលជ្ជិនោ ឥមេ សមណា សក្យបុត្តិយា ទុស្សីលា មុសាវាទិនោ ឥមេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ នដ្ឋំ ឥមេសំ សាមញ្ញំ នដ្ឋំ ឥមេសំ ព្រហ្មញ្ញំ កុតោ ឥមេសំ សាមញ្ញំ កុតោ ឥមេសំ ព្រហ្មញ្ញំ អបគតា ឥមេ សាមញ្ញា អបគតា ឥមេ ព្រហ្មញ្ញា ឥមេ មេ សាមិកស្ស មរណវណ្ណំ សំវណ្ណេសុំ ឥមេហិ មេ សាមិកោ មារិតោតិ ។ អញ្ញេបិ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ



កាលជញ្ជាប់ជញ្ជក់នូវវត្ថុសម្រាប់ជញ្ជាប់ជញ្ជក់មិនសប្បាយផង ផឹកទឹកដែលមិនសប្បាយផង អាពាធដ៏ក្លៀវក្លាក៏កើតឡើង ។ ឧបាសកនោះក៏ធ្វើកាលកិរិយាស្លាប់ទៅដោយអាពាធនោះឯង ។ ហើយប្រពន្ធរបស់ឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈទាំងនេះជាសក្យបុត្រ ជាបុគ្គលឥតខ្មាស ជាមនុស្សទ្រុស្តសីល មានប្រក្រតីពោលពាក្យមុសា ពួកសមណៈទាំងនេះនឹងប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ ជាអ្នកប្រព្រឹត្តរៀបរយ ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកពោលពាក្យសច្ច ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌ ដូចម្តេចបាន គុណសមណៈរបស់ភិក្ខុទាំងនេះគ្មានទេ ព្រហ្មចរិយធម៌របស់ភិក្ខុទាំងនេះក៏គ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា សមណៈទាំងនេះប្រាសចាកសាមញ្ញគុណហើយ សមណៈទាំងនេះប្រាសចាកព្រហ្មញ្ញគុណហើយ (ព្រោះ) សមណៈទាំងនេះបានពណ៌នាគុណនៃសេចក្តីស្លាប់ដល់ស្វាមីរបស់អញ ស្វាមីរបស់អញ ក៏ សមណៈទាំងនេះសម្លាប់ហើយ ។ ទាំងពួកមនុស្សឯទៀតក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈ

អស្សទ្ធា តេ សមណា សក្យបុត្តិយា ទុស្សីលា មុសាវាទិនោ តេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ តេសំ សាមញ្ញំ នត្ថិ តេសំ ព្រហ្មញ្ញំ នដ្ឋំ តេសំ សាមញ្ញំ នដ្ឋំ តេសំ ព្រហ្មញ្ញំ កុតោ តេសំ សាមញ្ញំ កុតោ តេសំ ព្រហ្មញ្ញំ អបគតា តេ សាមញ្ញា អបគតា តេ ព្រហ្មញ្ញា តេ ឧបា-សកស្ស មរណវណ្ណំ សំវណ្ណេសុំ តេហិ ឧបាសកោ មារិតោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ឧបាសកស្ស មរណវណ្ណំ សំវណ្ណេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។



ពួកនេះជាសក្យបុត្រ ជាមនុស្សឥតខ្មាស ជាមនុស្សទ្រុស្តសីល ពោលតែពាក្យមុសា ពួកសមណៈទាំងនេះប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តព្រហ្មចរិយធម៌ ពោលពាក្យសច្ច មានសីល មានកល្យាណធម៌ ដូច្នេះបាន (ព្រោះ) សាមញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះក៏គ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញ-គុណរបស់សមណៈទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា ពួកសមណៈទាំងនេះឃ្លាតចាកសាមញ្ញគុណហើយ ពួកសមណៈទាំងនេះឃ្លាតចាកព្រហ្មញ្ញគុណហើយ (ព្រោះ) សមណៈទាំងនេះបានពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក ឧបាសកដែលស្លាប់ពីព្រោះតែសមណៈទាំងនេះ ។ ភិក្ខុទាំងឡាយបានឮមនុស្សពួកនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុម្តេចបានជា ពួកឆព្វគ្គិយភិក្ខុទៅពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក (ដូច្នេះ) ។ គ្រានោះឯង ពួកភិក្ខុទាំងនោះ បានក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។

សច្ចំ កិរ តុម្ហេ ភិក្ខវេ ឧបាសកស្ស មរណវណ្ណំ
សំវណ្ណេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា
អននុច្ឆវិកំ មោឃបុរិសា អននុលោមិកំ អប្បដិរូបំ
អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម
តុម្ហេ មោឃបុរិសា ឧបាសកស្ស មរណវណ្ណំ សំ-
វណ្ណេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសា-
ទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ
ជីវិតា វោរោបេយ្យ សត្ថហារកំ វាស្ស បរិយេសេយ្យ
មរណវណ្ណំ វា សំវណ្ណេយ្យ មរណាយ វា សមាទបេយ្យ
អម្ភោ បុរិស កឹ តុយ្ហិមិនា បាបកេន ទុជ្ជីវិតេន
មតន្តេ ជីវិតា សេយ្យោតិ ឥតិ ចិត្តមនោ ចិត្តសង្កប្បោ



ព្រះបរមសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក មែនឬ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ (អំពើដែលអ្នកទាំងអស់គ្នាធ្វើហើយនុ៎ះ) មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើសោះ ម្នាលមោឃ-បុរសទាំងឡាយ ហេតុម្តេច បានជាអ្នកទាំងឡាយទៅពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក (ដូច្នោះ) ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្លែងផ្តាច់បង់នូវកាយរបស់មនុស្សឲ្យឃ្លាតចាកជីវិតក្តី ទោះបី ស្វែងរកគ្រឿងសស្ត្រា (ឲ្យគេសម្លាប់) នូវកាយមនុស្សនោះក្តី ពណ៌-នាគុណនៃសេចក្តីស្លាប់ក្តី ឬនិយាយណែនាំដើម្បីសេចក្តីស្លាប់ថា នែបុរសដ៏ចំរើន អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ (ក៏ក្តី) មានចិត្តគិតដូច្នេះ មានសេចក្តីត្រិះរិះ

អនេកបរិយាយេន មរណវណ្ណំ វា សំវណ្ណេយ្យ មរណាយ វា សមាទបេយ្យ អយម្បិ បារាជិកោ ហោតិ អសំវាសោ ។

(១៨១) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សញ្ចិច្ចាតិ ជានន្តោ សញ្ជានន្តោ ចេច្ច អភិវិតរិត្វា វីតិក្កមោ ។ មនុស្សវិគ្គហោ នាម យំ មាតុកុច្ឆិស្មឹ បឋមំ ចិត្តំ ឧប្បន្នំ បឋមំ វិញ្ញាណំ បាតុភូតំ យាវ មរណកាលា ឯត្ថន្តរេ ឯសោ មនុស្សវិគ្គហោ នាម ។ ជីវិតា វោរោបេយ្យាតិ ជីវិតិន្ទ្រិយំ ឧបច្ឆិន្ទតិ ឧបរោធេតិ សន្តតឹ វិកោបេតិ ។ សត្ថហារកំ វាស្ស បរិយេសេយ្យាតិ អសឹ វា សត្តឹ វា ភេណ្ឌឹ វា លគុឡំ វា បាសាណំ វា សត្ថំ វា វិសំ វា រជ្ជុំ វា ។

(១៨២) មរណវណ្ណំ វា សំវណ្ណេយ្យាតិ ជីវិតេ អាទីនវំ ទស្សេតិ មរណេ វណ្ណំ ភណតិ ។



ចំពោះ ក៏ឬក៏ពណ៌នាគុណនៃសេចក្តីស្លាប់ ឬបបួលដោយដើម្បីសេចក្តីស្លាប់ដោយអនេកបរិយាយ ភិក្ខុនេះក្តី ហៅថាត្រូវអាបត្តិបារាជិក មិនមានសំវាសឡើយ ។

(១៨១) ត្រង់ពាក្យថា ភិក្ខុណាមួយ (គឺខេត្តប្រភេទណា មានសេចក្តីអធិប្បាយដូចគ្នានឹងបារាជិកសិក្ខាបទទី ១) ។ ត្រង់បទថា ភិក្ខុ (នោះ) គឺជាក់ច្បាស់ហើយភិក្ខុសម្មត ។ ដែលហៅថា កាយនៃមនុស្ស (នោះ) គឺបឋមចិត្តណាដែលកើតឡើងហើយ បឋមវិញ្ញាណណាដែលកើតឡើងប្រាកដហើយក្នុងផ្ទៃមាតាដរាបដល់ពេលស្លាប់ ក្នុងកាលប៉ុណ្ណេះ នេះឯងហៅថាកាយរបស់មនុស្ស ។ ត្រង់ពាក្យថា ផ្តាច់បង់ចាកជីវិត គឺចូលទៅផ្តាច់បង់ ញុំាងជីវិតិន្ទ្រិយឲ្យលះទៅ គឺញុំាងសន្តតិ (ខ្សែតនៃចិត្ត) ឲ្យកំរើក ។ ត្រង់ពាក្យថា ពេលនោះបីស្វែងរកគ្រឿងសស្ត្រាវុធ (ឲ្យគេសម្លាប់) កាយមនុស្សនោះក្តី សេចក្តីថា គឺស្វែងរកដាវក្តី លំពែងក្តី ព្រួញក្តី ឈើស្រួចក្តី អន្ទាក់ក្តី ថ្មក្តី កាំបិតក្តី ថ្នាំពិសក្តី ខ្សែក្តី ។

(១៨២) ត្រង់ពាក្យថា ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី សេចក្តីថា សំដែងទោសក្នុងជីវិតរស់នៅ ពោលសរសើរគុណក្នុងការស្លាប់ ។

[១៥៣] មរណាយ វា សមាទបេយ្យាតិ សត្ថំ វា អាហរ វិសំ វា ខាទ រជ្ជុយា វា ឧព្ភន្ធិត្វា កាលំ ករោហីតិ ។

[១៥៤] អម្ភោ បុរិសាតិ អាលបនមេតំ អម្ភោបុរិសាតិ[១] ។ កឹ តុយ្ហិមិនា បាបកេន ទុជ្ជីវិតេន មតន្តេ ជីវិតា សេយ្យោតិ បាបកំ នាម ជីវិតំ អឌ្ឍានំ ជីវិតំ ឧបាទាយ ទលិទ្ទានំ ជីវិតំ បាបកំ សធនានំ ជីវិតំ ឧបាទាយ អធនានំ ជីវិតំ បាបកំ ទេវានំ ជីវិតំ ឧបាទាយ មនុស្សានំ ជីវិតំ បាបកំ ។ ទុជ្ជីវិតំ នាម ហត្ថច្ឆិន្នស្ស បាទច្ឆិន្នស្ស ហត្ថបាទច្ឆិន្នស្ស កណ្ណច្ឆិន្នស្ស នាសច្ឆិន្នស្ស កណ្ណនាសច្ឆិន្នស្ស ។ ឥមិនា ច បាបកេន ឥមិនា ច ទុជ្ជីវិតេន មតន្តេ

១ គេសុ ត្រៃបិដកបោត្ថកេសុ នត្ថិ វិចំ ៥ បញ្ញាយតិ ។



[១៥៣] ត្រង់ពាក្យថា ឬនិយាយណែនាំដើម្បីសេចក្ដីស្លាប់ក្ដី សេចក្ដីថា និយាយណែនាំថា អ្នកចូរនាំគ្រឿងសស្ត្រាមកក្ដី ចូរស៊ីថ្នាំពិសក្ដី ចូរចងកដោយខ្សែហើយធ្វើមរណកាលទៅក្ដី (យ៉ាងនេះហៅថា និយាយណែនាំដើម្បីសេចក្ដីស្លាប់) ។

[១៥៤] ត្រង់ពាក្យថា នែបុរសដ៏ចំរើន (នេះ) ជាឈ្មោះនៃពាក្យ អាលបន (ពាក្យស្រែកហៅ)ថា ម្នាលបុរសដ៏ចំរើន ។ ត្រង់ពាក្យថា អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងការរស់នៅ មានអធិប្បាយថា ជីវិតរបស់ពួកមនុស្សកំសត់បើធៀបផ្ទឹមនឹងជីវិតរបស់ពួកមនុស្សស្ដុកស្ដម្ភ (គឺឃើញថា) ជាជីវិតលាមក ជីវិតរបស់ពួកមនុស្សឥតទ្រព្យបើធៀបផ្ទឹមនឹងជីវិតរបស់ពួកមនុស្សមានទ្រព្យ (គឺឃើញថា) ជាជីវិតលាមក ជីវិតរបស់មនុស្សទាំងឡាយ បើធៀបផ្ទឹមនឹងជីវិតរបស់ទេវតាទាំងឡាយ (គឺឃើញថា) ជាជីវិតលាមក (យ៉ាងនេះ) ហៅថា ជីវិតលាមក ។ ជីវិតរបស់មនុស្សដាច់ដៃ ដាច់ជើង ដាច់ទាំងដៃទាំងជើង មនុស្សដាច់ត្រចៀក មនុស្សដាច់ច្រមុះ មនុស្សដាច់ទាំងត្រចៀកទាំងច្រមុះ (ជាដើមនេះ) ហៅថា ជីវិតអាក្រក់ ។ អ្នកមានប្រយោជន៍អ្វីនឹងជីវិតដ៏លាមកនេះ នឹងជីវិតដ៏អាក្រក់នេះ អ្នកស្លាប់ទៅ

ជីវិតា សេយ្យោ ។ ឥតិចិត្តមនោតិ យំ ចិត្តំ តំ មនោ យំ មនោ តំ ចិត្តំ ។ ចិត្តសង្កប្បោតិ មរណសញ្ញី មរណចេតនោ មរណាធិប្បាយោ ។ អនេកបរិយាយេនាតិ ឧច្ចាវចេហិ អាការេហិ ។ មរណវណ្ណំ វា សំវណ្ណេយ្យាតិ ជីវិតេ អាទីនវំ ទស្សេតិ មរណេ វណ្ណំ ភណតិ ឥតោ ត្វំ កាលង្កតោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សសិ តត្ថ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេស្សសីតិ ។

[១៨៥] មរណាយ វា សមាទបេយ្យាតិ សត្ថំ វា អាហរ វិសំ វា ខាទ រជ្ជុយា វា ឧព្វន្ធិត្វា កាលំករោហិ សោព្ភេ វា នរកេ វា បបាតេ វា បបតាតិ ។

[១៨៦] អយម្បីតិ បុរិមំ ឧបាទាយ វុច្ចតិ ។ បារាជិកោ ហោតីតិ



ប្រសើរជាងរស់នៅ ។ ត្រង់ពាក្យថា មានចិត្តគិតដូច្នេះ សេចក្តីថា ធម្មជាតណាជាចិត្ត ធម្មជាតនោះជាមនោ ធម្មជាតណាជាមនោ ធម្មជាតនោះក៏ជាចិត្ត ។ ត្រង់ពាក្យថា មានសេចក្តីត្រិះរិះក្នុងចិត្តដូច្នេះ សេចក្តីថា មានសេចក្តីសំគាល់ក្នុងសេចក្តីស្លាប់ មានចេតនាចង់ឲ្យស្លាប់ មានសេចក្តីប្រុងប្រឹងចង់ឲ្យស្លាប់ ។ ត្រង់ពាក្យថា ដោយអនេកបរិយាយ គឺដោយអាការជាច្រើនយ៉ាងខ្ពស់ទាប (ដោយឧបាយច្រើនយ៉ាង) ។ ត្រង់ពាក្យថា ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី អធិប្បាយថា តិះដៀលនូវទោសក្នុងការរស់នៅ ពោលសរសើរគុណក្នុងការស្លាប់ទៅដូច្នេះថា អ្នកស្លាប់អំពីលោកនេះ គឺអ្នកលះនូវខន្ធស្លាប់ទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិ ឋានសួគ៌ អ្នកនឹងបានផ្អែកស្កប់ស្កល់ (ឲ្យស្រេចពេកប្រាថ្នាចង់ឡាយ) បម្រើដោយកាមគុណទាំង ៥ ជាទិព្វក្នុងឋានសួគ៌នោះ ។

(១៨៥) ត្រង់ពាក្យថា ឬនិយាយណែនាំដើម្បីសេចក្តីស្លាប់ សេចក្តីថា (និយាយដឹកនាំ) ថាអ្នកចូរនាំគ្រឿងសស្ត្រាមកក្តី អ្នកចូរស៊ីថ្នាំពិសក្តី អ្នកចូរចងកដោយខ្សែហើយធ្វើកាលកិរិយាទៅក្តី អ្នកចូរលោតទម្លាក់ទៅក្នុងរណ្តៅក្តី អណ្តូងក្តី ជ្រោះក្តី ។

(១៨៦) ត្រង់ពាក្យថា ភិក្ខុនេះក្តី មានសេចក្តីអធិប្បាយដូចខាងដើម (ត្រង់បារាជិកកណ្ឌទី ១) ។ ត្រង់ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយ

សេយ្យថាបិ នាម បុថុសិលា ទ្វេធា ភិន្នា អប្បដិ-
សន្ធិកា ហោតិ ឯវមេវ ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ
ជីវិតា វោរោបេត្វា អស្សមណោ ហោតិ អសក្យ-
បុត្តិយោ តេន វុច្ចតិ បារាជិកោ ហោតីតិ ។
អសំវាសោតិ សំវាសោ នាម ឯកកម្មំ ឯកុទ្ទេសោ
សមសិក្ខាតា ឯសោ សំវាសោ នាម សោ តេន
សទ្ធឹ នត្ថិ តេន វុច្ចតិ អសំវាសោតិ ។

[១៨៧] សាមំ អធិដ្ឋាយ ទូតេន ទូតបរម្បរាយ
វិសក្កិយេន ទូតេន គតប្បច្ចាគតេន ទូតេន អរហោ-
រហោសញ្ញី រហោ អរហោសញ្ញី អរហោ អរហោ-
សញ្ញី រហោ រហោសញ្ញី កាយេន សំវណ្ណេតិ
វាចាយ សំវណ្ណេតិ កាយេន វាចាយ សំវណ្ណេតិ
ទូតេន សំវណ្ណេតិ លេខាយ សំវណ្ណេតិ ឱបាតំ
អបស្សេនំ ឧបនិក្ខិបនំ ភេសជ្ជំ រូបូបហារោ



ដូចថ្មបន្ទះបែកជាពីរចំណែក តភ្ជាប់គ្នាមិនបានទៀត យ៉ាងណាមិញ
ភិក្ខុក៏ផ្ដាច់បង់នូវកាយរបស់មនុស្សឲ្យចាកជីវិត មិនមែនជាសមណ
មិនមែនជាសក្យបុត្រ មានទោសយ៉ាងធ្ងន់ ព្រោះហេតុនោះ ទើប
ហៅថា ត្រូវអាបត្តិបារាជិក ។ ត្រង់ពាក្យថា រកសំវាសគ្មាន សេចក្ដី
ថា កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សិក្ខាស្មើគ្នា នេះហៅថាមាន
សំវាស ភិក្ខុនោះគ្មានសំវាសជាមួយនោះទេ ព្រោះហេតុនោះ ទើបហៅថា
រកសំវាសគ្មាន ។

(១៨៧) ភិក្ខុស្ថិតនៅក្នុងទីដ៏ជិត (គំនិតនឹងសម្លាប់មនុស្ស) ដោយ
ខ្លួនឯង ដោយប្រើបម្រើ ដោយប្រើបម្រើត ៗ គ្នា ដោយបម្រើទៅធ្វើការ
ឲ្យសម្រេច ដោយបម្រើទៅហើយត្រឡប់មកវិញ ភិក្ខុនៅក្នុងទីមិនកំបាំង
សំគាល់ថាកំបាំង នៅក្នុងទីកំបាំងសំគាល់ថាមិនកំបាំង នៅក្នុងទីមិន
កំបាំង សំគាល់ថាមិនកំបាំង នៅក្នុងទីកំបាំងសំគាល់ថាកំបាំង ភិក្ខុពណ៌នា
(សេចក្ដីស្លាប់) ដោយកាយ ពណ៌នាដោយវាចា ពណ៌នាដោយកាយ
និងវាចា ពណ៌នាដោយប្រើបម្រើ ពណ៌នាដោយចារឹកអក្សរ ជីក
រណ្ដៅ [illegible] [illegible] ឲ្យភេសជ្ជៈ សម្លាប់ដោយរូប សម្លាប់

សទ្ទូបហារោ គន្ធូបហារោ រសូបហារោ ផោដ្ឋព្វូបហារោ ធម្មូបហារោ អាចិក្ខណា អនុសាសនី សង្កេតកម្មំ និមិត្តកម្មន្តិ ។

(១៨៨) សាមន្តិ សយំ ហនតិ កាយេន វា កាយប្បដិពទ្ធេន វា និស្សគ្គិយេន វា ។ អធិដ្ឋាយាតិ អធិដ្ឋហិត្វា អាណាបេតិ ឯវំ វិជ្ឈ ឯវំ បហារ ឯវំ ឃាតេហីតិ ។

(១៨៩) ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ តំ មញ្ញមានោ តំ ជីវិតា វោរោបេតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ តំ មញ្ញមានោ អញ្ញំ ជីវិតា វោរោបេតិ មូលដ្ឋស្ស អនាបត្តិ វធកស្ស អាបត្តិ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ



ដោយសំឡេង សម្លាប់ដោយក្លិន សម្លាប់ដោយរស សម្លាប់ដោយសម្ផស្ស សម្លាប់ដោយធម៌ បង្គាប់ឲ្យស្លាប់ ប្រៀនប្រដៅដើម្បីឲ្យស្លាប់ ធ្វើសង្កេតកម្ម ធ្វើនិមិត្តកម្ម ។

(១៨៨) ត្រង់ពាក្យថា ដោយខ្លួនឯង គឺភិក្ខុសម្លាប់ (គេ) ខ្លួនឯង ដោយកាយក្តី ដោយគ្រឿងដែលជាប់នឹងកាយក្តី ដោយគ្រឿងប្រយោគក្តី ។ ត្រង់ពាក្យថា ឋិតនៅក្នុងទីជិត សេចក្តីថា ឋិតនៅ (ក្នុងទីជិត) ក៏បង្គាប់ថា អ្នកចូរចាក់យ៉ាងនេះ អ្នកចូរប្រហារយ៉ាងនេះ អ្នកចូរសម្លាប់យ៉ាងនេះ ។

(១៨៩) ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះចំណាំមនុស្សនោះបាន ហើយផ្តាច់បង់ជីវិតមនុស្សនោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សបាន (ប៉ុន្តែ) ទៅផ្តាច់បង់ជីវិតមនុស្សដទៃវិញ ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិឡើយ ភិក្ខុអ្នកសម្លាប់ត្រូវអាបត្តិបារាជិក ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរផ្តាច់បង់ជី

ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ អញ្ញំ មញ្ញមានោ តំ ជីវិតា វោរោបេតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ អញ្ញំ មញ្ញមានោ អញ្ញំ ជីវិតា វោរោបេតិ មូលដ្ឋស្ស អនាបត្តិ វធកស្ស អាបត្តិ បារាជិកស្ស ។

(១៩០) ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមស្ស បាវទ ឥត្ថន្នាមោ ឥត្ថន្នាមស្ស បាវទតុ ឥត្ថន្នាមោ ឥត្ថន្នាមំ ជីវិតា វោរោបេតូតិ អាបត្តិ ទុក្កដស្ស ។ សោ ឥតរស្ស អារោចេតិ អាបត្តិ ទុក្កដស្ស ។ វធកោ បដិគ្គណ្ហាតិ មូលដ្ឋស្ស អាបត្តិ ថុល្លច្ចយស្ស ។ សោ តំ ជីវិតា វោរោបេតិ អាបត្តិ សព្វេសំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមស្ស បាវទ ឥត្ថន្នាមោ



ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សដទៃវិញ (ប៉ុន្តែ) ទៅផ្តាច់បង់ជីវិតមនុស្សនោះ (គឺមនុស្សដែលអ្នកប្រើប្រាប់ឲ្យសម្លាប់នោះ) ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុបង្គាប់ភិក្ខុថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សដទៃវិញ (លុះវេលា)ទៅផ្តាច់បង់ ។ ជីវិតមនុស្សដទៃនោះ (ដោយខុសបង្គាប់ដូច្នេះ) ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិទេ ភិក្ខុអ្នកសម្លាប់ត្រូវអាបត្តិបារាជិក ។

[១៩០] ភិក្ខុបង្គាប់ភិក្ខុថា[១] លោកចូរប្រាប់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះប្រាប់ដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅប្រាប់អ្នកឯទៀតវិញ (ដូច្នេះ) ក៏ត្រូវអាបត្តិទុក្កដដែរ ។ ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ ភិក្ខុអ្នកប្រើដើមត្រូវអាបត្តិថុល្លច្ច័យ ។ លុះភិក្ខុអ្នកសម្លាប់បានផ្តាច់បង់ជីវិតបុគ្គលនោះសម្រេច ត្រូវអាបត្តិបារាជិកគ្រប់ទាំងបួនរូប ។ ភិក្ខុបង្គាប់ភិក្ខុថា លោកចូរទៅប្រាប់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះ

១ ក្នុងអដ្ឋកថា ពន្យល់សេចក្តីថា ភិក្ខុជាអាចារ្យ ប្រើភិក្ខុឈ្មោះពុទ្ធរក្ខិត ឲ្យទៅប្រាប់ភិក្ខុឈ្មោះធម្មរក្ខិត ឲ្យប្រាប់ភិក្ខុឈ្មោះសង្ឃរក្ខិត ឲ្យទៅសម្លាប់មនុស្សឈ្មោះនេះ ។ ត្រង់ពាក្យថា ឈ្មោះនេះ គឺមនុស្សនោះឈ្មោះអ្វី ទាំងឈ្មោះនោះឯង ។

ឥត្ថន្នាមស្ស បាវទតុ ឥត្ថន្នាមោ ឥត្ថន្នាមំ ជីវិតា វោរោ-បេតូតិ អាបត្តិ ទុក្កដស្ស ។ សោ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស ។ វធកោ បដិគ្គណ្ហាតិ អាបត្តិ ថុល្លច្ចយស្ស ។ សោ តំ ជីវិតា វោរោបេតិ មូលដ្ឋស្ស អនាបត្តិ អាណាបកស្ស ច វធកស្ស ច អាបត្តិ បារាជិកស្ស ។

(១៩១) ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ គន្ត្វា បុន បច្ចាគច្ឆតិ នាហំ សក្កោមិ តំ ជីវិតា វោរោបេតុន្តិ ។ សោ បុន អាណាបេតិ យទា សក្កោសិ តទា តំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ តំ ជីវិតា វោរោបេតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។

(១៩៤) ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ តំ អាណា-បេត្វា វិប្បដិសារី ន សាវេតិ មា ឃាតេហីតិ ។ សោ



ទៅប្រាប់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅបង្គាប់ភិក្ខុឯទៀតវិញ (ក្រៅពីសេចក្តីបង្គាប់ដូច្នេះ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុអ្នកសម្លាប់នោះ បានផ្តាច់បង់ជីវិតបុគ្គលនោះសម្រេច ភិក្ខុអ្នកបង្គាប់ដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកបង្គាប់ និងភិក្ខុអ្នកសម្លាប់ ។

(១៩១) ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅហើយត្រ-ឡប់មកប្រាប់វិញថា ខ្ញុំមិនអាចនឹងផ្តាច់បង់ជីវិតបុគ្គលនោះទេ ។ ភិក្ខុនោះបង្គាប់ទៀតថា លោកអាចវេលាណា លោកចូរទៅផ្តាច់បង់ជីវិតគេវេលានោះចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះភិក្ខុអ្នកទទួលបង្គាប់នោះ បានផ្តាច់បង់ជីវិតបុគ្គលនោះស្រេច ក៏ត្រូវអាបត្តិបារាជិកទាំងពីររូប ។

(១៩៤) ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះលុះបង្គាប់ភិក្ខុដទៃនោះហើយ ក៏ស្រាប់តែកើតសេចក្តីក្តៅក្រហាយ (ស្តាយក្រោយ) តែមិនបានប្រាប់ឲ្យគេដឹងថា លោកកុំទៅសម្លាប់ដូច្នេះតទៅ ។ ភិក្ខុអ្នកទទួលបង្គាប់

តំ ជីវិតា វោរោបេតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ អាណាបេត្វា វិប្បដិសារី សាវេតិ មា ឃាតេហីតិ ។ សោ អាណត្តោ អហំ តយាតិ តំ ជីវិតា វោរោបេតិ មូលដ្ឋស្ស អនាបត្តិ វធកស្ស អាបត្តិ បារាជិកស្ស ។ ភិក្ខុ ភិក្ខុំ អាណាបេតិ ឥត្ថន្នាមំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ សោ អាណាបេត្វា វិប្បដិសារី សាវេតិ មា ឃាតេហីតិ ។ សោ សាធូតិ ឱរមតិ ឧភិន្នំ អនាបត្តិ ។

[១៩៣] អរហោ រហោសញ្ញី ឧល្លបតិ អហោ ឥត្ថន្នាមោ ហតោ អស្សាតិ អាបត្តិ ទុក្កដស្ស ។ រហោ អរហោសញ្ញី ឧល្លបតិ អហោ ឥត្ថន្នាមោ ហតោ អស្សាតិ អាបត្តិ ទុក្កដស្ស ។ អរហោ អរហោសញ្ញី ឧល្លបតិ អហោ ឥត្ថន្នាមោ ហតោ អស្សាតិ



លុះផ្តាច់បង់ជីវិតបុគ្គលនោះស្រេច គឺត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ (តែ) ភិក្ខុនោះលុះបង្គាប់រួចហើយក៏ស្តាប់តែកើតសេចក្តីក្តៅក្រហាយ (ស្តាយក្រោយ) ទើបប្រាប់វិញថា លោកកុំទៅសម្លាប់ឡើយ ។ ភិក្ខុនោះគាត់ថា លោកបង្គាប់ខ្ញុំហើយ ក៏ទៅផ្តាច់ជីវិតបុគ្គលនោះទៅ (យ៉ាងនេះ) ភិក្ខុអ្នកប្រើដើមមិនត្រូវអាបត្តិទេ ត្រូវអាបត្តិបារាជិកតែអ្នកសម្លាប់ ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា លោកចូរទៅផ្តាច់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះភិក្ខុនោះបង្គាប់ហើយក៏កើតសេចក្តីក្តៅក្រហាយ (ស្តាយក្រោយ) ទើបប្រាប់វិញថា លោកកុំទៅសម្លាប់ឡើយ ។ ភិក្ខុអ្នកសម្លាប់នោះទទួលថា សាធុ ហើយឈប់វិញ (ដូច្នេះ) មិនត្រូវអាបត្តិទាំងពីររូប ។

(១៩៣) ភិក្ខុសំគាល់ទីដែលមិនស្ងាត់ថាទីស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះអញត្រូវតែសម្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ទីដែលស្ងាត់ថាទីមិនស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមឲ្យវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ទីដែលមិនស្ងាត់ថាទីមិនស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមវិនាសទៅចុះ ដូច្នេះ

អាបត្តិ ទុក្កដស្ស ។ រហោ រហោសញ្ញី ឧល្លបតិ អហោ ឥត្ថន្នាមោ ហតោ អស្សាតិ អាបត្តិ ទុក្កដស្ស ។

(១៨៤) កាយេន សំវណ្ណេតិ នាម . កាយេន វិការំ ករោតិ យោ ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ ,អាបត្តិ ទុក្កដស្ស ។ តាយ សំវណ្ណនាយ មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ វាចាយ សំវណ្ណេតិ នាម វាចាយ ភណតិ យោ ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ អាបត្តិ ទុក្កដស្ស ។ តាយ សំវណ្ណនាយ មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ កាយេន វាចាយ សំវណ្ណេតិ នាម កាយេន ច វិការំ ករោតិ វាចាយ ច ភណតិ





ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ទីដែលស្ងាត់ថាស្ងាត់ ហើយពោលថា ៖ បុគ្គលឈ្មោះនេះ សូមឲ្យតែស្លាប់ទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។

(១៨៤) ដែលហៅថា ពណ៌នាដោយកាយ (នោះ) គឺភិក្ខុធ្វើការដោយកាយដូច្នេះ បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬនឹងបានយសស័ក្តិ ឬនឹងទៅកាន់ស្ថានសួគ៌ (ភិក្ខុធ្វើយ៉ាងនេះ) ត្រូវអាបត្តិទុក្កដ ។ (បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ) ញុំាងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយគឺយោការពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ពោលពណ៌នាដោយវាចា (នោះ) គឺភិក្ខុពោលដោយវាចាថា បុគ្គលណាស្លាប់យ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ (បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ) ញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ដោយគឺយោពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើបុគ្គលនោះ) ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ពោលពណ៌នាដោយកាយនិងវាចា (នោះ) គឺភិក្ខុធ្វើការដោយកាយផង ពោលដោយវាចាផង

យោ ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ អាបត្តិ ទុក្កដស្ស ។ តាយ សំវណ្ណនាយ មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។

(១៩៨) ទូតេន សំវណ្ណេតិ នាម ទូតស្ស សាសនំ អារោចេតិ យោ ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ អាបត្តិ ទុក្កដស្ស ។ ទូតស្ស សាសនំ សុត្វា មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ លេខាយ សំវណ្ណេតិ នាម លេខំ ឆិន្ទតិ យោ ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ អក្ខរក្ខរាយ អាបត្តិ ទុក្កដស្ស ។ លេខំ បស្សិត្វា មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។



ដូច្នេះថា បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ (បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ) ញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ បើបុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

(១៩៨) ដែលហៅថា ពោលពណ៌នាដោយប្រើបម្រើ (នោះ) គឺភិក្ខុប្រាប់ដំណឹងដល់បម្រើថា បុគ្គលណាស្លាប់យ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬក៏នោះទៅកាន់ស្ថានសួគ៌ ដូច្នេះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ (បើ) បុគ្គលនោះបានស្តាប់ដំណឹងរបស់បម្រើ ហើយគិតថា អញនឹងស្លាប់ ហើយក៏ញុំាងទុក្ខវេទនាឲ្យកើតឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) បុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ពណ៌នាដោយវិធីសរសេរអក្សរ (នោះ) គឺភិក្ខុឆ្លាក់អក្សរ (ជាសេចក្តី) ថា បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដគ្រប់ៗអក្សរ ។ (បុគ្គលនោះ) ឃើញអក្សរហើយគិតថា អញនឹងស្លាប់ទៅហើយ ញុំាងទុក្ខវេទនាឲ្យកើតឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) បុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

(១៨៦) ឱបាតំ នាម មនុស្សំ ឧទ្ទិស្ស ឱបាតំ ខណតិ បបតិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស[១] ។ បបតិតេ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ អនោទិស្ស ឱបាតំ ខណតិ យោ កោចិ បបតិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ មនុស្សោ តស្មឹ បបតតិ អាបត្តិ ទុក្កដស្ស ។ បបតិតេ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ យក្ខោ វា បេតោ វា តិរច្ឆានគតមនុស្សវិគ្គហោ វា តស្មឹ បបតតិ អាបត្តិ ទុក្កដស្ស ។ បបតិតេ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ទុក្កដស្ស ។ មរតិ អាបត្តិ ថុល្លច្ចយស្ស ។ តិរច្ឆានគតោ តស្មឹ បបតតិ អាបត្តិ ទុក្កដស្ស ។ បបតិតេ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ទុក្កដស្ស ។ មរតិ អាបត្តិ បាចិត្តិយស្ស ។

---

១ សីហឡ ម. ឯកច្ចេសុ បោត្ថកេសុ មនុស្សោ តស្មឹ បបតតិ អាបត្តិ ទុក្កដស្សាតិ អយំ បាឋោ ទិស្សតិ ។ សព្វបោត្ថកេសុ ន ទិស្សតិ ។



(១៨៦) ដែលហៅថា រណ្ដៅ (នោះ) គឺភិក្ខុជីករណ្ដៅចំពោះមនុស្ស ដោយគិតថា អ្នកណាមួយធ្លាក់ទៅគង់នឹងស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ កាលបើអ្នកណាមួយធ្លាក់ទៅហើយ កើតទុក្ខវេទនាឡើង (ដល់អ្នកនោះ) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ បើអ្នកនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុជីករណ្ដៅមិនចំពោះ (មនុស្ស ឬ អមនុស្ស) ដោយគិតថា ជនណាមួយធ្លាក់ទៅគង់នឹងស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ (បើ) មនុស្សធ្លាក់ទៅក្នុងរណ្ដៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលមនុស្សនោះធ្លាក់ទៅកើតទុក្ខវេទនាឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើមនុស្សនោះ) ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ (បើ) យក្សក្ដី ប្រេតក្ដី សត្វតិរច្ឆានដែលមានកាយដូចមនុស្សក្ដី ធ្លាក់ទៅក្នុងរណ្ដៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលបើជនមានយក្សជាដើមនោះធ្លាក់ទៅហើយកើតទុក្ខវេទនា ភិក្ខុក៏ត្រូវអាបត្តិទុក្កដដែរ ។ (បើ) ជនមានយក្សជាដើមនោះស្លាប់ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) សត្វតិរច្ឆានធ្លាក់ទៅក្នុងរណ្ដៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលបើធ្លាក់ទៅហើយកើតទុក្ខវេទនា ត្រូវអាបត្តិទុក្កដ ។ (បើ) វាស្លាប់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

(១៩៧) អបស្សេនំ នាម អបស្សេនេ សត្ថំ វា ឋបេតិ វិសេន វា មក្ខេតិ ទុព្ពលំ វា ករោតិ សោព្ភេ វា នរកេ វា បបាតេ វា ឋបេតិ ឥមិនា(១) បបតិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ សត្ថេន វា វិសេន វា បបតិតេន វា ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។

(១៩៨) ឧបនិក្ខិបនំ នាម អសឹ វា សត្តឹ វា ភេណ្ឌឹ វា ស្វស់(២) វា លគុឡំ វា បាសាណំ វា សត្ថំ វា វិសំ វា រជ្ជុំ វា ឧបនិក្ខិបតិ ឥមិនា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តេន មរិស្សាមីតិ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។

(១៩៩) ភេសជ្ជំ នាម សប្បឹ វា នវនីតំ វា តេលំ វា មធុំ វា ផាណិតំ វា ទេតិ ឥមំ សាយិត្វា

១ មោចិយាបោត្ថកេ អយម្បិ បាឋោ ៖ បព្ពាយតិ ។ ២ កេសុ ឆ្នៃបោត្ថកេសុ អយម្បិ បាឋោ ៖ បព្ពាយសោ ។



(១៩៧) ដែលហៅថា បង្អែក (នោះ) គឺភិក្ខុបង្កប់សស្ត្រាក្នុងទីសម្រាប់ផ្អែកក្តី លាបដោយថ្នាំពិសក្តី ធ្វើឲ្យទ្រុឌទ្រោមក្តី បង្កប់សស្ត្រាក្នុងត្រពាំងក្តី ក្នុងរណ្តៅក្តី ក្នុងជ្រោះក្តី ដោយគិតថា មនុស្សណាមួយនឹងធ្លាក់ទៅស្លាប់ដោយគ្រឿងប្រហារនេះ ត្រូវអាបត្តិទុក្កដ ។ បើមនុស្សនោះមានទុក្ខវេទនាកើតឡើងដោយសស្ត្រាក្តី ដោយថ្នាំពិសក្តី ដោយជំរាលដែលធ្លាក់ចុះទៅ (តាមជម្រាល)ក្តី ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ បើមនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

(១៩៨) ដែលហៅថា បង្កប់ឲ្យទៀប (នោះ) គឺភិក្ខុបង្កប់ដាវក្តី លំពែងក្តី ល្បុកក្តី ឈើស្រួចក្តី អន្ទង់ក្តី ថ្មក្តី កាំបិតក្តី ថ្នាំពិសក្តី ខ្សែក្តី ដោយគិតថា មនុស្សណាមួយនឹងស្លាប់ដោយវត្ថុមានដាវជាដើមនេះ (យ៉ាងនេះ) ត្រូវអាបត្តិទុក្កដ ។ (បើ) មនុស្សនោះញ៉ាំងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយវត្ថុមានដាវជាដើមនោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

(១៩៩) ដែលហៅថា ភេសជ្ជៈ (នោះ) គឺភិក្ខុឲ្យសប្បិក្តី នវនីតក្តី ប្រេងក្តី ទឹកឃ្មុំក្តី ស្ករអំពៅក្តី(១) ដោយគិតថា មនុស្សដែលផឹក

១ អដ្ឋកថា ពន្យល់សេចក្តីថា ភិក្ខុឲ្យភេសជ្ជៈមានសប្បិជាដើម ដល់ភិក្ខុដែលមានជម្ងឺ ដោយមានបំណងថា ឲ្យឆាប់ទៅដល់សេចក្តីស្លាប់ ។

មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ សាយិតោ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។

[៦០០] រូបូបហារោ នាម អមនាបិកំ រូបំ ឧបសំហរតិ ភយានកំ ភេរវំ ឥមំ បស្សិត្វា ឧត្តសិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ បស្សិត្វា ឧត្តសតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ មនាបិកំ រូបំ ឧបសំហរតិ បេមនិយំ(១) ហទយង្គមំ(២) ឥមំ បស្សិត្វា អលាភកេន សុស្សិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ បស្សិត្វា អលាភកេន សុស្សតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ សទ្ទូបហារោ នាម អមនាបិកំ សទ្ទំ ឧបសំហរតិ ភយានកំ ភេរវំ

១-២ ឥមេ ទ្វេ បាឋា កត្ថចិ បោត្ថកេសុ ន ទិស្សន្តិ ។



ផ្អែក (ស៊ី) គេសង្គមានសញ្ញាជាដើមនេះហើយ នឹងធ្លាក់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ កាលបើមនុស្សស៊ីគេសង្គមានសញ្ញាជាដើមនោះហើយ កើតទុក្ខវេទនា ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[៦០០] ដែលហៅថា សម្លាប់ដោយរូប (នោះ) គឺភិក្ខុនាំយករូបដែលមិនគាប់ចិត្ត គួរឲ្យខ្លាច គួរភ័យ ស្ញប់ស្ញែង ដោយគំនិតថា មនុស្សណាមួយមកឃើញរូបនេះហើយនឹងតក់ស្លុតស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ (បើ) មនុស្សឃើញរូបនោះហើយតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) មនុស្សស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយករូបដែលជាទីគាប់ចិត្ត គួរឲ្យស្រឡាញ់ ពេញចិត្ត ដោយគំនិតថា មនុស្សណាមួយមកឃើញរូបនេះហើយ តែមិនបាន (រូបនេះ) មុខជានឹងសោកស្រៀមស្រពោនស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ (បើ) មនុស្សឃើញរូបនោះហើយ ក្រៀមក្រំ ព្រោះមិនបាន (តាមប្រាថ្នា) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយសំឡេង (នោះ) គឺភិក្ខុនាំយកសំឡេងមិនជាទីគាប់ចិត្ត គួរឲ្យខ្លាច គួរភ័យ ស្ញប់ស្ញែង ដោយគំនិតថា មនុស្ស

ឥមំ សុត្វា ឧត្តសិត្វា មរិស្សតីតិ អាបត្តិ ទុក្ក-
ដស្ស ។ តំ សុត្វា ឧត្តសតិ អាបត្តិ ថុល្ល-
យស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ មនាបិកំ
សទ្ទំ និច្ឆារេតិ បេមនិយំ[១] ហទយង្គមំ[២] ឥមំ
សុត្វា អលាភកេន សុស្សិត្វា មរិស្សតីតិ អាបត្តិ
ទុក្កដស្ស ។ តំ សុត្វា អលាភកេន សុស្សតិ
អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។
គន្ធូបហារោ នាម អមនាបិកំ គន្ធំ ឧបសំហរតិ
ជេគុច្ឆំ បាដិកុល្យំ ឥមំ ឃាយិត្វា ជេគុច្ឆតា
បាដិកុល្យតា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។
តំ ឃាយតោ ជេគុច្ឆតា បាដិកុល្យតា ទុក្ខា វេទនា
ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិ-
កស្ស ។ មនាបិកំ គន្ធំ ឧបសំហរតិ ឥមំ ឃាយិត្វា
អលាភកេន សុស្សិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។
តំ ឃាយិត្វា អលាភកេន សុស្សតិ អាបត្តិ ថុល្លច្-
ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ រសូបហារោ នាម

១-២ [illegible] ។



ណាមួយ បានឮសំឡេងនេះហើយ នឹងតក់ស្លុតស្លាប់ ដូច្នេះ ត្រូវ
អាបត្តិទុក្កដ ។ លុះមនុស្សឮសំឡេងនោះហើយតក់ស្លុត ត្រូវអាបត្តិ
ថុល្លច្ច័យ ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយកសំឡេង
ជាទីគាប់ចិត្ត គួរឲ្យស្រឡាញ់ ចូលដល់ក្នុងចិត្ត ដោយចំណង់ថា មនុស្ស
ណាមួយបានឮសំឡេងនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះបរិទាមមិន
បាន ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះមនុស្សឮសំឡេងនោះហើយក្រៀមក្រំ
ចិត្ត ព្រោះបរិទាមមិនបាន ត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) មនុស្សនោះ
ស្លាប់ ត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយក្លិន (នោះ)
គឺភិក្ខុនាំយកក្លិនមិនគាប់ចិត្ត គួរខ្ពើមរអើម ដោយចំណង់ថា មនុស្សណា
មួយហិតក្លិនហើយគង់នឹងស្លាប់ ព្រោះជារបស់គួរខ្ពើម គួរឆ្អើម ដូច្នេះ
ត្រូវអាបត្តិទុក្កដ ។ កាលបើគេហិតក្លិននោះហើយ មានទុក្ខវេទនាកើត
ឡើង ព្រោះខ្ពើម ព្រោះឆ្អើម ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ គេស្លាប់
ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយកក្លិនជាទីគាប់ចិត្តចូលទៅ ដោយ
ចំណង់ថា មនុស្សណាមួយបានហិតក្លិននេះហើយ នឹងក្រៀមក្រំស្លាប់
ព្រោះបរិទាមមិនបាន ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេហិតក្លិននោះ
ហើយក្រៀមក្រំព្រោះមិនបាន ត្រូវអាបត្តិថុល្លច្ច័យ ។ (បើ)
គេស្លាប់ ត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយរស

អមនាបិកំ រសំ ឧបសំហរតិ ជេគុច្ឆំ បាដិកុល្យំ ឥមំ សាយិត្វា ជេគុច្ឆតា បាដិកុល្យតា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ សាយិតេ ជេគុច្ឆតា បាដិកុល្យតា ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ មនាបិកំ រសំ ឧបសំហរតិ ឥមំ សាយិត្វា អលាភកេន សុស្សិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ សាយិត្វា អលាភកេន សុស្សតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ ផោដ្ឋព្វូបហារោ នាម អមនាបិកំ ផោដ្ឋព្វំ ឧបសំហរតិ ទុក្ខសម្ផស្សំ ខរសម្ផស្សំ ឥមិនា ផុដ្ឋោ មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តេន ផុដ្ឋស្ស ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ មនាបិកំ ផោដ្ឋព្វំ ឧបសំហរតិ សុខសម្ផស្សំ





(រសៈ) ភិក្ខុនាំយករសដែលមិនជាទីគាប់ចិត្ត គួរខ្ពើមរអើម ដោយតាំងទុកថា មនុស្សណាមួយបានភ្លក់ភ្លក្សរសនេះហើយ នឹងស្លាប់ ព្រោះជារសគួរខ្ពើមរអើម ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ កាលបើគេភ្លក់ភ្លក្សរសនោះហើយ មានទុក្ខវេទនាកើតឡើង ព្រោះជារសគួរខ្ពើមរអើម ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយករសជាទីគាប់ចិត្តដោយបំណងថា មនុស្សណាមួយបានភ្លក់ភ្លក្សរសនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះមិនបាន (ដូចបំណង) ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេភ្លក់ភ្លក្សរសនោះហើយកើតក្រៀមក្រំ ព្រោះមិនបាន (តាមបំណង) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថាសម្លាប់ដោយសម្ផស្សនោះ គឺភិក្ខុនាំយកផោដ្ឋព្វមិនជាទីគាប់ចិត្ត ដែលមានសម្ផស្សនាំមកនូវសេចក្ដីទុក្ខ ដែលមានសម្ផស្សគ្រើម ដោយបំណងថា មនុស្សណាមួយបានពាល់ត្រូវសម្ផស្សនេះមុខជានឹងស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ (បើ) ទុក្ខវេទនាកើតឡើងដល់បុគ្គលដែលបានពាល់ត្រូវសម្ផស្សនោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយកផោដ្ឋព្វជាទីគាប់ចិត្ត ដែលមានសម្ផស្សជាសុខ ដែលមានសម្ផស្សទន់

មុទុសម្ផស្សំ ឥមិនា ផុដ្ឋោ អលាភកេន សុស្សិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តេន ផុដ្ឋោ អលាភកេន សុស្សតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ ធម្មូបហារោ នាម នេរយិកស្ស និរយកថំ កថេតិ ឥមំ សុត្វា ឧត្តសិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ សុត្វា ឧត្តសតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ កល្យាណកម្មស្ស សគ្គកថំ កថេតិ ឥមំ សុត្វា អធិមុត្តោ មរិស្សតីតិ អាបត្តិ ទុក្កដស្ស ។ តំ សុត្វា អធិមុត្តោ មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។

(៦០០) អាចិក្ខនា នាម បុដ្ឋោ ភណតិ ឯវំ មរស្សុ យោ



ដោយបំណងថា បុគ្គលណាមួយមកពាល់គ្រឿងសម្ផស្សនេះហើយ នឹងក្រៀមក្រស្លាប់ ព្រោះមិនបាន (តាមប្រាថ្នា) ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេពាល់គ្រឿងសម្ផស្សនោះហើយ កើតក្រៀមក្រ ព្រោះមិនបាន (តាមប្រាថ្នា) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយធម៌នោះ គឺភិក្ខុពោលអំពីរឿងនរកនៃសត្វដែលទៅកើតក្នុងនរក ដោយបំណងថា មនុស្សណាមួយបានស្តាប់រឿងនរកនេះហើយ នឹងតក់ស្លុតហើយស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេបានស្តាប់រឿងនរកនោះហើយកើតតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុពោលអំពីរឿងស្ថានសួគ៌នៃបុគ្គលដែលបានធ្វើកម្មល្អ ដោយបំណងថា មនុស្សណាមួយបានស្តាប់និទានអំពីស្ថានសួគ៌នេះហើយ នឹងអស់ផ្ដើមស្លាប់ ដូច្នេះត្រូវអាបត្តិទុក្កដ ។ លុះគេបានស្តាប់និទានអំពីស្ថានសួគ៌នោះហើយ ផ្ដាំចិត្តទៅខាងឲ្យកើតឡើងដោយគិតថា អញនឹងអស់ផ្ដើមស្លាប់ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

(៦០០) ដែលហៅថា បង្គាប់ឲ្យស្លាប់ (នោះ) គឺបានមនុស្សសួរភិក្ខុ ។ ឆ្លើយថា អ្នកឯងចូរស្លាប់ទៅយ៉ាងនេះចុះ ព្រោះបុគ្គលណាមួយ

ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ អាបត្តិ ទុក្កដស្ស ។ តាយ អាចិក្ខនាយ មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។ អនុសាសនី នាម អមុត្ថ ភណតិ ឯវំ មរស្សុ យោ ឯវំ មរតិ សោ ធនំ វា លភតិ យសំ វា លភតិ សគ្គំ វា គច្ឆតីតិ អាបត្តិ ទុក្កដស្ស ។ តាយ អនុសាសនិយា មរិស្សាមីតិ ទុក្ខំ វេទនំ ឧប្បាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ មរតិ អាបត្តិ បារាជិកស្ស ។

[៦០៦] សង្កេតកម្មំ នាម សង្កេតំ ករោតិ បុរេភត្តំ វា បច្ឆាភត្តំ វា រត្តឹ វា ទិវា វា តេន សង្កេតេន តំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ តេន សង្កេតេន តំ ជីវិតា វោរោបេតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ តំ



ស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ បុគ្គលនោះញ៉ាំងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ តាមបង្គាប់នោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះតែស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា រៀនប្រដៅដើម្បីឲ្យស្លាប់ (នោះ) គឺតម្រង់បានសួគ៌ភិក្ខុទេ ក៏ភិក្ខុនិយាយថា អ្នកចូរស្លាប់យ៉ាងនេះចុះ (ព្រោះ) បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ព្រោះពាក្យរៀនប្រដៅប៉ុណ្ណោះ បើបុគ្គលនោះញ៉ាំងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះបុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[៦០៦] ដែលហៅថា ធ្វើសង្កេតកម្ម (នោះ) គឺភិក្ខុកំណត់វេលាថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលនោះ តាមសេចក្តីកំណត់នោះ គឺវេលាមុនបាយក្តី ក្រោយបាយក្តី យប់ក្តី ថ្ងៃក្តី ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះ តាមសេចក្តីកំណត់នោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ (បើ) ភិក្ខុទទួលបង្គាប់ទៅផ្តាច់បង់ជីវិត

សង្កេតំ បុរេ វា បច្ឆា វា តំ ជីវិតា វោរោបេតិ មូលដ្ឋស្ស អនាបត្តិ វធកស្ស អាបត្តិ បារាជិកស្ស ។ និមិត្តកម្មំ នាម និមិត្តំ ករោតិ អក្ខឹ វា និខណិស្សាមិ ភមុកំ វា ឧក្ខិបិស្សាមិ សីសំ វា ឧក្ខិបិស្សាមិ តេន និមិត្តេន តំ ជីវិតា វោរោបេហីតិ អាបត្តិ ទុក្កដស្ស ។ តេន និមិត្តេន តំ ជីវិតា វោរោបេតិ អាបត្តិ ឧភិន្នំ បារាជិកស្ស ។ តំ និមិត្តំ បុរេ វា បច្ឆា វា តំ ជីវិតា វោរោបេតិ មូលដ្ឋស្ស អនាបត្តិ វធកស្ស អាបត្តិ បារាជិកស្ស ។

[៤០៣] អនាបត្តិ អសញ្ចិច្ច អជានន្តស្ស នមរណាធិប្បាយស្ស ឧម្មត្តកស្ស ខិត្តចិត្តស្ស[១] វេទនដ្ដស្ស[១] អាទិកម្មិកស្សាតិ ។

មនុស្សវិគ្គហបារាជិកស្ស បទភាជនីយំ និដ្ឋិតំ ។

[៤០៤] សំវណ្ណនា និសីទន្តោ មុសលេ ឧទុក្ខលេន ច

១–២ [illegible] ន ទិស្សន្តិ ។



បុគ្គលនោះ មុនក្តី ក្រោយក្តី អំពីកំណត់នោះ ភិក្ខុអ្នកប្រើមិនត្រូវអាបត្តិទេ ឯអ្នកសម្លាប់ត្រូវអាបត្តិបារាជិក ។ ដែលហៅថា ធ្វើនិមិត្តកម្ម (នោះ) គឺភិក្ខុធ្វើនិមិត្តសញ្ញា ដូចជាថា (បើ) ខ្ញុំប្រិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី លោកចូរផ្តាច់បង់ជីវិតបុគ្គលនោះតាមនិមិត្តសញ្ញានោះចុះ (ធ្វើនិមិត្តសញ្ញាប៉ុណ្ណេះ) ត្រូវអាបត្តិទុក្កដ ។ (បើ) ភិក្ខុអ្នកទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះតាមនិមិត្តសញ្ញានោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ (បើ) ភិក្ខុអ្នកទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះមុនឬក្រោយនិមិត្តសញ្ញានោះ ភិក្ខុអ្នកប្រើជាដើមមិនត្រូវអាបត្តិឡើយ ឯអ្នកសម្លាប់ត្រូវអាបត្តិបារាជិក ។

(៤០៣) ភិក្ខុមិនក្លែង១ ភិក្ខុមិនដឹង១ ភិក្ខុមិនប្រាថ្នាឲ្យស្លាប់១ ភិក្ខុឆ្កួត១ ភិក្ខុមានចិត្តរវើរវាយ១ ភិក្ខុមានវេទនាគ្របសង្កត់១ ភិក្ខុដើមបញ្ញត្តិ១ (ភិក្ខុទាំងនេះ) មិនត្រូវអាបត្តិទេ ។

ចប់ បទភាជនីយក្នុងមនុស្សវិគ្គហបារាជិក ។

(មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសំដែងទៅ ដូចមានខាងក្រោយនេះ)

(៤០៤) រឿងភិក្ខុពណ៌នាសេចក្តីស្លាប់ រឿងភិក្ខុអង្គុយសង្កត់ក្មេង រឿងអង្រែទំលាក់ រឿងបិតានឹងបុត្របួសកាលចាស់

វុឌ្ឍបព្ពជិតា ភិសន្នោ អគ្គំ វិសញ្ច វីមំសា(១)
តយោ ច វត្ថុកម្មេហិ ឥដ្ឋកាហិបិ តេ តយោ
វាសី គោបានសី ចេវ អដ្ដកោតរណំ បតិ
សេទំ នត្ថុញ្ច សម្ពាហា ន្ហាបនព្ភញ្ជនេន ច
ឧដ្ឋាបេន្តោ និបាតេន្តោ អន្នបានេន មារណំ
ជារគព្ភោ សបត្តី ច មាតា បុត្តំ ឧភោ វធិ
ឧភោ ន មិយ្យរេ មទ្ទា តាបំ វញ្ឈា វិជាយិនី
បតោទំ និគ្គហេ យក្ខោ វាឡយក្ខញ្ច បាហិណិ
តំ មញ្ញមានោ បហរិ សគ្គញ្ច និរយំ ភណេ
អាឡវិយា តយោ រុក្ខា ទាយេហិ អបរេ តយោ
មា កិលមេសិ ន តុយ្ហំ តក្កំ សោវីរកេន(២)ចាតិ ។

(២០៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស ភិក្ខូ ការុញ្ញេន

---

១ វុឌ្ឍបព្ពជិតាភិសន្នោ អគ្គំ វីមំសា វិសន្តិ [illegible] ។ ម. [illegible] ។ ក. តក្កំ សោវីរកេន ។



រឿងសាច់ជាប់ចំពកទឹក រឿងភិក្ខុបំណងប្រាកដប្រាជ្ញខ្ទាប់លាយថ្នាំពិស រឿងភិក្ខុ៣រូបធ្វើការកសាងទីលំនៅ រឿងភិក្ខុ៣រូបទៀតធ្វើការកសាងដោយឥដ្ឋ រឿងកាំបិតព្រា រឿងបង្កង់ រឿងរនា រឿងទៀនត្ថុ រឿងស្អំឲ្យបែកញើស រឿងច្របាច់ រឿងផ្ងូតទឹក រឿងលាបប្រេង រឿងភិក្ខុលើកភិក្ខុមានជម្ងឺឲ្យក្រោក រឿងភិក្ខុផ្តួលភិក្ខុមានជម្ងឺ រឿងភិក្ខុសម្លាប់ភិក្ខុដោយបាយនិងទឹក រឿងស្រីមានផ្ទៃពោះព្រោះសហាយ រឿងស្រីរួមប្ដី រឿងភិក្ខុសម្លាប់ម្ដាយនិងកូនទាំងពីរនាក់ រឿងស្រីពីរនាក់ឲ្យកូនតែមិនស្លាប់ រឿងកំដៅផ្ទៃពោះ រឿងស្រីអារ រឿងស្រីមានកូន រឿងភិក្ខុចាក់ក្រឡេក រឿងខ្មោចចូលភិក្ខុ រឿងភិក្ខុបញ្ជូនភិក្ខុទៅកាន់ទីមានខ្មោចសាហាវ រឿងភិក្ខុសំគាល់ភិក្ខុជាសត្រូវហើយប្រហារ រឿងភិក្ខុពោលពីស្ថានសួគ៌និងនរក រឿងភិក្ខុស្រុកអាឡវីបីរូបនាំគ្នាកាប់ដើមឈើ រឿងភិក្ខុបីរូបទៀតដុតភ្លើងព្រៃ រឿងភិក្ខុនិយាយនឹងមនុស្សសម្លាប់ចោរ រឿងប្រើទឹកញ្ញរលាយនឹងទឹកជ្រក់ខ្ពុរ ។

(២០៨) សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ទើបភិក្ខុទាំងឡាយពណ៌នានូវគុណនៃសេចក្ដីស្លាប់ ដល់ភិក្ខុមានជម្ងឺនោះ ដោយចិត្ត

មរណវណ្ណំ សំវណ្ណេសុំ ។ សោ ភិក្ខុ កាលម-កាសិ ។ តេសំ កុក្កុច្ចំ អហោសិ កច្ចិ នុ ខោ មយំ បារាជិកំ អាបត្តឹ អាបន្នាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អាបត្តឹ តុម្ហេ ភិក្ខវេ អាបន្នា បារាជិកន្តិ ។

(២០៦) តេន ខោ បន សមយេន អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ បីឋកេ បិលោតិកាយ បដិច្ឆន្នំ ទារកំ និសីទន្តោ ឱត្ថរិត្វា មារេសិ ។ តស្ស កុក្កុច្ចំ អហោសិ កច្ចិ នុ ខោ អហំ បារាជិកំ អាបត្តឹ អាបន្នោតិ ។ អថខោ សោ ភិក្ខុ ភគវតោ ឯត-មត្ថំ អារោចេសិ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស ន ច ភិក្ខវេ អប្បដិវេក្ខិត្វា អាសនេ និសីទិតព្វំ យោ និសីទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២០៧) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភត្តគ្គេ អន្តរឃរេ អាសនំ បញ្ញាបេន្តោ មុសលេ ឧស្សាបេន្តោ ឯកំ មុសលំ អគ្គហេសិ ។ ទុតិយោ មុសលោ បរិវត្តិត្វា អញ្ញតរស្ស ទារកស្ស មត្ថកេ អវត្ថាសិ ។



ពេលភិតសាស្តូ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ទើបភិក្ខុទាំងនោះ មានសេចក្តីសង្ស័យថា យើងទាំងឡាយត្រូវអាបត្តិបារាជិកទេដឹង ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគក្នុងកាលនោះឯង ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

(២០៦) សម័យនោះឯង មានភិក្ខុមួយរូបកាន់បិណ្ឌចារិកវត្ត អង្គុយសង្កត់ក្មេងដែលគេដណ្តប់ដោយកំណាត់សំពត់នៅលើតាំងស្លាប់ទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អាត្មាត្រូវអាបត្តិបារាជិកទេដឹង ។ ទើបភិក្ខុនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនទាន់បានពិនិត្យទេ កុំគប្បីអង្គុយលើអាសនៈ ភិក្ខុណាអង្គុយ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។

(២០៧) សម័យនោះឯង មានភិក្ខុមួយរូបរៀបក្រាលអាសនៈក្នុងរោងភត្តក្នុងផ្ទះ ហើយបានឈោងទៅចាប់អង្រែមួយគ្រង់ក្នុងដៃដែលគេបញ្ឈរអង្រែ ។ អង្រែជាគំរប់ពីររលំទៅសង្កត់លើក្បាលទារកម្នាក់ ។

សោ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ អសញ្ចិច្ចាហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ អសញ្ចិច្ចាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភត្តគ្គេ អត្ថរយមា អាសនំ បញ្ញាបេន្តោ ឧទុក្ខលកណ្ឌិកំ អក្កមិត្វា បវដ្ដេសិ អញ្ញតរំ ទារកំ ឱត្ថរិត្វា មារេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អសញ្ចិច្ចាតិ ។

(២០៨) តេន ខោ បន សមយេន បិតាបុត្តា ភិក្ខូសុ បព្វជិតា ហោន្តិ ។ កាលេ អារោចិតេ បុត្តោ បិតរំ ឯតទវោច គច្ឆ ភន្តេ សង្ឃោ តំ បតិមានេតីតិ បិដ្ឋិយំ គហេត្វា បណាមេសិ ។ សោ បបតិត្វា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ នាហំ ភគវា មរណាធិប្បាយោតិ ។ អនាបត្តិ ភិក្ខុ



ការនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានក្លែងទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនក្លែង មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូប ឡើងក្រាលអាសនៈក្នុងរោងភត្ត ក៏ក្រើតបញ្ឈរផ្ទះ បានទៅជាន់ឈើដែលគេសម្រាប់ផ្តួលត្បាល់ ឲ្យរបេះទៅសង្កត់ទារកម្នាក់ស្លាប់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនក្លែង មិនត្រូវអាបត្តិទេ ។

(២០៨) សម័យនោះឯង បិតានិងបុត្របានចេញបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។ កាលដល់វេលាឆាន់គេបានប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចំរើន លោកឪពុកនិមន្តទៅចុះ ព្រះសង្ឃទ្រង់អង្គុយចាំលោកឪពុក (ថាហើយក៏) ចាប់ខ្នងច្រានទៅ ។ ភិក្ខុជាបិតានោះក៏ដួលស្លាប់ ។ ភិក្ខុជាកូននោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឥតមានបំណងឲ្យស្លាប់ទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានបំណងឲ្យស្លាប់ទេ

អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន បិតាបុត្តា ភិក្ខូសុ បព្វជិតា ហោន្តិ ។ កាលេ អារោចិតេ បុត្តោ បិតរំ ឯតទវោច គច្ឆ ភន្តេ សង្ឃោ តំ បតិមានេតីតិ មរណាធិប្បាយោ បិដ្ឋិយំ គហេត្វា បណាមេសិ ។ សោ បបតិត្វា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន បិតាបុត្តា ភិក្ខូសុ បព្វជិតា ហោន្តិ ។ កាលេ អារោចិតេ បុត្តោ បិតរំ ឯតទវោច គច្ឆ ភន្តេ សង្ឃោ តំ បតិមានេតីតិ មរណាធិប្បាយោ បិដ្ឋិយំ គហេត្វា បណាមេសិ ។ សោ បបតិត្វា ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

[២០៩] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ភុញ្ជន្តស្ស មំសំ កណ្ឋេ វិលគ្គំ ហោតិ ។ អញ្ញតរោ ភិក្ខុ តស្ស ភិក្ខុនោ គីវាយំ បហារំ អទាសិ ។



មិនត្រូវអាបត្តិទេ ។ សម័យនោះឯង បិតានឹងបុត្របានមកបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។ កាលដល់ពេលឆាន់គេប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចំរើន លោកឪពុកនិមន្តទៅចុះ សង្ឃនឹងអង្គាសលោកឪពុក (ថាហើយ) មានចំណងចង់ឲ្យស្លាប់ ក៏ចាប់ខ្នងច្រានទៅ ។ ភិក្ខុជាបិតានោះក៏ដួលចុះហើយស្លាប់ទៅ ។ ភិក្ខុជាបុត្រនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង បិតានឹងបុត្របានចេញបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។ កាលដល់ពេលឆ្អិនគេប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចំរើន លោកឪពុកនិមន្តទៅចុះ សង្ឃនឹងអង្គាសលោកឪពុក (ថាហើយ) មានចំណងចង់ឲ្យស្លាប់ ទើបចាប់ខ្នងច្រានទៅ ។ ភិក្ខុជាបិតានោះក៏ដួលទៅ តែមិនស្លាប់ ។ ភិក្ខុជាបុត្រនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។

[២០៩] សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ចង្ហាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក ។ មានភិក្ខុមួយរូបទៀត បានវាយចំពីក្រោយកនៃភិក្ខុ

សលោហិតំ មំសំ បតិ ។ សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ភុញ្ជន្តស្ស មំសំ កណ្ឋេ វិលគ្គំ ហោតិ ។ អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ តស្ស ភិក្ខុនោ គីវាយំ បហារំ អទាសិ ។ សលោហិតំ មំសំ បតិ ។ សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ ភុញ្ជន្តស្ស មំសំ កណ្ឋេ វិលគ្គំ ហោតិ ។ អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ តស្ស ភិក្ខុនោ គីវាយំ បហារំ អទាសិ ។ សលោហិតំ មំសំ បតិ ។ សោ ភិក្ខុ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។



នោះ ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ (អេ) មិនមានបំណងនឹងឲ្យស្លាប់ទេ មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក ។ មានភិក្ខុមួយរូបទៀតចង់ឲ្យស្លាប់ ទើបវាយចំបំពង់កនៃភិក្ខុនោះ ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក ។ មានភិក្ខុមួយរូបទៀតមានចេតនាចង់ឲ្យស្លាប់ ទើបវាយចំបំពង់កនៃភិក្ខុនោះ ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង តែភិក្ខុនោះមិនស្លាប់ ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ចយ ។

[២០០] តេន ខោ បន សមយេន អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ វិសគតំ បិណ្ឌបាតំ លភិត្វា បដិក្កមនំ ហរិត្វា ភិក្ខូនំ អគ្គការិកំ អទាសិ ។ តេ ភិក្ខូ កាលមកំសុ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ នាហំ ភគវា ជានាមីតិ ។ អនាបត្តិ ភិក្ខុ អជានន្តស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វីមំសាធិប្បាយោ អញ្ញតរស្ស ភិក្ខុនោ វិសំ អទាសិ ។ សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ វីមំសាធិប្បាយោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

[២០១] តេន ខោ បន សមយេន អាឡវិកា[1] ភិក្ខូ វិហារវត្ថុំ ករោន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា សិលំ ឧច្ចាបេសិ ។ ឧបរិមេន ភិក្ខុនា ទុគ្គហិតា សិលា ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ អវត្ថាសិ ។

១ ឱ. ម. អាឡវកា ។



[២០០] សម័យនោះឯង មានបិណ្ឌចារិកភិក្ខុមួយរូប បានចង្ហាន់ លាយដោយថ្នាំពិសហើយនាំចេញទៅ បានប្រគេនភោជនដ៏ឧត្តម ដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងនោះក៏ (នាំគ្នាឆាន់) ក៏ស្លាប់អស់ទៅ ។ ភិក្ខុអ្នកប្រគេនបិណ្ឌបាតនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់សួរថា នែភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងសោះ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនដឹង មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូប មានប្រាថ្នាចង់ល្បងមើល បានឲ្យថ្នាំពិសដល់ភិក្ខុមួយរូប ។ ភិក្ខុនោះស្លាប់ ។ ភិក្ខុអ្នកឲ្យនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងល្បងមើលទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[២០១] សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី នាំគ្នារៀបចំទីវត្ត ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចថ្មទៅ ភិក្ខុនៅខាងលើទទួលថ្មមិនជាប់ ក៏របូតធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម ។

សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អសញ្ចិច្ចាតិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ វិហារំ ករោន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា សិលំ ឧក្ខិបិ ។ ឧបរិមោ ភិក្ខុ មារណាធិប្បាយោ ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ សិលំ មុញ្ចិ ។ សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិ ត្វំ ភិក្ខុ បារាជិកន្តិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ វិហារំ ករោន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា សិលំ ឧក្ខិបិ ។ ឧបរិមោ ភិក្ខុ មារណាធិប្បាយោ ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ សិលំ មុញ្ចិ ។ សោ ភិក្ខុ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ វិហារស្ស កុដ្ដំ ឧដ្ឋាបេន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា ឥដ្ឋកំ ឧក្ខិបិ ។



ភិក្ខុត្រូវថ្មធ្លាក់លើនោះក៏ស្លាប់ទៅ ។ ភិក្ខុអ្នកទទួលថ្មមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង ។ សម័យនោះឯង ពួកភិក្ខុស្រុកអាឡវី (នាំគ្នា) រៀបចំវិហារ ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចថ្មទៅលើ ។ ភិក្ខុអ្នកនៅខាងលើ មានចំណង់ចង់សម្លាប់ ក៏ទម្លាក់ថ្មចំក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុនោះស្លាប់ ។ ភិក្ខុអ្នកទម្លាក់ថ្មនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) រៀបចំវិហារ ។ មានភិក្ខុមួយរូប (ទៀត) នោះនៅខាងក្រោមហុចថ្មទៅ ។ ភិក្ខុនៅខាងលើមានចំណង់ចង់សម្លាប់ (ភិក្ខុនៅខាងក្រោម) ហើយទម្លាក់ថ្មចំក្បាលភិក្ខុនៅខាងក្រោមនោះ ។ ភិក្ខុនោះមិនស្លាប់ ។ ភិក្ខុអ្នកទម្លាក់ថ្មនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) លើកជញ្ជាំងវិហារ ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចឥដ្ឋទៅខាងលើ ។

ឧបរិមេន ភិក្ខុនា ទុគ្គហិតា ឥដ្ឋកា ហេដ្ឋិមស្ស
ភិក្ខុនោ មត្ថកេ អវត្ថាសិ ។ សោ ភិក្ខុ កាលម-
កាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ
ភិក្ខុ អសញ្ចិច្ចស្សាតិ ។ តេន ខោ បន សមយេន
អាឡវិកា ភិក្ខូ វិហារស្ស កុឌ្ឌំ ឧដ្ឋាបេន្តិ ។ អញ្ញតរោ
ភិក្ខុ ហេដ្ឋា ហុត្វា ឥដ្ឋកំ ឧច្ចារេសិ ។ ឧបរិមោ ភិក្ខុ
មរណាធិប្បាយោ ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ ឥដ្ឋកំ
មុញ្ចិ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ
ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។
អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។
តេន ខោ បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ
ករោន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា ភសិំ
ឧច្ចារេសិ ។ ឧបរិមេន ភិក្ខុនា ទុគ្គហិតា ភសី
ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ អវត្ថាសិ ។ សោ
ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ
។ បេ ។ អនាបត្តិ ភិក្ខុ អសញ្ចិច្ចស្សាតិ ។ តេន ខោ
បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ ករោន្តិ ។
អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា ភសី ឧច្ចារេសិ ។





ឥដ្ឋដែលភិក្ខុនៅខាងលើកាន់មិនខ្ជាប់ ក៏ធ្លាក់ចុះចំក្បាលភិក្ខុអង្គនៅខាង
ក្រោម ។ ភិក្ខុនោះស្លាប់ ។ ភិក្ខុទទួលឥដ្ឋនោះមានសេចក្តីសង្ស័យ
។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង ។
សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនអាឡវី (នាំគ្នា) កជញ្ជាំងវិហារ ។
មានភិក្ខុមួយរូបនៅខាងក្រោមហុចឥដ្ឋទៅ ។ ភិក្ខុ (អ្នកទទួលឥដ្ឋ)
នៅខាងលើមានបំណងឲ្យស្លាប់ ក៏ទម្លាក់ឥដ្ឋចុះចំក្បាលភិក្ខុអង្គនៅ
ខាងក្រោម ។ ភិក្ខុនោះស្លាប់ ។ បេ ។ ភិក្ខុនោះមិនស្លាប់ ។ ភិក្ខុអង្គ
ទម្លាក់ឥដ្ឋនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ
មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះ
ឯង ពួកភិក្ខុនៅប្រទេសអាឡវី (នាំគ្នា) ធ្វើនវកម្ម (ការកសាង)
មានភិក្ខុមួយរូបទៀតនៅខាងក្រោមហុចតំបែតទៅខាងលើ ។ តំ-
បែតដែលភិក្ខុនៅខាងលើកាន់មិនជាប់ ក៏របូតមកចំក្បាលភិក្ខុនៅខាង
ក្រោម ។ ភិក្ខុនោះធ្វើកាលកិរិយាទៅ ។ ភិក្ខុអង្គទទួលតំបែតនោះមាន
សេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ
ព្រោះមិនបានក្លែង ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា)
ធ្វើនវកម្ម ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចតំបែតទៅខាងលើ ។

ឧបរិមោ ភិក្ខុ មារណាធិប្បាយោ ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ ភសិំ មុញ្ចិ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ វិហារំ ករោន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា គោបានសិំ ឧទ្ធាបេសិ ។ ឧបរិមេន ភិក្ខុនា ទុគ្គហិតា គោបានសី ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ អវត្ថាសិ ។ សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អសញ្ចិច្ចាតិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ វិហារំ ករោន្តិ ។ អញ្ញតរោ ភិក្ខុ ហេដ្ឋា ហុត្វា គោបានសិំ ឧទ្ធាបេសិ ។ ឧបរិមោ ភិក្ខុ មារណាធិប្បាយោ ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ គោបានសិំ មុញ្ចិ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។



ភិក្ខុនៅខាងលើមានចំណងចង់សម្លាប់ (ភិក្ខុនៅខាងក្រោម) ទើបទម្លាក់កំបិតក្រោចំក្បាលភិក្ខុនៅខាងក្រោម ។ ភិក្ខុនោះក៏ធ្វើកាលកិរិយាទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើកាលកិរិយា ។ ភិក្ខុអ្នកទម្លាក់កំបិតនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវី (នាំគ្នា) ធ្វើវិហារ ។ មានភិក្ខុមួយរូបនៅខាងក្រោម ហុចបង្កង់ទៅឲ្យខាងលើ ។ បង្កង់ដែលភិក្ខុនៅខាងលើកាន់មិនជាប់ ក៏ធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុនោះក៏ធ្វើកាលកិរិយាទៅ ។ ភិក្ខុអ្នកទម្លាក់នោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវី (នាំគ្នា) ធ្វើវិហារ ។ មានភិក្ខុមួយរូបនៅខាងក្រោម ហុចបង្កង់ទៅខាងលើ ។ ភិក្ខុនៅខាងលើមានចំណងចង់សម្លាប់ (ភិក្ខុនៅខាងក្រោម) ទើបទម្លាក់បង្កង់មកចំក្បាលភិក្ខុនៅខាងក្រោម ។ ភិក្ខុនោះធ្វើកាលកិរិយាទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើកាលកិរិយា ។ ភិក្ខុអ្នកទម្លាក់បង្កង់នោះមានសេចក្តីសង្ស័យ

។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ ករោន្តា អដ្ដកំ ពន្ធិំសុ ។ អញ្ញតរោ ភិក្ខុ អញ្ញតរំ ភិក្ខុំ ឯតទវោច អាវុសោ អត្រ ឋិតោ ពន្ធាហីតិ ។ សោ តត្រ ឋិតោ ពន្ធន្តោ បបតិត្វា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ នាហំ ភគវា មរណាធិប្បាយោតិ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ ករោន្តា អដ្ដកំ ពន្ធិំសុ ។ អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ អញ្ញតរំ ភិក្ខុំ ឯតទវោច អាវុសោ អត្រ ឋិតោ ពន្ធាហីតិ ។ សោ តត្រ ឋិតោ ពន្ធន្តោ បបតិត្វា កាលមកាសិ ។ បេ ។ បបតិត្វា ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។



។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) ធ្វើនវកម្មចងរន្ទា ។ មានភិក្ខុមួយរូបបាននិយាយទៅនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរត្រង់ទីនោះហើយចងរន្ទាទៅ ។ ភិក្ខុនោះឈរនៅត្រង់ទីនោះចងរន្ទា ក៏ធ្លាក់ធ្លាយមកហើយធ្វើកាលកិរិយាទៅ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានចំណង់នឹងសម្លាប់ទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានចំណង់នឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវីកាលនឹងធ្វើនវកម្ម (បាននាំគ្នា) ចងរន្ទា ។ មានភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ទើបនិយាយនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ លោកចូរឈរនៅទីនោះចងរន្ទាទៅ ។ ភិក្ខុនោះឈរនៅទីនោះកំពុងតែចងរន្ទា ក៏ធ្លាក់ធ្លាយចុះមកធ្វើមរណកាលទៅ ។ បេ ។ (មានភិក្ខុមួយរូបទៀត) ធ្លាក់ធ្លាយដែរ តែមិនបានធ្វើមរណកាលទេ ។ លោកដែលបង្គាប់នោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។

(៤០៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វិហារំ ឆាទេត្វា ឱតរតិ ។ អញ្ញតរោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច អាវុសោ ឥតោ ឱតរាហីតិ ។ សោ តេន ឱតរន្តោ បរិបតិត្វា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ វិហារំ ឆាទេត្វា ឱតរតិ ។ អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ តំ ភិក្ខុំ ឯតទវោច អាវុសោ ឥតោ ឱតរាហីតិ ។ សោ តេន ឱតរន្តោ បរិបតិត្វា កាលមកាសិ ។ បេ ។ បរិបតិត្វា ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(៤០៧) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អនភិរតិយា បីឡិតោ គិជ្ឈកូដំ អភិរុហិត្វា បបាតេ បបតន្តោ អញ្ញតរំ វិលីវការំ ឱត្ថរិត្វា មារេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស ។ ន ច ភិក្ខវេ



(៤០៦) សម័យនោះឯង មានភិក្ខុមួយរូបប្រក់វិហារហើយចុះមក ។ មានភិក្ខុមួយរូបទៀតបាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរចុះខាងនេះ ។ ភិក្ខុនោះកាលចុះមកតាមផ្លូវនោះក៏ធ្លាក់ធ្វើមរណកាលទៅ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់អ្នកដែលមិនមានបំណងនឹងឲ្យស្លាប់ទេ ។ សម័យនោះឯង មានភិក្ខុមួយរូបប្រក់វិហារហើយចុះមក ។ មានភិក្ខុមួយរូបទៀតមានបំណងនឹងឲ្យស្លាប់ ទើបនិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរចុះខាងនេះ ។ ភិក្ខុនោះកាលចុះតាមផ្លូវនោះមក ក៏ធ្លាក់ចុះធ្វើមរណកាលទៅ ។ បេ ។ (មានភិក្ខុមួយរូបទៀត) ធ្លាក់ចុះហើយ តែមិនបានធ្វើមរណកាល ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។

(៤០៧) សម័យនោះឯង មានភិក្ខុមួយរូបមានសេចក្តីអផ្សុកមកបៀតបៀន ឡើងទៅកាន់ភ្នំគិជ្ឈកូដ ក៏ទម្លាក់ខ្លួនចុះមកកន្លែងជ្រោះ សង្កត់លើជាងត្បាញផែងម្នាក់ស្លាប់ទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ

អត្តានំ បាតេតព្វំ យោ បាតេយ្យ អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ គិជ្ឈកូដំ បព្វតំ អភិរុហិត្វា ទវាយ សិលំ បដិវិជ្ឈឹសុ ។ សា(១) អញ្ញតរំ គោបាលកំ ឱត្ថរិ មារេសិ(២) ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស ន ច ភិក្ខវេ ទវាយ សិលា បដិវិជ្ឈិតព្វា យោ បដិវិជ្ឈេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២១៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ សេទេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ មរណាធិប្បាយា សេទេសុំ ។ សោ ភិក្ខុ កាលមកាសិ ។បេ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ

១ ឧបាលិយេមរម្មាពាក្យលុ សយំ ឆលិ ៤ ទំស្សនិ ។ សមត្ថាពាក្យ ប៩ សិលាតិ វិស្សជ្ជិ ។ ២ ឱ. ម. មារេសុំ ។



ប៉ុន្តែភិក្ខុកុំគប្បីទម្លាក់សម្លាប់ខ្លួនឯង ភិក្ខុណាទម្លាក់សម្លាប់ខ្លួនឯង (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (នាំគ្នា) ឡើងទៅកាន់ភ្នំគិជ្ឈកូដ ហើយប្រមៀលថ្មលេង ។ ថ្មនោះធ្លាក់មកសង្កត់អ្នកគង្វាលគោម្នាក់ស្លាប់ទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ ភិក្ខុមិនត្រូវប្រមៀលថ្មដើម្បីជាល្បែងលេងទេ ភិក្ខុណាប្រមៀល (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។

(២១៦) សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ទើបភិក្ខុទាំងឡាយនាំគ្នាស្រោចភិក្ខុនោះនឹង ។ ភិក្ខុនោះធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបស្រោចភិក្ខុនោះនឹង ។ ភិក្ខុនោះធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ

អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ សីសាភិតាបោ ហោតិ ។ តស្ស ភិក្ខូ នត្ថុំ អទំសុ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ សីសាភិតាបោ ហោតិ ។ តស្ស ភិក្ខូ មរណាធិប្បាយា នត្ថុំ អទំសុ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ សម្ពាហេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ





។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបកើតរោគក្តៅក្បាល ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះនត្ថុំ ។ ភិក្ខុនោះធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានរោគក្តៅក្បាល ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះនត្ថុំ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយនាំគ្នាច្របាច់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំង

មរណាធិប្បាយា សម្ពាហេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ នហាបេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ មរណាធិប្បាយា នហាបេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ តេលេន អព្ភញ្ជិំសុ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ



ទាំងឡាយមានបំណងនឹងសម្លាប់ ទើបនាំគ្នាច្របាច់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះងូតទឹក ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ទេ មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះស្រង់ទឹក ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ទើបភិក្ខុទាំងឡាយយកប្រេងមកលាបភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។

អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ មរណាធិប្បាយា តេលេន អព្ភញ្ជឹសុ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ វុដ្ឋាបេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ មរណាធិប្បាយា វុដ្ឋាបេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ និបាតេសុំ ។



សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ហើយ (នាំគ្នា) យកប្រេងមកលាបភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ហើយភិក្ខុទាំងឡាយឲ្យភិក្ខុនោះក្រោកឡើង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ ឥតមានអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ហើយញ៉ាំងភិក្ខុនោះឲ្យស្ទុះក្រោកឡើង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំង

សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ មរណាធិប្បាយា ឧច្ឆាទេសុំ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស ភិក្ខូ អន្នំ អទំសុ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស ភិក្ខូ មរណាធិប្បាយា អន្នំ អទំសុ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។



ឡាយចាប់ភិក្ខុនោះផ្ទួល ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានចំណង់នឹងសម្លាប់ ឥតមានអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានចំណង់នឹងសម្លាប់ ទើប (នាំគ្នា) ផ្ទួលភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយបានឲ្យបាយដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានចំណង់នឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានចំណង់នឹងសម្លាប់ បានឲ្យបាយដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស ភិក្ខូ ខារំ អទំសុ ។ សោ ភិក្ខុ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តស្ស ភិក្ខូ មរណាធិប្បាយា ខារំ អទំសុ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

[២១៩] តេន ខោ បន សមយេន អញ្ញតរា ឥត្ថី បវុត្ថបតិកា ជារេន គព្ភិនី ហោតិ ។ សា កុលូបកំ ភិក្ខុំ ឯតទវោច ឥង្ឃយ្យ គព្ភបាតនំ ជានាហីតិ ។ សុដ្ឋុ ភគិនីតិ តស្សា គព្ភបាតនំ អទាសិ ។ ទារកោ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។





សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយបានឲ្យទឹកស្រម៉ាប់ដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យទឹកស្រម៉ាប់ដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។

(២១៩) សម័យនោះឯង មានស្រីម្នាក់ ព្រាត់ប្រាសចាកប្ដីមកយូរហើយ ទើបមានគភ៌នឹងសហាយ ។ ស្រីនោះបាននិយាយនឹងភិក្ខុជាជិតខាង[១] សូមបានមេត្តាជួយលោកម្ចាស់ ,សូមបានប្រាប់ថ្នាំរំលូតគភ៌ (ឲ្យបានខ្ញុំករុណា) ។ ភិក្ខុនោះទទួលថា ស្រួលហើយប្អូនស្រី ហើយក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ទារក (ដែលនៅក្នុងផ្ទៃ) ក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា

១ ភិក្ខុអ្នកចូលទៅកាន់ត្រកូល គឺភិក្ខុដែលជិតដិតស្និទ្ធស្នាលនឹងត្រកូល ។

អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្ស បុរិសស្ស ទ្វេ បជាបតិយោ ហោន្តិ ឯកា វញ្ឈា[១] ឯកា វិជាយិនី ។ វញ្ឈា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច សចេ សា ភន្តេ វិជាយិស្សតិ សព្វស្ស កុដុម្ពស្ស ឥស្សរា ភវិស្សតិ ឥង្ឃយ្យ តស្សា គព្ភបាតនំ ជានាហីតិ ។ សុដ្ឋុ ភគិនីតិ តស្សា គព្ភបាតនំ អទាសិ ។ ទារកោ កាលមកាសិ ។ មាតា ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរស្ស បុរិសស្ស ទ្វេ បជាបតិយោ ហោន្តិ ឯកា វញ្ឈា ឯកា វិជាយិនី ។ វញ្ឈា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច សចេ សា ភន្តេ វិជាយិស្សតិ សព្វស្ស កុដុម្ពស្ស ឥស្សរា ភវិស្សតិ ឥង្ឃយ្យ តស្សា គព្ភបាតនំ ជានាហីតិ ។ សុដ្ឋុ ភគិនីតិ តស្សា គព្ភបាតនំ អទាសិ ។ មាតា កាលមកាសិ ។ ទារកោ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស

១ វញ្ឈិកាតិ បាឋោ កត្ថចិ បោត្ថកេ ទិស្សតិ ។ សោ បន វញ្ឈា សមេតិ ។



ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ (នាក់) ប្រពន្ធម្នាក់នោះជាស្រីអារ ម្នាក់ទៀតជាស្រីមានកូន ។ ស្រីអារនិយាយនឹងភិក្ខុជាជំនិតថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន មុខតែនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមបានមេត្តាចុះលោកម្ចាស់ សូមបានប្រាប់ថ្នាំរំលូតគភ៌ចេញ ។ ភិក្ខុទទួលថា ស្រួលហើយ ប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ទារក (ដែលនៅក្នុងគភ៌) ក៏ធ្វើមរណកាលទៅ ។ ឯម្តាយមិនបានធ្វើមរណកាលទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធម្នាក់ជាស្រីអារ ម្នាក់ជាស្រីមានកូន ។ ឯស្រីអារនិយាយនឹងភិក្ខុជាជំនិតថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន គេនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមបានមេត្តាចុះ លោកម្ចាស់ សូមបានប្រាប់ថ្នាំរំលូតគភ៌ចេញ ។ ភិក្ខុជាជំនិតទទួលថា ស្រួលហើយ ប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ម្តាយក៏ធ្វើមរណកាលទៅ ។ ឯទារកមិនបានធ្វើមរណកាលទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ

អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរស្ស បុរិសស្ស ទ្វេ បជាបតិយោ ហោន្តិ ឯកា វញ្ឈា ឯកា វិជាយិនី ។ វញ្ឈា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច សចេ សា ភន្តេ វិជាយិស្សតិ សព្វស្ស កុដុម្ពស្ស ឥស្សរា ភវិស្សតិ ឥង្ឃយ្យ តស្សា គព្ភបាតនំ ជានាហីតិ ។ សុដ្ឋុ ភគិនីតិ តស្សា គព្ភបាតនំ អទាសិ ។ ឧភោ កាលមកំសុ ។ បេ ។ ឧភោ ន កាលមកំសុ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា គព្ភិនី ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច ឥង្ឃយ្យ គព្ភបាតនំ ជានាហីតិ ។ តេនហិ ភគិនិ មទ្ទស្សូតិ ។ សា មទ្ទិត្វា គព្ភំ បាតេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរា គព្ភិនី ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច ឥង្ឃយ្យ គព្ភបាតនំ ជានាហីតិ ។



ព្រោះត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធម្នាក់ជាស្រីអារ ម្នាក់ទៀតជាស្រីមានកូន ។ ស្រីអារនិយាយនឹងភិក្ខុជាជិតកុលថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន គេនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមតាមមេត្តាចុះ លោកម្ចាស់ សូមបានប្រាប់ថ្នាំរំលូតគភ៌ចេញ ។ ភិក្ខុនោះទទួលថា ស្រួលហើយប្អូនស្រី (ជាការហើយ) ក៏ឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ម្តាយនឹងកូនទាំងពីរនាក់ក៏ធ្វើមរណកាលទៅ ។ បេ ។ ម្តាយនឹងកូនទាំងពីរនាក់មិនបានធ្វើមរណកាល ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានស្រីម្នាក់មានគភ៌ បាននិយាយនឹងភិក្ខុជាជិតកុលថា សូមតាមមេត្តាចុះ លោកម្ចាស់ សូមបានប្រាប់ថ្នាំរំលូតគភ៌ (ដល់ខ្ញុំ) ។ ភិក្ខុនោះពោលថា នែប្អូនស្រី បើដូច្នោះ នាងចូរច្របាច់ពោះទៅ ។ ស្រីនោះក៏ច្របាច់ពោះរំលូតគភ៌មក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីម្នាក់មានគភ៌បាននិយាយនឹងភិក្ខុជាជិតកុលថា សូមតាមមេត្តាចុះ លោកម្ចាស់ សូមបានប្រាប់ថ្នាំរំលូតគភ៌ (ឲ្យខ្ញុំព្រះ

តេនហិ ឥតិទំ ការេហីតិ ។ សា ការេត្វា គព្ភំ បាតេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរា វញ្ឈា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច ឥង្ឃាយ្យ ភេសជ្ជំ ជានាហិ យេនាហំ វិជាយេយ្យន្តិ ។ សុដ្ឋុ ភគិនីតិ តស្សា ភេសជ្ជំ អទាសិ ។ សា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា វិជាយិនី ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច ឥង្ឃាយ្យ ភេសជ្ជំ ជានាហិ យេនាហំ ន វិជាយេយ្យន្តិ ។ សុដ្ឋុ ភគិនីតិ តស្សា ភេសជ្ជំ អទាសិ ។ សា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ទុក្កដស្សាតិ ។



ករុណា) ភិក្ខុនោះប្រាប់ថា នែប្អូនស្រី បើដូច្នោះ នាងចូរកំដៅផ្ទៃពោះទៅ ។ នាងនោះក៏កំដៅគភ៌ឲ្យធ្លាក់មក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីអារម្នាក់បាននិយាយនឹងកុលូបកភិក្ខុ ថា (ជីតូន) ថា សូមមានមេត្តាចុះ លោកម្ចាស់ ខ្ញុំគប្បីសម្រាលកូនដោយថ្នាំណា (ស្រួល) មេត្តាប្រាប់ថ្នាំនោះ (ដល់ខ្ញុំ) ។ ភិក្ខុនោះទទួលថា ស្រួលហើយ ប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំដល់នាងនោះ ។ នាងនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមានកូន បាននិយាយនឹងភិក្ខុជាជីតូនថា សូមបានមេត្តាចុះ លោកម្ចាស់ ខ្ញុំមិនសម្រាលកូនដោយថ្នាំណា សូមលោកម្ចាស់ឲ្យថ្នាំនោះ (ដល់ខ្ញុំ) ។ លោកនោះទទួលថា ស្រួលហើយ ប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំដល់ស្រីនោះ ។ នាងនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិទុក្កដ ។

[២១៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយំ ភិក្ខុំ អង្គុលិបតោទកេន ហាសេសុំ ។ សោ ភិក្ខុ ឧត្តសន្តោ(១) អនស្សាសកោ កាលមកាសិ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ បាចិត្តិយស្សាតិ(២) ។

[២១៧] តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ ឆព្វគ្គិយំ ភិក្ខុំ កម្មំ ករិស្សាមាតិ ឱត្ថរិត្វា មារេសុំ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ បាចិត្តិយស្សាតិ(៣) ។

[២១៨] តេន ខោ បន សមយេន អញ្ញតរោ ភូតវេជ្ជកោ ភិក្ខុ យក្ខំ ជីវិតា វោរោបេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

[២១៩] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញតរំ ភិក្ខុំ វាឡយក្ខវិហារំ បាហេសិ ។ តំ យក្ខា ជីវិតា វោរោបេសុំ ។

១ ម. ឧ. ឧត្តន្តោ ។ ២-៣ ម. ឧ. អនាបត្តិ ភិក្ខវេ បារាជិកស្សាតិ ។





(២១៦) សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបានចាក់ក្រឡេកភិក្ខុ (មួយរូប) ដែលរាប់បញ្ចូលក្នុងពួកសត្តរសវគ្គិយភិក្ខុ ដោយចុងម្រាមដៃ ។ ភិក្ខុនោះ (សើចក្អាកក្អាយ) តក់ស្លុតផុតដង្ហើមស្លាប់ទៅ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ ។

(២១៧) សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុគិតគ្នាថា យើងនឹងធ្វើកម្ម(១) (តិះដៀល) ក៏ចាប់សង្កត់សង្កៀបឆព្វគ្គិយភិក្ខុមួយរូប ទាល់តែស្លាប់ទៅ ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះមានសេចក្តីសង្ស័យកើតឡើង ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ ។

(២១៨) សម័យនោះឯង មានភិក្ខុមួយរូបជាគ្រូពេទ្យចាប់ខ្មោចបាន ផ្តាច់បង់ជីវិតយក្សមួយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យកើតឡើង ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

(២១៩) សម័យនោះឯង មានភិក្ខុមួយរូបបានបញ្ជូនភិក្ខុមួយរូបទៅកាន់វិហារដែលមានយក្សកាច (ក្រោយទៅ) ។ ពួកយក្សក៏ (នាំគ្នា ផ្តាច់

១ ធ្វើបាបឲ្យពិបាក ។

តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ អញ្ញតរំ ភិក្ខុំ វាឡយក្ខំ វិហារំ បាហេសិ ។ តំ យក្ខា ជីវិតា វោរោបេសុំ ។ បេ ។ តំ យក្ខា ន ជីវិតា វោរោបេសុំ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញតរំ ភិក្ខុំ វាឡកន្តារំ បាហេសិ ។ តំ វាឡា ជីវិតា វោរោបេសុំ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ អញ្ញតរំ ភិក្ខុំ វាឡកន្តារំ បាហេសិ ។ តំ វាឡា ជីវិតា វោរោបេសុំ ។ បេ ។ តំ វាឡា ជីវិតា ន វោរោបេសុំ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន



បង់ជីវិតភិក្ខុនោះទៅ ។ ឯភិក្ខុដែលជាអ្នកបញ្ជូនក៏មានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យស្លាប់ទេ ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងឲ្យស្លាប់ ក៏បញ្ជូនភិក្ខុមួយរូបទៅកាន់វិហារដែលមានយក្សកាច ។ ពួកយក្សក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ បេ ។ ពួកយក្សមិនបានផ្តាច់បង់ជីវិតភិក្ខុនោះទេ ។ ឯភិក្ខុជាអ្នកបញ្ជូននោះក៏មានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុមួយរូប បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវលំបាកមានសត្វសាហាវ ។ សត្វសាហាវទាំងឡាយក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ ភិក្ខុអ្នកបញ្ជូនមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យស្លាប់ទេ ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងឲ្យស្លាប់ បានបញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាលមានសត្វសាហាវ ។ សត្វសាហាវទាំងឡាយក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ បេ ។ ពួកសត្វសាហាវមិនបានផ្តាច់ជីវិតភិក្ខុនោះទេ ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង

អញ្ញតរោ ភិក្ខុ អញ្ញតរំ ភិក្ខុំ ចោរកន្តារំ បាហេសិ ។ តំ ចោរា ជីវិតា វោរោបេសុំ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ អញ្ញតរំ ភិក្ខុំ ចោរកន្តារំ បាហេសិ ។ តំ ចោរា ជីវិតា វោរោបេសុំ ។ បេ ។ តំ ចោរា ន ជីវិតា វោរោបេសុំ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

[៤៤០] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ តំ មញ្ញមានោ តំ ជីវិតា វោរោបេសិ ។ តំ មញ្ញមានោ អញ្ញំ ជីវិតា វោរោបេសិ ។ អញ្ញំ មញ្ញមានោ តំ ជីវិតា វោរោបេសិ ។ អញ្ញំ មញ្ញមានោ អញ្ញំ ជីវិតា វោរោបេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។





មានភិក្ខុមួយរូប ចាប់បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់ស្រទ្ធ ដែលមានចោរ (ក៏សម្លាប់ទៅ) ។ ពួកចោរក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានចំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ភិក្ខុមួយរូបមានចំណងនឹងសម្លាប់ ក៏បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់ស្រទ្ធ ដែលមានចោរ (ក៏សម្លាប់ទៅ) ។ ពួកចោរក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ បេ ។ ពួកចោរមិនបានផ្តាច់បង់ជីវិតភិក្ខុនោះទេ ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ច័យ ។

[៤៤០] សម័យនោះឯង មានភិក្ខុមួយរូប ចំណាំភិក្ខុជាសត្រូវនោះបាន ហើយក៏ទៅផ្តាច់បង់ជីវិតភិក្ខុជាសត្រូវនោះទៅ ។ ចំណាំភិក្ខុជាសត្រូវនោះបាន តែទៅផ្តាច់បង់ជីវិតភិក្ខុដទៃវិញ ។ ចូលចិត្តថាជាភិក្ខុដទៃ តែទៅផ្តាច់បង់ជីវិតភិក្ខុជាសត្រូវនោះវិញ ។ សំគាល់ថាជាភិក្ខុដទៃ ក៏ទៅផ្តាច់បង់ជីវិតភិក្ខុដទៃ (នោះ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(៦៦៣) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អមនុស្សេន គហិតោ ហោតិ ។ អញ្ញតរោ ភិក្ខុ តស្ស ភិក្ខុនោ ឧបការំ អកាសិ ។ សោ ភិក្ខុ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អមនុស្សេន គហិតោ ហោតិ ។ អញ្ញតរោ ភិក្ខុ មារណាធិប្បាយោ តស្ស ភិក្ខុនោ ឧបការំ អកាសិ ។ សោ ភិក្ខុ កាលមកាសិ ។ បេ ។ សោ ភិក្ខុ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(៦៦៤) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កល្យាណកម្មស្ស សគ្គកថំ កថេសិ ។ សោ អធិមុត្តោ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ



(៦៦៣) សម័យនោះឯង មានភិក្ខុមួយរូបត្រូវខ្មោចចូល ។ មានភិក្ខុមួយរូបទៀតបានវាយភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុដែលវាយនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានចំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបត្រូវខ្មោចចូលដែរ ។ មានភិក្ខុមួយរូបទៀតមានចំណងនឹងសម្លាប់ បានវាយភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ បេ ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ចយ ។

(៦៦៤) សម័យនោះឯង មានភិក្ខុមួយរូបពោលសគ្គកថា (រឿងអំពីស្ថានសួគ៌) ដល់បុគ្គលដែលបានធ្វើអំពើល្អ ។ បុគ្គលនោះបានស្ដាប់នោះ ក៏អស់ចិត្តធ្វើមរណកាលទៅ ។ ភិក្ខុអ្នកសំដែងមានសេចក្ដីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានចំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានចំណង

មរណាធិប្បាយោ កល្យាណកម្មស្ស សគ្គកថំ កថេសិ ។ សោ អធិមុត្តោ កាលមកាសិ ។ បេ ។ សោ អធិមុត្តោ ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ នេរយិកស្ស និរយកថំ កថេសិ ។ សោ ឧត្តសិត្វា កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ ន មរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ នេរយិកស្ស និរយកថំ កថេសិ ។ សោ ឧត្តសិត្វា កាលមកាសិ ។ បេ ។ សោ ឧត្តសិត្វា ន កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(៤៤៣) តេន ខោ បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ ករោន្តា រុក្ខំ ឆិន្ទន្តិ ។ អញ្ញតរោ ភិក្ខុ អញ្ញតរំ ភិក្ខុំ ឯតទវោច



នឹងស្លាប់ ទើបសំដែងសគ្គកថា របស់បុគ្គលដែលបានធ្វើអំពើល្អមកហើយ ។ បុគ្គលនោះក៏តក់ស្លុតធ្វើមរណកាលទៅ ។ បេ ។ បុគ្គលនោះបានតក់ស្លុតដែរ តែមិនបានធ្វើមរណកាលទេ ។ ឯភិក្ខុអង្គនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបសំដែងនិរយកថា (ដំណាលសំដីនរក) នៃសត្វដែលទៅកើតក្នុងនរក ។ ភិក្ខុអង្គស្តាប់នោះតក់ស្លុត ហើយធ្វើមរណកាលទៅ ។ ភិក្ខុអង្គសំដែងនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានប្រាថ្នានឹងស្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានប្រាថ្នានឹងស្លាប់ ទើបពោលនិរយកថានៃសត្វដែលទៅកើតក្នុងនរក ។ បុគ្គលនោះតក់ស្លុតហើយធ្វើមរណកាលទៅ ។ បេ ។ បុគ្គលនោះតក់ស្លុត តែមិនបានធ្វើមរណកាលឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ច័យ ។

(៤៤៣) សម័យនោះឯង ពួកភិក្ខុនៅក្រុងអាឡវី កាលធ្វើនវកម្ម ទើបនាំគ្នាកាប់ដើមឈើ ។ មានភិក្ខុមួយរូបបាននិយាយនឹងភិក្ខុមួយរូប

អាវុសោ ឯត្ថ ឋិតោ ឆិន្ទាហីតិ ។ តំ ឯត្ថ ឋិតំ ឆិន្ទន្តំ រុក្ខោ ឱត្ថរិត្វា មារេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ អមរណាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អាឡវកា ភិក្ខូ នវកម្មំ ករោន្តា រុក្ខំ ឆិន្ទន្តិ ។ អញ្ញតរោ ភិក្ខុ មរណាធិប្បាយោ អញ្ញតរំ ភិក្ខុំ ឯតទវោច អាវុសោ ឯត្ថ ឋិតោ ឆិន្ទាហីតិ ។ តំ ឯត្ថ ឋិតំ ឆិន្ទន្តំ រុក្ខោ ឱត្ថរិត្វា មារេសិ ។ បេ ។ រុក្ខោ ឱត្ថរិត្វា ន មារេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(២២៦) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទាយំ អាលិម្បេសុំ ។ មនុស្សា ទឌ្ឍា កាលមកំសុ ។ តេសំ កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខវេ អមរណាធិប្បាយានន្តិ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មរណាធិប្បាយា ទាយំ អាលិម្បេសុំ ។ មនុស្សា ទឌ្ឍា កាលមកំសុ ។ បេ ។



ទៀតថា ម្នាលអាវុសោ លោកចូរឈរត្រង់ទីនេះកាប់ឈើទៅ ។ ដើមឈើក៏រលំសង្កត់ភិក្ខុនោះដែលកំពុងឈរកាប់ស្លាប់ក្នុងទីនោះទៅ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនប្រាថ្នានឹងសម្លាប់មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី កាលនឹងធ្វើនវកម្មបាននាំគ្នាកាប់ដើមឈើ ។ មានភិក្ខុមួយរូបមានចំណងនឹងសម្លាប់ ហើយនិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរត្រង់ទីនេះកាប់ឈើទៅ ។ ដើមឈើក៏រលំសង្កត់ភិក្ខុនោះដែលកំពុងឈរកាប់ស្លាប់ក្នុងទីនោះទៅ ។ បេ ។ ដើមឈើរលំសង្កត់មិនស្លាប់ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមអាបត្តិថុល្លច្ច័យ ។

(២២៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយនាំគ្នាដុតភ្លើងព្រៃ ។ មនុស្ស (ដែលនៅក្នុងព្រៃ) ត្រូវភ្លើងឆេះស្លាប់ (ជាច្រើននាក់) ។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានចំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមានចំណងនឹងសម្លាប់ក៏នាំគ្នាដុតភ្លើងព្រៃ ។ មនុស្សទាំងឡាយត្រូវភ្លើងព្រៃឆេះស្លាប់ (ជាច្រើននាក់) ។ បេ ។

មនុស្សា ន ច កាលមកំសុ ។ តេសំ កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខវេ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(២២៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អាឃាតនំ គន្ត្វា ចោរឃាតកំ ឯតទវោច អាវុសោ មាយិមំ កិលមេសិ ឯកេន បហារេន ជីវិតា វោរោបេហីតិ ។ សុដ្ឋុ ភន្តេតិ ឯកេន បហារេន ជីវិតា វោរោបេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អាឃាតនំ គន្ត្វា ចោរឃាតកំ ឯតទវោច អាវុសោ មាយិមំ កិលមេសិ ឯកេន បហារេន ជីវិតា វោរោបេហីតិ ។ សោ នាហំ តុយ្ហំ វចនំ ករិស្សាមីតិ តំ ជីវិតា វោរោបេសិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(២២៩) តេន ខោ បន សមយេន អញ្ញតរោ បុរិសោ ញាតកេហិ(១) ហត្ថបាទច្ឆិន្នោ ញាតកេហិ

១ ឱ. ម. ញាតិយេ ។



ពួកមនុស្សត្រូវភ្លើងឆេះ តែនៅតែមិនស្លាប់ ។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

(២២៨) សម័យនោះឯង មានភិក្ខុមួយរូបដើរទៅកាន់ទីសម្លាប់ចោរ ហើយបាននិយាយនឹងពេជ្ឈឃាតថា ម្នាលអាវុសោ អ្នកកុំធ្វើឲ្យបុរសនេះលំបាកឡើយ អ្នកចូរផ្តាច់បង់ជីវិតដោយប្រហារតែម្តងទៅ ។ ពេជ្ឈឃាតទទួលពាក្យថា ស្រួលហើយ លោកម្ចាស់ (ជាហើយ) ក៏ផ្តាច់បង់ជីវិត (ចោរ) ដោយប្រហារតែម្តង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុមួយរូបដើរទៅកាន់ទីសម្លាប់ចោរ ហើយបាននិយាយនឹងពេជ្ឈឃាតថា ម្នាលអាវុសោ អ្នកកុំធ្វើបុរសនេះឲ្យលំបាកឡើយ ចូរអ្នកផ្តាច់បង់ជីវិតដោយប្រហារតែម្តងទៅ ។ ពេជ្ឈឃាតឆ្លើយថា ខ្ញុំព្រះគុណមិនធ្វើតាមពាក្យលោកទេ (ជាហើយ) ក៏ផ្តាច់បង់ជីវិតបុរសនោះទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

(២២៩) សម័យនោះឯង មានបុរសម្នាក់ត្រូវគេកាត់ដៃកាត់ជើង (មកនៅ) ក្នុងផ្ទះត្រកូល មានពួកញាតិមកប្រជុំគ្នាព្យាបាល ។ មានភិក្ខុមួយរូប

សម្បរិកិណ្ណោ ហោតិ ។ អញ្ញតរោ ភិក្ខុ តេ មនុស្សេ ឯតទវោច អាវុសោ ឥច្ឆថ ឥមស្ស មរណន្តិ ។ អាម ភន្តេ ឥច្ឆាមាតិ ។ តេនហិ តក្កំ បាយេថាតិ ។ តេ តំ តក្កំ បាយេសុំ ។ សោ កាលមកាសិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ បុរិសោ កុលឃរេ ហត្ថបាទច្ឆិន្នោ ញាតកេហិ សម្បរិកិណ្ណោ ហោតិ ។ អញ្ញតរា ភិក្ខុនី តេ មនុស្សេ ឯតទវោច អាវុសោ ឥច្ឆថ ឥមស្ស មរណន្តិ ។ អាមយ្យេ ឥច្ឆាមាតិ ។ តេនហិ លោណសោវីរកំ[1] បាយេថាតិ ។ តេ តំ លោណសោវីរកំ[2] បាយេសុំ ។ សោ កាលមកាសិ ។ តស្សា កុក្កុច្ចំ អហោសិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អាបត្តឹ សា ភិក្ខវេ ភិក្ខុនី អាបន្នា បារាជិកន្តិ ។

តតិយបារាជិកំ និដ្ឋិតំ ។

១-២ ឱ. ម. លោណសុវីរកំ ។



បាននិយាយនឹងពួកមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចង់ឲ្យបុរសនេះស្លាប់ឬ ។ ពួកមនុស្សឆ្លើយតបថា ករុណា យើងចង់ឲ្យគាត់ស្លាប់ដែរ ។ ភិក្ខុនោះប្រាប់ថា បើដូច្នោះ អ្នកទាំងឡាយចូរឲ្យគាត់ផឹកខ្លាញ់ទឹកដោះគោទៅ ។ ពួកមនុស្សក៏ឲ្យបុរសនោះផឹកខ្លាញ់ទឹកដោះគោ ។ បុរសនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានបុរសម្នាក់គេកាត់ដៃកាត់ជើង (មកនៅ) ក្នុងត្រកូល ពួកញាតិក៏ប្រជុំគ្នាមកព្យាបាល ។ មានភិក្ខុនី (មួយរូប) និយាយនឹងពួកមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចង់ឲ្យបុរសនេះស្លាប់ឬទេ ។ ពួកមនុស្សឆ្លើយថា ករុណា លោកម្ចាស់ យើងចង់ឲ្យស្លាប់ដែរ ។ ភិក្ខុនីនោះប្រាប់ថា បើដូច្នោះ អ្នកទាំងឡាយចូរឲ្យគាត់ផឹកជាំត្រៃដោយអំបិលទៅ ។ មនុស្សទាំងនោះក៏ឲ្យបុរសនោះផឹកជាំត្រៃដោយអំបិលនោះ ។ បុរសនោះធ្វើមរណកាលទៅ ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ ។ លំដាប់នោះឯង ភិក្ខុនីនោះបានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីក៏ចំណាលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះ ត្រូវអាបត្តិបារាជិកហើយ ។

បារាជិកទី ៣ ចប់ ។

(៦២៧) តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ វគ្គុមុទាយ នទិយា តីរេ វស្សំ ឧបគច្ឆិំសុ ។ តេន ខោ បន សមយេន វជ្ជី ទុព្ភិក្ខា ហោតិ ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ វជ្ជី ទុព្ភិក្ខា ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ កេន នុ ខោ មយំ ឧបាយេន



(៦២៧) សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ មានភិក្ខុច្រើនរូបជាមិត្តធ្លាប់ឃើញគ្នា ជាមិត្តស្និទ្ធស្នាលនឹងគ្នា បាននៅចាំវស្សាទៀបឆ្នេរស្ទឹងវគ្គុមុទា ។ កាលនោះ ស្រុកវជ្ជីកើតទុរ្ភិក្សអត់បាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្ស (ដែលក្រលំបាកស្លាប់ គឺដល់នូវសេចក្ដីស្លាប់) មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្ស (ដែលមានទ្រព្យសម្បត្តិល្មមចិញ្ចឹមខ្លួនបាន) ក៏មិនងាយនឹងចិញ្ចឹមខ្លួនដែរ លុះតែមានស្លាកកាត់ជាសំគាល់ ទើបចិញ្ចឹមខ្លួនបាន មនុស្សទាំងអស់ក្នុងស្រុកនោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក ។ វេលានោះឯង ភិក្ខុទាំងនោះក៏គិតគ្នាថា ឥឡូវនេះ ស្រុកវជ្ជីកើតទុរ្ភិក្សអត់បាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្ស (ដែលក្រលំបាកស្លាប់ គឺដល់នូវសេចក្ដីស្លាប់) មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្ស (ដែលមានទ្រព្យសម្បត្តិល្មមចិញ្ចឹមខ្លួនបាន) ក៏មិនងាយនឹងចិញ្ចឹមខ្លួនដែរ លុះតែមានស្លាកកាត់ជាសំគាល់ទើបចិញ្ចឹមខ្លួនបាន មនុស្សទាំងអស់ក្នុងស្រុកនោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក តើយើងនឹងគិតធ្វើឧបាយដូចម្ដេច

សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមេយ្យាមាតិ ។ ឯកច្ចេ ឯវមាហំសុ ហន្ទ មយំ អាវុសោ គិហីនំ កម្មន្តំ អធិដ្ឋេម ឯវន្តេ អម្ហាកំ ទាតុំ មញ្ញិស្សន្តិ ឯវំ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិស្សាម ន ច បិណ្ឌកេន កិលមិស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ អលំ អាវុសោ កឹ គិហីនំ កម្មន្តំ អធិដ្ឋិតេន ហន្ទ មយំ អាវុសោ គិហីនំ ទូតេយ្យំ ហរាម ឯវន្តេ អម្ហាកំ ទាតុំ មញ្ញិស្សន្តិ ឯវំ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិស្សាម ន ច បិណ្ឌកេន កិល-មិស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ អលំ អាវុសោ កឹ គិហីនំ កម្មន្តំ អធិដ្ឋិតេន កឹ គិហីនំ ទូតេយ្យំ ហដេន[១] ហន្ទ មយំ អាវុសោ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសិស្សាម អសុកោ

១ ហរណេនាតិ បាឋោ ។



ឲ្យបានសាមគ្គីស្មោះសរ កុំឲ្យមានវិវាទទាស់ទែងគ្នា នៅចាំវស្សាឲ្យបានស្រួលផង កុំឲ្យលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុខ្លះនិយាយថា ម្នាលអាវុសោ បើដូច្នោះ យើងត្រូវទទួលកាន់ធុរៈការងាររបស់ពួកគ្រហស្ថចុះ កាលបើយើងធ្វើយ៉ាងនេះហើយ ពួកគ្រហស្ថទាំងនោះ គង់នឹងនឹកនាំឲ្យអាហារដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏បានសាមគ្គីស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុខ្លះនិយាយថា ម្នាលអាវុសោ កុំ ប្រយោជន៍អ្វីនឹងទទួលកាន់ធុរៈការងាររបស់គ្រហស្ថ (នោះ) ម្នាលអាវុសោ ណ្ហើយចុះ យើងត្រូវធ្វើជាអ្នកបំរើនាំដំណឹងដល់ពួកគ្រហស្ថវិញ កាលបើយើងធ្វើយ៉ាងនេះហើយ ពួកជនទាំងនោះគង់នឹងនឹកនាំឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះ យើងនឹងព្រមព្រៀងស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុខ្លះនិយាយថា ម្នាលអាវុសោ កុំ ប្រយោជន៍អ្វីនឹងទទួលកាន់ធុរៈការងាររបស់គ្រហស្ថ ប្រយោជន៍អ្វីនឹងធ្វើជាអ្នកបំរើនាំដំណឹងដល់ពួកគ្រហស្ថ (នោះ) ម្នាលអាវុសោ ណ្ហើយចុះ យើងត្រូវពោលអួតនូវឧត្តរិមនុស្សធម្មការយើងទៅវិញទៅមក ឲ្យពួកគ្រហស្ថ (គេស្ដាប់វិញ) ថាភិក្ខុឯណោះ

កិញ្ចា បឋមស្ស ឈានស្ស លាភី អស្សុ... កិញ្ចា ទុតិយស្ស ឈានស្ស លាភី អស្សុកោ កិញ្ចា តតិយស្ស ឈានស្ស លាភី អស្សុកោ កិញ្ចា ចតុត្ថស្ស ឈានស្ស លាភី អស្សុកោ កិញ្ចា សោតាបន្នោ អស្សុកោ កិញ្ចា សកទាគាមី អស្សុកោ កិញ្ចា អនាគាមី អស្សុកោ កិញ្ចា អរហា អស្សុកោ កិញ្ចា តេវិជ្ជោ អស្សុកោ កិញ្ចា ឆឡភិញ្ញោតិ ឯវំ អត្ថានំ ... អភិស្សន្ទិ ឯវំ មយំ សមត្ថា ... ឥមានិ ... ចត្តារិ ... ផាសុ ... ។ បរោ ... អាវុសោ ... ។ ឯកោ អញ្ញតរំ គិហិនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសិតោតិ ។ អថខោ តេ ភិក្ខូ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសិំសុ អស្សុកោ កិញ្ចា បឋមស្ស ឈានស្ស លាភី ។ បេ ។ អស្សុកោ កិញ្ចា ចតុត្ថស្ស ឈានស្ស លាភី អស្សុកោ កិញ្ចា សោតាបន្នោ ។ បេ ។ អស្សុកោ កិញ្ចា ឆឡភិញ្ញោតិ ។ អថខោ តេ មនុស្សា លាភា វត នោ



បានឈានទី ១ ភិក្ខុឯណោះបានឈានទី ២ ភិក្ខុឯណោះបានឈានទី ៣ ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតាបន្ន ភិក្ខុឯណោះជាសកទាគាមី ភិក្ខុឯណោះជាអនាគាមី ភិក្ខុឯណោះជាព្រះអរហន្ត ភិក្ខុឯណោះបានវិជ្ជា ៣ ភិក្ខុឯណោះបានអភិញ្ញា ៦ កាលបើយើងពោលយ៉ាងនេះហើយ ពួកជនទាំងនោះនឹងនឹកនាំឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏នឹងមានសាមគ្គីស្មោះសាទីនឹងគ្នា មិនទាស់ទែងគ្នាឡើយ នៅជាសុខស្រួលហើយមិនលំបាកដោយបិណ្ឌបាតផង ។ ភិក្ខុទាំងនោះក៏យល់ព្រមថា ម្នាលអាវុសោ ទាំងឡាយ ការពោលគុណឧត្តរិមនុស្សធម្មរបស់គ្នាយើងទៅវិញទៅមកដល់ពួកគ្រហស្ថ ដែលលោកជាមកនឹងយើង (អម្បាញ់មិញនេះ) ស្រួលហើយ ។ គ្រឹកាលជាខាងក្រោយមក ភិក្ខុទាំងនោះក៏បានពោលគុណឧត្តរិមនុស្សធម្មទៅវិញទៅមកដល់ពួកគ្រហស្ថថា ភិក្ខុឯណោះបានឈានទី ១ ។ បេ ។ ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតាបន្ន ។ បេ ។ ភិក្ខុឯណោះបានអភិញ្ញា ៦ ។ គ្រានោះ មនុស្សទាំងនោះក៏និយាយគ្នាថា យើងក៏លាភបានភិក្ខុប្រពៃរបស់ឲ្យនៅជាសុខ ម្យ៉ាង យ៉ាងពេញជាលាភ

សុលទ្ធំ វត នោ យេសំ នោ ឯវរូបា ភិក្ខូ វស្សំ ឧបគតា ។ ន វត នោ ឥតោ បុព្វេ ឯវរូបា ភិក្ខូ វស្សំ ឧបគតា យថយិមេ ភិក្ខូ សីលវន្តោ កល្យាណធម្មាតិ ។ តេ[១] ន[២] តាទិសានិ ភោជនានិ អត្តនា ភុញ្ជន្តិ ន មាតាបិតូនំ ទេន្តិ ន បុត្តទារស្ស ទេន្តិ ន ទាសកម្មករបោរិសស្ស ទេន្តិ ន មិត្តាមច្ចានំ ទេន្តិ ន ញាតិសាលោហិតានំ ទេន្តិ យាទិសានិ ភិក្ខូនំ ទេន្តិ ។ ន តាទិសានិ ខាទនីយានិ អត្តនា ខាទន្តិ ន មាតាបិតូនំ ទេន្តិ ។ បេ ។ ន ញាតិសាលោហិតានំ ទេន្តិ យាទិសានិ ភិក្ខូនំ ទេន្តិ ។ ន[៣] តាទិសានិ សាយនីយានិ អត្តនា សាយន្តិ ន មាតាបិតូនំ ទេន្តិ ។ បេ ។ ន ញាតិសាលោហិតានំ ទេន្តិ យាទិសានិ ភិក្ខូនំ ទេន្តិ ។ ន[៤] តាទិសានិ បានានិ អត្តនា បិវន្តិ ន មាតាបិតូនំ ទេន្តិ ន បុត្តទារស្ស ទេន្តិ ន ទាសកម្មករបោរិសស្ស ទេន្តិ ន មិត្តាមច្ចានំ ទេន្តិ

១-២ ម. យ. បោត្ថកេសុ អយំ បាឋោ សព្វត្ថ ទិស្សតិ ។ ៣-៤ [illegible]



របស់យើង ឈ្មោះថាយើងបានបុណ្យជាយើងហើយណាស់ហ្ន៎ គឺដើមយើង ពីព្រោះមិនដែលបានពួកភិក្ខុមានសីល មានធម៌ជាកុសល ដូចជាភិក្ខុនេះមកនៅចាំវស្សា (ជល់មួង) សោះឡើយ ។ មនុស្សទាំងនោះ (កាលបើបាន) ភោជនាហារដែលឆ្ញាញ់ពិសា ក៏បរិច្ចាគតែទីប្រគេនភិក្ខុទាំងនោះ មិនហ៊ានបរិភោគម្នាក់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស[១] មិត្រ អមាត្យ មន្ត្រីនិងញាតិសាលោហិតសោះឡើយ ឬបានខាទនីយាហារដែលឆ្ញាញ់ពិសា ក៏បរិច្ចាគតែទីប្រគេនភិក្ខុទាំងនោះ មិនហ៊ានបរិភោគម្នាក់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតាទេ ។ បេ ។ មិនដែលបានឲ្យទៅញាតិសាលោហិតឡើយ ឬបានគ្រឿងសម្រាប់ផ្ទក់ផ្ទាប់ដែលឆ្ញាញ់ពិសា ក៏បរិច្ចាគតែទីប្រគេនភិក្ខុទាំងនោះ មិនហ៊ានផ្ទក់ផ្ទាប់មាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតាទេ ។ បេ ។ មិនដែលបានឲ្យទៅញាតិសាលោហិតឡើយ ឬបានទឹកដែលមានរសល្អ ក៏បរិច្ចាគតែទីប្រគេនភិក្ខុទាំងនោះ មិនហ៊ានផឹកម្នាក់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្រ

១ ឈ្មោះអ្នកធ្វើការស៊ីឈ្នួល ។

ន ញាតិសាលោហិតានំ ទេន្តិ យថាសកំ ភិក្ខូនំ ទេន្តិ ។ អថខោ តេ ភិក្ខូ វណ្ណវន្តោ អហេសុំ បីណិន្ទ្រិយា បសន្នមុខវណ្ណា វិប្បសន្នឆវិវណ្ណា ។ អាចិណ្ណំ ខោ បនេតំ វស្សំ វុត្ថានំ ភិក្ខូនំ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ ។ អថខោ តេ ភិក្ខូ វស្សំ វុត្ថា តេមាសច្ចយេន សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន វេសាលី តេន បក្កមឹសុ អនុបុព្វេន ចារិកំ(១) ចរមានា(២) យេន វេសាលី យេន មហាវនំ យេន កូដាគារសាលា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

(២២៨) តេន ខោ បន សមយេន ទិសាសុ វស្សំ វុត្ថា ភិក្ខូ កិសា ហោន្តិ លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តា ។ វគ្គុមុទាតីរិយា បន ភិក្ខូ វណ្ណវន្តា ហោន្តិ បីណិន្ទ្រិយា បសន្នមុខវណ្ណា វិប្បសន្នឆវិវណ្ណា ។ អាចិណ្ណំ ខោ បនេតំ

១-២ ពីសុចិ បោត្ថកេសុ ឥទំ បាឋទ្វយំ ន ទិស្សតិ ។



អោយ ញាតិសាលោហិតឡើយ ។ គ្រានោះ ភិក្ខុទាំងនោះ (លុះបានអាហារគ្រាន់បរិបូណ៌) ក៏មានសម្បុរល្អមានឥន្ទ្រិយពេញលេញ មានទឹកមុខស្រស់បស់សម្បុរស្បែកក៏ថ្លាផុត ។ ភិក្ខុទាំងឡាយ កាលបើចេញវស្សារួចហើយ តែងតែនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ នេះជាទំនៀមទម្លាប់ដែលមានឡើយ ។ វេលានោះឯង ភិក្ខុទាំងនោះ លុះបាននៅចាំវស្សាគ្រប់ ៣ ខែហើយ ក៏រៀបចំទុកដាក់គ្រឿងសេនាសនៈរួចហើយ នាំយកបាត្រនិងចីវរចូលទៅក្រុងវេសាលី ដើរទៅតាមចារិកតាមលំដាប់ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ដែលគង់នៅក្នុងកូដាគារសាលាក្នុងមហាវនទៀបក្រុងវេសាលី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។

(២២៨) សម័យនោះឯង ពួកភិក្ខុដែលនៅចាំវស្សាក្នុងទិសទាំងឡាយ (ក្រៅពីនេះទៀត) សុទ្ធតែមានកាយស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់កើតជាកេសល្បឿងស្លេកស្លាំងមានខ្លួនគ្របដោយសរសៃ ។ រីឯពួកភិក្ខុដែលនៅទៀបច្រាំងស្ទឹងវគ្គុមុទា សុទ្ធតែមានសម្បុរល្អមានឥន្ទ្រិយពេញលេញ មានមុខមាត់ស្រស់បស់ សម្បុរស្បែកក៏ថ្លាផុតទាំងអស់គ្នា ។ មានសេចក្ដីថា ការស្មោះរាប់អានជាមួយនឹងអាគន្តុកភិក្ខុ នឹងភិក្ខុដែល

ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធិំ បដិ-
សម្មោទិតុំ ។ អថខោ ភគវា វគ្គុមុទាតីរិយេ ភិក្ខូ
ឯតទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ យាបនីយំ
កច្ចិ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ
វស្សំ វសិត្ថ ន ច បិណ្ឌកេន កិលមិត្ថាតិ ។
ខមនីយំ ភគវា យាបនីយំ ភគវា សមគ្គា ច មយំ
ភគវា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិម្ហា
ន ច បិណ្ឌកេន កិលមិម្ហាតិ ។ ជានន្តាបិ តថាគតា
បុច្ឆន្តិ ជានន្តាបិ ន បុច្ឆន្តិ កាលំ វិទិត្វា បុច្ឆន្តិ



ដើម្បីនឹងរាក់ទាក់ នេះជាទំនៀមរបស់ព្រះពុទ្ធដ៏មានព្រះភាគគ្រប់ព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សួរទៅភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាល្មមអត់ធន់បានទេឬ(១) អ្នកទាំងអស់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេឬ(២) អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះសរ មិនទាស់ទែងគ្នា នៅចាំវស្សាស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមប្រព្រឹត្តទៅបានដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងអស់គ្នាមានសេចក្តីសាមគ្គីស្មោះសររីករាយមិនទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេ ។ (មានសេចក្តីថា) ព្រះតថាគតទាំងឡាយទ្រង់ជ្រាបច្បាស់នូវហេតុហើយត្រាស់សួរក៏មាន ជ្រាបច្បាស់ហើយមិនត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយត្រាស់សួរក៏មាន

---

១ ក្នុងអដ្ឋកថា ពន្យល់ថា ព្រះអង្គត្រាស់សួរដោយសំដៅសេចក្តីដូច្នេះថា យន្តគឺសរីររបស់អ្នកទាំងអស់គ្នា ដែលមានចក្រ ៤ មានទ្វារ ៩ នេះ អ្នកទាំងអស់គ្នាអាចធន់ទ្រាំទ្របាន មិនមានទុក្ខលំបាកពេកទេឬ ។ ២ យន្តគឺសរីរនេះ អ្នកទាំងអស់គ្នាអាចប្រព្រឹត្តទៅបានគ្រប់ពេលទាំងពួងមិនមានអន្តរាយរើសពាល់អ្វីទេឬ ។

កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសញ្ហិតំ តថាគតា បុច្ឆន្តិ នោ អនត្ថសញ្ហិតំ អនត្ថសញ្ហិតេ សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា ភគវន្តោ ភិក្ខូ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាមាតិ ។ អថខោ ភគវា វគ្គុមុទាតីរិយេ ភិក្ខូ ឯតទវោច យថា កថំ បន តុម្ហេ ភិក្ខវេ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិត្ថ ន ច បិណ្ឌកេន កិលមិត្ថាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ កច្ចិ បន វោ ភិក្ខវេ ភូតន្តិ ។ អភូតំ ភគវាតិ ។

(២២៩) វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិសា អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ





ជ្រាបច្បាស់នូវកាលគួរហើយ មិនត្រាស់សួរក៏មាន ព្រះតថាគតទាំងឡាយទ្រង់សួរចំពោះតែអំពើដែលមានប្រយោជន៍ អំពើដែលមិនមានប្រយោជន៍ទ្រង់មិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយទ្រង់ផ្តាច់បង់នូវអំពើដែលមិនមានប្រយោជន៍ដោយអរិយមគ្គអស់ហើយ ។ ព្រះសម្ពុទ្ធជាម្ចាស់ទាំងឡាយដ៏មានជោគ ទ្រង់សួរពួកភិក្ខុដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសំដែងធម៌ ១ ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់ពួកសាវ័ក ១ ។ កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពួកភិក្ខុដែលនៅនៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាបានជាមានសេចក្តីសាមគ្គីស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាត ដោយរបៀបដោយហេតុអ្វី ។ គ្រានោះ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់) ។ ទើបព្រះអង្គត្រាស់សួរថា នែភិក្ខុទាំងឡាយ ហេតុនុះពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលតបវិញថា បពិត្រព្រះដ៏មានព្រះភាគ ហេតុនុះមិនពិតទេ ។

(២២៩) ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងអស់គ្នាធ្វើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើសោះ

អករណីយំ កថំ ហិ នាម តុម្ហេ មោឃបុរិសា ឧទរស្ស ការណា គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសិស្សថ វរំ តុម្ហេហិ មោឃបុរិសា តិណ្ហេន គោវិកន្តនេន(១) កុច្ឆិ បរិកន្តិតោ ន ត្វេវ ឧទរស្ស ការណា គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណោ ភាសិតោ តំ កិស្ស ហេតុ តតោនិទានញ្ហិ មោឃបុរិសា មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ន ត្វេវ តប្បច្ចយា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឥតោនិទានញ្ច ខោ មោឃបុរិសា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។

---

១ ឱ. ម. គោវិកត្តនេន ។



នែមោឃបុរសទាំងឡាយ ម្ដេចក៏ពួកឯងនាំគ្នាហ៊ានពោលគុណឧត្តរិមនុស្សធម្មទៅវិញទៅមកចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ចំអែតផ្ទៃ នែមោឃបុរសទាំងឡាយ បើអ្នកកាត់ផ្ទាយយកកាំបិតយ៉ាងមុត ដែលសំរាប់ពន្លះសាច់គោ មកវះពោះ (របស់ខ្លួន) វិញប្រសើរជាង ឯការពោលគុណឧត្តរិមនុស្សធម្មរបស់គ្នានឹងគ្នាចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ចំអែតផ្ទៃ ដែលពួកឯងនាំគ្នាពោលរួចទៅហើយ (នោះ) ពុំប្រសើរសោះឡើយ ហេតុអ្វីបានជាតថាគតពោលយ៉ាងនេះ ម្នាលមោឃបុរសទាំងឡាយ គឺព្រោះបុគ្គលដែលវះពោះខ្លួនឯងនោះ ជាហេតុបានតែត្រឹមសេចក្តីស្លាប់ខ្លះ បានទុក្ខប្រៀបស្លាប់ប៉ុណ្ណោះ កាលបើលាន់ខ្ទង់អំពីមរណកាលទៅ ក៏មិនទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នរក ព្រោះហេតុដែលវះពោះនោះឡើយ ម្នាលមោឃបុរសទាំងឡាយ ឯចំណែកភិក្ខុដែលពោលគុណឧត្តរិមនុស្សធម្ម ជាហេតុជាទីតាំងនេះ កាលបើក្សិណខ្ទង់អំពីមរណកាលទៅហើយ ទៀតតែទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នរក មិនខានឡើយ ម្នាលមោឃបុរសទាំងឡាយ ការដែលពោលគុណឧត្តរិមនុស្សធម្មនេះ មិនបាននាំមនុស្សដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ឬមនុស្សដែលជ្រះថ្លាហើយឲ្យកាន់តែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់តិះដៀលពួកភិក្ខុទាំងនោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំហើយ ទើបទ្រង់សំដែងធម្មីកថា ត្រាស់ថា ។

[៤៣០] ចត្តារោមេ ភិក្ខវេ មហាចោរា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស មហាចោរស្ស ឯវំ ហោតិ កុទាស្សុ នាមាហំ សតេន វា សហស្សេន វា បរិវុតោ គាមនិគមរាជធានីសុ អាហិណ្ឌិស្សាមិ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បចាបេន្តោតិ ។ សោ អបរេន សមយេន សតេន វា សហស្សេន វា បរិវុតោ គាមនិគមរាជធានីសុ អាហិណ្ឌតិ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បចាបេន្តោ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បាបភិក្ខុនោ ឯវំ ហោតិ កុទាស្សុ នាមាហំ សតេន វា សហស្សេន វា បរិវុតោ គាមនិគមរាជធានីសុ ចារិកំ ចរិស្សាមិ សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ គហដ្ឋានញ្ចេវ បព្វជិតានញ្ច លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ សោ អបរេន សមយេន សតេន វា



[៤៣០] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានភិក្ខុជាមហាចោរ ៤ ពួក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមហាចោរ ៤ ពួកនោះដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់មហាចោរខ្លះដែលមានក្នុងលោកនេះថា បើដល់វេលាណា អញបានបរិវារ ១ រយ ឬ ១ ពាន់ចោមរោមជាគ្នាហើយ នឹងលើកចូលទៅក្នុងស្រុកនិគមរាជធានី ហើយនឹងកាប់សំលាប់ផ្តាច់ជីវិតពួកអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតកំទេចអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតកំទេច ។ លុះដល់សម័យតទៅក្រោយមក មហាចោរនោះបានបរិវារ ១ រយ ឬ ១ ពាន់ ចោមរោមជាគ្នាហើយ ក៏លើកចូលទៅក្នុងស្រុកនិគមរាជធានី កាប់សំលាប់ផ្តាច់ជីវិតអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតកំទេចអ្នកស្រុកទាំងនោះដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតកំទេច យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់ភិក្ខុបាបខ្លះដែលមានក្នុងសាសនានេះ ក៏យ៉ាងនោះដែរ (ត្រិះរិះ) ថា បើដល់កាលណា អញបានបរិវារ ១ រយ ឬ ១ ពាន់ចោមរោមជាគ្នាហើយ នឹងត្រាច់ទៅកាន់ចារិកក្នុងស្រុកនិគមរាជធានី គឺនឹងបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថ ពួកបព្វជិតធ្វើសក្ការៈគោរពរាប់អានបូជាកោតក្រែង ។ លុះដល់សម័យតទៅក្រោយមក

សហស្សេន វា បរិវុតោ គាមនិគមរាជធានីសុ ចារិកំ ចរតិ សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ គហដ្ឋានញ្ចេវ បព្វជិតានញ្ច លាភី ចីវរបិណ្ឌបាត-សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អយំ ភិក្ខវេ បឋមោ មហាចោរោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បាបភិក្ខុ តថាគតប្បវេទិតំ ធម្មវិនយំ បរិយាបុណិត្វា អត្តនោ ទហតិ[១] ។ អយំ ភិក្ខវេ ទុតិយោ មហាចោរោ សន្តោ សំវិជ្ជមានោ លោកស្មឹ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បាបភិក្ខុ សុទ្ធំ ព្រហ្មចារឹ បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តំ អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ ។ អយំ ភិក្ខវេ តតិយោ មហាចោរោ

១ ម. យ. ឧបតិ ។



មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកដែលប្រកបដោយព្យាយាមត្រូវហើយ ទើបនឹងញ៉ាំងព្រះធម៌ឲ្យត្រាស់ដឹងបាន ។ ភិក្ខុនោះក៏មានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិឡើយ ។ គ្រានោះ មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុ មានឧត្តរិមនុស្សធម្មដែរឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រារព្ធហើយ ទើបនឹងញ៉ាំងព្រះធម៌ឲ្យត្រាស់ដឹងបាន ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុ មានឧត្តរិមនុស្សធម្មដែរឬ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រកបត្រូវហើយ ទើបនឹងញ៉ាំងព្រះធម៌ឲ្យត្រាស់ដឹងបាន ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។

តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ ឯតទវោចុំ កច្ចាវុសោ ខមនីយំ កច្ចិ យាបនីយន្តិ ។ នាវុសោ សក្កា យេន វា តេន វា អធិវាសេតុន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ អនុល្លបនាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខូ ឯតទវោចុំ កច្ចាវុសោ ខមនីយំ កច្ចិ យាបនីយន្តិ ។ នាវុសោ សក្កា បុថុជ្ជនេន អធិវាសេតុន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ ឧល្លបនាធិប្បាយោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ បារាជិកស្ស អាបត្តិ ថុល្លច្ចយស្សាតិ ។

(៤៩១) តេន ខោ បន សមយេន អញ្ញតរោ ព្រាហ្មណោ ភិក្ខូ និមន្តេត្វា ឯតទវោច អាយន្តុ ភោន្តោ អរហន្តោតិ ។ តេសំ កុក្កុច្ចំ អហោសិ



សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា ម្នាលអាវុសោ លោកល្មមអត់ធន់បានទេឬ លោកល្មមប្រព្រឹត្តទៅបានទេឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលក្រៅការមិនអាចនឹងអត់ធន់បានឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងនិយាយអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា ម្នាលអាវុសោ លោកល្មមអត់ធន់បានទេឬ លោកល្មមប្រព្រឹត្តទៅបានទេឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលជាបុថុជ្ជនមិនអាចនឹងអត់ធន់បានឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកនឹកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនិយាយអួត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រូវអាបត្តិថុល្លច្ច័យ ។

[៤៩១] សម័យនោះ មានព្រាហ្មណ៍ម្នាក់បាននិមន្តពួកភិក្ខុ ហើយបាននិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តចូលមក ។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យថា

មយញ្ហិ ន អរហន្តោ(១) អយញ្ច ព្រាហ្មណោ អម្ហេ អរហន្តវាទេន សមុទាចរតិ កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្ពន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ បសាទភញ្ញេតិ ។ តេន ខោ បន សមយេន អញ្ញតរោ ព្រាហ្មណោ ភិក្ខូ និមន្តេត្វា ឯតទវោច និសីទន្តុ ភោន្តោ អរហន្តោតិ ។ បេ ។ ភុញ្ជន្តុ ភោន្តោ អរហន្តោតិ ។ បេ ។ តប្បេន្តុ ភោន្តោ អរហន្តោតិ ។ បេ ។ គច្ឆន្តុ ភោន្តោ អរហន្តោតិ ។ តេសំ កុក្កុច្ចំ អហោសិ មយញ្ហិ ន អរហន្តោ អយញ្ច ព្រាហ្មណោ អម្ហេ អរហន្តវាទេន សមុទាចរតិ កថំ នុ ខោ អម្ហេហិ បដិបជ្ជិតព្ពន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនាបត្តិ ភិក្ខវេ បសាទភញ្ញេតិ ។

(២៩២) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញតរស្ស ភិក្ខុនោ ឧត្តរិមនុស្សធម្មំ ឧល្លបតិ ។ សោបិ ឯវមាហ មយ្ហំបិ អាវុសោ អាសវា បហីនាតិ ។

១ ម. ឆ. អនរហន្តោ ។



យើងទាំងឡាយ មិនមែនជាព្រះអរហន្តទេ ប៉ុន្តែ ព្រាហ្មណ៍នេះនិយាយលើកយើងទាំងឡាយដោយពាក្យថា ព្រះអរហន្ត យើងរាល់គ្នាត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយព្រាហ្មណ៍ពោលដោយសេចក្តីជ្រះថ្លា មិនត្រូវអាបត្តិទេ ។ សម័យនោះ មានព្រាហ្មណ៍ម្នាក់និមន្តភិក្ខុទាំងឡាយហើយបានពោលពាក្យថា បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តគង់ ។ បេ ។ បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តឆាន់ ។ បេ ។ បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តឆាន់ឲ្យឆ្អែត ។ បេ ។ បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តទៅចុះ ។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យថា យើងទាំងឡាយមិនមែនជាអរហន្តទេ ក៏ព្រាហ្មណ៍នេះនិយាយលើកយើងដោយពាក្យថា ព្រះអរហន្ត យើងត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ពោលដោយសេចក្តីជ្រះថ្លា មិនត្រូវអាបត្តិទេ ។

(២៩២) សម័យនោះ មានភិក្ខុមួយរូបពោលឧត្តរិមនុស្សធម្មចំពោះភិក្ខុមួយរូប ។ ភិក្ខុដែលគេពោលនោះបាននិយាយយ៉ាងនេះថា

តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញតរស្ស ភិក្ខុនោ ឧត្តរិមនុស្សធម្មំ ឧល្លបតិ ។ សោបិ ឯវមាហ មយ្ហំបិ អាវុសោ ឯតេ ធម្មា សំវិជ្ជន្តីតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អញ្ញតរស្ស ភិក្ខុនោ ឧត្តរិមនុស្សធម្មំ ឧល្លបតិ ។ សោបិ ឯវមាហ អហំបិ អាវុសោ ឯតេសុ ធម្មេសុ សន្ទិស្សាមីតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

[២៩៣] តេន ខោ បន សមយេន អញ្ញតរំ ភិក្ខុំ ញាតកា ឯតទវោចុំ ឯហិ ភន្តេ អគារំ អជ្ឈាវសាតិ ។ អភព្វោ ខោ អាវុសោ មាទិសោ អគារំ អជ្ឈាវសិតុន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។



ម្នាលអាវុសោ អាសវធម៌ទាំងឡាយ ខ្ញុំបានលះបង់អស់ហើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ គ្រានោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម៌ចំពោះភិក្ខុមួយរូប ។ ភិក្ខុដែលគេពោលអួតនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ គឺឧត្តរិមនុស្សធម្មទាំងនេះ ខ្ញុំក៏បានមានសព្វគ្រប់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម៌ចំពោះភិក្ខុមួយរូប ។ ភិក្ខុដែលគេពោលអួតនោះបានពោលយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំឃើញច្បាស់នូវខ្លួនឯង ក្នុងធម៌ទាំងនោះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(២៩៣) សម័យនោះ ជនទាំងឡាយជាញាតិបាននិមន្តភិក្ខុមួយរូបថា បពិត្រលោកដ៏ចំរើន សូមលោកនិមន្តមកនៅគ្រប់គ្រងផ្ទះ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលដូចជាអាត្មា មិនគួរដើម្បីនឹងនៅគ្រប់គ្រងផ្ទះទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ទើប

ភគវតោ ឯតមត្ថំ អារោចេសិ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ អនុល្លបនាធិប្បាយោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ អនុល្លបនាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរំ ភិក្ខុំ ញាតកា ឯតទវោចុំ ឯហិ ភន្តេ កាមេ បរិភុញ្ជាហីតិ ។ អាវដា មេ អាវុសោ កាមាតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ អនុល្លបនាធិប្បាយោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ អនុល្លបនាធិប្បាយស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរំ ភិក្ខុំ ញាតកា ឯតទវោចុំ អភិរមសិ ភន្តេតិ ។ អភិរតោ អហំ អាវុសោ បរមាយ អភិរតិយាតិ ។ តស្ស កុក្កុច្ចំ អហោសិ យេ ខោ



ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកដ៏មានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានបំណងនឹងពោលអួតទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងពោលអួតមិនត្រូវអាបត្តិទេ ។ សម័យនោះ ជនទាំងឡាយជាញាតិបាននិមន្តភិក្ខុមួយរូបថា បពិត្រលោកដ៏ចំរើន សូមលោកនិមន្តមកបរិភោគកាមទាំងឡាយចុះ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ឯកាមទាំងឡាយ អាត្មាបានកំចាត់បានហើយ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ ទើបក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកដ៏មានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួតទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ ជនទាំងឡាយជាញាតិបានសួរភិក្ខុមួយរូបថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ត្រេកសប្បាយដែរឬទេ ។ ភិក្ខុនោះនិយាយថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អាត្មាត្រេកសប្បាយដែរ (តែត្រេកសប្បាយ) ដោយសេចក្ដីសប្បាយដ៏ឧត្តម ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា ភិក្ខុទាំងឡាយណា

យេ ភគវតោ សាវកា តេ ឃរំ ភុញ្ជន្តុ អហញ្ចម្ហិ ខោ ភគវតោ សាវកោ កច្ចិ នុ ខោ អហំ បារាជិកំ អាបត្តិំ អាបន្នោតិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ កឹចិត្តោ ត្វំ ភិក្ខូតិ ។ អនុល្លបនាធិប្បាយោ អហំ ភគវាតិ ។ អនាបត្តិ ភិក្ខុ អនុល្លបនាធិប្បាយស្សាតិ ។

(២៩៦) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កតិកំ កត្វា អញ្ញតរស្មឹ អាវាសេ វស្សំ ឧបគច្ឆឹសុ យោ ឥមម្ហា អាវាសា បឋមំ បក្កមិស្សតិ តំ មយំ អរហាតិ ជានិស្សាមាតិ ។ អញ្ញតរោ ភិក្ខុ មំ អរហាតិ ជានន្តូតិ តម្ហា អាវាសា បឋមំ បក្កាមិ ។ តស្ស កុក្កុច្ចំ អហោសិ កច្ចិ នុ ខោ អហំ បារាជិកំ អាបត្តិំ អាបន្នោតិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អាបត្តិំ ត្វំ ភិក្ខុ អាបន្នោ បារាជិកន្តិ ។

(២៩៧) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ច លក្ខណោ អាយស្មា ច មហាមោគ្គល្លានោ គិជ្ឈកូដេ បព្វតេ វិហរន្តិ ។



មួយដែលជាសាវករបស់ព្រះដ៏មានព្រះភាគ ភិក្ខុទាំងនោះនឹងបរិភោគភក្សាហារនៅផ្ទះនេះបាន ក៏ខ្លួនអញមែនជាសាវករបស់ព្រះដ៏មានព្រះភាគទេ អញត្រូវអាបត្តិបារាជិកហើយឬនៅ ។ ភិក្ខុនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក៏ទូលតបថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានបំណងនឹងពោលអួតទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។

(២៩៦) សម័យនោះ មានភិក្ខុច្រើនរូបនៅចាំវស្សាក្នុងអាវាសមួយ បានធ្វើកតិកា (ណាត់គ្នា) ថា ភិក្ខុអង្គណានឹងចេញចាកអាវាសនេះមុន នោះយើងទាំងឡាយនឹងដឹងថាភិក្ខុអង្គនោះជាព្រះអរហន្ត ។ មានភិក្ខុមួយរូបចេញចាកអាវាសនោះទៅមុនគេ ដោយគិតថា ភិក្ខុទាំងនោះចូរដឹងនូវអញថា ជាព្រះអរហន្តចុះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិបារាជិកហើយឬនៅ ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

(២៩៧) គ្រានោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ។ សម័យនោះ ព្រះលក្ខណត្ថេរនឹងព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ គង់នៅលើភ្នំគិជ្ឈកូដ ។ គ្រានោះឯង ព្រះមហា-

អថខោ អាយស្មា មហាមោគ្គល្លានោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេនាយស្មា លក្ខណោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ លក្ខណំ ឯតទវោច អាយាមាវុសោ លក្ខណ រាជគហំ បិណ្ឌាយ បវិសិស្សាមាតិ ។ ឯវមាវុសោតិ ខោ អាយស្មា លក្ខណោ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អញ្ញតរស្មឹ បទេសេ សិតំ បាត្វាកាសិ ។ អថខោ អាយស្មា លក្ខណោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច កោ នុ ខោ អាវុសោ មហាមោគ្គល្លាន ហេតុ កោ បច្ចយោ សិតស្ស បាតុកម្មាយាតិ ។ អកាលោ ខោ អាវុសោ លក្ខណ ឯតស្ស បញ្ហស្ស វេយ្យាករណាយ[1] ភគវតោ មំ សន្តិកេ ឯតំ បញ្ហំ បុច្ឆាតិ ។ អថខោ អាយស្មា ច លក្ខណោ អាយស្មា ច មហាមោគ្គល្លានោ រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា

[1] ឱ. ម. ពោត្ថកេសុ អយំ បាឋោ ន ទិស្សតិ ។



មោគ្គល្លានត្ថេរដ៏មានអាយុ ស្លៀកស្បង់ទ្រទ្រង់បាត្រនិងចីវរ ចូលសំដៅទៅកន្លែងដែលព្រះលក្ខណត្ថេរគង់ ក្នុងវេលាបុព្វណ្ហសម័យ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះលក្ខណត្ថេរដ៏មានអាយុថា ម្នាលអាវុសោលក្ខណៈ មកយើងនឹងចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ ព្រះលក្ខណត្ថេរដ៏មានអាយុ ក៏ទទួលពាក្យព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុថា ករុណា អាវុសោ ។ គ្រាដែលព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ កំពុងតែចុះអំពីភ្នំគិជ្ឈកូដ (ដល់មក) ត្រង់កន្លែងមួយក៏បានធ្វើនូវញញឹមឲ្យប្រាកដ ។ លំដាប់នោះ ព្រះលក្ខណត្ថេរដ៏មានអាយុ ក៏សួរព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុថា ម្នាលអាវុសោមហាមោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យលោកធ្វើនូវញញឹមឲ្យប្រាកដ (នេះ) ។ ព្រះមហាមោគ្គល្លានត្ថេរឆ្លើយតបថា ម្នាលអាវុសោលក្ខណៈ កាលនេះមិនមែនជាកាលគួរនឹងព្យាករប្រស្នានេះទេ ចូរលោកសួរប្រស្នានេះនឹងខ្ញុំក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ ។ លំដាប់នោះ ព្រះលក្ខណត្ថេរដ៏មានអាយុ នឹងព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ ក៏ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយត្រឡប់អំពីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះ

កុករត្តំ អតិក្កមេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា លក្ខណោ អាយស្មន្តំ មហា-មោគ្គល្លានំ ឯតទវោច ឥធាយស្មា មហាមោគ្គល្លានោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អញ្ញតរស្មឹ បទេសេ សិតំ បាត្វាកាសិ កោ នុ ខោ អាវុសោ មោគ្គល្លាន ហេតុ កោ បច្ចយោ សិតស្ស បាតុកម្មាយាតិ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ អដ្ឋិកសង្ខលិកំ វេហាសំ គច្ឆន្តឹ តមេនំ គិជ្ឈាបិ កាកោលាបិ(១) កុលលាបិ អនុបតិត្វា អនុបតិត្វា ផាសុឡន្តរិកាហិ វិតុទេន្តិ វិតច្ឆេន្តិ(២) វិរាជេន្តិ(៣) សា សុទំ(៤) អដ្ដស្សរំ ករោតិ តស្ស មយ្ហំ អាវុសោ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯវរូបោបិ នាម សត្តោ ភវិស្សតិ ឯវរូបោបិ នាម យក្ខោ ភវិស្សតិ ឯវរូបោបិ នាម បេតោ ភវិស្សតិ(៥) ឯវរូបោបិ នាម អត្តភាវប្បដិ-លាភោ ភវិស្សតីតិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ

១ ម. ច. កាកោលាបិ ។ ២-៣ ឱ. ម. វិតច្ឆេន្តិ វិរាជេន្តិ ឥតិ ទិស្សតិ ។ ៤ ម. សោ សុទំ ។ ឆដ្ឋសង្គាយនំ បន សា សុទំ អាគតំ ។ ឥទំ ហិ ន្តិ សា សុទំ អដ្ឋិសង្ខលិកា អដ្ដស្សរំ ករោតីតិ ឯត្ថ សុទន្តិ និបាតោ ។ សា អដ្ឋិសង្ខលិកា អដ្ដស្សរំ អាតុរស្សរំ ករោតីតិ អត្ថោ ។ ៥ ឯវរូបោបិ នាម បេតោ ភវិស្សតីតិ ម. ច. បោត្ថកេសុ ន ទិស្សតិ ។



ភាគនុះហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះលក្ខណៈដ៏មានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះមហាមោគ្គល្លានដ៏មានអាយុថា ក្នុងថ្ងៃនេះ មហាមោគ្គល្លានដ៏មានអាយុ កាលដែលចុះអំពីភ្នំគិជ្ឈកូដ បានធ្វើនូវញញឹមឲ្យប្រាកដក្នុងទីកន្លែងមួយ ម្នាលអាវុសោមោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវញញឹមឲ្យប្រាកដនោះ ។ ព្រះមហាមោគ្គល្លានឆ្លើយតបថា ម្នាលអាវុសោ ក្នុងថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញអដ្ឋិសង្ខលិកប្រេត(១) កំពុងតែអណ្តែតឯអាកាស ពពួកត្មាត ពពួកក្អែក(២) ពពួកខ្លែង(៣) ដេញតាមចោមចាបចឹកចោះហែកហួរចឹកអដ្ឋិសង្ខលិកប្រេតនោះតាមចន្លោះនៃឆ្អឹងជំនីរទាំងឡាយ អដ្ឋិសង្ខលិកប្រេតនោះឯនោះស្រែកថ្ងូរ ម្នាលអាវុសោ ទើបខ្ញុំបានបរិវិតក្កថា អើហ្ន៎ (នេះបាល់កញ) ជាអស្ចារ្យ អើហ្ន៎ មិនធ្លាប់កើតមានសោះឡើយ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្លះទេ យក្សបែបនេះនឹងត្រឡប់ទៅជាមានខ្លះ ប្រេតបែបនេះនឹងត្រឡប់ទៅជាមានខ្លះ កិរិយាត្រ-ឡប់បានអត្តភាពបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរតើ ។ ភិក្ខុទាំងឡាយ

១ ប្រេតដែលគ្មានសាច់ឈាមទៀយ មានតែឆ្អឹង ។ ២-៣ បាលីពីទំព័រមើលបន្ថែមទៀត ទាំងក្នុងអដ្ឋកថាបច្ចុប្បន្នលោកជាដើម ឃើញថា គន្ធ ប្រែថា ខ្លែង កុលល ប្រែថា អាកត ឬ ប្រែងស់ ។ ត្រង់ កាកោលាបិ ក្នុងទីនេះ ម. ជា កាកាបិ (ក្អែក) ។ សត្វទាំង ៣ ពួកនេះ មិនមែនសុទ្ធតែស្គាល់តាំងពីពួកអ្នកដែលបានឃើញរបស់ព្រេងនោះឯង ។

វិបាចេន្តិ ឧត្តរិមនុស្សធម្មំ អាយស្មា មហាមោគ្គ-ល្លានោ ឧល្លបតីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ចក្ខុភូតា វត ភិក្ខវេ សាវកា វិហរន្តិ ញាណភូតា វត ភិក្ខវេ សាវកា វិហរន្តិ យត្រ ហិ នាម សាវកោ ឯវរូបំ ញស្សតិ វា ទក្ខតិ វា សក្ខិំ វា ករិស្សតិ ។ បុព្វេវ មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ អហោសិ អបិចាហំ ន ព្យាកាសិំ អហញ្ចេតំ ព្យាករេយ្យំ បរេ ច មេ ន សទ្ទហេយ្យុំ យេ មេ ន សទ្ទហេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយ ឯសោ ភិក្ខវេ សត្តោ ឥមស្មិំ-យេវ រាជគហេ គោឃាតកោ អហោសិ សោ តស្ស កម្មស្ស វិបាកេន ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ ពហូនិ វស្ស-សតសហស្សានិ និរយេ បច្ចិត្វា តស្សេវ កម្មស្ស-វិបាកាវសេសេន ឯវរូបំ អត្តភាវប្បដិលាភំ បដិសំវេ-ទេតិ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ



ទើបពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងឡាយមានចក្ខុកើតកន់ហើយ ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងឡាយមានញាណកើតកន់ហើយ ព្រោះហេតុថា សាវ័កនឹងដឹងក្តីនឹងឃើញប្រេតបែបនេះ ឬថានឹងធ្វើប្រេតបែបនេះឲ្យជាក់ច្បាស់ (របស់តថាគត) ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតបានឃើញពីក្នុងកាលមុនរួចមកហើយ ប៉ុន្តែតថាគតមិនបានសំដែង ព្រោះថា បើតថាគតសំដែងទៅ ពួកជនដទៃមិនជឿ (ពាក្យ) តថាគត ពួកជនណាដែលមិនជឿតថាគត សេចក្តីដែលមិនជឿនោះនឹងនាំឲ្យឥតប្រយោជន៍ នាំឲ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ពួកជនទាំងនោះ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកសំលាប់គោ ក្នុងក្រុងរាជគ្រឹះនេះឯង ដោយកម្មវិបាកនោះ អ្នកសំលាប់គោនោះទៅឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយពាន់ សែនឆ្នាំដ៏ច្រើន ដោយសេសសល់នៃកម្មវិបាកនោះ ក៏ត្រូវបានមកទទួលផលគឺត្រូវបានអត្តភាពបែបនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិ

ភិក្ខវេ មោគ្គល្លានស្ស សក្ខិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ មំសបេសឹ វេហាសំ គច្ឆន្តឹ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ(១) វិតច្ឆេន្តិ វិរាជេន្តិ(២) សា សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិំយេវ រាជគហេ គោឃាតកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ មំសបិណ្ឌំ វេហាសំ គច្ឆន្តំ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិំយេវ រាជគហេ សាកុណិកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ និច្ឆវឹ បុរិសំ វេហាសំ គច្ឆន្តំ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ

១ ម. ម. ហេត្ឋាពេសុ អយំ បាឋោ នត្ថិ ។ ២ ឱ. ម. វិភជេន្តិ ។



។ ១ ។ បេ ។ ម្នាលអាវុសោលក្ខណៈ ក្នុងទីនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញមំសបេសីប្រែត(១) កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ក្អែក រអាត ដេញតាមចោមរោមចឹកបោះដោតផ្ទួនមំសបេសីប្រែតនោះឯង មំសបេសីប្រែតនោះបន្លឺសំឡេងស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកសម្លាប់គោ ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ក្នុងទីនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញមំសបិណ្ឌប្រែត(២) កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ក្អែក រអាត ដេញតាមចោមរោមចឹកបោះដោតផ្ទួនមំសបិណ្ឌប្រែតនោះឯង មំសបិណ្ឌប្រែតនោះបន្លឺសំឡេងស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាព្រានសត្វស្លាប ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ក្នុងទីនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជានិច្ឆវិប្រែត(៣) កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ក្អែក រអាត ដេញតាមចោមរោមចឹកបោះដោតផ្ទួននិច្ឆវិប្រែតនោះឯង និច្ឆវិប្រែតនោះបន្លឺសំឡេងស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុ

១ ប្រែតមានរាងកាយដូចជាចំណិតសាច់ ។ ២ ប្រែតមានរាងកាយដូចជាដុំសាច់ ។
៣ ប្រែតមានរាងកាយគ្មានស្បែក ។

សត្តោ ឥមស្មឹយេវ រាជគហេ ឱរព្ភិកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ អសិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តេ អសី ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កាយេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មឹយេវ រាជគហេ សូករិកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សត្តិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តា សត្តិយោ ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កាយេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មឹយេវ រាជគហេ មាគវិកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ ឧសុលោមំ បុរិសំ វេហាសំ



ទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកសម្លាប់សត្វចៀម ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាអសិលោមប្រេត[1] កំពុងតែអណ្តែតទៅឯអាកាស ដាវទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើង ៗ ហើយធ្លាក់មកដោតជាប់ក្នុងកាយនៃប្រេតនោះឯង អសិលោម-ប្រេតនោះចេះតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតជ្រូកចិញ្ចឹមជីវិត ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាសត្តិលោមប្រេត[2] កំពុងតែអណ្តែតទៅឯអាកាស លំពែងទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើង ៗ ហើយធ្លាក់មកដោតជាប់ក្នុងកាយនៃប្រេតនោះឯង សត្តិលោមប្រេតនោះចេះតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាព្រានម្រឹគ ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាឧសុលោម-

---

១ ប្រេតមានដាវកើតតាមចំណែកនៃកាយទូទៅ ។ ២ ប្រេតមានលំពែងកើតតាមចំណែកនៃកាយទូទៅ ។

គច្ឆន្តំ តស្ស តេ ឧសូ ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កាយេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មឹយេវ រាជគហេ ការណិកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សូចិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តា សូចិយោ ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កាយេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មឹយេវ រាជគហេ សារថិ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សូចិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តា សូចិយោ សីសេ បវិសិត្វា មុខតោ និក្ខមន្តិ មុខេ បវិសិត្វា ឧរតោ និក្ខមន្តិ



ប្រេត[១] កំពុងតែអណ្តែតទៅឯអាកាស ព្រួញទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើង ៗ ហើយធ្លាក់មកដោតជាប់ក្នុងកាយនៃប្រេតនោះឯង ។ សូចិលោមប្រេតនោះរមែងតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាពេជ្ឈឃាត[២] ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាសូចិលោមប្រេត[៣] កំពុងតែអណ្តែតទៅឯអាកាស ម្ជុលទាំងឡាយរបស់ប្រេតនោះ អណ្តែតខ្ពស់ឡើង ៗ ហើយធ្លាក់មកដោតជាប់ក្នុងកាយរបស់ប្រេតនោះឯង សូចិលោមប្រេតនោះរមែងតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជានាយសារថី ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាសូចិលោមប្រេត[៤] កំពុងតែអណ្តែតទៅឯអាកាស ដែកស្រួចទាំងឡាយរបស់ប្រេតនោះដោតចូលទៅតាមក្បាល ហើយធ្លាយចេញមកតាមមាត់ ដោតចូលទៅតាមមាត់ហើយធ្លាយចេញមកតាមទ្រូង ដោតចូលទៅតាម

---

១ ប្រេតមានព្រួញដោតជាប់នឹងកាយខ្លួនជានិច្ច ។ ២ ជាពេជ្ឈឃាតបាញ់មនុស្សដោយព្រួញ ។ ៣ ប្រេតមានរោមដូចជាម្ជុលដោតជាប់នឹងកាយខ្លួនជានិច្ច ។ ៤ ប្រេតមានដែកស្រួចធ្លាក់ធ្លុះចុះឡើងក្នុងកាយខ្លួនជានិច្ច ។

ឧរេ បវិសិត្វា ឧទរតោ និក្ខមន្តិ ឧទរេ បវិសិត្វា ឩរូហិ និក្ខមន្តិ ឩរូសុ បវិសិត្វា ជង្ឃាហិ និក្ខមន្តិ ជង្ឃាសុ បវិសិត្វា បាទេហិ និក្ខមន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ សូចកោ(១) អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ កុម្ភណ្ឌំ បុរិសំ វេហាសំ គច្ឆន្តំ សោ(២) គច្ឆន្តោបិ តេវ អណ្ឌេ ខន្ធេ អារោបេត្វា គច្ឆតិ និសីទន្តោបិ តេស្វេវ អណ្ឌេសុ និសីទតិ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ គាមកូដោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ បុរិសំ គូថកូបេ សសីសកំ និមុគ្គំ ។ បេ ។

១ ម. ឧ. សូចកោ ។ ២ ម. ស ។



ទ្រូង ហើយធ្លាយចេញមកតាមពោះ ដោតចូលទៅតាមពោះ ហើយធ្លាយចេញមកតាមភ្លៅ (ទាំងពីរ) ដោតចូលទៅតាមភ្លៅ (ទាំងពីរ) ហើយធ្លាយចេញមកតាមស្មង (ទាំងពីរ) ដោតចូលទៅតាមស្មង (ទាំងពីរ) ហើយធ្លាយចេញមកតាមជើង (ទាំងពីរ) សូចំណោម ប្រុសនោះចេះតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកញុះញង់គេ ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាកុម្ភណ្ឌប្រេត(១) កំពុងតែអណ្តែតទៅឯអាកាស ប្រេតនោះកាលបើដើរ លុះតែលើកអណ្ឌៈទាំងនោះលើ ទើបដើរទៅបាន កាលបើអង្គុយ ក៏ចេះតែអង្គុយសង្កត់លើអណ្ឌៈទាំងនោះឯង ត្មាត ក្អែក ខ្លែង រអាក ដេញតាមចោមចាបចឹកចោះឆ្កៀរ កុម្ភណ្ឌប្រេតនោះនៅតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាមេស្រុកអ្នកវិនិច្ឆ័យក្តី ដែលកាត់ស្រេចជាយក់ក៏វៀច ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលលិចចុះទាំងក្បាលទៅក្នុងរណ្តៅលាមក(២) ។ បេ ។

១ ប្រែថាមានអណ្ឌៈ (ពងស្វាស) ប៉ុនក្អមឃ្លោកធំ ។ ២ ហៅក្តុចលាមកក៏ប្រែ ។

ឯសោ ភិក្ខវេ សត្តោ ឥមស្មិំយេវ រាជគហេ បរទារិកោ(១) អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ បុរិសំ គូថកូបេ សសីសកំ និមុគ្គំ ឧភោហិ ហត្ថេហិ គូថំ ខាទន្តំ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិំយេវ រាជគហេ ទុដ្ឋព្រាហ្មណោ អហោសិ សោ កស្សបស្ស សម្មាសម្ពុទ្ធស្ស បាវចនេ ភិក្ខុសង្ឃំ ភត្តេន និមន្តេត្វា ទោណិយោ គូថស្ស បូរាបេត្វា កាលំ អារោចាបេត្វា ឯតទវោច អតោ(២) ភោន្តោ យាវទត្ថំ ភុញ្ជន្តុ ចេវ ហរន្តុ ចាតិ ។ សោ តស្ស កម្មស្ស វិបាកេន ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ ពហូនិ វស្សសតសហស្សានិ និរយេ បច្ចិត្វា តស្សេវ កម្មស្ស វិបាកាវសេសេន ឯវរូបំ អត្តភាវប្បដិលាភំ បដិសំវេទេតិ ។ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ ភិក្ខវេ មោគ្គល្លានស្សាតិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ

១ ម. បារទារិកោ ។ ២ ម. ឥ. ឥតោ ។



ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកល្មើសភរិយាគេ ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលលិចចុះទាំងក្បាលទៅក្នុងរណ្ដៅលាមក(១) កំពុងតែ (ចាប់) លាមកដោយដៃទាំងពីរស៊ី ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាព្រាហ្មណ៍កំណាចក្នុងក្រុងរាជគ្រឹះនេះឯង ព្រាហ្មណ៍នោះកាលក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប បាននិមន្តភិក្ខុសង្ឃដោយ (ពាក្យថានិមន្តឆាន់) ភត្តាហារ ក៏ដាក់លាមកពេញក្នុងស្នូកស្រូវហើយប្រើគេឲ្យប្រាប់ភត្តកាលថា(២) បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកម្ចាស់និមន្តឆាន់ (ចង្ហាន់) តាមត្រូវការក្នុងទីនេះផង សូមនិមន្តយក (ចង្ហាន់) អំពីទីនេះទៅផង ដោយកម្មវិបាកនោះ ព្រាហ្មណ៍កំណាចនោះក៏ឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយ ពាន់ សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះឯង ក៏បានមកសោយនូវផលកម្មដែលត្រូវជួបបាននូវអត្តភាពបែបនេះ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លាននិយាយនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។ បេ ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះ

១ លាមកដ៏ច្រើន ។ ២ ពេលដែលបាយចម្អិនឆ្អិនស្រេចហើយ គួរនិមន្តឆាន់ ។

បិដ្ឋឹ សត្តំ វេហាសំ គច្ឆន្តំ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សាស្សុទំ(១) អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិំយេវ រាជគហេ គោឃាតកោ អហោសិ ។ បេ ។ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ ភិក្ខវេ មោគ្គល្លានស្សាតិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សត្តំ ឧត្តត្ថំ មត្តុលឹ វេហាសំ គច្ឆន្តំ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សាស្សុទំ(២) អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិំយេវ រាជគហេ សាកុណិកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ ឧប្បក្កំ ទុក្កលិនឹ ទុក្ករណឹ វេហាសំ គច្ឆន្តឹ សាស្សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ

១-២ ម. សា សុទំ ។



ចុះពីភ្នំគិជ្ឈកូដ បានឃើញសត្វដែលកើតជាឆ្អឹងប្រេត(១) កំពុងតែអណ្ដែតទៅឯអាកាស ពពួកត្មាត ខ្លែង ក្អែក ដេញតាមចោមចាប់ចឹកចោះជញ្ជួនឆ្អឹងប្រេតនោះឯង ឆ្អឹងប្រេតនោះ ចេះតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាសត្វប្រព្រឹត្តគោឃាតកម្ម ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលត្រូវតាមពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។ បេ ។ ម្នាលអាវុសោលគុណៈ ថ្ងៃនេះ ខ្ញុំកាលដែលកំពុងចុះអំពីភ្នំគិជ្ឈកូដ បានឃើញសត្វដែលកើតជាមត្តុលីប្រេត(២) មានក្លិនស្អុយ កំពុងតែអណ្ដែតទៅឯអាកាស ពពួកត្មាត ខ្លែង ក្អែក ដេញតាមចោមចាប់ចឹកចោះជញ្ជួនមត្តុលីប្រេតនោះឯង មត្តុលីប្រេតនោះចេះតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាសត្វមេមកក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោលគុណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញសត្វដែលកើតជានិច្ឆវីប្រេត(៣) គេរបកស្បែកចេញអស់ មានសរសៃក្រហមស្រាក់ស្រោចពេញខ្លួន (ក្អាមខ្លួនសាច់) កំពុងតែអណ្ដែតទៅឯអាកាស និច្ឆវីប្រេតនោះចេះតែស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុ

១ ប្រេតមានរាងកាយនៅសល់តែស្បែក ។ ២ ប្រេតមានរាងកាយជាគ្រាំគ្រាខ្ទើចខ្ទើម ។ ៣ ប្រេតមានរាងកាយស្រោចទៅដោយលោហិត ។

ការល័ន្តស្ស ភញ្ញា អត្តមហោសិ អហោសិ(១) សក វស្សូបគតា សបត្តិ អត្តរាកជាហោន ទុក្ខំ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ អសីសកពន្ធំ វេហាសំ គច្ឆន្តំ តស្ស ឧរេ អក្ខីនិ ចេវ ហោន្តិ មុខញ្ច តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ ហារិកោ(២) នាម ចោរឃាតកោ អហោសិ ។ បេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ ភិក្ខុំ វេហាសំ គច្ឆន្តំ តស្ស សង្ឃាដិបិ អាទិត្តា សម្បជ្ជលិតា សជោតិភូតា បត្តោបិ អាទិត្តោ សម្បជ្ជលិតោ សជោតិភូតោ កាយពន្ធនំបិ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ កាយោបិ អាទិត្តោ សម្បជ្ជលិតោ សជោតិភូតោ សោ សុទំ អដ្ដស្សរំ ករោតិ ។ បេ ។ ឯសោ ភិក្ខវេ ភិក្ខុ កស្សបស្ស សម្មាសម្ពុទ្ធស្ស បាវចនេ បាបភិក្ខុ អហោសិ ។ បេ ។

១ ម. [illegible] នត្ថិ ។ ២ ម. ហារិកោ ។



ទាំងឡាយ ស្រីនុះ (កាលពីដើម) ជាអ្នកមហាសិទ្ធិស្ដេចក្នុងនីវ៉ែនអាល័ក្ខ ជាស្រីអាចពិត្តបុស្ស បានចាក់ឆ្អឹងមួយអម្បែងលើស្រីជាសត្រូវ ។ បេ ។ ម្នាលអាវុសោ ក្នុងណះ ខ្ញុំ ចុះអំពីភ្នំគិជ្ឈកូដ បានឃើញអសីសកពន្ធប្រេត(១) កំពុងតែអណ្តែតទៅឯអាកាស ទ្រូងនោះមានភ្នែកនិងមុខនៅត្រង់ទ្រូង ពពួកត្មាត ក្អែក ខ្លែង រអែង ដេញតាមចោមរោមចឹកចោះ ហែកនូវអសីសកពន្ធប្រេតនោះឯង ប្រេតនោះស្រែកខ្លាំងស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុះ (កាលពីដើម) ជាអ្នកពិឃាតចោរ ឈ្មោះហារិក ក្នុងក្រុងរាជគ្រឹះនេះឯង ។ បេ ។ ម្នាលអាវុសោ ក្នុងណះ ខ្ញុំ ចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុ(២) កំពុងតែអណ្តែតទៅឯអាកាស សង្ឃាដិរបស់ភិក្ខុនោះក្តៅ មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក៏ក្តៅ មានភ្លើងឆេះសន្ធោសន្ធៅ វត្ថុចងចង្កេះក៏ក្តៅ មានភ្លើងឆេះសន្ធោសន្ធៅ កាយរបស់ភិក្ខុនោះក៏ក្តៅ មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនោះស្រែកថ្ងូរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុះ ជាភិក្ខុបាបក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ។ បេ ។

• ប្រេតនេះគ្មានក្បាល [illegible] ១ ២ [illegible] ។

ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ ភិក្ខុនឹ ។ បេ ។ អទ្ទសំ សិក្ខមានំ អទ្ទសំ សាមណេរំ អទ្ទសំ សាមណេរឹ វេហាសំ គច្ឆន្តឹ តស្សា សង្ឃាដិបិ អាទិត្តា សម្បជ្ជលិតា សញ្ជោតិភូតា(១) បត្តោបិ អាទិត្តោ សម្បជ្ជលិតោ សញ្ជោតិភូតោ(២) កាយពន្ធនំបិ អាទិត្តំ សម្បជ្ជលិតំ សញ្ជោតិភូតំ(៣) កាយោបិ អាទិត្តោ សម្បជ្ជលិតោ សញ្ជោតិភូតោ សា សុទំ អដ្ដស្សរំ ករោតិ តស្ស មយ្ហំ អាវុសោ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯវរូបោបិ នាម សត្តោ ភវិស្សតិ ឯវរូបោបិ នាម យក្ខោ ភវិស្សតិ ឯវរូបោបិ នាម អត្តភាវប្បដិលាភោ ភវិស្សតីតិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ឧត្តរិមនុស្សធម្មំ អាយស្មា មហាមោគ្គល្លានោ ឧល្លបតីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ចក្ខុភូតា វត ភិក្ខវេ សាវកា

១.២.៣ ឧ.ម. សញ្ជោតិភូតា សញ្ជោតិភូតោ សញ្ជោតិភូតំ សីហឡ តំ ចក្ខុបិ សជោតិភូតា សជោតិភូតោ សជោតិភូតំ ទិស្សន្តិ ។



ម្នាលអាវុសោលក្ខណៈ ខ្ញុំនេះ កាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុនី(១) ។ បេ ។ បានឃើញសិក្ខមានា(២) បានឃើញសាមណេរ(៣) បានឃើញសាមណេរី(៤) កំពុងតែអណ្តែតទៅឯអាកាស សង្ឃាដិរបស់សាមណេរីនោះក្តី មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ បាត្រក្តីក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ វត្តពន្ធចង្កេះក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ សាមណេរីនោះបន្លឺស្រែកថ្ងូរ ម្នាលអាវុសោលក្ខណៈ ខ្ញុំក៏មានបរិវិតក្កថា អើហ្ន៎ (នេះបារពេញ) ជាអស្ចារ្យ អើហ្ន៎ មិនដែលកើតមានសោះឡើយ សត្វបែបនេះចំនឹងត្រូវជាប់ជាមានខ្លះបុះតើ យក្សបែបនេះចំនឹងត្រូវជាប់ជាមានខ្លះ ប្រេត បែបនេះចំនឹងត្រូវជាប់ជាមានខ្លះ គឺថាត្រូវបានអត្តភាពបែបនេះ ក៏សឹងមានខ្លះដែរតើ ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះមហាមោគ្គល្លានមានអាយុ ពោលអួតឧត្តរិមនុស្សធម្ម ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះសាវ័កទាំងឡាយ

១ បាលីភិក្ខុនិប្រែថា ។ ២ បាលីសិក្ខមានាប្រែថា ។ ៣ បាលីសាមណេរប្រែថា ។ ៤ បាលីសាមណេរីប្រែថា ។

វិហរន្តិ ញាណភូតា វត ភិក្ខវេ សាវកា វិហរន្តិ យត្រ ហិ នាម សាវកោ ឯវរូបំ ញស្សតិ វា ទក្ខតិ វា សក្ខឹ វា ករិស្សតិ ។ បុព្វេវ មេ សោ ភិក្ខវេ សាមណេរោ ទិដ្ឋោ អហោសិ អបិ ចាហំ ន ព្យាកាសឹ អហញ្ចេតំ ព្យាករេយ្យំ បរេ ច មេ ន សទ្ទហេយ្យុំ យេ មេ ន សទ្ទហេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយ ឯសោ ភិក្ខវេ សាមណេរោ កស្សបស្ស សម្មាសម្ពុទ្ធស្ស បាវចនេ បាបសាមណេរោ អហោសិ សោ តស្ស កម្មស្ស វិបាកេន ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ ពហូនិ វស្សសតសហស្សានិ និរយេ បច្ចិត្វា តស្សេវ កម្មស្ស វិបាកាវសេសេន ឯវរូបំ អត្តភាវបដិលាភំ បដិសំវេទេតិ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ ភិក្ខវេ មោគ្គល្លានស្សាតិ ។





មានចក្ខុកើតកើតហើយ ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយមានញាណកើតកើតហើយ ព្រោះហេតុថា សាវកនឹងដឹងខ្លួន ឃើញសាមណេរបែបនេះ ឬធ្វើនូវសាមណេរបែបនេះឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ សាមណេរនោះតថាគតបានឃើញអំពីកាលមុនរួចមកហើយដែរ តែតថាគតមិនបានសំដែងប្រាប់ ព្រោះថាបើតថាគតសំដែងប្រាប់ទៅ ជនទាំងឡាយឯទៀតគេក៏មិនជឿ ពួកជនណាដែលមិនជឿពាក្យតថាគត សេចក្ដីដែលមិនជឿនោះនឹងនាំឲ្យបានទុក្ខមិនមែនជាប្រយោជន៍ នឹងនាំឲ្យបានសេចក្ដីទុក្ខអស់កាលយូរអង្វែងដល់ជនទាំងនោះ ម្នាលភិក្ខុទាំងឡាយ សាមណេរនុ៎ះជាសាមណេរបាប ក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ដោយកម្មវិបាកនោះ សាមណេរនោះទៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺថា អស់រយៈកាលរាប់សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះ ទើបបានមកសោយផលកម្មដែលត្រឡប់បាននូវអត្តភាពបែបនេះ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

[២៧៦] អថខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ យាយំ អាវុសោ តបោទា សន្ទតិ សោ ទហោ អច្ឆោទកោ សីតោទកោ សាតោទកោ សេតោទកោ សុបតិត្ថោ រមណីយោ បហូតមច្ឆកច្ឆបោ ចក្កមត្តានិ ច បទុមានិ បុប្ផន្តិ អថ ច បនាយំ តបោទា កុថិតា(១) សន្ទតីតិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា មហាមោគ្គល្លានោ ឯវំ វក្ខតិ យាយំ អាវុសោ តបោទា សន្ទតិ សោ ទហោ អច្ឆោទកោ សីតោទកោ សាតោទកោ សេតោទកោ សុបតិត្ថោ រមណីយោ បហូតមច្ឆកច្ឆបោ ចក្កមត្តានិ ច បទុមានិ បុប្ផន្តិ អថ ច បនាយំ តបោទា កុថិតា(២) សន្ទតីតិ ឧត្តរិមនុស្សធម្មំ អាយស្មា មហាមោគ្គល្លានោ ឧល្លបតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ យាយំ ភិក្ខវេ តបោទា សន្ទតិ សោ ទហោ អច្ឆោទកោ សីតោទកោ សាតោទកោ សេតោទកោ សុបតិត្ថោ រមណីយោ បហូតមច្ឆកច្ឆបោ ចក្កមត្តានិ ច បទុមានិ បុប្ផន្តិ

---

១-២ ឧត្តមាគាយំ កុថិតាតិ លិខិតំ ។



(២៧៦) គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកហើយនិយាយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ស្រះតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះមានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ល្អ គួរជាទីរីករាយ មានត្រីនឹងអណ្តើកដ៏ច្រើន មានផ្កាឈូកប៉ុនកង់ (រទេះ) រីកស្គុះស្គាយ តែថាស្រះតបោទានេះមានទឹកក្តៅហូរមក ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច បានជាព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ស្រះតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះ មានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ល្អ គួរជាទីរីករាយ មានត្រីនឹងអណ្តើកដ៏ច្រើន មានផ្កាឈូកប៉ុនកង់ (រទេះ) រីកស្គុះស្គាយ តែថាស្រះតបោទានេះមានទឹកក្តៅហូរមក ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម (ទេតើ) ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្រះតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះ មានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ល្អ គួរជាទីរីករាយ មានត្រីនឹងអណ្តើកដ៏ច្រើន មានផ្កាឈូកប៉ុនកង់ (រទេះ) រីក

អបិចាយំ ភិក្ខវេ តបោទា ទ្វិន្នំ មហានិរយានំ អន្តរិកាយ អាគច្ឆតិ តេនាយំ តបោទា កុថិតា សន្ទតិ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ ភិក្ខវេ មោគ្គល្លានស្សាតិ ។

(២៤៧) តេន ខោ បន សមយេន រាជា មាគធោ សេនិយោ ពិម្ពិសារោ លិច្ឆវីហិ សទ្ធិំ សង្គាមេន្តោ បភគ្គោ ហោតិ ។ អថ រាជា បច្ឆា សេនំ សង្កឌ្ឍិត្វា លិច្ឆវិយោ(១) បរាជេសិ ។ សង្គាមេ ច នន្ទិ ចរតិ រញ្ញោ លិច្ឆវិយោ(២) បរាជិតា ។ អថាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ រាជា អាវុសោ លិច្ឆវីហិ បភគ្គោ សង្គាមេ ច នន្ទិ ចរតិ រញ្ញោ លិច្ឆវិយោ

● លិច្ឆវី ក លិច្ឆវិត ឥតិ អដ្ឋកថា ១ ២ ឧ. ឆ. លិច្ឆវី ។



ស្រុះស្រាយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្ទឹងតបោទានេះ មកតាមចន្លោះនៃមហានរកទាំងពីរ(១) ព្រោះហេតុនោះបានជាស្ទឹងតបោទានេះ មានទឹកក្ដៅហូរមក ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

(២៤៧) សម័យនោះ ព្រះរាជាទ្រង់ព្រះនាមពិម្ពិសារ ជាអធិបតីក្នុងដែនមគធៈ ជាអធិបតីលើសេនា កំពុងតែកសង្គ្រាមជាមួយនឹងពួកស្ដេចលិច្ឆវី ក៏ទ្រង់បាក់ទ័ព ( បរាជ័យ) ។ លុះកាលជាខាងក្រោយមកព្រះរាជាទ្រង់ត្រាស់ឲ្យកេណ្ឌប្រមូលពួកសេនា ហើយទ្រង់ផ្ចាញ់ពួកស្ដេចលិច្ឆវីបានវិញ ។ ស្ដេចក៏ទ្រង់ឲ្យធ្វើជ័យភេរីទៅក្នុងទីសង្គ្រាមដោយប្រកាសសេចក្ដីថា ពួកស្ដេចលិច្ឆវី ព្រះរាជាទ្រង់ឲ្យបាក់ទ័ព ( បរាជ័យ) បានហើយ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានហៅពួកភិក្ខុមកហើយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារ ទ្រង់ផ្ចាញ់ពួកស្ដេចលិច្ឆវីបានហើយ រួចទ្រង់ឲ្យធ្វើជ័យភេរីទៅក្នុងទីសង្គ្រាមដោយប្រកាសសេចក្ដីថា ពួកស្ដេចលិច្ឆវីព្រះរាជាទ្រង់ឲ្យ

● អដ្ឋកថាពន្យល់សេចក្ដីថា មានមហានរកលោហៈ ទំហំប៉ុណ្ណេះ ... ស្ទឹងតបោទានេះ មកតាមចន្លោះនៃមហានរកទាំងពីរ ព្រោះហេតុនោះបានជាមានទឹកក្ដៅហូរមក ។

បភគ្គាតិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា មហាមោគ្គល្លានោ ឯវំ វក្ខតិ រាជា អាវុសោ លិច្ឆវីហិ បភគ្គោ សង្គាមេ ច បន រញ្ញា លិច្ឆវិយោ បភគ្គាតិ ឧត្តរិមនុស្សធម្មំ អាយស្មា មហាមោគ្គល្លានោ ឧល្លបតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ ភិក្ខវេ រាជា លិច្ឆវីហិ បភគ្គោ អថ រាជា បច្ឆា សេនំ សង្កឌ្ឍិត្វា លិច្ឆវិយោ បភញ្ជេសិ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ ភិក្ខវេ មោគ្គល្លានស្សាតិ ។

(២៩៨) អថខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ ឥធាហំ អាវុសោ សប្បិនិកាយ នទិយា តីរេ អានេញ្ជំ សមាធិំ សមាបន្នោ នាគានំ ឱគយ្ហ ឧត្តរន្តានំ កោញ្ចំ ករោន្តានំ សទ្ទំ អស្សោសិន្តិ ។



ចាក់ចេញ ( បរាជ័យ ) បានហើយ ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្ដេច ព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់ចាញ់ពួកស្ដេចលិច្ឆវីបានហើយ ក៏ទ្រង់ឲ្យទ័ពវិលយាត្រាទៅក្នុងទីសង្គ្រាមដោយប្រកាសសេចក្ដីថា ពពួកស្ដេចលិច្ឆវីព្រះរាជាទ្រង់ឲ្យចាក់ចេញ ( បរាជ័យ ) បានហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលនូវឧត្តរិមនុស្សធម៌(ទេរឹ) ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់ចាក់ចេញ ( បរាជ័យចាញ់ ) ពួកស្ដេចលិច្ឆវីជាទីដំបូង លុះកាលជាខាងក្រោយ ស្ដេចទ្រង់ឲ្យកេណ្ឌប្រមូលពួកសេនាបាន ទើបផ្ចាញ់ពួកស្ដេចលិច្ឆវីបានវិញ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

(២៩៨) គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកហើយ ប្រាប់ថា ម្នាលអាវុសោទាំងឡាយ ខ្ញុំនេះ ខ្ញុំបានចូលសមាធិឥតមានកក្រើកប្រែប្រួល ទៀបឆ្នេរស្ទឹងឈ្មោះសប្បិនិកា បានឮសូរស្រែកដំរីទាំងឡាយ ដែលកំពុងចុះឡើងនៅស្រែកបន្លឺកោញ្ចនាទ(១) ។

១ ដាក់ប្រមោយក្នុងមាត់ បញ្ចេញឮទៅដូចសំឡេងត្រែ ។

ភិក្ខូ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា មហាមោគ្គល្លានោ ឯវំ វក្ខតិ ឥធាហំ អាវុសោ សប្បិនិកាយ នទិយា តីរេ អានេញ្ជំ សមាធឹ សមាបន្នោ នាគានំ ឱគយ្ហ ឧត្តរន្តានំ កោញ្ចំ ករោន្តានំ សទ្ទំ អស្សោសិន្តិ ឧត្តរិមនុស្សធម្មំ អាយស្មា មហាមោគ្គល្លានោ ឧល្លបតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អត្ថេសោ ភិក្ខវេ សមាធិ សោ ច ខោ អបរិសុទ្ធោ សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ អនាបត្តិ ភិក្ខវេ មោគ្គល្លានស្សាតិ ។

(២៤៤) អថខោ អាយស្មា សោភិតោ ភិក្ខូ អាមន្តេសិ អហំ អាវុសោ បញ្ច កប្បសតានិ អនុស្សរាមីតិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា សោភិតោ ឯវំ វក្ខតិ អហំ អាវុសោ បញ្ច កប្បសតានិ អនុស្សរាមីតិ ឧត្តរិមនុស្សធម្មំ អាយស្មា សោភិតោ ឧល្លបតីតិ ។ ភគវតោ



ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជាព្រះមហាមោគ្គល្លានដ៏មានអាយុពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំបានចូលសមាធិឥតមានកំរើកប្រែប្រួល ទៀបឆ្នេរស្ទឹងសប្បិនិកា បានឮសូរសំឡេងដំរីទាំងឡាយ ដែលកំពុងចុះឡើងផងស្រែកបន្លឺកោញ្ចនាទ ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម (ទោស) ។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមាធិនុ៎ះមាន ប៉ុន្តែសមាធិនោះមិនបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

(៦៤៤) គ្រានោះ ព្រះសោភិតត្ថេរដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកហើយនិយាយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរលឹកជាតិបានប្រមាណ ៥០០ កប្ប ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជាព្រះសោភិតត្ថេរដ៏មានអាយុពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរលឹកជាតិបានប្រមាណ ៥០០ កប្ប ព្រះសោភិតត្ថេរដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម (ទោស) ។

ឯតមត្ថំ អារោចេសុំ ។ អត្ថេសា ភិក្ខវេ សោភិតស្ស សា ច ខោ ឯកាយេវ ជាតិ សច្ចំ ភិក្ខវេ សោភិតោ អាហ អនាបត្តិ ភិក្ខវេ សោភិតស្សាតិ ។

ចតុត្ថភាណវារំ និដ្ឋិតំ ។

(៣០០) ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បារាជិកា ធម្មា យេសំ ភិក្ខុ អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជិត្វា ន លភតិ ភិក្ខូហិ សទ្ធឹ សំវាសំ យថា បុរេ តថា បច្ឆា បារាជិកោ ហោតិ អសំវាសោ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា



ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុរលឹកជាតិបានមែន តែជារលឹកបានត្រឹមតែជាតិ ១ ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុពោលខ្លួនពិត ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុមិនត្រូវអាបត្តិទេ ។

ភាណវារៈទី ៤ ចប់ ។

(៣០០) បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះបារាជិកទាំង ៤ ដែលខ្ញុំបានសំដែងហើយនេះ បណ្តាអាបត្តិទាំង ៤ នុ៎ះ ភិក្ខុណាត្រូវអាបត្តិណាមួយហើយ គឺមិនបាននូវកិរិយានៅរួមជាមួយនឹងភិក្ខុទាំងឡាយឡើយ ភិក្ខុនោះជាបារាជិករកសំវាសគ្មាន កាលពីមុនយ៉ាងណាមិញ ខាងក្រោយក៏ដូច្នោះដែរ(១) ។ ខ្ញុំព្រះករុណា សូមសួរលោកដ៏មានអាយុទាំងឡាយ ក្នុងអាបត្តិបារាជិកទាំង ៤ នោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំព្រះករុណា សូមសួរគំរប់ពីរដងទៀត លោកទាំងឡាយជាអ្នក

(១) អដ្ឋកថា ពន្យល់សេចក្តីថា កាលដែលបុគ្គលនោះនៅជាគ្រហស្ថ ឬ ទៅជាសាមណេរ មិនអាចចូលរួមសង្ឃកម្មជាមួយនឹងភិក្ខុទាំងឡាយបាន យ៉ាងណា លុះដល់ត្រូវអាបត្តិបារាជិក ហើយក៏ដូច្នោះដែរ ។

ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បារាជិកកណ្ឌំ និដ្ឋិតំ ។

តស្សុទ្ទានំ

មេថុនាទិន្នាទានញ្ច មនុស្សវិគ្គហុត្តរិ

បារាជិកានិ ចត្តារិ ឆេជ្ជវត្ថូ អសំសយាតិ ។

---



បរិសុទ្ធហើយឬ ខ្ញុំព្រះករុណា សូមសួរគំរប់ ៣ ដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងបារាជិកាបត្តិទាំង ៤ នុ៎ះ ព្រោះហេតុដូច្នោះ ទើបនៅស្ងៀម ។ ខ្ញុំព្រះករុណាដឹងថា លោកទាំងឡាយបរិសុទ្ធហើយ ដោយហេតុដែលស្ងៀមយ៉ាងនេះ ។

បារាជិកកណ្ឌ ចប់ ។

## ចំនួនសិក្ខាបទរបស់បារាជិកកណ្ឌនោះ

បារាជិកសិក្ខាបទទាំង ៤ គឺសេពមេថុន ១ លួចទ្រព្យគេ ១ សម្លាប់មនុស្ស ១ ពោលអួតឧត្តរិមនុស្សធម្ម ១ ហៅថាឆេជ្ជវត្ថុ (វត្ថុដាច់ចាកភិក្ខុភាវៈ) មិនត្រូវសង្ស័យឡើយ ។

---

# សន្ទិការចន្ទុលក្រមមាតិកា


លេខទំព័រ

សេចក្តីផ្តើម សៀវភៅជាភាសាបារាំង . . . . . . . . . . . . . . . . V

សេចក្តីផ្តើម សៀវភៅជាភាសាខ្មែរ . . . . . . . . . . . . . . . . VI

សារឆ្លងបាព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស . . . . . . . . . . VII

សារឆ្លងបារបស់ក្រុមជំនុំ . . . . . . . . . . . . . . . . . . . . . . XI

បវេសនកណ្ឌ ១

សំដែងអំពីវេរញ្ជព្រាហ្មណ៍ពោលបង្អាប់ព្រះមានព្រះភាគ . . . . . . . . ៣

សំដែងអំពីសេចក្តីប្រៀបធៀបដោយកូនមាន់ . . . . . . . . . . . . . . ៩

សំដែងអំពីវេរញ្ជា . . . . . . . . . . . . . . . . . . . . . . ១៣

សំដែងអំពីស្រុកវេរញ្ជាអត់បាយ . . . . . . . . . . . . . . . . . . ១៨

សំដែងអំពីព្រហ្មចរិយធម៌មិនស្ថិតនៅយូរ . . . . . . . . . . . . . . ២៣

ការក្រាបទូលអារាធនានូវសេចក្តីបញ្ញត្តិសិក្ខាបទ . . . . . . . . . . . . ២៧

សំដែងអំពីពុទ្ធដំណើរទៅកាន់ផ្ទះវេរញ្ជព្រាហ្មណ៍ . . . . . . . . . . . ៣១

បារាជិកកណ្ឌ សិក្ខាបទទី ១ ៣៩

និទានសុទិន្នភិក្ខុ . . . . . . . . . . . . . . . . . . . . . . . . [illegible]

សេចក្តីបញ្ញត្តិជាដំបូង . . . . . . . . . . . . . . . . . . . . . . ៤៨

សេចក្តីបញ្ញត្តិតាមលំដាប់ ទី ១ និទានមេស្វា . . . . . . . . . . . . . ៦៨

សេចក្តីបញ្ញត្តិតាមលំដាប់ ទី២ និទានវជ្ជីបុត្តកភិក្ខុ . . . . . . . . . . . ៧១

ចំណែកសិក្ខាបទ . . . . . . . . . . . . . . . . . . . . . . . . ៧៣

លក្ខណៈមិនពោលលាសិក្ខា . . . . . . . . . . . . . . . . . . . . ៧៨

លេខទំព័រ

លក្ខណៈគោលសិក្សា ..... ៩៣
លក្ខណៈមិនគោលសិក្សា ..... ៩៧
របៀបសំដែងអំពីអង្គជាតកនិងក្បាលខ្សែស្រាយប្រទាប់ ..... ៩៩
របៀបសំដែងអំពីអង្គជាតកនិងក្បាលខ្សែខាងស្រោមប្រទាប់ ..... ១០៧
វិធីវត្ថុ រឿងភិក្ខុចំពោះកោសលសិក្សាជាដើម ..... ១១៣

## ថ្នាក់ទីកណ្ដាលសិក្ខាបទ ទី ២ ..... ១៣៥

និទាននិយកិច្ច ..... ១
សេចក្ដីបញ្ញត្តិជាដំបូង ..... ១៤៧
សេចក្ដីបញ្ញត្តិជាបន្ទាប់ ..... -
បំណែកសិក្ខាបទ ..... ១៥១
និយាយអំពីទ្រព្យដែលស្ថិតនៅក្នុងផែនដី ..... ១៥៥
និយាយអំពីប្រយោគបន្ទាប់ ..... ១៦៣
អាការនៃអវហារ ..... ១៦៨
វិធីវត្ថុ រឿងភិក្ខុប្រចេសទៅបិណ្ឌបាតជាដើម ..... ១៨៥

## ថ្នាក់ទីកណ្ដាលសិក្ខាបទ ទី ៣ ..... ២២២

និទានក្នុងសេចក្ដីបញ្ញត្តិជាដំបូង ..... ១
និយាយអំពីអាតាបោះស្បូតសម្មាន ..... ២២៧
និទានក្នុងសេចក្ដីបញ្ញត្តិជាបន្ទាប់ ..... ២៣៣
បំណែកសិក្ខាបទ ..... ២៣៧
និយាយអំពីប្រយោគបន្ទាប់ ..... ២៤៣



លេខទំព័រ

និយាយអំពីកំណើតសេចក្ដីស្លាប់ ..... ២៦៧
និយាយអំពីដំណើរសម្លាប់ដោយរូបជាដើម ..... ២៨១
និយាយអំពីដំណើរបង្គាប់ឲ្យស្លាប់ជាដើម ..... ២៨៨
វិធីវត្ថុ រឿងភិក្ខុកំណើតសេចក្ដីស្លាប់ជាដើម ..... ២៩៧

## ថ្នាក់ទីកណ្ដាលសិក្ខាបទ ទី ៤ ..... ២៩៩

រឿងភិក្ខុកោសលប្រកបឧត្តរិមនុស្សធម្ម ..... ២៩៧
រឿងពួកភិក្ខុនៅទៀបច្រាំងវគ្គមុទា ..... ២៩៩
និយាយអំពីមហាចោរ ៥ ពួក ..... ៣០៣
សេចក្ដីបញ្ញត្តិជាដំបូង ..... ២៩៧
សេចក្ដីបញ្ញត្តិជាបន្ទាប់ ..... -
បំណែកសិក្ខាបទ ..... ២៩៩
និយាយអំពីឧត្តរិមនុស្សធម្មមានឈានជាដើម ..... ៣០៣
និយាយអំពីសុទ្ធិកវារៈ ..... ៣១១
និយាយអំពីចក្កជាដើម ..... ៣១៣
និយាយអំពីវណ្ណបក្ខ ..... ៣១៥
និយាយអំពីអន្តបុគ្គ ..... ៣២៥
និយាយអំពីបេយ្យាល ១៥ ..... ៣៣៥
វិធីវត្ថុ និយាយអំពីសេចក្ដីចាំងនិងវិក្ខជាដើម ..... ៣៤៧
វិធីវត្ថុ និទានអង្គុលិមាលភិក្ខុជាដើម ..... ៣៦១

បោះពុម្ពនៅរោងពុម្ពព្រះបរមរាជវាំង ក្រុងភ្នំពេញ

មាន ស. ន. ទំព. កោសលាណហេង ចប់នៅថ្ងៃទី ៤ ខែតុលា ឆ្នាំ ១៩៥៩

ដោយពុទ្ធសាសនបណ្ឌិត្យចាត់ការ

លើកទី ២

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់ឧបត្ថម្ភនៃ
អ្នកឧបត្ថម្ភខាងក្រោមនេះ :

Printing costs were met through the gift of

Wat Setoshu Fukusenji Temple
The Rev. Seikyo Muchaku · Toki Muchaku
292 Hitokuwada, Tako-Machi, Katori-Gun, Chiba Prefecture Japan

この本は次の方によって復刻されました。

宗教法人 曹洞宗 福泉寺 住職 無着成恭・無着とき
〒289-22 日本国千葉県香取郡多古町一鍬田292
☎0479-75-0694


ព្រះត្រៃបិដក ភាគទី ១១០ • វិនយបិដក •
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៨៨
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 1 (of 110 volumes total)
"VINAYA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ〔南伝大蔵経〕全110巻・第1巻ヴィナヤピタカ（律部）

発　　行：プノンペン仏教研究所
復刻教援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　　行：1994年12月8日

印刷・製本／弘前総互印刷株式会社
製作にあたり弘前総互印刷株式会社の多大な協力を得ました。